ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍បូកសរុប

## ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រចាំឆ្នាំ២០១៧-២០១៨ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៨-២០១៩



សន្និបាតកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

# មាតិកា


**I- សេចក្តីផ្តើម**......1

**II- គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម**......5

**III- លទ្ធផលជារួម**......14

**IV- លទ្ធផលតាមអនុវិស័យ**......17

១. លទ្ធផលនៃការលើកកម្ពស់ផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម......18

២. ការជំរុញផលិតកម្មសត្វ និងសុខភាពសត្វ......40

៣. លទ្ធផលនៃការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព......49

៤. លទ្ធផលនៃការគ្រប់គ្រងព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព......53

៥. លទ្ធផលនៃការពង្រឹងស្ថាប័ន ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស......59

**V- បញ្ហាប្រឈម**......87

**VI- ទិសដៅអនុវត្តឆ្នាំ២០១៨-២០១៩**......88

១. ផែនការផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម......88

២. ផែនការផលិតកម្មដំណាំកៅស៊ូ......89

៣. ផែនការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ......90

៤. ផែនការផ្នែកជលផល......91

៥. ផែនការផ្នែកព្រៃឈើ......92

**VII- សេចក្តីសន្និដ្ឋាន**......93

**ឧបសម្ព័ន្ធ**

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៧-២០១៨
# និងទិសដៅអនុវត្តឆ្នាំ២០១៨-២០១៩

## I- សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយ និងជំរុញការអនុវត្ត **"យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨"** ដែលនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសមធម៌ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដោយបានកំណត់យ៉ាងច្បាស់ថា ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការកែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ពិសេសធនធានព្រៃឈើនិងជលផល គឺជាមុខព្រួញស្នូលដ៏សំខាន់ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

អនុវត្តតាមគោលនយោបាយនិងយុទ្ធសាស្ត្រនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការបន្តធ្វើទំនើបកម្មវិស័យកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដោយបានជំរុញការអនុវត្តវិធានការចាំបាច់មួយចំនួនរួមមានៈ ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ការស្រាវជ្រាវបច្ចេកទេសកសិកម្ម សំដៅបង្កើនទិន្នផលដំណាំនិងបន្សាំការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនជីជាតិដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ព្រមទាំងការកសាងនិងពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម។ ទន្ទឹមនឹងនេះ ក្រសួងក៏បានយកចិត្តទុកដាក់ខ្ពស់អំពីការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ព្រមទាំងខិតខំយ៉ាងខ្លាំងក្លាលើការអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសសមស្រប ក្នុងការគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិ ព្រៃឈើនិងជលផលប្រកបដោយចីរភាព។ ការខិតខំប្រឹងប្រែងទាំងអស់នេះ គឺក្នុងទិសដៅចូលរួមចំណែកបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាការជួយបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ការបន្តជំរុញការធ្វើកសិពាណិជ្ជកម្ម និងការបង្កើនចំណូលជាតិ។

គួរកត់សម្គាល់ថា បច្ចុប្បន្ននេះ ផលិតកម្មដំណាំស្រូវមានការវិវឌ្ឍឈានឡើងជាលំដាប់ គឺអាស្រ័យដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា អង្គការជាតិ និងអន្តរជាតិ អាជ្ញាធរថ្នាក់ក្រោមជាតិ និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ ជាពិសេសការប្តូរទម្លាប់ពីការផលិតសម្រាប់ហូបចុកមកជាការផលិតសម្រាប់ពាណិជ្ជកម្ម។ ការសម្រេចបានក្នុងការបង្កើនផលិតភាពដំណាំស្រូវបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួនដូចជា ការផ្លាស់ប្តូរពូជស្រូវដែលមានទិន្នផលខ្ពស់ ដែលជាលទ្ធផលទទួលបានពីការពិសោធន៍ស្រាវជ្រាវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ជាពិសេស ការពង្រីកកាន់តែមានប្រសិទ្ធភាពលើការធ្វើស្រែបង្ហាញតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ការអនុវត្តបច្ចេកទេសគ្រប់គ្រងដីដើម្បីបង្កើនជីជាតិនិងទិន្នផល ការបង្កើនការស្រាវជ្រាវនិងអភិវឌ្ឍពូជស្រូវដែលស្របនឹងលក្ខណៈដី អាកាសធាតុ ការកំណត់ប្រភេទពូជសំខាន់ៗស្របតាមតម្រូវការទីផ្សារ។

ការធ្លាក់ចុះនៃថ្លៃស្រូវក្នុងពេលប្រមូលផល បានកើតមានជារៀងរាល់ឆ្នាំ និងបានធ្វើឱ្យកសិករទទួលរងផលប៉ះពាល់គួរឱ្យកត់សម្គាល់។ ជាការឆ្លើយតប ក្រសួងបានដាក់ចេញនូវវិធានការបន្ទាន់មួយចំនួន ដោយបានស្នើឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត សហការជាមួយអាជ្ញាធរខេត្ត រួមនឹងស្ថាប័នពាក់ព័ន្ធ ចុះពិនិត្យជាក់ស្តែង

ដល់មូលដ្ឋាន ដើម្បីទប់ស្កាត់ការប្រមូលទិញផ្តាច់មុខពីសំណាក់ឈ្មួញនៅតាមតំបន់ និងធ្វើការចរចាជាមួយសហគមន៍រោងម៉ាស៊ីនកិនស្រូវតាមបណ្តាខេត្ត ដើម្បីប្រមូលទិញស្រូវពីកសិករឱ្យអស់លទ្ធភាពក្នុងតម្លៃសមស្រប។ ឆ្លើយតបទៅនឹងបញ្ហាតម្លៃស្រូវធ្លាក់ចុះនេះផងដែរ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសអន្តរាគមន៍ក្នុងការប្រមូលទិញស្រូវដោយបង្កើនឥណទានដល់៥០លានដុល្លារ សម្រាប់ប្រមូលទិញស្រូវ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលបានពង្រឹងនីតិវិធីនាំចូលផលិតផលកសិកម្មពីប្រទេសជិតខាង និងស្នើឱ្យមានការសម្របសម្រួលចរចាជាមួយប្រទេសដៃគូពាណិជ្ជកម្ម ដើម្បីនាំចេញអង្ករឬផលិតផលកសិកម្មពីកម្ពុជា។

គោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ដែលត្រូវបានដាក់ចេញនៅក្នុងឆ្នាំ២០១០ កន្លងទៅ បានកំណត់នូវគោលដៅសំខាន់ៗចំនួន០៣គឺ៖ ១)- បង្កើនផលិតផលស្រូវលើសពីសេចក្តីត្រូវការឱ្យដល់៤លានតោន ២)- ជំរុញការនាំចេញអង្ករឱ្យបានយ៉ាងតិច១លានតោន ៣)- ធ្វើឱ្យអង្ករកម្ពុជាត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅឆ្នាំ២០១៥។ ទោះបីយើងមិនទាន់អាចសម្រេចបាននូវការនាំអង្ករចេញ១លានតោន គិតមកទល់នឹងពេលនេះក្តី តែយើងបានសម្រេចធ្វើឱ្យអង្ករកម្ពុជាត្រូវបានទទួលស្គាល់ជាអន្តរជាតិ ហើយផលិតផលស្រូវលើសពីសេចក្តីត្រូវការបានកើនឡើងដល់ប្រមាណជាង៥លានតោននៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលបានក្លាយជាប្រភពដ៏សំខាន់ នៅក្នុងការធានាបាននូវស្ថិរភាពនៃប្រភពស្រូវ ដើម្បីធ្វើការកែច្នៃសម្រាប់នាំអង្ករចេញ។ ទន្ទឹមនឹងនេះ ប្រព័ន្ធខ្សែចង្វាក់ស្រូវអង្ករកម្ពុជា ក៏បានបង្កើតនូវស្ថានភាពមួយ ដែលតួអង្គពាក់ព័ន្ធទាំងអស់កាន់តែមានការយល់ដឹង និងសមត្ថភាពជំនាញ ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ពង្រីកលទ្ធភាពនាំចេញរបស់កម្ពុជាទៅថ្ងៃមុខ តាមរយៈការដោះស្រាយនូវបញ្ហាប្រឈមនានា និងពង្រឹងភាពទន់ខ្សោយរបស់កម្ពុជានៅក្នុងប្រព័ន្ធខ្សែចង្វាក់កែច្នៃអង្ករទាំងមូល។

ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានសម្រេចដាក់ចុះនូវយន្តការអន្តរាគមន៍រយៈពេលខ្លី ដើម្បីដោះស្រាយបញ្ហាហេដ្ឋារចនាសម្ព័ន្ធឡសម្ងួតនិងឃ្លាំងស្តុកស្រូវ ក៏ដូចជាទុនបង្វិល ដើម្បីការពារផលប្រយោជន៍កសិករ តាមរយៈការការពារស្ថិរភាពនៃថ្លៃស្រូវ គឺទ្រទ្រង់ថ្លៃស្រូវកុំឱ្យធ្លាក់ចុះខ្លាំងពេក ហួសពីថ្លៃទីផ្សារដោយមិនសមហេតុផល។ អន្តរាគមន៍នេះ រួមមាន៖ ទី១)- បង្កើនការវិនិយោគលើមជ្ឈមណ្ឌលប្រមូលទិញស្រូវ ដែលរួមមានការសាងសង់ឃ្លាំងស្តុកស្រូវ និងឡសម្ងួតដល់ប្រមាណ ៣០លានដុល្លារអាមេរិក ដោយផ្តោតលើតំបន់ផលិតស្រូវសំខាន់ៗ ដើម្បីស្រូបយកផលស្រូវពីកសិករ នៅពេលគាត់មានតម្រូវការនៅក្នុងការលក់បន្ទាប់ពីគាត់ធ្វើការប្រមូលផលរួច។ ទី២)-បង្កើនឥណទានប្រមូលទិញស្រូវឱ្យកើនឡើងដល់ ៥០លានដុល្លារអាមេរិក ដោយធនាគារអភិវឌ្ឍន៍ជនបទដើរតួជាប្រតិបត្តិករក្នុងការផ្តល់ឥណទានដល់រោងម៉ាស៊ីនកិនស្រូវធំៗប្រើប្រាស់ជាទុនបង្វិលសម្រាប់ប្រមូលទិញស្រូវ ជាមួយនឹងនីតិវិធីផ្តល់ឥណទានឆាប់រហ័ស និងមានអត្រាការប្រាក់៥%ក្នុងមួយឆ្នាំ។ ទី៣)- ដោយសារការដឹកជញ្ជូន ក៏ជះឥទ្ធិពលដល់ការលក់ស្រូវរបស់កសិករ រាជរដ្ឋាភិបាលនឹងបង្កើនការវិនិយោគបន្ថែមលើការសាងសង់ផ្លូវដើម្បីភ្ជាប់ទៅទីផ្សារ។ ទី៤)- សម្រួលច្រកព្រំដែនជាមួយប្រទេសជិតខាង ដើម្បីឱ្យយើងអាចធ្វើការនាំចេញស្រូវ ក៏ដូចជាកសិកផលផ្សេងទៀតទៅប្រទេសជិតខាងដោយងាយស្រួលនិងមិនមានការរាំងស្ទះ តាមរយៈសម្រួលនីតិវិធីបែបបទការនាំចេញ និងការបន្តខិតខំកាត់បន្ថយថ្លៃដឹកជញ្ជូន រួមទាំងចំណាយផ្លូវការនិងក្រៅផ្លូវការ។ ទី៥)- បន្តខិតខំស្វែរកទីផ្សារក្រៅប្រទេសថ្មីៗថែមទៀត ដើម្បីជំរុញការនាំអង្ករចេញ ជាពិសេសទៅកាន់ប្រទេសទីផ្សារគោលដៅសំខាន់ៗ រួមទាំងទីផ្សារប្រទេសចិន និងទីផ្សារសក្តានុពលមួយចំនួនទៀត។

នាពេលកន្លងទៅនេះ ក្រសួងបានប្រកាសដាក់ឲ្យប្រើប្រាស់នូវឯកសារ "គោលនយោបាយផ្សព្វផ្សាយកសិកម្ម **នៅកម្ពុជា**" ដើម្បីឲ្យកសិករនិងសហគមន៍កសិករទទួលបាន និងប្រើប្រាស់ចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មបានល្អប្រសើរ។ បន្ថែមលើនេះ ក្រោយពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយស្តីពី "**ការជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ**" បរិមាណអង្ករនាំចេញបានកើនឡើងទៅកាន់ទីផ្សារអន្តរជាតិ និងអង្ករពូជស្រូវផ្ការំដួលត្រូវបានចាត់ទុកថាមានគុណភាពល្អជាងគេក្នុងពិភពលោក។

ការបង្វែរទិសពីការអភិវឌ្ឍតាមបែបទូលាយ ឬតាមបែបវិបុលកម្មទៅកាន់ការអភិវឌ្ឍតាមបែបស៊ីជម្រៅ ឬតាមបែបប្រពលវប្បកម្ម ពោលគឺការពង្រីកសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ តាមរយៈប្រពលវប្បកម្ម និងការបង្កើនរដូវដាំដុះបានក្លាយជារបៀបវារៈអាទិភាពមួយដ៏សំខាន់។ ជាកត្តាសត្យានុម័ត ការពង្រីកនិងការពង្រឹងសេវាកម្មគាំទ្រដ៏មានប្រសិទ្ធភាព ដូចជាការស្រាវជ្រាវ ការផ្សព្វផ្សាយនូវបច្ចេកវិទ្យាទំនើបទៅតាមអនុវិស័យ អាស្រ័យទៅតាមសក្តានុពលនៃភូមិសាស្ត្រ ការបែងចែកពូជ ជី សម្ភារកសិកម្ម និងការផ្តល់ឥណទានជនបទត្រូវបានយកចិត្តទុកដាក់ និងជាអាទិភាពរបស់រាជរដ្ឋាភិបាល សំដៅលើកកម្ពស់ផលិតភាពកសិកម្ម ឆ្លើយតបទៅតាមតម្រូវការទីផ្សារទាំងបរិមាណ គុណភាព សុវត្ថិភាព និងស្តង់ដារអន្តរជាតិ។

បច្ចុប្បន្ននេះ យើងបានកត់សម្គាល់ថា ប្រជាកសិករយើងកំពុងប្រែប្រួលទម្លាប់ ពីការផលិតសម្រាប់បម្រើសេចក្តីត្រូវការផ្ទាល់ខ្លួន មកជាការផលិតដើម្បីលក់ ព្រោះមានតម្រូវការទីផ្សារខ្ពស់។ ផ្អែកលើការប្រែប្រួលនេះ យើងអាចសន្និដ្ឋានបានថា សហគមន៍កសិកម្មកំពុងក្លាយជាកម្លាំងចលករមួយយ៉ាងសំខាន់ ដែលនាំឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសង្គមជនបទកម្ពុជា។ នេះបង្ហាញឱ្យឃើញថា កសិករយើងបាននិងកំពុងប្រែក្លាយខ្លួនចេញពី "កសិករទៅជាកសិ-ពាណិជ្ជករ" ដើម្បីទទួលបានតម្លៃបន្ថែមក្នុងជីវភាពរស់នៅរបស់ខ្លួន។ ក្នុងបរិបទនេះ យើងសង្កេតឃើញថា មានស្ថាប័នជាច្រើនទាំងរដ្ឋ វិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាលបាននិងកំពុងផ្តល់សេវាកម្ម ដើម្បីបង្កើនចំណេះដឹង និងចំណេះធ្វើដល់កសិករនៅមូលដ្ឋាន ហើយក៏មានកសិករជាច្រើនបានក្រេបជញ្ជក់ យកបទពិសោធន៍ និងទេពកោសល្យទាំងអស់នេះយកទៅអនុវត្ត ប្រកបដោយភាពឧស្សាហ៍ព្យាយាមនិងច្នៃប្រឌិត ដោយទទួលបានលទ្ធផលជាផ្លែផ្កាយ៉ាងត្រចះត្រចង់ នៅក្នុងតំបន់ជាច្រើនទៅតាមអនុវិស័យនីមួយៗ។

សន្ទុះនៃការដាំដុះកៅស៊ូនៅកម្ពុជាមានការកើនឡើងជាលំដាប់ អាស្រ័យដោយស្ថានភាពនយោបាយ សន្តិសុខល្អប្រសើរ សក្តានុពលនៃដីសមស្រប និងគោលនយោបាយទីផ្សារសេរី លើការលក់ដូរផលិតផលកៅស៊ូគ្រួសារក្នុងស្រុក។ ទន្ទឹមនឹងនេះ មានការចូលរួមពីផ្នែកឯកជន ក្នុងការធ្វើវិនិយោគលើដីសម្បទានសេដ្ឋកិច្ច និងផ្នែកកៅស៊ូគ្រួសារ ដែលបានធ្វើឱ្យផ្ទៃដីដាំដុះកៅស៊ូកើនឡើងគួរឱ្យកត់សម្គាល់។

ផលិតកម្មសត្វទាំងលក្ខណៈគ្រួសារនិងពាណិជ្ជកម្មនៅកម្ពុជា ក៏មានការវិវឌ្ឍគួរឲ្យកត់សម្គាល់ ទាំងបរិមាណសត្វ និងបែបផែនផលិតកម្ម។ ការរីកចម្រើនទាំងអស់នេះ គឺជាលទ្ធផលនៃការស្រាវជ្រាវ និងការយល់ដឹងអំពីបច្ចេកទេសចិញ្ចឹមសត្វ ការជ្រើសរើសនិងការបង្កាត់ពូជសត្វ ការផលិតចំណីសត្វ និងការផ្តល់សេវាថែទាំសុខភាពសត្វ។ ជាមួយគ្នានេះ ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ដែលបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ត្រូវបាននិងកំពុងអនុវត្តយ៉ាងមានប្រសិទ្ធភាព ព្រមទាំងបានជំរុញការអភិវឌ្ឍផ្នែកផលិតកម្មសត្វ និងសុខភាពសត្វនៅកម្ពុជាផងដែរ។ ពិសេសជាងនេះទៀតនោះ ការទប់ស្កាត់ចលនាសត្វខុសច្បាប់ត្រូវបានអនុវត្តយ៉ាងយកចិត្តទុកដាក់ ហើយការទប់ស្កាត់ជំងឺឆ្លងសត្វក៏ត្រូវបានពង្រឹងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ការកែទម្រង់ស៊ីជម្រៅវិស័យជលផលត្រូវបន្តបានអនុវត្តយ៉ាងសកម្ម។ កំណែទម្រង់នេះ បានធ្វើឱ្យប្រជាជនទូទៅ ជាពិសេសអ្នកប្រកបរបរនេសាទជាលក្ខណៈគ្រួសារ អាចធ្វើអាជីវកម្មបានទូលំទូលាយជាងមុន។ រហូតមកដល់ពេលនេះ យើងបានបង្កើតសហគមន៍នេសាទចំនួន៥១៦ ដើម្បីគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាព។ សព្វថ្ងៃនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងខិតខំអនុវត្តទិសស្លោក "សហគមន៍នេសាទគ្មានបទល្មើស" ក្នុងគោលបំណងពង្រឹងសហគមន៍នេសាទឱ្យបានរឹងមាំ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមគ្រប់គ្រងថែរក្សាការពារធនធានជលផលឱ្យបានគង់វង្ស។ ជាការកែទម្រង់ថ្មីមួយទៀត ក្រសួងបានបើកឱ្យមានការចិញ្ចឹមត្រីរស់ និងត្រីឆ្តោឡើងវិញ ទាំងជាលក្ខណៈគ្រួសារនិងពាណិជ្ជកម្ម ហើយការចិញ្ចឹមនេះ ត្រូវភ្ជាប់ជាមួយលក្ខខណ្ឌមួយចំនួន ដើម្បីងាយស្រួលគ្រប់គ្រង និងផ្តល់បច្ចេកទេស និងជាពិសេសទៀតនោះ គឺសំដៅធានាឱ្យបាននូវការអនុវត្តស្របតាមបទដ្ឋានបច្ចេកទេសសមស្រប ធានានិរន្តរភាពធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ីនិងបរិស្ថាន។ ជាលទ្ធផលជាក់ស្តែង ការចិញ្ចឹមត្រីមានការកើនឡើងរហូតដល់ជាង២០% បើប្រៀបធៀបនឹងឆ្នាំមុន។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ លើកម្មវិធីកំណែទម្រង់វិស័យព្រៃឈើ ដោយខិតខំបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ និងពិសេសយកចិត្តទុកដាក់ជាសំខាន់លើការត្រួតពិនិត្យតាមដានដ៏តឹងរ៉ឹង ព្រមទាំងសម្រេចបាននូវលទ្ធផលមួយចំនួនផងដែរ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកត់សម្គាល់ឃើញអំពីការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា។ លើសពីនេះទៀត ក្រសួងក៏បានចូលរួមអនុវត្តយ៉ាងសកម្មជាមួយគណៈកម្មការជាតិ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅទប់ស្កាត់និងបង្ក្រាបសកម្មភាពអនាធិបតេយ្យកាប់ឈើ ការនាំចេញឈើខុសច្បាប់ និងបទល្មើសនានានៅភាគឦសាន្តនៃប្រទេស។

ជាការកែទម្រង់មួយថ្មីទៀត ក្រសួងបានដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផល ឱ្យស្ថិតនៅក្រោមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត។ បន្ថែមពីនេះទៀតនោះ ក្រសួងក៏បានផ្ទេរធនធាននិងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលនៃខណ្ឌ ផ្នែក សង្កាត់ រដ្ឋបាលព្រៃឈើនិងរដ្ឋបាលជលផល ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត។ ជាមួយគ្នានេះ ក្រសួងបានវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីយកចិត្តទុកដាក់មិនខ្លាចនឿយហត់ និងការលះបង់ខ្ពស់របស់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃរដ្ឋបាលជលផលនិងរដ្ឋបាលព្រៃឈើ ដែលបានខិតខំតស៊ូបំពេញភារកិច្ចរបស់ខ្លួនបានល្អប្រសើរក្នុងរយៈពេល១ឆ្នាំកន្លងមក ជាពិសេសការខិតខំប្រឹងប្រែងក្នុងឱកាសដែលរាជរដ្ឋាភិបាលកំពុងធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យទាំងពីរនេះ ដែលនេះជាសក្ខីភាពបង្ហាញឱ្យឃើញនូវការចូលរួមចំណែកក្នុងបុព្វហេតុនៃការលើកកម្ពស់ផ្នែកជលផល និងព្រៃឈើនៅកម្ពុជា ឲ្យមានការរីកចម្រើនជាលំដាប់ប្រកបដោយមោទនភាព។ ទន្ទឹមនឹងនេះ ក្រសួងក៏សូមវាយតម្លៃខ្ពស់ ចំពោះកិច្ចសហការល្អ និងការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផល និងព្រៃឈើប្រកបដោយនិរន្តរភាព ជាពិសេសការបង្ក្រាបបទល្មើសតាមគ្រប់រូបភាពឱ្យទទួលបានលទ្ធផលល្អប្រសើរ ទោះបីនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។ ជាការកត់សម្គាល់ ប្រសិទ្ធភាពនៃការគ្រប់គ្រងក្នុងអនុវិស័យទាំងពីរនេះ ត្រូវបានវាយតម្លៃថាមានការកើនឡើងគួរជាទីពេញចិត្ត។

ក្នុងគោលបំណងជំរុញការងាររៀបចំកំណត់តំបន់ដាំដុះកសិកម្ម ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតគណៈកម្មាធិការកំណត់តំបន់ដាំដុះកសិកម្ម តាមរយៈសេចក្តីសម្រេចលេខ ៦៧៩ សសរ.កសក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧។ គណៈកម្មាធិការនេះ ដឹកនាំដោយឯកឧត្តមអនុរដ្ឋ លេខាធិការនៃក្រសួង និងមានសមាសភាពចូលរួមពីថ្នាក់ដឹកនាំ រួមទាំងអង្គភាពជំនាញពាក់ព័ន្ធចំនួន១៦រូប។ ក្នុងកិច្ចដំណើរការនៃការរៀបចំ គណៈកម្មាធិការកំណត់តំបន់ដាំដុះកសិកម្ម បានរៀបចំកិច្ចប្រជុំលើកទី១ កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ ដើម្បីជំរុញការអនុវត្តស្របតាមតួនាទី និងភារកិច្ចដែលបានប្រគល់ជូន។ គណៈកម្មាធិការនេះ បានពិនិត្យនិងសិក្សាឡើងវិញអំពីទិន្នន័យពាក់ព័ន្ធនឹងព័ត៌មានដីកសិកម្ម ដែលរួមមាន៖ (១) ផែនទីដីរបស់លោក Crocker ឆ្នាំ១៩៦២ (២) ផែនទីប្រព័ន្ធគ្រ្បេគ្របរិស្ថានដំណាំស្រូវ (Rice Ecosystem Map) (៣) ផែនទីចំណាត់ថ្នាក់ដី និងផែនទីប្រើប្រាស់ដី ដែលនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម បានផលិតក្នុងស្រុកគោលដៅចំនួន១០នៃខេត្តសំខាន់ៗ (៤)ទិន្នន័យ ផ្កាយរណបរបស់អង្គការណាសា (NASA Satellite Data) និង (៥) ឯកសារបច្ចេកទេសដីរបស់អង្គការ FAO (Framework for Land Evaluation)។ សម្រាប់ការងារបន្ទាប់ គណៈកម្មាធិការនេះនឹងរៀបចំឯកសារទស្សនទានកំណត់ការងារ ជំហានដែលត្រូវធ្វើ និងសេចក្តីត្រូវការធនធានផ្សេងៗ ព្រមទាំងមាតិកានៃឯកសារស្តីពីការកំណត់តំបន់ដាំដុះកសិកម្ម។

## II- គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម

### ១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨នេះ គឺជាឯកសារផែនការគោលនយោបាយ និងយុទ្ធសាស្ត្រមួយដ៏សំខាន់សម្រាប់រយៈពេលមធ្យម និងជាផែនទីបង្ហាញផ្លូវ ដែលបានកំណត់ច្បាស់អំពីទិសដៅអភិវឌ្ឍន៍វិស័យកសិកម្ម ជាមួយនឹងគោលបំណង លទ្ធផលរំពឹងទុក សូចនាករ និងចង្កោមសកម្មភាព របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់អនុវត្តក្នុងរយៈពេល៥ឆ្នាំពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៨ និងបានឆ្លុះបញ្ចាំងពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេស យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ សំដៅរួមចំណែកដល់ការរីកចម្រើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំសម្រាប់អនុវត្ត ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា ទៅតាមអភិក្រមក្នុងវិសាលភាព និងល្បឿនថ្មី សំដៅជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្ម និងការនាំចេញផលិតផលកសិកម្ម រួមនឹងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

ការកំណត់ទិសដៅគោលនយោបាយរួមរបស់ក្រសួងសម្រាប់អនុវត្តរយៈពេល៥ឆ្នាំគឺ "*ជំរុញកំណើនកសិកម្មប្រចាំឆ្នាំឱ្យបានក្នុងរង្វង់៥% តាមរយៈការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការលើក កម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារ និងគ្រប់គ្រងធនធានធម្មជាតិព្រៃឈើនិងជលផលប្រកបដោយចីរភាព*"។

ដើម្បីសម្រេចបានទិសដៅគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតកម្មវិធីយុទ្ធសាស្ត្រចំនួន៥ ដូចខាងក្រោមនេះ៖

**កម្មវិធីទី ១៖ បង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម**

ជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់១០%ក្នុងមួយឆ្នាំ តាមរយៈការបង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មសំដៅបង្កើនទិន្នផលដំណាំ លើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម និងអង្គការកសិករនានា ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មប្រកបដោយនិរន្តរភាព។

**កម្មវិធីទី ២៖ ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ**

ជំរុញការចិញ្ចឹមសត្វក្នុងអត្រាកំណើន៣%ក្នុងមួយឆ្នាំ ដោយផ្អែកលើប្រសិទ្ធភាពនៃការពិសោធន៍ស្រាវជ្រាវ និងផ្សព្វផ្សាយ បង្កើនសមត្ថភាពបង្ការទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺសូណូស៊ីស ធានាការផ្គត់ផ្គង់សត្វ ផលិតផលសត្វ ប្រកបដោយអនាម័យ សុវត្ថិភាព និងបង្កើនសក្តានុភាពនៃការនាំចេញ។

**កម្មវិធីទី ៣៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព**

បង្កើនការការពារ និងអភិរក្សធនធានជលផល ដោយលុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព ពង្រឹងសមត្ថភាពគ្រប់គ្រង១០០សហគមន៍នេសាទ និងជំរុញការអភិវឌ្ឍវារីវប្បកម្មក្នុងកំណើន១៥%រៀងរាល់ឆ្នាំ ដើម្បីធានាឱ្យបាននូវនិរន្តរភាពធនធានជលផល ព្រមទាំងកែលម្អគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផល សម្រាប់ការប្រើប្រាស់ក្នុងស្រុកនិងនាំចេញ។

**កម្មវិធីទី ៤៖ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព**

បង្កើនការគ្រប់គ្រងព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំឈើឡើងវិញ បង្កើនតំបន់អភិរក្សសត្វព្រៃ និងសហគមន៍ព្រៃឈើឱ្យបាន២០សហគមន៍ក្នុង១ឆ្នាំ។

**កម្មវិធីទី ៥៖ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស**

បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រនិងពង្រឹងសមត្ថភាពផ្នែករអប់រំ និងបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព។

ដើម្បីសម្រេចបាននូវទិសដៅគោលនយោបាយទាំងអស់ខាងលើ ការងារជាច្រើនត្រូវបានអនុវត្ត និងវាយតម្លៃថាសម្រេចបានលទ្ធផលគួរជាទីពេញចិត្ត។ គ្រប់អង្គភាពជំនាញពាក់ព័ន្ធក្នុងផ្នែកនីមួយៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំអនុវត្តនូវបណ្តាសកម្មភាពអាទិភាពទាំងឡាយដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨នេះ។ ជាមួយគ្នានេះ បណ្តាដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិល ក៏បានចូលរួមអនុវត្តការងារតាមជំនាញរបស់ខ្លួន ដើម្បីរួមចំណែកសម្រេចបាននូវទិសដៅដែលបានកំណត់នេះ។ បន្ថែមលើនេះ ផែនការយុទ្ធសាស្ត្រនេះមានលក្ខណៈពហុវិស័យសង្គតិភាព និងបំពេញឱ្យគ្នាជាមួយផែនការនិងគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាល។

ផ្អែកលើផែនការយុទ្ធសាស្ត្រនេះ ការរៀបចំនិងអនុវត្តតាមប្រព័ន្ធ "អភិក្រមផ្អែកតាមកម្មវិធី (Programme Based Approach)" ត្រូវបានជំរុញនិងលើកទឹកចិត្តឱ្យអនុវត្ត ដោយត្រូវបញ្ចូលគ្នានូវធនធាន ដែលមានទាំងថវិកាជាតិនិងថវិកាពីដៃគូអភិវឌ្ឍន៍ ដើម្បីសម្រេចបាននូវគោលដៅរួមគ្នា។ ជាងនេះទៀត ការកសាងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី គឺចាំបាច់ត្រូវអនុវត្តឱ្យស្របទៅនឹងផែនការយុទ្ធសាស្ត្រនេះផងដែរ។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងរៀបចំកសាង "ផែនការមេស្តីពីការអភិវឌ្ឍវិស័យកសិកម្មឆ្ពោះទៅឆ្នាំ២០៣០" ដោយបានកំណត់នូវទិសដៅគោលនយោបាយដូចខាងក្រោម៖

**<u>ចក្ខុវិស័យ</u>**៖ "កសិកម្មកម្ពុជាជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលធានាបាននូវសន្តិសុខនិងសុវត្ថិភាពស្បៀង ព្រមទាំងអាហារូបត្ថម្ភ សម្រាប់វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ"។

**<u>បេសកកម្ម</u>**៖ "ផ្តល់សេវាគាំទ្រមានគុណភាពខ្ពស់ ប្រកបដោយលក្ខណៈវិទ្យាសាស្ត្របច្ចេកទេស បទដ្ឋានគតិយុត្ត សម្រាប់បម្រើឱ្យការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព"។

**<u>គោលដៅគោលនយោបាយ</u>**៖ "ជំរុញកំណើនកសិកម្ម និងបង្កើនការនាំចេញផលិតផលកសិកម្មប្រកបដោយគុណភាពនិងសុវត្ថិភាព តាមរយៈការលើកកម្ពស់ផលិតភាពកសិកម្ម បង្កើនតម្លៃបន្ថែម និងពង្រីកការប្រកួតប្រជែងទីផ្សារ ព្រមទាំងរក្សាបានតុល្យភាពនៃការប្រើប្រាស់ដីកសិកម្ម និងធានាការគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព "។

ក្នុងឆ្នាំ២០១៨នេះ ក្រសួងនឹងរៀបចំកសាង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០១៩-២០២៣ ឱ្យស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលនឹងត្រូវដាក់ចេញនាពេលខាងមុខដ៏ខ្លី។

## ២. យុទ្ធសាស្ត្រចំបងៗសម្រាប់តម្រង់ទិសអភិវឌ្ឍន៍កសិកម្មសម្រាប់ឆ្នាំ២០១៨

សារៈសំខាន់របស់វិស័យកសិកម្មត្រូវបានស្តែងឱ្យឃើញ តាមរយៈក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាច្រើន ជាអាទិ៍៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ក៏ដូចជាគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករបស់រាជរដ្ឋាភិបាល ដែលបានផ្តោតជាសំខាន់លើការជំរុញ និងលើកស្ទួយវិស័យកសិកម្ម តាមរយៈការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ជាមួយនឹងរបត់ថ្មី ដើម្បីឈានឆ្ពោះទៅរកការពន្លឿនកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស។ បន្ថែមលើសពីនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដែលមានគោលដៅសំខាន់ពាក់ព័ន្ធនឹងវិស័យកសិកម្ម គឺត្រូវជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឲ្យបាន១២% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥។ ក្នុងន័យនេះ យើងត្រូវតែធ្វើឱ្យប្រាកដនូវរាល់គោលដៅ ក្នុងការងារអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជា គឺត្រូវចាប់ច្បាមនូវកាលានុវត្តភាពនេះឱ្យបានជាពិសេសត្រូវធ្វើឱ្យកម្ពុជាមានឧត្តមភាពប្រកួតប្រជែងទីផ្សារក្នុងស្រុក និងការនាំចេញកសិផលទាំងក្នុងតំបន់ និងពិភពលោក និងកាត់បន្ថយការនាំចូល។

ទន្ទឹមនឹងនេះ ក្រសួងក៏បានពិនិត្យឃើញថា ការអភិវឌ្ឍវិស័យកសិកម្ម មានការជាប់ពាក់ព័ន្ធដោយផ្ទាល់ និងមានលក្ខណៈប្រទាក់ក្រឡាគ្នាទៅនឹងខ្សែចង្វាក់ផលិតកម្មនិងតម្លៃផលិតផលកសិកម្ម និងការប្រកួតប្រជែងកសិផលនៅលើទីផ្សារ បើទោះបីក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះយើងបានពិនិត្យឃើញថា ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី ការចាត់ចែងនិងវាយបណ្តាញអគ្គិសនីមានការរីចម្រើនគួរឲ្យកត់សម្គាល់យ៉ាងណាក៏ដោយ ក៏មិនទាន់បានផ្តល់ការទាក់ទាញដល់អ្នកវិនិយោគពីខាងក្រៅទៅលើការផ្គត់ផ្គង់សម្ភារកសិកម្ម និងការវេចខ្ចប់ផលិតផលកសិកម្មនៅឡើយ។

បន្ថែមលើសពីនេះទៅទៀត ការផ្តល់សេវាបច្ចេកទេស និងកែលម្អធាតុចូលកសិកម្ម គប្បីធ្វើឡើងដោយមានចំណងទាក់ទងដ៏ខ្លាំងក្លារវាងតួអង្គសំខាន់ៗមួយចំនួនគឺ ស្ថាប័នដែលមានការជាប់ពាក់ព័ន្ធខាងលើ កសិករ ស្ថាប័នស្រាវជ្រាវ និងស្ថាប័នផ្សព្វផ្សាយកសិកម្ម។ យន្តការដែលត្រូវប្រទាក់ក្រឡាគ្នា រួមមានគោលនយោបាយ និងបទដ្ឋានគតិយុត្ត រចនាសម្ព័ន្ធនិងអង្គការចាត់តាំងស្ថាប័ន និងប្រតិបត្តិការផ្តល់សេវាផ្សព្វផ្សាយ។ ចំពោះការចាត់ចែងវិធីសាស្ត្រនៃការផ្សព្វផ្សាយកសិកម្មត្រូវ៖ (១) អនុវត្តទៅតាមអភិក្រមប្រព័ន្ធកសិកម្មចម្រុះ សម្រាប់ការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព (២) គាំទ្រដល់កសិករគ្រប់ប្រភេទ តាមរយៈការលើកកម្ពស់អភិក្រមដែលបំពេញទៅតាមតម្រូវការទីផ្សារនិងអ្នកទទួលផល នៅក្នុងដំណើរការជ្រើសរើសបច្ចេកវិទ្យាថ្មីៗ និងការអនុវត្តនានាដែលនាំមកនូវការបង្កើនទិន្នផល និងទទួលបានប្រាក់ចំណេញខ្ពស់ (៣) សហការជាមួយគ្រប់ក្រុមកសិករទាំងអស់ និងគិតគូអំពីសារៈសំខាន់នៃចំណេះដឹង និងគំនិតច្នៃប្រឌិតថ្មីៗដល់កសិករនៅមូលដ្ឋាន (៤) លើកកម្ពស់ការផ្តល់បច្ចេកវិទ្យាពត៌មាននិងសារទូរគមនាគមន៍នៅតាមជនបទ និង(៥) វិនិយោគលើការកែលម្អគុណភាពប្រធានបទ និងធ្វើបច្ចុប្បន្នភាពសម្ភារផ្សព្វផ្សាយជាប្រចាំ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងការងារអាទិភាពរបស់កសិករ។

ដើម្បីធានាឲ្យមានទីផ្សារតម្លៃកសិផលបានល្អសម្រាប់កសិករក្នុងរយៈពេលវែង ក៏ដូចជាការធានាបាននូវផលប្រយោជន៍សម្រាប់កសិករ ការលើកទឹកចិត្តកសិករដែលជាអ្នកផលិត និងលើកស្ទួយផលិតផលកសិកម្មរបស់ជាតិ គួរត្រូវបានពិនិត្យពិចារណាលើការកែលម្អរចនាសម្ព័ន្ធដឹកជញ្ជូន និងបែបបទនៃការវិនិយោគលើការរៀបចំចាត់ចែងរបស់សហព័ន្ធស្រូវ អង្ករ ក្នុងការនាំផលិតផលកសិកម្មចេញពីកម្ពុជា ដោយត្រូវផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងការផ្គត់ផ្គង់ពូជសុទ្ធជូនដល់កសិករ ដែលនឹងទទួលបានជំនឿជឿជាក់មកវិញពីអ្នកទិញ។

ទន្ទឹមនឹងបញ្ហាប្រឈមដូចបានជម្រាបជូនខាងលើ ក្រសួងពាក់ព័ន្ធគួរធ្វើការរួមគ្នាលើការតម្រង់ទិសលើការវិនិយោគក្នុងរយៈពេលមធ្យម និងវែងទៅលើហេដ្ឋារចនាសម្ព័ន្ធ ទឹក ផ្លូវ ភ្លើង បម្រើដល់វិស័យកសិកម្មឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ដើម្បីបម្រើឲ្យការនាំចេញ។ ដោយឡែកការរៀបចំផែនការគ្រប់គ្រងដីកសិកម្ម ក៏ត្រូវការចាំបាច់មានការចូលរួមយ៉ាងពេញលេញពីសំណាក់អ្នកពាក់ព័ន្ធ ដូចជាការកំណត់ប្រភេទដី និងដំណាំកសិកម្ម សក្តានុពលធនធានធម្មជាតិដូចជា ទឹកនិងព្រៃឈើ តំបន់ការពារ និងការរៀបចំដែនដី។ល។ ស្ថិតនៅក្នុងសភាពការណ៍ចំពោះមុខនេះ យើងអាចកំណត់ប្រភេទដាំដុះដំណាំកសិកម្ម ទៅតាមតំបន់នីមួយៗជាបឋមបានដែរ ដែលអាចយកជាមូលដ្ឋានឈានទៅដល់ការតម្រង់ទិស លើការអភិវឌ្ឍវិស័យនាពេលខាងមុខរួមមាន៖

(១) ការដាំដុះដំណាំស្រូវ និងការធ្វើវារីវប្បកម្ម សម្រាប់បម្រើដល់ការនាំចេញ គួរកំណត់យកតំបន់ដែលមានប្រភពទឹកគ្រប់គ្រាន់ ឋិតថេរ និងវិសាលភាពដីដាំដុះមានភាពទូលំទូលាយ ដូចជាផ្នែកខាងក្រោមតាមបណ្តាស្ទឹងសំខាន់ៗមួយចំនួន ជាពិសេសតំបន់អាងទឹកដែលស្ថិតនៅជុំវិញបឹងទន្លេសាប និងទន្លេមេគង្គនៃខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ និងតាកែវ ។

(២) ការដាំដុះដំណាំកសិ-ឧស្សាហកម្ម ការចិញ្ចឹមសត្វ សម្រាប់បម្រើដល់ការនាំចេញគួរកំណត់យកតំបន់ខ្ពង់រាបតំបន់ជុំវិញទន្លេសាបនិងទន្លេមេគង្គ។

(៣) ការធ្វើកសិកម្មចម្រុះ ដូចជាការផលិតបន្លែគ្រប់មុខ និងការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ គួរតម្រង់ទិសទៅលើតំបន់ដែលមានការខ្សត់ប្រភពទឹកលើដី ដែលគួរអនុវត្តនៅខេត្តគោលដៅមួយចំនួនដូចជាខេត្តកំពត តាកែវ ស្វាយរៀង ព្រៃវែង កណ្តាល មណ្ឌលគីរី ត្បូងឃ្មុំ និងកំពង់ចាមជាដើម។

ម្យ៉ាងទៀតក្នុងគោលបំណងលើកកម្ពស់ប្រាក់ចំណូលរបស់កសិករ ស្របតាមកំណើនសេដ្ឋកិច្ចកម្ពុជាដែលកំពុងកើនឡើងប្រកបដោយស្ថិរភាព និងមានតម្លៃថេរក្នុងរង្វង់៧%ក្នុងមួយឆ្នាំ រួមទាំងការកាត់បន្ថយការធ្វើចំណាកស្រុករបស់កសិករដែលខ្វះមធ្យោបាយផលិត ជាពិសេសកសិករដែលមានផ្ទៃដីតិចនោះ ក្រសួងពិនិត្យឃើញថា ការអភិវឌ្ឍកសិកម្មចម្រុះគឺជាមធ្យោបាយតែមួយគត់ដែលត្រូវកំណត់យកមកអនុវត្តក្នុងរយៈខ្លីនិងមធ្យម។

ដើម្បីមានលទ្ធភាពឈានទៅដល់ការអនុវត្តពេញលេញ នូវគោលនយោបាយធ្វើកំណែទម្រង់លើវិស័យកសិកម្ម ក្រសួងនឹងផ្តោតទៅលើសកម្មភាពជាអាទិភាពមួយចំនួនដូចខាងក្រោម៖

១. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដោយបំពាក់បច្ចេកវិទ្យាទំនើបក្នុងការផ្គត់ផ្គង់ទឹក (ពិសេសការតម្លើងប្រព័ន្ធដំណក់ទឹក) សម្រាប់បម្រើដល់ការដាំដុះដំណាំរួមផ្សំ សាកវប្បកម្ម ដំណាំបន្លែ និងចិញ្ចឹមសត្វ នៅតាមសហគមន៍/សហករណ៍កសិកម្ម ដែលត្រូវបានបង្កើតឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសនៅលើតំបន់កសិករក្រីក្រ និងមានដីតិច។ ផលិតកម្មកសិកម្មត្រូវអនុវត្តតាមគោលការណ៍ GAP ដើម្បីសុវត្ថិភាពចំណីអាហារជាចាំបាច់។

២. សហការជាមួយក្រសួងពាក់ព័ន្ធក្នុងការកសាងតភ្ជាប់ប្រឡាយជើងក្អែបជូនសហគមន៍/សហករណ៍កសិកម្ម ដើម្បីឈានទៅដល់ការប្រើប្រាស់ទឹកបានពេញលេញនៅលើប្រព័ន្ធស្រោចស្រពមួយចំនួន ដែលបានធ្វើការវិនិយោគដ៏ច្រើនសន្ធឹកសន្ធាប់ដោយរាជរដ្ឋាភិបាល និងបម្រើដល់ការធ្វើប្រពលវប្បកម្មដំណាំស្រូវ និងការធ្វើវារីវប្បកម្មឱ្យទទួលបានជោគជ័យ និងប្រសិទ្ធភាព។

៣. បង្កើនការយកចិត្តទុកដាក់ទៅលើការស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្ម សំដៅបង្កើនទិន្នផលដំណាំ លើកកម្ពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងនិងប្រើប្រាស់ដីប្រកបដោយនិរន្តភាព។

៤. ជំរុញការចិញ្ចឹមសត្វឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព តាមរយៈការពង្រឹងប្រសិទ្ធភាពការស្រាវជ្រាវនិងផ្សព្វផ្សាយ ការពង្រីកការចិញ្ចឹមសត្វ ការចែកចាយនិងបង្កាត់ពូជសត្វដែលមានតម្លៃនៅលើទីផ្សារ បង្កើនសមត្ថភាពបង្ការ ទប់ស្កាត់ជំងឺឆ្លងសត្វ ដើម្បីធានាបានការផ្គត់ផ្គង់សត្វ សាច់សត្វ ប្រកបដោយអនាម័យ សុវត្ថិភាព និងបង្កើនសក្តានុពលនៃការនាំចេញ។

៥. ជំរុញការអភិវឌ្ឍវារីវប្បកម្ម (កើន២០%ក្នុងមួយឆ្នាំ) នៅតាមតំបន់ដែលមានប្រភពទឹកគ្រប់គ្រាន់ និងបង្កើនការការពារនិងអភិរក្សធនធានជលផល ដើម្បីធានាឲ្យបាននូវនិរន្តភាពធនធានជលផល ព្រមទាំងកែលម្អគុណភាព និងសុវត្ថិភាពផល ផលិតផលជលផល សម្រាប់ការប្រើប្រាស់ក្នុងស្រុកនិងនាំចេញ។

៦. ជំរុញការដាំនិងស្តារព្រៃឈើឡើងវិញ (ពិសេសការសហការដៃគូជាមួយផ្នែកឯកជន) ព្រមទាំងពង្រីក និងពង្រឹងសហគមន៍ព្រៃឈើឱ្យមាននិរន្តភាព (ការរកមុខរបរបន្ថែម ដូចជា ការចិញ្ចឹមសត្វ ដាំដុះដំណាំមានទីផ្សារខ្ពស់ជាដើម កាត់បន្ថយការពឹងផ្អែកខ្លាំងលើព្រៃឈើក្នុងសហគមន៍) និង

៧. សិក្សាពិនិត្យលើលទ្ធភាពធ្វើកំណែទម្រង់រចនាសម្ព័ន្ធរបស់ក្រសួង ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រ និងពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្តុះបណ្តាលសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយនិរន្តរភាព។

ក្រសួងបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលទាំងឡាយដែលសម្រេចបានក្នុងឆ្នាំ២០១៧នេះ ដែលបានកើតចេញពីការខិតខំប្រឹងប្រែងរួមគ្នារវាងក្រសួង ស្ថាប័ននានា និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កន្លងមក។ សមិទ្ធផលដែលសម្រេចបាននេះ គឺបានមកពីការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល មន្ត្រីរាជការគ្រប់

លំដាប់ថ្នាក់ និងប្រជាកសិករ ព្រមទាំងការគាំទ្រនិងចូលរួមពីរដ្ឋអំណាចមូលដ្ឋាន ដៃគូអភិវឌ្ឍន៍នានា វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។ ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា និងគ្រប់ដៃគូពាក់ព័ន្ធទាំងអស់ ដែលបានជួយឧបត្ថម្ភគាំទ្រ និងចូលរួមវិភាគទានដ៏ថ្លៃថ្លាក្នុងការលើកកម្ពស់ និងអភិវឌ្ឍន៍វិស័យកសិកម្ម។

## ៣. ផែនការសកម្មភាព សម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥

រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការនូវ **"គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥"** នៅដើមខែមិថុនា ឆ្នាំ២០១៥ កន្លងទៅនេះ ដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មកម្ពុជា ដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ពង្រីកការប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។

ឯកសារគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជានេះ បានកំណត់ច្បាស់អំពីស្ថាប័ននាំមុខ និងស្ថាប័នទទួលខុសត្រូវ ព្រមទាំងបានកំណត់ច្បាស់នូវចំណុចវិធានការគោលនយោបាយ និងផែនការសកម្មភាពសំខាន់ៗពាក់ព័ន្ធផលិតកម្មកសិ-ឧស្សាហកម្ម រួមមាន (ទី១)-ការពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផល និងការផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់ទាំងនោះ (ទី២)-បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផលបច្ចេកទេសកែច្នៃកសិផល និងការអភិវឌ្ឍបច្ចេកទេសដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ (ទី៣)-រៀបចំសម្រួលយន្តការដល់ការនាំចេញកសិផលកែច្នៃ ដោយដោះស្រាយបញ្ហាឡូជីស្ទីក លុបបំបាត់កម្រៃក្រៅផ្លូវការ និងកែលម្អការសម្រួលពាណិជ្ជកម្ម (ទី៤)-កំណត់នូវមុខទំនិញអាទិភាព ដែលមានសក្តានុពលកែច្នៃសម្រាប់នាំចេញ និងរៀបចំផែនការសកម្មភាពជាក់លាក់គាំទ្រការអភិវឌ្ឍវិស័យនេះ។

ចំណុចគន្លឹះដែលត្រូវយកចិត្តទុកដាក់ក្នុងការជំរុញការអភិវឌ្ឍកសិ-ឧស្សាហកម្ម ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយដែលបានដាក់ឲ្យអនុវត្តនេះ គឺការតម្រង់ទិសការអភិវឌ្ឍតំបន់កែច្នៃកសិផល តំបន់កែច្នៃផលិតសម្ភារអំពីកៅស៊ូ តំបន់កែច្នៃផលិតម្ហូបអាហារពីផលិតផលដំណាំ សត្វ និងជលផល និងការអភិវឌ្ឍសួនកសិ-ឧស្សាហកម្មសម្រាប់គោលដៅនៃការប្រមូលផ្តុំកសិផល ដែលមានសក្តានុពលសម្រាប់កែច្នៃប្រើប្រាស់ក្នុងស្រុក និងនាំចេញ។ យន្តការគន្លឹះដែលត្រូវយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍកសិឧស្សាហកម្មនោះគឺ ការសម្របសម្រួល និងការលើកទឹកចិត្តវិស័យឯកជន ក្នុងការអភិវឌ្ឍបច្ចេកទេសកែច្នៃកសិផល ស្របតាមស្តង់ដារផលិតផលអាស៊ាន និងតម្រូវការស្តង់ដារទីផ្សារអន្តរជាតិ។ ការផ្សារភ្ជាប់រវាងក្រុមអ្នកផលិតជាមួយអ្នកប្រមូលទិញ តាមយន្តការ "ផលិតកម្មកសិកម្មតាមកិច្ចសន្យា" ដើម្បីធានាការផ្គត់ផ្គង់កសិផលប្រកបដោយនិរន្តរភាព គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់ផងដែរ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រមូលផ្តុំនូវសក្តានុពលក្នុងការរៀបចំផែនការសកម្មភាព ដើម្បីចូលរួមចំណែកជំរុញការអនុវត្ត គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ដោយផ្តល់លើវិធានការជាយុទ្ធសាស្ត្រចំនួន៤គឺ៖ (១). វិធានការជំរុញការទាក់ទាញវិនិយោគក្នុងវិស័យកសិកម្ម ដែលពាក់ព័ន្ធនឹងការកំណត់តំបន់សក្តានុពលផលិតកម្មកសិកម្ម ការបង្កើតតំបន់កសិ-ឧស្សាហកម្មកែច្នៃកសិផល (២). វិធានការពង្រីកនិងទំនើបកម្មសហគ្រាសកសិកម្មធុនតូចនិងមធ្យម សំដៅពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ជំរុញឱ្យអនុវត្តបច្ចេកវិទ្យាសមស្រប ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា (៣). វិធានការពាក់ពន្ធ័នឹងការកែលម្អបរិស្ថាននិយ័តកម្ម ដែលមានការពាក់ព័ន្ធនឹងការកសាងច្បាប់ លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ និង(៤). វិធានការសម្របសម្រួលគោលនយោបាយ ដែលផ្តោតជាសំខាន់លើយន្តការសម្របសម្រួល ពិសេសយន្តការច្រកចេញចូលតែមួយ ការចរចាការតម្រូវនានា ពិសេសកិច្ចការអនាម័យនិងភូតគាមអនាម័យ ដើម្បីសម្រួលការនាំចេញ ...។ល។

ក្រសួងនឹងយកចិត្តទុកដាក់លើវិធានការពង្រីក និងទំនើបកម្មសហគ្រាសកសិកម្មធុនតូចនិងមធ្យម និងពង្រឹងសមត្ថភាពសហគមន៍កសិកម្មឲ្យមានលក្ខណៈជាអាជីព ដោយជំរុញឱ្យអនុវត្តបច្ចេកវិទ្យាសមស្រប និងអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ព្រមទាំងលើកកម្ពស់ការចូលរួមវិនិយោគពីវិស័យឯកជន ក្នុងគ្រប់ខ្សែសង្វាក់តម្លៃកសិកម្ម ដើម្បីផ្សារភ្ជាប់កសិករខ្នាតតូច ទៅនឹងទីផ្សារតាមអភិក្រម "**ភាពជាដៃគូក្នុងចំណោមរដ្ឋ-ឯកជន-ផលិតករ** (Public Private and Producer Partnership in Agriculture)"។

បន្ថែមលើនេះទៀត ក្រសួងនឹងបន្តលើកកម្ពស់វិធានអនាម័យ និងភូតគាមអនាម័យ (SPS) ដោយយកចិត្តទុកដាក់ទៅលើយន្តការ ក្របខ័ណ្ឌគតិយុត្ត និងបច្ចេកវិទ្យា ព្រមទាំងពង្រីកនិងពង្រឹងសមត្ថកិច្ចត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យ ដើម្បីសម្រួលពាណិជ្ជកម្ម សមាហរណកម្មសេដ្ឋកិច្ច និងទទួលបានទីផ្សារផលិតផលកសិកម្មក្នុងតំបន់និងអន្តរជាតិ។

ជាក់ស្តែង ក្រសួងបាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តមួយចំនួន ពិសេសសេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ និងសេចក្តីព្រាងអនុក្រឹត្យ ប្រកាសអន្តរក្រសួង ប្រកាសក្រសួងមួយចំនួនទៀត ព្រមទាំងផែនការយុទ្ធសាស្រ្តសម្រាប់គ្រប់គ្រងនិងអភិវឌ្ឍន៍ពូជស្រូវនៅកម្ពុជា។ លើសពីនេះទៀត ក្រសួងបានរៀបចំចងក្រងឯកសារមគ្គុទេស សម្រាប់អ្នកវិនិយោគក្នុងវិស័យកសិកម្ម (Guidebook for Investor in Agricultural Sector) ដែលបានបង្ហាញអំពីស្ថានភាពនៃការអភិវឌ្ឍវិស័យកសិកម្ម លក្ខណៈអំណោយផល សក្តានុពលភាពនៃការអភិវឌ្ឍ និងនីតិវិធីសំខាន់ៗសម្រាប់ការធ្វើវិនិយោគក្នុងវិស័យនេះ។

ដោយពិនិត្យឃើញសក្តានុពលខ្ពស់នៃផលិតកម្មដំណាំស្វាយចន្ទី និងតម្រូវការទីផ្សារនៃផលិតផលនេះ មានការកើនឡើង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ស្តីពីការជំរុញផលិតកម្មស្វាយចន្ទីកម្ពុជាសម្រាប់ការនាំចេញ ជាមួយសមាគមស្វាយចន្ទីវៀតណាម កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨ កន្លងទៅនេះ។ ជាមួយគ្នានេះ ភាគីសមាគមស្វាយចន្ទីវៀតណាមបានយល់ព្រមផ្តល់ប្រភេទពូជស្វាយចន្ទី គាំទ្របច្ចេកទេស និងប្រមូលទិញផលិតផលស្វាយចន្ទីពីកសិករ ឬសហគមន៍កសិកម្ម ដោយអនុវត្តតាមគោលការណ៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ក្នុងគោលបំណងបង្កើនផលិតកម្មដំណាំស្វាយចន្ទីនៅកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានណែនាំដល់អង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ដូចខាងក្រោម៖

១- សិក្សាសក្តានុពលជាយុទ្ធសាស្រ្ត និងកំណត់តំបន់ដាំដុះដំណាំស្វាយចន្ទី សម្រាប់ប្រជាកសិករ និងសហគមន៍កសិកម្មធ្វើការផលិត និងភ្ជាប់ទីផ្សារតាមរយៈការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ក្រោមក្របខ័ណ្ឌនៃការអនុវត្តអនុស្សរណៈយោគយល់គ្នា ស្តីពីការជំរុញផលិតកម្មស្វាយចន្ទីកម្ពុជាសម្រាប់ការនាំចេញ ជាមួយសមាគមស្វាយចន្ទីវៀតណាម។

២- សហការឱ្យបានជិតស្និទជាមួយសមាគមស្វាយចន្ទីវៀតណាម ក្នុងការជ្រើសរើសក្រុមផលិត ការផ្តល់បច្ចេកទេសទំនើបជូនដល់ក្រុមកសិករ ឬ សហគមន៍កសិកម្ម ដើម្បីដាំដុះដំណាំស្វាយចន្ទី ស្របតាមសក្តានុពលភាពជំនួសប្រភេទដំណាំណាដែលផ្តល់ទិន្នផលទាប មិនសមស្របនឹងប្រព័ន្ធអេកូឡូស៊ីត្រូវបរិស្ថានចំពោះមុខនិងទៅអនាគត។

៣- ធ្វើការណែនាំនិងផ្សព្វផ្សាយដល់ក្រុមកសិករ ឬសហគមន៍កសិកម្ម ព្រមទាំងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ឱ្យចូលរួមបង្កើនផលិតកម្មដំណាំស្វាយចន្ទី និងត្រូវភ្ជាប់ទំនាក់ទំនងទីផ្សារនាំចេញ ជាមួយសមាគមស្វាយចន្ទីវៀតណាមឱ្យបានល្អប្រសើរ។

## ៤. វេទិកាស្តីពីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេទិកានេះបានប្រព្រឹត្តទៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨ ក្នុងគោលបំណងដើម្បីពិភាក្សា និងស្វែងយល់អំពីការអភិវឌ្ឍវិស័យកសិកម្ម ពិសេសបង្កលក្ខណៈឱ្យមានឱកាសប្រាស្រ័យទាក់ទងដោយផ្ទាល់ ជាមួយអ្នកជំនាញបច្ចេកទេស

ក៏ដូចជាស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញអំពីបញ្ហាប្រឈមនានាដែលបានជួបប្រទះ និងពិភាក្សាគ្នាឱ្យបានស៊ីជម្រៅ សំដៅដោះស្រាយបញ្ហាទាំងអស់នោះឱ្យបានល្អប្រសើរ សម្រាប់ជាចក្ខុវិស័យក្នុងការអភិវឌ្ឍវិស័យកសិកម្មឱ្យទទួលបានជោគជ័យ។

អង្គវេទិកាបានលើកឡើងបញ្ហាពាក់ព័ន្ធនឹង (១) ការធ្វើប្រតិភូកម្មដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២) ស្នើសុំបង្កើតតំបន់សិប្បកម្ម ឧស្សាហកម្ម ដើម្បីងាយទទួលបានឥណទាន (៣) ការទប់ស្កាត់បទល្មើសព្រៃឈើនៅតំបន់ភ្នំប្រាំពាន់និងភ្នំសេះក្នុងខេត្តក្រចេះ (៤) ការចូលទន្ទ្រានកាន់កាប់ក្នុងដីសម្បទានសេដ្ឋកិច្ច (៥) សុពលភាពលើការផ្តល់វិញ្ញាបនបត្រលើការនាំចេញ (៦) បញ្ហាប្រឈមក្នុងប្រកួតប្រជែងទីផ្សាររបស់សមាគមន៍ចិញ្ចឹមសត្វកម្ពុជា (៧) បញ្ហាពន្ធអាករ និងអាករតម្លៃបន្ថែមក្នុងខ្សែចង្វាក់ផលិតកម្ម (៨) ការគាំទ្រទុនដល់សហគមន៍កសិកម្ម (៩) ការកើតមានបទល្មើសក្នុងដែននេសាទសហគមន៍ (១០) បញ្ហាកង្វះទឹកសម្រាប់ស្រោចស្រពដំណាំកសិកម្មនៅសហគមន៍។

ជាមួយនឹងការលើកឡើងនូវរាល់បញ្ហាដូចបានជម្រាបជូនខាងលើ អង្គវេទិកាបានលើកជាសំណូមពរជាក់ស្តែងមួយចំនួនដូចខាងក្រោម៖

១) វិស័យឯកជនបានស្នើសុំឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិចារណាក្នុងការផ្តល់ប្រតិភូកម្មដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ឲ្យបានច្រើនថែមទៀត ដើម្បីដោះស្រាយបញ្ហាបន្ទាន់ៗដែលប្រឈមនៅមូលដ្ឋាន។ ចំពោះការលើកឡើងនេះ ក្រសួងបានធ្វើប្រតិភូកម្មរួចហើយ ដូច្នេះក្រសួងបានស្នើឲ្យផ្នែកឯកជន ធ្វើការទំនាក់ទំនងឲ្យបានជិតស្និទ្ធ ជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត។

២) វិស័យឯកជនបានស្នើសុំឱ្យរាជរដ្ឋាភិបាល ពិចារណាក្នុងការបង្កើតតំបន់ពិសេសសម្រាប់សិប្បកម្ម ឧស្សាហកម្មខ្នាតតូចនិងមធ្យម (SME) នៅថ្នាក់រាជធានីខេត្ត ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការទទួលបានឥណទាន ពីធនាគារដែលគាំទ្រដល់ផ្នែក SME ដែលប្រមុខរាជរដ្ឋាភិបាលបានប្រកាសឱ្យបង្កើតនាពេលកន្លងមក។ ពាក់ព័ន្ធនឹងសំណើនេះក្រសួងបានយល់ស្រប ហើយក្រសួងនឹងស្នើឲ្យស្ថាប័នពាក់ព័ន្ធពិនិត្យពិចារណាទៅលើក្របខ័ណ្ឌគតិយុត្ត ដើម្បីបង្កើតតំបន់ពិសេសសម្រាប់សិប្បកម្ម ឧស្សាហកម្មខ្នាតតូចនិងមធ្យម ក្នុងទិសដៅជំរុញការកែច្នៃផលិតផលកសិកម្ម សម្រាប់ធ្វើការផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងការនាំចេញ។

៣) បណ្តាញសហគមន៍ព្រៃឈើ បានស្នើសុំឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាត់វិធានការទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើនៅតំបន់ភ្នំប្រាំពាន់ និងតំបន់ភ្នំសេះក្នុងខេត្តក្រចេះ ដែលជាតំបន់វប្បធម៌ប្រវត្តិសាស្រ្តធម្មជាតិ ជាមួយនឹងការស្នើឲ្យពន្លឿនការចេញប្រកាសទទួលស្គាល់សហគមន៍ព្រៃឈើជាផ្លូវការ និងគាំទ្រដល់ក្រុមល្បាតការពារព្រៃសហគមន៍ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ពាក់ព័ន្ធនឹងការលើកឡើងនេះ ក្រសួងបានជំរុញឲ្យរដ្ឋបាលព្រៃឈើ តាមរយៈមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត និងអាជ្ញាធរខេត្ត ចាត់វិធានការជាបន្ទាន់ដើម្បីទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើនេះ។ ជាមួយគ្នានោះ ក្រសួងបានស្នើឲ្យរដ្ឋបាលព្រៃឈើ ពិនិត្យលើសំណុំឯកសារស្នើសុំនេះឲ្យលឿនតាមដែលអាចធ្វើបាន ដើម្បីក្រសួងចេញប្រកាសទទួលស្គាល់សហគមន៍ព្រៃឈើជាផ្លូវការទាន់ពេលវេលា។

៤) ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមួយចំនួនបានស្នើសុំឲ្យក្រសួងមានវិធានការទប់ស្កាត់ ការចូលទន្ទ្រានកាន់កាប់ក្នុងដីសម្បទានសេដ្ឋកិច្ចពីសំណាក់ជនខិលខូច។ បញ្ហានេះក្រសួងតែងតែពិនិត្យ និងដោះស្រាយជាបណ្តើរៗ ហើយក្រសួងទាមទាឲ្យក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច សហការជាមួយអាជ្ញាធរខេត្ត ដើម្បីពន្លឿនការបំពេញនីតិវិធីឲ្យបានគ្រប់ជ្រុងជ្រោយ ជាពិសេសលើការចុះបញ្ជីដី ការធ្វើអនុបយោគ ការដោះស្រាយផលប៉ះពាល់ជាមួយប្រជាពលរដ្ឋ។ ជាមួយគ្នានេះដែរ ក្រសួងស្នើសុំឲ្យក្រុមហ៊ុនទាំងអស់ដែលកំពុងជួបបញ្ហាពីការទន្ទ្រានកាន់កាប់ដីត្រូវអនុវត្តតាមគោលការណ៍ ឬវិធានការរបស់ក្រសួងឲ្យមានប្រសិទ្ធភាព ត្រូវសហការជាមួយអាជ្ញាធរដែនដី និងរដ្ឋបាលព្រៃឈើដើម្បីចុះបញ្ជីដី និងធ្វើអនុបយោគដីពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ។ ចំពោះថ្លៃសម្បទាន និងសួយសារអាករ ក្រសួងស្នើឱ្យក្រុមហ៊ុនយកចិត្តទុកដាក់ក្នុងការបង់ជូនរដ្ឋឲ្យបានទាន់ពេលវេលា។

៥) ក្រុមហ៊ុនកែច្នៃស្បែកសត្វសម្រាប់នាំចេញទៅក្រៅប្រទេស បានស្នើឲ្យក្រសួងពិនិត្យលើការផ្តល់សុពលភាពវិញ្ញាបនបត្រនាំចេញស្បែកសត្វឲ្យមានរយៈពេល៣ខែ ដើម្បីឆ្លើយតបទៅនឹងរយៈពេលដឹកជញ្ជូនទៅកាន់ប្រទេសនាំចូល។ ឆ្លើយតបទៅនឹងសំណើនេះ ក្រសួងបានប្រគល់ភារកិច្ចជូនអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ពិនិត្យ ទាំងក្របខ័ណ្ឌច្បាប់និងបច្ចេកទេស ដើម្បីសម្រួលនិងដោះស្រាយបញ្ហានេះ។

៦) សមាគមន៍ចិញ្ចឹមសត្វកម្ពុជា បានលើកឡើងនូវបញ្ហាប្រឈមក្នុងប្រកួតប្រជែងទីផ្សារក្នុងខ្សែចង្វាក់ផលិតកម្មសត្វ ជាពិសេសការស្នើឲ្យទប់ស្កាត់ការនាំចូលសត្វ ដែលជះឥទ្ធិពលដល់ផលិតកម្មសត្វក្នុងស្រុក។ ពាក់ព័ន្ធនឹងបញ្ហានេះ ក្រសួងបានស្នើឲ្យសមាគមន៍ពិចារណាលើការធ្វើទំនើបកម្មក្នុងខ្សែចង្វាក់ផលិតកម្មសត្វ ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងទីផ្សារ។ ទន្ទឹមនឹងនេះ ក្រសួងបានស្នើឲ្យអាជ្ញាធរខេត្ត និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត បន្តចាត់វិធានការទប់ស្កាត់ការនាំចូលសត្វខុសច្បាប់ឲ្យកាន់តែមានប្រសិទ្ធភាព។

៧) ផ្នែកឯកជនបានលើកឡើងពីបញ្ហាពន្ធអាករ និងអាករតម្លៃបន្ថែមក្នុងខ្សែចង្វាក់ផលិតកម្ម ដែលក្នុងនោះបានផ្តោតទៅលើ (១) ការនាំចូលវត្ថុធាតុដើមផ្សំចំណីសត្វ ការនាំចូលសត្វ សត្តឃាតដ្ឋាន និងការកែច្នៃសាច់ (២) គ្រឿងបន្លាស់គ្រឿងយន្តកសិកម្ម។ ឆ្លើយតបនឹងការលើកឡើងនេះ ក្រសួងស្នើឲ្យក្រុមហ៊ុនបញ្ជាក់អំពីប្រភេទវត្ថុធាតុដើម ដែលត្រូវស្នើសុំឲ្យបានច្បាស់ ដើម្បីឱ្យក្រសួងមានមូលដ្ឋានពិនិត្យពិចារណា និងពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួចដាក់សំណើជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

៨) សហគមន៍កសិកម្មតាមបណ្តាខេត្តបានស្នើសុំឲ្យមានការគាំទ្រទុនកម្ចី ដែលមានអាត្រាការប្រាក់ទាបសម្រាប់ដំណើរការអភិវឌ្ឍន៍សហគមន៍កសិកម្ម។ សហគមន៍កសិកម្មបានត្អូញត្អែរលើការយកសេវាបន្ថែម (សេវារដ្ឋបាល សេវាហានិភ័យ និងសេវាពិនិត្យឈ្មោះ) ពីស្ថាប័នមីក្រូហិរញ្ញវត្ថុ។ ចំពោះសំណើនេះ ក្រសួងបានស្នើឱ្យសហគមន៍ពិចារណាលើភាពចាំបាច់នៃប្រាក់កម្ចី មុននឹងសម្រេចចិត្តទទួលយកឥណទាន ដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន ស្របពេលដែលស្ថាប័នមីក្រូហិរញ្ញវត្ថុបានបន្ថយអាត្រាការប្រាក់ត្រឹម១៨% រួចហើយ។

៩) សហគមន៍នេសាទបានលើកឡើងពីបញ្ហាបទល្មើសនេសាទក្នុងដែននេសាទសហគមន៍ ហើយមានការវាយមកលើសមត្ថកិច្ចពីសំណាក់ជនល្មើស។ ចំពោះបញ្ហានេះ ក្រសួងបានសម្រេចឲ្យរដ្ឋបាលជលផល សហការជាមួយសហគមន៍ និងអាជ្ញាធរដែនដី ចាត់វិធានការទប់ស្កាត់បទល្មើសនេសាទឲ្យមានប្រសិទ្ធភាព។ ជាមួយគ្នានេះ រដ្ឋបាលជលផលនឹងបន្តជំរុញឲ្យមានការសិក្សាអំពីលទ្ធភាពធ្វើវារីវប្បកម្ម ដើម្បីកាត់បន្ថយសម្ពាធនៃការធ្វើនេសាទត្រីធម្មជាតិទៅជាការចិញ្ចឹមបែបពាណិជ្ជកម្ម។

១០) តំណាងសហគមន៍នៅខេត្តសៀមរាប បានបង្ហាញពីបញ្ហាកង្វះទឹកសម្រាប់ស្រោចស្រពដំណាំកសិកម្មសរីរាង្គក្នុងសហគមន៍ ដើម្បីបម្រើសេវាកម្មអេកូទេសចរណ៍។ ពាក់ព័ន្ធនឹងសំណើនេះ ក្រសួងបានស្នើឲ្យគណៈអភិបាលខេត្ត មន្ទីរធនធានទឹក និងឧតុនិយមខេត្ត និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ដើម្បីពិនិត្យនិងសិក្សាលទ្ធភាពនៅតំបន់នោះ។

១១) តំណាងសហគមន៍ព្រៃឈើនិងជលផល បានលើកឡើងអំពីការឧបត្ថម្ភគាំទ្រធនធានថវិកាចំនួន៤លានរៀលក្នុងមួយសហគមន៍ ដើម្បីដំណើរការគ្រប់គ្រងសហគមន៍ និងការអភិរក្សធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ បញ្ហានេះ ក្រសួងបានស្នើឱ្យរដ្ឋបាលព្រៃឈើនិងរដ្ឋបាលជលផល រៀបចំគម្រោងថវិកាក្នុងក្របខ័ណ្ឌថវិកាកម្មវិធីរបស់ក្រសួង ដើម្បីស្នើសុំការគាំទ្រពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងថវិកាជាតិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ឆ្នាំ២០១៩។

## ៥. ការទទួលស្គាល់នូវបញ្ហាប្រឈម និងការវិវត្តនៃវិស័យកសិកម្មនៅក្នុងបរិបទនៃការរីកចម្រើនសេដ្ឋកិច្ចកម្ពុជា

ក្នុងពេលថ្មីៗនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានពិនិត្យឃើញថា មានការកើនឡើងនូវការបញ្ចេញទស្សនៈផ្សេងៗទាក់ទងទៅនឹងវិស័យកសិកម្ម ទីផ្សារកសិកម្ម និងការធ្វើចំណាកស្រុក។ តាមការពិនិត្យឃើញនូវការ

បញ្ចេញទស្សនៈ និងតាមការស្រាវជ្រាវថ្មីរបស់ក្រសួង យើងបានដឹងថានឹងមានអ្វីកើតឡើងចំពោះមុខ ដែលជាបញ្ហាប្រឈមថ្មីៗរបស់កសិករក្នុងការដោះស្រាយជីវភាព និងការប្រកបមុខរបរកសិកម្មពីមុន និងរហូតមកដល់ពេលបច្ចុប្បន្ននេះ ក៏ដូចជាពេលអនាគតនៅកម្ពុជា។ បញ្ហាប្រឈមដែលបានកើតឡើង នឹងកើតឡើងនោះប្រាកដណាស់វាបានវាយលុកទៅលើវិស័យកសិកម្មទាំងមូល ជាពិសេសការធ្វើកសិកម្មខ្នាតតូច គឺកសិករដែលទទួលបានប្រាក់ចំណូលពីរបរកសិកម្មកើនឡើងតិចតួច ដោយសារទំហំដីកសិកម្មរបស់កសិករខ្នាតតូចគឺនៅដដែលឬកាន់តែតិចទៅៗ ដោយសារការចែករំលែកទៅកូនចៅរបស់ពួកគាត់ ជាមួយនឹងកំណើនសេដ្ឋកិច្ចកម្ពុជាបានកើនឡើងក្នុងល្បឿនថេរជាង ៧%ក្នុងមួយឆ្នាំ ក្នុងរយៈពេលជិត២០ឆ្នាំកន្លងមកនេះ។ ហេតុផលទាំងអស់នេះ គឺបានស្តែងចេញឲ្យឃើញកម្លាំងពលកម្មក្នុងវិស័យកសិកម្មបានធ្លាក់ចុះយ៉ាងគំហុកពី៨០% នៅឆ្នាំ១៩៩៣ ៦០%នៅឆ្នាំ២០០៥ និងបានធ្លាក់ចុះមកជិត៤៤%នៅឆ្នាំ២០១៧។ លទ្ធផលនេះបានបង្ហាញឲ្យឃើញថា មិនមែនជារឿងកើតឡើងចម្លែកតែចំពោះប្រទេសកម្ពុជាមួយនោះទេ បើតាមអ្វីដែលក្រសួងបានធ្វើការសិក្សាស្រាវជ្រាវនៅតាមបណ្តាប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍មួយចំនួនបានពិនិត្យឃើញថា គឺជាដំណើរវិវត្តទៅដូចៗគ្នាទាក់ទងទៅនឹងការធ្វើចំណាកស្រុករបស់ប្រជាជន/កសិករ ដែលបានដើរចេញពីស្រុកកំណើត និងការងារកសិកម្មរបស់ខ្លួន ទៅស្វែងរកការងារថ្មីប្រសើរជាងមុន។ ប្រទេសអង់គ្លេសនៅឆ្នាំ១៥០០ ចំនួនកសិករធ្វើការក្នុងវិស័យកសិកម្មមានចំនួន៥៦,៨% និងបានធ្លាក់មកត្រឹម១,៥%នៅឆ្នាំ ២០០០។ ប្រទេសអ៊ីតាលីនៅឆ្នាំ១៨០០ មានកសិករចំនួន៥៧,៨% និងបានធ្លាក់មកត្រឹម៣,៧% នៅឆ្នាំ២០១២។ ប្រទេសថៃពលកម្មកសិកម្មបានធ្លាក់ចុះពី៧៦,៧% នាឆ្នាំ១៩៧១ មកត្រឹមតែ៣២,២៤% នៅឆ្នាំ២០១៥។

ក្រៅពីធ្វើចំណាកស្រុកដើម្បីស្វែរកការងារប្រសើរជាងមុននៅក្នុងប្រទេសរបស់ខ្លួន ប្រជាជន/ប្រជាកសិករតាមបណ្តាប្រទេសនីមួយៗ បានធ្វើចំណាកស្រុកទៅកាន់បណ្តាប្រទេសនានាក្នុងពិភពលោកយើងនេះ ដែលគេបានគិតថាមានកម្រិតសេដ្ឋកិច្ចខ្ពស់ជាង ឬអាចទទួលបានប្រាក់ចំណូលខ្ពស់ជាងប្រទេសរបស់ខ្លួនកំពុងរស់នៅ ដូចជា៖ ប្រទេសឥណ្ឌាបានធ្វើចំណាកស្រុកទៅក្រៅប្រទេសមានជាង៣០,៨លាននាក់ ប្រទេសចិនមានជាង១០លាននាក់ ប្រទេសអាមេរិកមានជាង៨លាននាក់ ប្រទេសជប៉ុនមានជាង៣,៦លាននាក់ ប្រទេសកូរ៉េមានជាង៧លាននាក់ ប្រទេសវៀតណាមមានជាង៧លាននាក់ ប្រទេសឥណ្ឌូនេស៊ីមានជាង៨លាននាក់ និងប្រទេសហ្វីលីពីនធ្វើចំណាកស្រុកក្រៅប្រទេសមានជាង១០,២លាននាក់ ។ល។

របកគំហើញមួយចំនួនតូចខាងលើនេះ គឺពិតជាបានចូលរួមចំណែកក្នុងការឆ្លុះបញ្ចាំងឲ្យឃើញថាប្រមុខរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងខិតខំដាក់ចេញនូវគោលនយោបាយយុទ្ធសាស្ត្រនៃការអភិវឌ្ឍជាតិ បានយ៉ាងត្រឹមត្រូវក្នុងការចូលរួមចែករំលែកការលំបាករបស់ប្រជាជន។ យុទ្ធសាស្ត្រសំខាន់ៗទាំងនោះរួមមាន៖

1. ការធ្វើអំពាវនាវដល់ប្រទេសកំពុងអភិវឌ្ឍន៍ និងអភិវឌ្ឍន៍ឲ្យទទួលយកពលករពីកម្ពុជា
2. ការដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥
3. ការធ្វើទំនើបកម្មវិស័យកសិកម្ម តាមអភិក្រមនិងក្នុងវិសាលភាពនិងល្បឿនកំណើនសេដ្ឋកិច្ចថ្មី
4. ការពង្រីកទីផ្សារកសិកម្ម តាមរយៈការទទួលយកការវិនិយោគពីឯកជន ទាំងក្នុងនិងក្រៅប្រទេស (ដែលជាឱកាសមួយរបស់ប្រជាកសិករដែលរស់នៅតំបន់វិនិយោគនោះមានការងារធ្វើ ជាមួយនឹងការទទួលបានបច្ចេកវិទ្យាថ្មីក្នុងការដាំដុះ ឆ្លើយតបតាមសេចក្តីត្រូវការទីផ្សារ ហើយកសិករដែលរស់នៅជុំវិញតំបន់នោះអាចចូលរួមផលិតនូវផលិតផលកសិកម្មក្នុងការនាំចេញជាមួយក្រុមហ៊ុន) ការងារនេះកំពុងលេចចេញជារូបរាងបណ្តើរៗ តាមរយៈការវាយតម្លៃរបស់ក្រសួងនាពេលកន្លងមកនេះ។ សូមបញ្ជាក់ឲ្យដឹងថា ការបោះទុនវិនិយោគលើការដាំដុះឈើហូបផ្លែជិតមួយឆ្នាំកន្លងមកនេះ គឺធ្វើឡើងឲ្យដឹងតាមការបញ្ជាទិញពីក្រុមហ៊ុនក្រៅប្រទេសដូចជា ប្រទេសជប៉ុន ចិន និងអូស្ត្រាលី ជាមួយនឹងការផ្តល់ជំនាញបច្ចេកទេសក្នុងការដាំដុះនិងវេចខ្ចប់។

5. ផែនការនៃការពង្រីកវិស័យហេដ្ឋារចនាសម្ព័ន្ធគាំទ្រដូចជា បណ្តាញគមនាគមន៍ កំពង់ផែទឹកជ្រៅ ១២ម៉ែត្រ ព្រលានយន្តហោះនៅខេត្តសៀមរាប ថាមពលអគ្គិសនី (វារីអគ្គិសនី) ប្រព័ន្ធផ្គត់ផ្គង់ទឹក ។ល។ ក្នុងការទទួលបានការវិនិយោគពីក្នុងនិងក្រៅប្រទេសបន្ថែមទៀត ជាពិសេស លើវិស័យកសិ-ឧស្សាហកម្ម ក្នុងការកែច្នៃផលិតផលកសិកម្មដែលកំពុងផលិតលើសពីតម្រូវការផ្គត់ផ្គង់ក្នុងស្រុក និង
6. មានយុទ្ធសាស្ត្រសំខាន់ៗជាច្រើនទៀតក្នុងការជួយគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្ម។

## III- លទ្ធផលជារួម

នៅក្នុងឆ្នាំ២០១៧នេះ ទឹកភ្លៀងបានចាប់ផ្តើមធ្លាក់ជាបន្តបន្ទាប់ចាប់ពីដើមរដូវវស្សា ប៉ុន្តែមានកូនរដូវប្រាំងកើតឡើងនៅតាមបណ្តាខេត្តមួយចំនួន។ ទោះជាយ៉ាងនេះក្តី គ្រោះរាំងស្ងួតក៏បានបង្កការលំបាកដល់ដំណើរការបង្កបង្កើនផលដំណាំក្នុងអំឡុងខែសីហា និងដើមខែកញ្ញា និងជាចុងក្រោយគឺគ្រោះទឹកជំនន់បានកើតមានក្នុងអំឡុងខែតុលា។

ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រើប្រាស់គ្រប់មធ្យោបាយ និងបានផ្តល់សម្ភារកសិកម្ម ដើម្បីជួយអន្តរាគមន៍ក្នុងពេលជួបប្រទះនូវគ្រោះធម្មជាតិ មានដូចជា៖ ពូជស្រូវ ពូជបន្លែ ពូជសត្វ បសុឱសថ វ៉ាក់សាំង និងមធ្យោបាយអន្តរាគមន៍ផ្សេងៗទៀតដែលចាំបាច់ និងបានជំរុញការប្រមូលផលស្រូវរដូវវស្សាឲ្យបានល្អ ដោយយកចិត្តទុកដាក់ណែនាំដល់ប្រជាកសិករ អនុវត្តនូវវិធានការទប់ស្កាត់ការបាត់បង់ក្រោយពេលប្រមូលផល ទាំងបរិមាណនិងគុណភាពស្រូវ។ ក្រសួងបានអនុវត្តការងារវាយតម្លៃទិន្នផល និងបរិមាណផលស្រូវបានច្បាស់លាស់តាមដានជាប់ជាប្រចាំនូវដំណើរការបង្កបង្កើនផលស្រូវរដូវប្រាំង និងជំរុញការដាំដុះនៅតំបន់ដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ ដោយសហការជាមួយមន្ទីរធនធានទឹកនិងឧតុនិយម និងអាជ្ញាធរថ្នាក់ក្រោមជាតិសម្របសម្រួលបែងចែកការប្រើប្រាស់ទឹកស្រោចស្រព និងអន្តរាគមន៍បូមបាចតាមស្ថានភាពជាក់ស្តែង។ បន្ថែមពីនេះក្រសួងបាន ខិតខំផ្សព្វផ្សាយបច្ចេកទេសដល់កសិករ ការប្រើប្រាស់ធាតុចូលកសិកម្មសមស្រប ជំរុញប្រើប្រាស់ពូជល្អមានទិន្នផលខ្ពស់ និងការប្រើប្រាស់ឧបករណ៍ព្រោះ ដើម្បីកាត់បន្ថយបរិមាណគ្រាប់ពូជ និងថ្លៃដើមផលិតកម្ម។

លើសពីនេះទៀត បញ្ហាផលិតភាពទាបនៃផលិតកម្មកសិកម្ម ពិសេសផលិតកម្មដំណាំស្រូវ ជាកង្វល់មួយដែលត្រូវប្រឹងប្រែងដោះស្រាយ ហើយបញ្ហានេះមានការពាក់ព័ន្ធដល់បញ្ហាថ្លៃស្រូវ។ ក្រសួងបានមើលឃើញពីបញ្ហានេះ និងបានខិតខំជំរុញការបង្កបង្កើនផលស្រូវរបៀបទំនើបតាមបែបស៊ីជម្រៅជាប្រពលវប្បកម្ម ដើម្បីឱ្យទទួលបានទិន្នផលខ្ពស់និងគុណភាពល្អ ដោយប្រើប្រាស់យន្តូបនីយកម្ម និងបច្ចេកវិទ្យាថ្មីៗ ស្របតាមចរន្តសកលភាវូបនីយកម្ម។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម សំដៅជំរុញលើកកម្ពស់ផលិតភាពកសិកម្ម ទាំងបរិមាណនិងគុណភាព ដោយធានាបានសន្តិសុខស្បៀង និងបង្កើនការនាំចេញកសិផល ក៏ដូចជាការគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយចីរភាព។ មិនតែប៉ុណ្ណោះ វិស័យកសិកម្មបាននិងកំពុងស្រូបទាញនូវទុនវិនិយោគ ពីអ្នកវិនិយោគទាំងក្នុងនិងក្រៅប្រទេសកាន់តែច្រើនឡើងជាលំដាប់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ទោះជួបប្រទះនូវកត្តាអវិជ្ជមានខ្លះៗក៏ដោយ។

### ១. ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ

វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ២៤,៩% (ថ្លៃបច្ចុប្បន្ន) នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៧។ ដោយឡែក វិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ៣២,៩% និងវិស័យសេវាកម្មប្រមាណ៤២,២%។ ការកើនឬថយចុះនូវចំណែកនៃការចូលរួមរបស់វិស័យកសិកម្ម គឺអាស្រ័យទៅនឹងការរីកលូតលាស់នៃផ្នែកពីរសំខាន់ផ្សេងទៀតក្នុងវិស័យសេដ្ឋកិច្ច (វិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្ម) ដែលជាការកត់សម្គាល់នាពេលកន្លងមក ការ

ចូលរួមចំណែករបស់វិស័យកសិកម្មមានការប្រែប្រួលពី៣៣,៦%-២៤,៩% ក្នុងចន្លោះឆ្នាំ២០១៣-២០១៧ ដោយសារតែវិស័យឧស្សាហកម្ម និងសំណង់មានការកើនឡើង។

**ក្រាហ្វិកបង្ហាញពីការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ**




**ប្រភព៖** ការប៉ាន់ស្មានពីក្រសួងផែនការឆ្នាំ២០១៧

ទោះជាយ៉ាងនេះក្តី បើពិនិត្យទៅលើតម្លៃបន្ថែមសរុប គិតតាមតម្លៃបច្ចុប្បន្ន នៃវិស័យកសិកម្ម (Agricultural Gross Value Added-GVA) គឺមានការកើនឡើងជារៀងរាល់ឆ្នាំ។ តម្លៃបន្ថែមសរុបនៃវិស័យកសិកម្មបានកើនពី ១៣ ៧៤៥ពាន់លានរៀលនៅឆ្នាំ២០០៨ ដល់១៧ ៩៩៤ពាន់លានរៀល នៅឆ្នាំ២០១១ និងបានបន្តកើនពី១៩ ៣៧៦ ពាន់លានរៀល នៅឆ្នាំ២០១៣ ដល់ ២០ ៩៨៦ពាន់លានរៀល នៅឆ្នាំ២០១៧។

**ក្រាហ្វិកបង្ហាញពីការកើនឡើងតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម**




**ប្រភព៖** ការប៉ាន់ស្មានពីក្រសួងផែនការឆ្នាំ២០១៧

## ២. កំណើនវិស័យកសិកម្មពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧

ជាទូទៅ កំណើនក្នុងវិស័យកសិកម្មមានក្នុងចន្លោះពី៤%ទៅ៥% ក្នុងរយៈពេលពីឆ្នាំ២០០៨ដល់២០១២។ កំណើននេះបានធ្លាក់ចុះជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០១៣ រហូតដល់ឆ្នាំ២០១៥ គឺបានធ្លាក់ចុះពី៤,៣%ពីឆ្នាំ២០១២ មកត្រឹម១,៦%នៅឆ្នាំ២០១៣ និងបន្តធ្លាក់ចុះដល់០,៣%នៅឆ្នាំ២០១៤ និង០,២%នៅឆ្នាំ២០១៥។ ការធ្លាក់ចុះនេះ គឺបណ្តាលមកពីកត្តាគ្រោះធម្មជាតិ ពិសេសផលវិបាកនៃគ្រោះរាំងស្ងួតធ្ងន់ធ្ងរក្នុងឆ្នាំ២០១៤និង២០១៥។ ដោយឡែក

អំឡុងឆ្នាំ២០១៦ ស្ថានភាពអំណោយផលនៃអាកាសធាតុ បានធ្វើឱ្យកំណើននេះកើនឡើងវិញ គឺបានកើនពី១,៤% នៅឆ្នាំ២០១៦ ដល់ប្រមាណ១,៧%នៅឆ្នាំ២០១៧នេះ។

**ក្រាហ្វិកបង្ហាញពីកំណើននៃវិស័យកសិកម្មរយៈពេល៥ឆ្នាំកន្លងមក**




ប្រភព÷ ការប៉ាន់ស្មានពីក្រសួងផែនការឆ្នាំ២០១៧

## ៣. សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម

នៅឆ្នាំ២០១៧នេះ ការចូលរួមចំណែកនៃអនុវិស័យក្នុងផលិតផលក្នុងស្រុកសរុប (GDP) រួមមាន៖ ផ្នែកដំណាំ ១៣% ផ្នែកផលិតកម្មសត្វ២,៦% ផ្នែកជលផល៥,៥% និងផ្នែកព្រៃឈើ១,៦%។ ជាការកត់សម្គាល់ ផលិតកម្មដំណាំ និងជលផល គឺជាកម្លាំងចលករនាំមុខក្នុងផលិតកម្មកសិកម្ម។ ផលិតកម្មសត្វ គឺជាមុខព្រួញសំខាន់មួយទៀត ក្នុងការផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងការនាំចេញ ដែលផ្នែកនេះត្រូវជំរុញអភិវឌ្ឍន៍ឱ្យបានខ្លាំងក្លាផងដែរ។

**ក្រាហ្វិកបង្ហាញពីការចូលរួមនៃអនុវិស័យកសិកម្ម (%)**




| | 2013 | 2014 | 2015 | 2016 | 2017 |
|---|---|---|---|---|---|
| ដំណាំ Crops | 18.4% | 17.1% | 15.8% | 14.6% | 13.0% |
| សត្វ Livestock & Poultry | 3.5% | 3.3% | 3.0% | 2.8% | 2.6% |
| ជលផល Fisheries | 6.9% | 6.4% | 5.9% | 5.7% | 5.5% |
| ព្រៃឈើ Forestry & Logging | 2.3% | 2.0% | 1.8% | 1.7% | 1.6% |

ប្រភព៖ ការប៉ាន់ស្មានពីក្រសួងផែនការឆ្នាំ២០១៧

## ៤. ស្ថានភាពកម្លាំងពលកម្មក្នុងវិស័យកសិកម្ម

ក្នុងក្របខ័ណ្ឌនៃសេដ្ឋកិច្ចប្រទេសកម្ពុជាកម្លាំងពលកម្មត្រូវបានបែងចែកជាបីប្រភេទសំខាន់គឺ៖ (ទី១)ពលកម្មក្នុងវិស័យកសិកម្ម (ទី២)ពលកម្មក្នុងវិស័យឧស្សាហកម្ម និង(ទី៣)ពលកម្មក្នុងវិស័យសេវាកម្ម។ ជាការសង្កេត ពលកម្មក្នុងវិស័យកសិកម្មបាននិងកំពុងធ្លាក់ចុះគួរឱ្យកត់សម្គាល់។ កម្លាំងពលកម្មក្នុងវិស័យកសិកម្មឆ្នាំ ២០១០ មានចំនួន៥៤,២%នៃពលកម្មសរុប ដោយឡែកឆ្នាំ២០១១ កម្លាំងពលកម្មក្នុងវិស័យកសិកម្មមានការកើន

ឡើងដល់៥៥,៨% ហើយបន្តថយចុះមកត្រឹមតែ៥១%ឆ្នាំ២០១២ ៤៨,៧%នៅឆ្នាំ២០១៣ និង៤៥,៣%នៅឆ្នាំ២០១៤។ ឆ្នាំ២០១៥ កម្លាំងពលកម្មមានចំនួនត្រឹមតែ៤១,៥%ប៉ុណ្ណោះ។ ចរន្តនៃការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង និងទៅក្រៅប្រទេសកំពុងមាននិន្នាការកើនឡើង។ ពលកម្មក្នុងវិស័យឧស្សាហកម្មមានតែ ១៦,២%នៅឆ្នាំ២០១០ និងកើនដល់១៦,៩%នៅឆ្នាំ២០១១ ១៩,៩%នៅឆ្នាំ២០១៣ ២៤,៣%នៅឆ្នាំ២០១៤ និងមានការកើនបន្តដល់២៥,៥%នៅឆ្នាំ២០១៥។ ចំពោះពលកម្មក្នុងវិស័យសេវាកម្មមានចំនួន២៩,៦%ឆ្នាំ២០១០ ៣០,៤%ឆ្នាំ២០១២ និងកើនដល់៣២,៩% នៅឆ្នាំ២០១៥។

**តារាងប្រៀបធៀបកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច**

| កម្លាំងពលកម្ម | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១០ | | | | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៥ | | | |
|---|---|---|---|---|---|---|---|---|
| | កម្ពុជា | ភ្នំពេញ | ទីប្រជុំជន | ជនបទ | កម្ពុជា | ភ្នំពេញ | ទីប្រជុំជន | ជនបទ |
| ចំនួនពលកម្មសរុប (ពាន់នាក់) | **៧ ៦៧៣** | **៦៨៧** | **៧៧២** | **៦ ២១៤** | **៨ ៣៥១** | **១ ១៤០** | **៩៥៧** | **៦ ២៧៩** |
| កសិកម្ម (%) | **៥៤,២** | ១,៦ | ១៩,៧ | ៦៤,៣ | **៤១,៥** | ០,៧ | ១៤,០ | ៥៣,០ |
| ឧស្សាហកម្ម (%) | **១៦,២** | ២៣,៣ | ១៧,៨ | ១៥,៣ | **២៥,៥** | ២៨,៧ | ២៣,៤ | ២៥,២ |
| សេវាកម្ម (%) | **២៩,៦** | ៧៤,៩ | ៦២,៥ | ២០,៥ | **៣២,៩** | ៧០,៦ | ៦២,៥ | ២១,៧ |
| ផ្សេងៗ | - | ០,២ | - | - | **០,១** | - | - | ០,១ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

## IV- លទ្ធផលតាមអនុវិស័យ

ក្នុងការធ្វើទំនើបកម្មកសិកម្មដំណាំស្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ក្នុងការកែប្រែទម្លាប់កសិករឱ្យអនុវត្តតាមបច្ចេកទេសសមស្រប ពិសេសការប្រើប្រាស់ឧបករណ៍កសិកម្មដែលប្រើប្រាស់កម្លាំងពលកម្មតិច ព្រមទាំងការបង្កើនសេវាភ្ជួររាស់ ស្ទូង និងច្រូតកាត់ដោយគ្រឿងយន្តកសិកម្ម។ ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា រវាងក្រុមហ៊ុនប្រមូលទិញស្រូវ និងសហគមន៍កសិកម្ម ត្រូវបានអនុវត្តយ៉ាងល្អប្រសើរ។ ជាមោទនភាពខ្លាំងជាងនេះ គឺពូជស្រូវផ្ការំដួល ត្រូវបានទទួលស្គាល់ថាជាប្រភេទស្រូវឆ្ងាញ់ជាងគេលើពិភពលោក។

ពាក់ព័ន្ធនឹងការងារស្រូវអង្ករនេះ ក្រសួងបានស្នើឱ្យរដ្ឋបាលខេត្តពាក់ព័ន្ធ បង្កើតក្រុមការងារសម្របសម្រួលដោះស្រាយបញ្ហាពាក់ព័ន្ធការងារស្រូវអង្ករនៅមូលដ្ឋានរាជធានីខេត្ត។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចអនុញ្ញាតឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បង្កើតប៉ុស្តិ៍ត្រួតពិនិត្យអនាម័យនិងភូតគាមអនាម័យនៅតាមច្រកនាំចេញនាំចូល ដើម្បីពិនិត្យឱ្យបានត្រឹមត្រូវលើផ្នែកអនាម័យនិងភូតគាមអនាម័យ សំដៅធានាសុវត្ថិភាពស្បៀង និងសុខុមាលភាពសាធារណៈក្នុងប្រទេស (លិខិតលេខ៩៨២ សជណ.កស ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី) ប៉ុន្តែត្រូវបានផ្អាកទៅវិញ។ នៅខែកុម្ភៈ ឆ្នាំ២០១៧ ក្រសួងបានស្នើសុំគោលការណ៍ទៅរាជរដ្ឋាភិបាលម្តងទៀត ដើម្បីអនុញ្ញាតដាក់សមត្ថកិច្ចពាក់ព័ន្ធ ចូលរួមត្រួតពិនិត្យអនាម័យនិងភូតគាមអនាម័យ លើផលិតផលកសិកម្ម ជលផល និងសត្វ នៅតាមច្រកចេញចូល ហើយរាជរដ្ឋាភិបាលក៏បានឯកភាពអនុញ្ញាតជាគោលការណ៍ ប៉ុន្តែត្រូវនៅក្រោមច្រកចេញចូលតែមួយ (លិខិតលេខ១៦៥ សជណ.កស ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី) ដែលពេលនេះក៏នៅតែមានការរាំងស្ទះមិនអាចអនុវត្តបានដែរ។

ក្នុងគោលដៅជំរុញការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាឱ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួងបានចេញសារាចរណែនាំស្តីពីនីតិវិធីនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា (លិខិតលេខ១៩៦ សរណន.កសស ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧) សំដៅរួមចំណែកដោះស្រាយបញ្ហារាំងស្ទះមួយចំនួន និងឈានដល់ការជឿទុកចិត្ត ការធានាតម្លៃ បរិមាណនិងគុណភាពផលិតផល ក៏ដូចជាការបង្កើនល្បឿននៃការអនុវត្តកិច្ចការនេះ តាមរយៈការផ្តល់នីតិវិធីសម្រាប់អនុវត្តច្បាស់លាស់។

ការធ្វើទំនើបកម្មកសិកម្ម ក៏ទាមទារឱ្យមានឯកសារបច្ចេកទេសដើម្បីកំណត់តំបន់ដាំដុះកសិកម្មជាចាំបាច់។ ដោយផ្អែកលើហេតុផលនេះ ក្រសួងបានបង្កើតគណៈកម្មាធិការកំណត់តំបន់ដាំដុះកសិកម្ម តាមរយៈសេចក្តីសម្រេចលេខ៦៧៩ សសរ.កសក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧។ គណៈកម្មាធិការនេះបាននិងកំពុងអនុវត្តការងារស្របតាមតួនាទីនិងភារកិច្ចដែលបានប្រគល់ជូន ហើយឯកសារបច្ចេកទេសដើម្បីកំណត់តំបន់ដាំដុះកសិកម្ម នឹងត្រូវបានរៀបចំដាក់ឱ្យអនុវត្តនាពេលខាងមុខ។

ជាមួយគ្នានេះ ក្រសួងក៏បានទទួលស្គាល់ដែរថា វិស័យឯកជនគឺជាកម្លាំងចលករស្នូលនៃកំណើនក្នុងវិស័យកសិកម្ម និងជាមូលដ្ឋានគ្រឹះក្នុងការធ្វើទំនើបកម្មកសិកម្មផងដែរ។ នាពេលកន្លងទៅ ក្រសួងបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយផ្នែកឯកជន ដើម្បីជួយសម្របសម្រួលដល់ការវិនិយោគកសិកម្ម។ ផលជាផ្លែផ្កានៃកិច្ចខិតខំប្រឹងប្រែងនេះ កំពុងកើតមានឡើងគួរឱ្យកត់សម្គាល់ ហើយនឹងទទួលបានសមិទ្ធផលធំៗថែមទៀតក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ។

ផ្អែកតាមសំណើរបស់ក្រសួង រាជរដ្ឋាភិបាលបានពិចារណាលើការបញ្ចុះថ្លៃអគ្គិសនី។ ប្រសិនបើនៅក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ មានទីតាំងណាមួយដែលមានសក្តានុពលប្រភពទឹកច្បាស់លាស់ ម្ចាស់កសិដ្ឋាន ឬសហគមន៍កសិកម្ម ត្រូវធ្វើលិខិតស្នើសុំទៅមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (ម.អ.ជ.) ឲ្យផ្តល់ជំនួយដល់ការប្រើប្រាស់អគ្គិសនីរបស់ទីតាំងនោះ។ អត្រាថ្លៃអគ្គិសនីដែលផ្គត់ផ្គង់ឲ្យការប្រើប្រាស់ខាងលើស្មើនឹង ៤៨០រ ក្នុង១គីឡូវ៉ាត់ម៉ោងសម្រាប់ការប្រើពេលយប់ពីម៉ោង ៩យប់ ដល់ម៉ោង ៧ព្រឹក។ គោលការណ៍នេះនឹងជួយសម្រួលច្រើនដល់កសិករក្នុងការបន្ទាបថ្លៃដើមផលិតកម្ម ប៉ុន្តែមកទល់ពេលនេះក៏នៅមានកសិករឬសហគមន៍កសិកម្មតិចតួចណាស់ បានទទួលផលពីអន្តរាគមន៍នេះ ហើយក្រសួងនឹងខិតខំជំរុញបន្តទៀតនាពេលខាងមុខ។

ការកែទម្រង់រចនាសម្ព័ន្ធក្នុងផ្នែកកសិកម្ម ដែលគួរឱ្យកត់សម្គាល់នោះ គឺការកែសម្រួលមាត្រា២៧ និងមាត្រា៣៤ នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលបានសម្រួលនិងបន្ថែមមុខងារភារកិច្ចជូននាយកដ្ឋានគ្រឿងយន្តកសិកម្ម ឱ្យទៅជានាយកដ្ឋានវិស្វកម្មកសិកម្ម លើការងារចាត់ចែង និងដោះស្រាយទឹកក្នុងក្របខ័ណ្ឌសហគមន៍ ក៏ត្រូវបានវាយតម្លៃថាទទួលបានប្រសិទ្ធភាពបន្ថែមមួយកម្រិតទៀត។

ជាក់ស្តែងក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចនូវសមិទ្ធផលធំៗតាមបណ្តាអនុវិស័យនីមួយៗដូចតទៅ៖

## ១. លទ្ធផលនៃការលើកកម្ពស់ផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម

### ក. ផលិតកម្មដំណាំស្រូវ

ផ្ទៃដីដាំដុះដំណាំស្រូវសម្រេចបានលើផ្ទៃដីជាង៣លានហិកតានៅឆ្នាំ២០១៣ និងបានកើនដល់៣,២១លានហិកតានៅឆ្នាំ២០១៧ (ស្រូវវស្សាមាន២,៦៦លានហ.ត និងស្រូវរដូវប្រាំងមាន០,៥៥លានហិកតា)។ ផ្ទៃដីដាំដុះដំណាំស្រូវបានកើន ប្រមាណ២,៨៩%ធៀបនឹងឆ្នាំ២០១៦។ ផ្ទៃដីប្រមូលផលមានចំនួន៣,១៩លានហ.ត (ស្រូវវស្សាមាន២,៦៤លានហ.ត និងស្រូវរដូវប្រាំងមានប្រមាណ០,៥៥លានហិកតា)។

ទិន្នផលស្រូវគិតជាមធ្យមទាំងប្រាំងនិងវស្សាបានកើនពី៣,១៦៣តោន/ហ.តពីឆ្នាំ២០១៣ ដល់៣,២៩៨តោន/ហ.តនៅឆ្នាំ២០១៧ ក្នុងនោះទិន្នផលស្រូវវស្សាទទួលបានប្រមាណ៣,០៤៧តោន/ហ.ត និងទិន្នផលស្រូវរដូវប្រាំងទទួលបាន៤,៥០៨តោន/ហ.ត។ ទិន្នផលស្រូវសរុបបានកើនប្រមាណ២,៧១%ធៀបនឹងឆ្នាំ២០១៦។

បរិមាណផលស្រូវបានកើនឡើងពី៩,៣៩លានតោននៅឆ្នាំ២០១៣ ដល់ប្រមាណ១០,៥២លានតោន នៅឆ្នាំ២០១៧នេះ ក្នុងនោះបរិមាណផលស្រូវវស្សាទទួលបានប្រមាណជាង៨,០៥លានតោន និងបរិមាណផលស្រូវរដូវប្រាំងទទួលបានប្រមាណ២,៤៧លានតោន (ពោលគឺកើនប្រហែល៥,៦៩%ធៀបនឹងឆ្នាំ២០១៦)។

នៅឆ្នាំ២០១៧នេះ អតិរេកស្រូវមានចំនួនជាង៥,៥៦លានតោន គិតជាអង្ករស្មើនឹង៣,៥៦លានតោន (កើនប្រមាណ៨,៦៦%ធៀបនឹងឆ្នាំ២០១៦)។

### តារាងផលិតកម្មដំណាំស្រូវពីឆ្នាំ២០១៣-២០១៧

| ឆ្នាំ | បរិយាយ | | | | |
|---|---|---|---|---|---|
| | ផ្ទៃដីដាំដុះ (លានហិកតា) | | | ទិន្នផល (តោន/ហ.ត) | បរិមាណផល (លានតោន) |
| | ផែនការ | ដាំដុះ | ប្រមូលផល | | |
| ២០១៣ | ២,៧៨ | ៣,០៥ | ២,៩៦ | ៣,១៦៣ | ៩,៣៩ |
| ២០១៤ | ២,៨២ | ៣,០៥ | ៣,០៣ | ៣,០៧៩ | ៩,៣២ |
| ២០១៥ | ២,៩៨ | ៣,០៥ | ៣,០២ | ៣,០៨៥ | ៩,៣៣ |
| ២០១៦ | ២,៩១ | ៣,១២ | ៣,១០ | ៣,២១១ | ៩,៩៥ |
| ២០១៧ | ២,៩៤ | ៣,២១ | ៣,១៩ | ៣,២៩៨ | ១០,៥២ |

គួរកត់សម្គាល់ថា បច្ចុប្បន្ននេះ ផលិតកម្មដំណាំស្រូវមានការរីកចម្រើនឡើងជាលំដាប់ គឺអាស្រ័យដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា អង្គការជាតិនិងអន្តរជាតិ អាជ្ញាធរថ្នាក់ក្រោមជាតិ និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ។

### ក្រាហ្វិក បង្ហាញអំពីផលិតកម្មដំណាំស្រូវពីឆ្នាំ២០១៣-២០១៧




ការសម្រេចបានក្នុងការបង្កើនផលិតភាពដំណាំស្រូវបណ្ដាលមកពីកត្តាសំខាន់ៗមួយចំនួនដូចជា ការផ្លាស់ប្ដូរពូជស្រូវដែលមានទិន្នផលខ្ពស់ ដែលជាលទ្ធផលទទួលបានពីការពិសោធន៍ស្រាវជ្រាវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ពិសេស ការពង្រីកកាន់តែមានប្រសិទ្ធភាព លើការធ្វើស្រែបង្ហាញតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ការអនុវត្តបច្ចេកទេសគ្រប់គ្រងដី ដើម្បីបង្កើនជីជាតិនិងទិន្នផលដំណាំ និងការបង្កើនការស្រាវជ្រាវនិងអភិវឌ្ឍពូជស្រូវ ដែលស្របនឹងលក្ខណៈដី អាកាសធាតុ ការកំណត់ប្រភេទពូជសំខាន់ៗស្របតាមតម្រូវការទីផ្សារ។ ជាការកត់សម្គាល់បន្ថែមទៀត យន្តូបនីយកម្មកសិកម្មពិតជាបាននិងកំពុងដើរតួសំខាន់ ព្រមទាំងបំពេញនូវកម្លាំងពលកម្មដែលខ្វះខាតក្នុងវិស័យកសិកម្មនាពេលកន្លងមក។

លទ្ធផលផ្ទៃដីភ្ជួររាស់ឆ្នាំ២០១៧នៅទូទាំងប្រទេសសម្រេចបានចំនួន៣,៦៥លានហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តកសិកម្ម ៣,៤៧៥លានហិកតា ស្មើនឹង៩៤,៤២% ក្នុងនោះនៅរដូវវស្សាភ្ជួររាស់ដោយគ្រឿងយន្តមានចំនួន២,៩៤លានហ.ត ស្មើនឹង៩៣,៧៤% និងភ្ជួរដោយគោក្របីបានចំនួនជាង១៩៣,២៩៣ពាន់ហ.តស្មើនឹង៥,៥៨% នៅរដូវប្រាំងការភ្ជួររាស់ដោយគ្រឿងយន្តកសិកម្មមានចំនួន៥១២,៣១៣ពាន់ហ.ត ស្មើនឹង៩៨,៣% និងភ្ជួររាស់ដោយគោក្របីសម្រេចបានចំនួន៨.៨៦០ហ.ត ស្មើនឹង១,៧០%។

### ក្រាហ្វិច បង្ហាញអំពីការប្រៀបធៀបលទ្ធផលភ្ជួររាស់ឆ្នាំ២០១៣-២០១៦ និងការភ្ជួររាស់ឆ្នាំ២០១៧







## ខ. ផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម (ដំណាំរដូវ)

### ខ.១. ផលិតកម្មដំណាំរួមផ្សំ

ឆ្នាំ២០១៧នេះ ផ្ទៃដីដាំដុះដំណាំរួមផ្សំ (ពោត ដំឡូងមី ដំឡូងជ្វា បន្លែគ្រប់មុខ សណ្តែកបាយ) សម្រេចបានចំនួន៩៤៦,៧៨៨ហិកតា កើនលើសឆ្នាំមុន១,៤៤% (ឆ្នាំ២០១៦ សម្រេចបានចំនួន៩៣៣.៣៧ពាន់ហិកតា)។ រយៈ៥ឆ្នាំចុងក្រោយនេះ ផ្ទៃដីដាំដុះគិតជាមធ្យមកើនប្រមាណ៥,៣៦% ពោលកើនពី៧៧៥ពាន់លានហិកតា នៅឆ្នាំ២០១៣ ដល់ ៩៤៧ពាន់លានហិកតា នៅឆ្នាំ២០១៧។ បរិមាណផលដំណាំរួមផ្សំបានកើនពី៩លានតោន ដល់ ១៥,៦លានតោននៅឆ្នាំ២០១៧។

### ខ.២. ផលិតកម្មដំណាំឧស្សាហកម្មរយៈពេលខ្លី

ផលិតកម្មដំណាំឧស្សាហកម្ម (សណ្តែកដី សណ្តែកសៀង ល្ង អំពៅ ក្រចៅ ថ្នាំជក់) មានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ហើយមានការធ្លាក់ចុះក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ។ ផ្ទៃដីផលិតកម្មដំណាំឧស្សាហកម្មរយៈពេលខ្លីបានធ្លាក់ចុះ ពី១០១.២៦៧ហ.ត មកត្រឹមតែ១០០.១១០ហ.ត (ថយចុះប្រមាណ១,១៤%នៅឆ្នាំ២០១៧ ធៀបនឹងឆ្នាំ២០១៦) បរិមាណផលបានថយចុះពី១,១លានតោននាឆ្នាំ២០១៣ មកត្រឹម០,៧៥លានតោននាឆ្នាំ២០១៧ (ថយចុះប្រមាណ១២,៦៩%ធៀបនឹងឆ្នាំ២០១៦)។

### ខ.៣. ផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្មសរុបពីឆ្នាំ២០១៣ដល់ឆ្នាំ២០១៧

ផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម ត្រូវបានកត់សម្គាល់ឃើញថា ផ្ទៃដីដាំដុះបានកើនពី៩៤១,០២៨ហ.ត នៅឆ្នាំ២០១៣ ដល់ប្រមាណ១,០៤៧លានហ.ត នៅឆ្នាំ២០១៧ (កំណើនជាមធ្យមក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះមានប្រមាណ២,៧៩% និងកើន១,១៨%បើធៀបនឹងឆ្នាំមុន)។ ចំពោះបរិមាណផលផលិតកម្មនៃដំណាំរួមផ្សំ និងឧស្សាហកម្មរយៈពេលខ្លី បានកើនពី១០,៥លានតោននាឆ្នាំ២០១៣ ដល់ប្រមាណ១៦,៤លានតោននាឆ្នាំ២០១៧ (កំណើនជាមធ្យមក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះមានប្រមាណ៩,៦១% និងថយចុះ២,៩៤%ធៀបនឹងឆ្នាំមុន)។

**តារាងប្រៀបធៀបផ្ទៃដីដាំដុះនិងបរិមាណផលដំណាំរួមផ្សំនិងឧស្សាហកម្មឆ្នាំ២០១៣-២០១៧**

| បរិយាយ | ផលិតកម្មដំណាំរួមផ្សំ | | ផលិតកម្មដំណាំឧស្សហកម្មរយៈពេលខ្លី | |
|---|---|---|---|---|
| | ផ្ទៃដីដាំដុះ (ពាន់ហ.ត) | បរិមាណផល (ពាន់តោន) | ផ្ទៃដីដាំដុះ (ពាន់ហ.ត) | បរិមាណផល (ពាន់តោន) |
| ២០១៣ | ៧៧៥,៣២ | ៩ ៤៣១,៥៣ | ១៦៥,៧២ | ១ ១០៥,២១ |
| ២០១៤ | ៧៧៥,៨២ | ១៣ ០២២,៩៦ | ១៧៧,៧៧ | ១ ៧០៤,៣០ |
| ២០១៥ | ៨៤៩,០៥ | ១៥ ២៩១,៥០ | ១៣៥,០៨ | ៨៥៧,២៦ |
| ២០១៦ | ៩៣៣,៣៧ | ១៦ ០២២,៩៥ | ១០១,២៧ | ៨៥៦,៨៧ |
| ២០១៧ | ៩៤៦,៨០ | ១៥ ៦៣៤,៩៩ | ១០០,១១ | ៧៤៨,០៩ |




## គ. ផលិតកម្មដំណាំអចិន្ត្រៃយ៍

ក្រៅពីដំណាំរដូវដូចបានរៀបរាប់ខាងលើ (ដំណាំរួមផ្សំនិងឧស្សាហកម្មរយៈពេលខ្លី) ផលិតកម្មដំណាំអចិន្ត្រៃយ៍ក៏មានសន្ទុះរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ។ ដំណាំអចិន្ត្រៃយ៍ត្រូវបានរាប់បញ្ចូលនូវប្រភេទដំណាំសំខាន់ៗមួយចំនួនគឺ៖ ចេក ស្វាយចន្ទី ដូង ស្វាយ ក្រូច ខ្នុរ ធូរេន ម្រេច ..។ល។ ផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍បានកើនពីជាង២៣៨ ពាន់ហ.ត នៅឆ្នាំ២០១៦ ដល់៤៣០ពាន់ហ.ត នៅឆ្នាំ២០១៧ (កើនប្រមាណ៨០,០៨%)។ បរិមាណផលជារួមបានកើនពី២,០៩លានតោននាឆ្នាំ២០១៦ ដល់២,៥លានតោននៅឆ្នាំ២០១៧នេះ (កើនប្រមាណជា១៩,២២%)។

**តារាងផលិតកម្មដំណាំអចិន្ត្រៃយ៍ឆ្នាំ២០១៦-២០១៧**

| មុខដំណាំ | ២០១៦ | | ២០១៧ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|
| | ផ្ទៃដីដាំដុះ | បរិមាណផល | ផ្ទៃដីដាំដុះ | បរិមាណផល | ផ្ទៃដីដាំដុះ | បរិមាណផល |
| -ដំណាំអចិន្ត្រៃយ៍ | ២៣៨ ៧៨០ | ២ ០៩៧ ០០០ | ៤៣០ ០០១ | ២ ៥០០ ១៣១ | ៨០,០៨% | ១៩,២២% |

ការសម្រេចបានក្នុងការបង្កើនផលិតភាពដំណាំ គឺបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួន ក្នុងការជំរុញប្រព័ន្ធប្រពលវប្បកម្មដំណាំ និងអនុវត្តបច្ចេកទេសកសិកម្មថ្មីៗ ដែលបានមកពីលទ្ធផលស្រាវជ្រាវនិងអភិវឌ្ឍ ការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីៗដល់កសិករមានប្រសិទ្ធភាព និងគុណភាពរួមមាន៖ ពូជដំណាំថ្មីៗមានទិន្នផលខ្ពស់មានគុណភាពល្អ និងធន់ ស្របតាមប្រព័ន្ធអេកូឡូស៊ីបរិស្ថានដាំដុះ និងតម្រូវការទីផ្សារ ការអនុវត្តកសិកម្មល្អ និងមានសុវត្ថិភាព វិធានការចំរុះថែទាំដំណាំ និងវិធានការចំរុះគ្រប់គ្រងដីជាតិដី អនុវត្តកសិកម្មវៃឆ្លាតនឹងអាកាសធាតុ ការបង្កើនផលិតភាពនិងប្រសិទ្ធភាពប្រើប្រាស់ទឹក និងធាតុចូលកសិកម្មនានា ការអនុវត្តបច្ចេកទេសក្រោយពេលប្រមូលផល និងការប្រើប្រាស់យន្តូបនីយកម្មកសិកម្ម ដើម្បីបំពេញការខ្វះខាតកម្លាំងពលកម្មក្នុងវិស័យកសិកម្ម។

## ឃ. ការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម

អនុលោមតាមគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មត្រូវអនុវត្តតាមបែបពហុនិយម និងទៅតាមតម្រូវកសិករនិងទីផ្សារ ដោយរាជរដ្ឋាភិបាល វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល សហគមន៍កសិករ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅមូលដ្ឋានដែលរួមមាន៖ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំភូមិ និងភ្នាក់ងារសុខភាពសត្វភូមិ។ ដើម្បីដឹកនាំ សម្របសម្រួល និងគាំទ្រការផ្តល់សេវាផ្សព្វផ្សាយកសិកម្មពីគ្រប់ភាគីពាក់ព័ន្ធឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលតម្រូវ មន្ត្រីផ្សព្វផ្សាយកសិកម្ម១នាក់ក្នុង១០០០គ្រួសារកសិករ គឺតម្រូវការប្រមាណ ២១០០ នាក់ សម្រាប់ធ្វើការនៅទូទាំងប្រទេស ក្នុងនោះ នៅនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ៥០នាក់ នៅការិយាល័យផ្សព្វផ្សាយកសិកម្មទាំង២៥ រាជធានីខេត្ត ៣៥០នាក់ និងការិយាល័យកសិកម្មស្រុក១ ៦៥០នាក់។

ចំនួនមន្ត្រីផ្សព្វផ្សាយកសិកម្មនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិសរុបចំនួន៧២៧នាក់ ស្រីចំនួន១៩២នាក់ ក្នុងនោះនៅនាយកដ្ឋានផ្សព្វផ្សាយកសិកម្មចំនួន៥៧នាក់ ស្រី១៧នាក់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត មាន១២៥នាក់ ស្រី៤៩នាក់ និងការិយាល័យកសិកម្មស្រុកចំនួន៥៩៥នាក់។

ពីឆ្នាំ២០១០ ដល់២០១៦ ចំនួនមន្ត្រីផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្តនិងស្រុកមានការថយចុះច្រើន ដោយសារមន្ត្រីចូលនិវត្តិន៍ តែចាប់ពីឆ្នាំ២០១៦ និង២០១៧ បានបណ្តុះបណ្តាលមន្ត្រីផ្សព្វផ្សាយកសិកម្មថ្មីបន្ថែមបាន សរុបចំនួន២៣៤នាក់ ស្រី៧៧នាក់ ដោយថវិកាតាមកម្មវិធីរបស់រាជរដ្ឋាភិបាល និងថវិកាកម្មវិធីផ្សព្វផ្សាយកសិកម្មដែលធន់នឹងអាកាសធាតុ (ASPIRE)។ ដើម្បីបំពេញបន្ថែមមន្ត្រីផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត និងការិយាល័យកសិកម្មស្រុក គឺតម្រូវបណ្តុះបណ្តាលបន្ថែមចំនួនប្រមាណ១ ២០០នាក់ទៀត សម្រាប់ដឹកនាំ សម្រួលសម្រួល គាំទ្រ និងប្រតិបត្តិការផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅមូលដ្ឋាន។ ដោយឡែក គិតត្រឹមឆ្នាំ២០១៧ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំសរុបមានចំនួន១ ២២០នាក់ ក្នុងនោះមានស្ត្រីចំនួន៥៥១ នាក់ស្មើនឹង៤១% និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិសរុបមានចំនួន៩ ២៧៦នាក់ ក្នុងនោះមានស្ត្រីចំនួន២ ៨៩១ នាក់ស្មើនឹង៩% ។

ការងារអប់រំនិងផ្សព្វផ្សាយបច្ចេកទេសកសិកម្មចម្បងៗ ត្រូវបានជំរុញអនុវត្តតាមរយៈ (១) សកម្មភាពបណ្តុះបណ្តាលនៅក្នុងថ្នាក់ បណ្តុះបណ្តាលជាក់ស្តែងនៅទីវាល ឬសាលារៀនស្រែកសិករ អនុវត្តស្រែបង្ហាញ ដំណើរការទិវាស្រែនិងទស្សនៈកិច្ចសិក្សា (២) ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មតាម មជ្ឈមណ្ឌលបណ្តុំព័ត៌មានផ្សព្វផ្សាយកសិកម្ម (Extension Hub) គេហទំព័រផ្សព្វផ្សាយកសិកម្ម (Extension Portal) និងប្រព័ន្ធវេទិកាផ្សព្វផ្សាយសាធារណៈ (៣) ការបោះពុម្ពនិងចែកចាយឯកសារបច្ចេកទេសកសិកម្ម។

បានដំណើរប្រតិបត្តិមជ្ឈមណ្ឌលបណ្តុំព័ត៌មានកសិកម្ម(Extension hub) និងគេហទំព័រផ្សព្វផ្សាយកសិកម្ម (Extension portal): បានតម្លើង ឧបករណ៍ និងសម្ភារស្តុកឯកសារ (Server) និងផ្ទុកឯកសារផ្សព្វផ្សាយនៅក្នុង Cloud តាមគេហទំព័រផ្សព្វផ្សាយ www.khmeragri.info ដែលមានឯកសារផ្សព្វផ្សាយចំនួន២១០ឯកសារ និងបានបណ្តុះបណ្តាលមន្ត្រីជំនាញ៧នាក់ សម្រាប់គ្រប់គ្រងនិងប្រតិបត្តិ និងមានអ្នកចូលមើល និងទាញឯកសារផ្សព្វផ្សាយចំនួន១២ ០៥០នាក់។

ដើម្បីលើកកម្ពស់សមត្ថភាពស្ថាប័ន ធនធានមនុស្សផ្សព្វផ្សាយកសិកម្ម និងសេវាផ្សព្វផ្សាយកសិកម្ម ឯកសារព្រាងក្របខ័ណ្ឌយុទ្ធសាស្ត្រផ្សព្វផ្សាយកសិកម្មចំនួន៣ បានរៀបចំផែនការសកម្មភាពយុទ្ធសាស្ត្រផ្សព្វផ្សាយកសិកម្មនៅកម្ពុជា យុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សផ្សព្វផ្សាយកសិកម្ម និងយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានកសិកម្ម (Mass Media) ព្រមទាំងឯកសារគោលការណ៍ណែនាំចំនួន៦គឺ៖ គោលការណ៍ណែនាំស្តីពីតួនាទី និងការទទួលខុសត្រូវការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា គោលការណ៍ណែនាំធានាគុណភាពផ្សព្វផ្សាយកសិកម្ម ការអនុវត្តការផ្សព្វផ្សាយពីកសិករទៅកសិករ ការអនុវត្តកិច្ចសន្យាខាងក្រៅ និងការអនុវត្តភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជនក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។

ក្នុងឆ្នាំ២០១៧ បណ្តុះបណ្តាលកសិករបានចំនួន៧៥ ៩១១នាក់ ក្នុងនោះស្ត្រីចំនួន៤០ ៦២៨នាក់ ស្មើនឹង៥៣,៥% ដែលពួកគាត់ទទួលបានចំណេះដឹងបន្ថែមអំពីបច្ចេកវិទ្យា និងបច្ចេកទេសមាន៖ ការប្រើប្រាស់ពូជបច្ចេកទេសដាំដុះដំណាំ បច្ចេកទេសគ្រប់គ្រងដំណាំ ការគ្រប់គ្រងជីជាតិដី បច្ចេកទេសក្រោយពេលប្រមូលផល និងការអនុវត្តកសិកម្មល្អលើដំណាំស្រូវ ដំណាំសាកវប្បកម្មនិងដំណាំរួមផ្សំ ឧស្សាហកម្ម ការគ្រប់គ្រងប្រើប្រាស់ ថែទាំ និងជួសជុលគ្រឿងយន្ត ឧបករណ៍ និងសម្ភារគ្រឿងយន្តកសិកម្ម ព្រមទាំងការអភិវឌ្ឍ និងគ្រប់គ្រងសហគមន៍កសិកម្ម។ ព្រមជាមួយនេះ ដើម្បីពង្រីកការទទួលបាននូវព័ត៌មាន និងចំណេះដឹងបច្ចេកទេសកសិកម្ម សកម្មភាពផ្សព្វផ្សាយបច្ចេកទេសកសិកម្មក៏ត្រូវបានជំរុញតាមរយៈការបោះពុម្ព និងចែកចាយឯកសារបច្ចេកទេស៥៨ ៤០០ច្បាប់ និងការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានសារធារណៈដូចជាទូរទស្សន៍ និងវិទ្យុបានចំនួន៧៧ប្រធានបទ។

## ក្រាហ្វិក បង្ហាញអំពីស្ថានភាពមន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម




## ខ. ការចងក្រង និងចុះបញ្ជីសហគមន៍កសិកម្ម

គិតត្រឹមឆ្នាំ២០១៧នេះ នៅទូទាំងប្រទេសមានសហគមន៍កសិកម្មសរុបចំនួន៨៨០សហគមន៍ ដែលមានសមាជិកសរុប៨៩ ៤៧៤នាក់ ក្នុងនោះស្ត្រីចំនួន៥៣ ៨៤១នាក់ ដែលស្មើនឹង៦០,១៧% នៃចំនួនសមាជិកសរុប ហើយមានប្រាក់ភាគហ៊ុនសរុបចំនួន២៤ ៦៥៦ ៧៨៥ ៦៥០រៀល និងមូលធនកសិកម្មសរុបចំនួន៣៩ ៤៥៩ ៤៥៨ ២០០រៀល។ ខេត្តដែលមានសហគមន៍អភិវឌ្ឍន៍កសិកម្មច្រើន ជាងគេគឺខេត្តតាកែវ មានចំនួន១០០សហគមន៍ បន្ទាប់គឺខេត្តបាត់ដំបង ដែលមានចំនួន៧៧សហគមន៍ ខេត្តកំពង់ធំមានចំនួន៥៥សហគមន៍ ខេត្តព្រៃវែងនិងខេត្តពោធិ៍សាត់មានចំនួនស្មើគ្នា គឺ៥២សហគមន៍ ដោយឡែកខេត្តដែលមានសហគមន៍អភិវឌ្ឍន៍កសិកម្មតិចជាងគេគឺ ខេត្តកែបដែលមានតែ ២សហគមន៍។

ក្រៅពីសហគមន៍កសិកម្ម ក្រសួងបានជំរុញ និងចុះបញ្ជីសហភាពសហគមន៍កសិកម្មទូទាំងប្រទេសសរុបបានចំនួន៦ ដែលក្នុងឆ្នាំ២០១៦ ចុះបញ្ជីសហភាពសហគមន៍កសិកម្មបានចំនួន០១ និងឆ្នាំ២០១៧ ចុះបញ្ជីបានចំនួន០៥ រួមមាន(១)សហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យ (២)សហភាពសហគមន៍កសិកម្មតាកែវមានជ័យ (៣)សហភាពសហគមន៍កសិកម្មប៉ៃលិនមានជ័យ (៤)សហភាពសហគមន៍កសិកម្មបាត់ដំបង និង(៥)សហភាពសហគមន៍កសិកម្មសៀមរាបអង្គរ។

## ក្រាហ្វិកបង្ហាញអំពីចំនួនសហគមន៍កសិកម្មពីឆ្នាំ២០០៤-២០១៧






## ច. ការខាងជំរុញការនាំចេញផលិតផលកសិកម្ម

ការនាំចេញផលិតផលកសិកម្មមាននិន្នាការកើនឡើងជាលំដាប់ ហើយមានសន្ទុះខ្លាំងក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ពោលគឺនៅឆ្នាំ២០១៣ និងនៅឆ្នាំ២០១៧ កើនដល់ចំនួន៥ ១៣៥ ០៨៤តោន។ កំណើននៃការនាំចេញបានកើនឡើង៧%ក្នុង១ឆ្នាំ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ហើយការនាំចេញនៅឆ្នាំ២០១៧ បានកើនឡើងជិត ១១% ធៀបនឹងការនាំចេញក្នុងឆ្នាំ២០១៦។

ដោយឡែកការនាំចេញផលិតផលកសិកម្មសំខាន់ៗ ដូចជា អង្ករ ចំណិតដំឡូងមី ដំឡូងមីស្រស់ ម្សៅដំឡូងមី ពោតក្រហម ម្រេច ផ្លែស្វាយស្រស់ និងដូងប្រេងឆៅមានការកើនឡើងជារៀងរាល់ឆ្នាំតាំងពីឆ្នាំ២០១៣ ពិសេសដំឡូងមី ពោតក្រហម ម្រេច និងផ្លែស្វាយស្រស់។

ក្នុងឆ្នាំ២០១៧ នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យបានសម្របសម្រួល និងធ្វើការត្រួតពិនិត្យភូតគាមអនាម័យលើកសិផលនាំចេញ និងផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យចំនួន២១ ៨២៤ច្បាប់ នៃបរិមាណផលិតផលនាំចេញសរុបចំនួន៥ ១៣៥ ០៨៤,៤៦តោន។

ក្រាហ្វិក បង្ហាញអំពីការនាំចេញផលិតផលកសិកម្មពីឆ្នាំ២០១៣-២០១៧



ការនាំចេញអង្ករកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ ជាក់ស្តែងការនាំចេញអង្ករនៅឆ្នាំ២០១៧ កើនឡើង ១៧,៣០% លើសឆ្នាំ២០១៦ ដែលកើនឡើងពីបរិមាណនាំចេញ ៥៤២ ១៤៤តោន នៅឆ្នាំ២០១៦ ដល់ ៦៣៥ ៦៧៩តោន នៅឆ្នាំ២០១៧។ ដោយឡែក បរិមាណអង្ករនាំចេញក្នុងឆ្នាំ២០១៧ តាមប្រភេទអង្ករ គឺអង្ករក្រអូបមានចំនួន៦១,៩៩% អង្ករសគ្រាប់វែងមានចំនួន២៤,៦៤% និងអង្ករចំហុយគ្រាប់វែងមានចំនួន១៣,៣៧% និងបាននាំចេញទៅកាន់ទិសដៅ៦៣ប្រទេសនៅលើសាកលលោក និងមានក្រុមហ៊ុននាំចេញអង្ករចំនួន៨៤ក្រុមហ៊ុន។







លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់នានាបម្រើឱ្យការអភិវឌ្ឍអនុវិស័យដំណាំកសិកម្ម បានរៀបចំរួច និងទទួលបានការអនុម័តនៅឆ្នាំ២០១៧ រួមមាន៖

- ប្រកាសអន្តរក្រសួងស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់តាមប្រកាសលេខ ១៧៥ ប្រក.កសក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧
- ប្រកាសស្តីពីស្លាកសញ្ញាព័ត៌មានបញ្ជាក់លើសំបកវេចខ្ចប់ពូជដំណាំត្រូវបានដាក់ឱ្យប្រើប្រាស់តាមប្រកាសលេខ៣៧៨ ប្រក.កសក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧
- ប្រកាសស្តីពីការសាកល្បង ការយកសំណាក ការចាត់ថ្នាក់ ការកំណត់ស្តង់ដារគុណភាពពូជដំណាំ និងនីតិវិធីនៃការត្រួតពិនិត្យលើគុណភាពពូជដំណាំដែលត្រូវបានដាក់ឱ្យប្រើប្រាស់តាមប្រកាសលេខ៣៧៤ ប្រក.កសក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧
- ប្រកាសស្តីពីគំរូពាក្យស្នើសុំនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំដែលត្រូវបានដាក់ឱ្យប្រើប្រាស់តាមប្រកាសលេខ ៣៧៥ ប្រក.កសក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧
- សេចក្តីសម្រេចស្តីពីការចាត់តាំងភ្នាក់ងារអធិការកិច្ចពូជដំណាំនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលត្រូវបានប្រកាសឱ្យប្រើប្រាស់តាមសេចក្តីសម្រេចលេខ៣៧៣ សសរ.កសក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧។

### ឆ. ការគ្រប់គ្រងសម្ភារកសិកម្ម

បច្ចុប្បន្ននេះតម្រូវការប្រើប្រាស់សម្ភារកសិកម្ម មានការកើនឡើងជារៀងរាល់ឆ្នាំ ស្របតាមស្ថានភាពអភិវឌ្ឍន៍ផលិតកម្មកសិកម្មនៅក្នុងប្រទេស ដែលធ្វើឱ្យបរិមាណសម្ភារកសិកម្មនាំចូល និងបរិមាណសម្ភារកសិកម្មដែលផលិតលាយផ្សំនៅក្នុងស្រុកត្រូវបានកើនឡើង។ រាជរដ្ឋាភិបាលបានកំណត់យុទ្ធសាស្ត្រមិនយកពន្ធ ឬកំណត់អត្រាពន្ធសូន្យលើការនាំចូលសម្ភារកសិកម្ម ក្នុងគោលបំណងបង្កភាពប្រកួតប្រជែងទីផ្សារនៃផលិតកម្មក្នុងស្រុក ដែលអាចឱ្យកសិករទិញ សម្ភារកសិកម្មប្រកបដោយគុណភាព និងមានតម្លៃថោក។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បានខិតខំពង្រឹងលើការគ្រប់គ្រងការធ្វើអាជីវកម្មសម្ភារកសិកម្មដែលបានចុះបញ្ជិកាត្រឹមត្រូវ ព្រមទាំងពង្រឹងការត្រួតពិនិត្យអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្មនៅតាមបណ្តារាជធានីខេត្តឱ្យបានសមស្របតាមនីតិវិធី។

ក្រុមហ៊ុនបានស្នើសុំលិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មក្នុងឆ្នាំ២០១៧ មានចំនួន២០៥ ក្រុមហ៊ុនដែលក្នុងនោះមាន ៖

- ថ្នាំកសិកម្មសរុបចំនួន ៖ ៥៣ ៤៨៥, ២៤២ តោន
- ជីកសិកម្មសរុបចំនួន ៖ ៨៤២ ៧០៦, ៦២ តោន
- ចំណីសត្វ និងចំណីបន្ថែមសរុបចំនួន ៖ ២២៤ ៣៣៥ តោន
- វត្ថុធាតុដើមផលិតចំណីសត្វសរុបចំនួន ៖ ៤៥៨ ២៣១ តោន
- បសុឱសថសរុបចំនួន ៖ ៣ ៨៩៩, ១៤ តោន
- បរិក្ខារបសុពេទ្យសរុបចំនួន ៖ ១២, ៨៣៣ តោន
- វ៉ាក់សាំងសរុបចំនួន ៖ ១៦, ៩៨៨ តោន
- ប្រតិករសរុបចំនួន ៖ ១, ៣៥០ តោន
- គ្រាប់ពូជសរុបចំនួន ៖ ២ ៨០៥,៥ តោន។

ចំពោះការងារផ្សព្វផ្សាយអប់រំ និងលើកកម្ពស់ការយល់ដឹង មានសកម្មភាពមួយចំនួនត្រូវបានអនុវត្តដូចជា៖

– ធ្វើសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី "បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេស ក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម" នៅតាមបណ្តាខេត្តក្រុងចំនួន២០
– វគ្គអប់រំសមត្ថភាពវិជ្ជាជីវៈដល់អាជីករលក់ដុំ លក់រាយសម្ភារកសិកម្មនៅតាមបណ្តាខេត្តក្រុងចំនួន០៩
– សហការជាមួយ GIZ រៀបចំសិក្ខាសាលាស្តីពីបទដ្ឋានគតិយុត្តក្នុងការប្រើប្រាស់ និងការធ្វើពាណិជ្ជកម្ម ភ្នាក់ងារជីវសាស្ត្រ BCAs សេចក្តីព្រាងទម្រង់ស្នើសុំការចុះបញ្ជីភ្នាក់ងារជីវសាស្ត្រ និងប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្ម BCAs" ក្នុងវិស័យកសិកម្មចំនួន០៥ លើក
– រៀបចំសិក្ខាសាលាស្តីពី" នីតិវិធី និងបច្ចេកទេសក្នុងការគ្រប់គ្រងធាតុចូលផលិតកម្មកសិកម្ម "ដែល ប្រព្រឹត្តទៅកាលពីថ្ងៃទី១៤-១៥ ខែមិថុនា ឆ្នាំ២០១៧ ក្រោមអធិបតីភាពឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ឆ.១. ការងារត្រួតពិនិត្យ និងអនុវត្តច្បាប់ក្នុងការគ្រប់គ្រងសម្ភារកសិកម្ម

– ធ្វើការណែនាំក្រុមហ៊ុនផ្គត់ផ្គង់ចែកចាយសម្ភារកសិកម្ម ស្តីពីតម្រូវការបមាណីយសំបកវេចខ្ចប់ព្រមទាំងសុពលភាពបញ្ជិកានៃថ្នាំកសិកម្ម និងជីកសិកម្មមួយចំនួន និងជំរុញឲ្យក្រុមហ៊ុនប្រកាសប្រតិវេទន៍ស្តីពីការនាំចូលសម្ភារកសិកម្ម
– ចុះត្រួតពិនិត្យ និងវាយតម្លៃទីតាំងឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្ម
– ចុះត្រួតពិនិត្យការនាំចូលរបស់ក្រុមហ៊ុនដែលបានធ្វើប្រតិវេទន៍អំពីការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងសម្ភារកសិកម្ម
– ចុះត្រួតពិនិត្យ និងវាយតម្លៃទីតាំង និងប្រព័ន្ធខ្សែចង្វាក់ផលិតកម្មនៃការលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្ម
– ចុះត្រួតពិនិត្យសកម្មភាពធ្វើអាជីវកម្មសម្ភារកសិកម្ម នៅតាមបណ្តាខេត្តគោលដៅ
– អនុវត្តវិធានការដកហូតវត្ថុតាងល្មើសច្បាប់ថ្នាំកសិកម្ម និងជីកសិកម្មដែលនាំចូលដោយគ្មានលេខបញ្ជិកា មិនបានអនុវត្តការតម្រូវបមាណីយសម្រាប់សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ និងលិខិតអនុញ្ញាតនាំចូល ដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងថ្នាំកសិកម្មដែលស្ថិតក្នុងបញ្ជីហាមឃាត់នៃព្រះរាជាណាចក្រកម្ពុជា

- ធ្វើសេចក្ដីជូនដំណឹងលេខ២៦៤៥ កសក ចុះថ្ងៃទី២៧ ខែមីនាឆ្នាំ២០១៧ស្ដីពី "ការបញ្ឈប់ការនាំចូល ផ្គត់ផ្គង់ចែកចាយ និងប្រើប្រាស់ថ្នាំកសិកម្មដែលមានធាតុសកម្ម Trycyclazole លើដំណាំស្រូវស្របតាមការជូនដំណឹងពីសហគមន៍អឺរ៉ុប"
- សេចក្ដីជូនដំណឹងស្ដីពីការបដិសេធលើសំណើសុំចុះបញ្ជីប្រភេទថ្នាំកសិកម្ម Racumin 0.75 CP ដែលផ្ទុកសារធាតុសកម្ម Coumatetralyl ដែលមានជាតិពុលខ្ពស់អាចបណ្ដាលឲ្យប៉ះពាល់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន ដល់ក្រុមហ៊ុន Bayer (Cambodia) Co.,Ltd
- ធ្វើលិខិតស្នើសុំទៅខេត្តជាប់ព្រំដែនដើម្បីជួយអន្តរាគមន៍ទប់ស្កាត់ការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម ដោយខុសច្បាប់ពីប្រទេសជិតខាងនៅតាមច្រកទ្វារព្រំដែន។

### ឆ.២. ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត

លិខិតបទដ្ឋានគតិយុត្តចំនួន០៥ បាននិងកំពុងរៀបចំ និងបានដាក់ឆ្លងប្រជុំពិភាក្សាពិគ្រោះយោបល់ថ្នាក់ជំនាញ និងអង្គភាពពាក់ព័ន្ធ។ លិខិតបទដ្ឋានទាំងនោះរួមមាន៖ ១)អនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពី "ឯកសណ្ឋានសញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម" ២)សេចក្ដីសម្រេចលេខ២៣៤ សសរ.កសក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ស្ដីពី "ការចាត់តាំងមន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" ៣) ប្រកាសលេខ៥២៦ ប្រក.កសក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧ ស្ដីពី "ការដាក់ឲ្យប្រើប្រាស់គំរូឯកសារសម្រាប់ធ្វើអាជីវកម្មភ្នាក់ងារជីវសាស្ត្រ (BCAs)" ៤) ប្រកាសអន្តរក្រសួងស្ដីពីការផ្ដល់នីតិសម្បទាជានគរបាលយុត្តិធម៌ដល់មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម" ៥) ប្រកាសស្ដីពីគោលការណ៍ណែនាំសម្រាប់ស្លាកសញ្ញាព័ត៌មាននិងគំរូស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្ម។

## ឈ. ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ជាអង្គភាពជំនាញបានបង្កើតពូជដំណាំកសិកម្មថ្មីៗ ថែរក្សានូវគុណភាពគ្រាប់ពូជនៃពូជដំណាំដែលបានបញ្ចេញ រួមទាំងផ្សព្វផ្សាយនូវពូជទាំងនោះ និងវិធីសាស្ត្រសម្រិតសម្រាំងគ្រាប់ពូជស្រូវបែបកសិករ បច្ចេកវិទ្យាដាំដុះ គ្រប់គ្រងសារធាតុចិញ្ចឹមដំណាំនិងជីជាតិដី ការពារនិងកម្ចាត់កត្តាចង្រៃ មុនពេលនិងក្រោយពេលប្រមូលផល បណ្ដុះបណ្ដាលធនធានមនុស្ស រួមទាំងចងក្រង បោះពុម្ព និងផ្សព្វផ្សាយអត្ថបទវិទ្យាសាស្ត្រ ព្រមទាំងឯកសារបច្ចេកវិទ្យា ជូនដល់អ្នកពាក់ព័ន្ធនិងកសិករទូទាំងប្រទេស។ ជាក់ស្ដែងការងារជាច្រើនត្រូវបានអនុវត្តនិងផ្ដល់លទ្ធផលសំខាន់ៗរួមមាន៖

- អត្ថបទវិទ្យាសាស្ត្រ៖ បានសរសេរនិងបោះពុម្ពអត្ថបទនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រអន្តរជាតិបានចំនួន៣ ព្រមទាំងសៀវភៅចំនួន៣ទៀតគឺ ១. សមិទ្ធផលនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យា (១៩៩៩–២០១៧) ២. Description of Crop Varieties Released by CARDI និង ៣. Rice Germplasm Catalog of Cambodia IV
- ការអភិរក្សពូជដំណាំកសិកម្ម៖ បានប្រមូលពូជដំណាំថ្មីៗទៀតចំនួន១១៥សំណាកមករក្សាទុក ព្រមទាំងបានដាំវាយតម្លៃនិងកំណត់លក្ខណៈពូជម្ទេសចំនួន៩៥សំណាក និងត្រសក់ស្រូវចំនួន៤៨សំណាក។ គិតជារួមត្រឹមដំណាច់ឆ្នាំ២០១៧នេះ ពូជដំណាំចំនួន៣៨ប្រភេទ ដែលសរុបទាំងអស់មានចំនួន៨ ៤១៩ បញ្ជីក/សំណាក បានអភិរក្សនៅក្នុងធនាគារពន្ធុរបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា សម្រាប់ប្រើប្រាស់ក្នុងកិច្ចអភិវឌ្ឍន៍ពូជដំណាំក្នុងរយៈពេលយូរអង្វែង
- បញ្ចេញពូជស្រូវផ្កាមាលតី៖ បានបញ្ចេញពូជស្រូវថ្មីចំនួន០១បន្ថែមទៀត ដោយដាក់ឈ្មោះពូជ ផ្កាមាលតី ដែលជាពូជស្រូវក្រអូប អង្ករប្រណិតល្អ អាយុកាលកណ្ដាលប្រកាន់រដូវ ធន់មធ្យមនឹងរាំងស្ងួត ធន់នឹងទឹកជំនន់និងដួលដើម ដែលបានមកពីការបង្កាត់ត្រឡប់ និងជ្រើសរើសតាមការវិភាគ DNA ដោយមាន

សារធាតុសម្គាល់ជាជំនួយ រវាងពូជ ផ្ការំដួល (ក្រអូបប្រណីត) និង ខា៣ (ធន់មធ្យមនឹងរាំងស្ងួត) ក្នុងឆ្នាំ២០០៤។ ពូជស្រូវផ្កាមាលតី ជាមធ្យមចេញផ្កាក្នុងកំឡុងពាក់កណ្តាលខែតុលា កម្ពស់១,៥ម អង្ករសថ្លា មានប្រវែង៧,២មម និងបន្ទារ២,០មម មានកម្រិតអាមីឡូស១៦% និងទិន្នផលមធ្យម៣,០ត/ហត និងអាចផ្តល់ផលរហូតដល់៥,៥ត/ហត

- ថ្នាំកសិកម្មការពារនិងកម្ចាត់ជំងឺខ្ទារអំបោះត្នោត៖ ការកាត់បន្ថយសំណល់សារធាតុ Tricyglazole ក្នុងអង្កររបស់សហគមន៍អ៊ឺរ៉ុប បានចោទជាបញ្ហាដល់អ្នកផ្សព្វផ្សាយនិងកសិករក្នុងការជ្រើសរើសថ្នាំកសិកម្មសមស្របមកប្រើប្រាស់ក្នុងការការពារនិងកាត់បន្ថយការបំផ្លាញផលស្រូវដោយជំងឺខ្ទារអំបោះត្នោត។ ដើម្បីចូលរួមដោះស្រាយបញ្ហានេះ ថ្នាំកសិកម្មចំនួន៤ប្រភេទ ក្នុងងនោះមួយប្រភេទជាថ្នាំជីវសាស្ត្រ (Trichoderma) ទៀតដែលមាននៅលើទីផ្សារ បានយកមកពិសោធន៍រកប្រសិទ្ធភាពការពារ (Prevent) និងកម្ចាត់ (Control) ជាមួយនឹងថ្នាំកសិកម្ម Tricyclazole 75% WP នៅក្នុងមន្ទីរពិសោធន៍ (Lab ចំនួន៥សារ) និងនៅក្នុងផ្ទះសំណាញ់ (NH) នៅកាឌី។ លទ្ធផលពិសោធន៍បានបង្ហាញថា ការប្រើប្រាស់ថ្នាំកសិកម្ម Isoprothiolane 40%EC ឬ Isolane 40%EC ដែលគ្មានសារធាតុ Tricyclazole ក្នុងកម្រិត១ល/ហត គឺអាចជំនួសថ្នាំកសិម្ម Tricyclazole 75% WP ឬ Bimzole ដែលកសិករពេញនិយមប្រើប្រាស់ក្នុងការការពារនិងកម្ចាត់ជំងឺខ្ទារអំបោះត្នោតបាន។
- ទំនាក់ទំនងរវាងបរិមាណអង្ករដើមនិងការប្រេះស្រាំរបស់គ្រាប់អង្ករ៖ លទ្ធផលនៃពិសោធន៍រយៈពេល ២ឆ្នាំ អំពីឥទ្ធិពលនៃពេលវេលានិងសំណើមគ្រាប់ស្រូវនាពេលច្រូតកាត់ទៅលើការប្រេះស្រាំនិងបរិមាណអង្ករដើមបានបង្ហាញថា ការច្រូតកាត់គ្រាប់ស្រូវដែលមានសំណើមគ្រាប់កាន់តែទាប នោះបរិមាណគ្រាប់អង្ករនិងទំហំប្រេះស្រាំកាន់តែច្រើននិងធំ (ក្រាហ្វិក១) បណ្តាលឲ្យបរិមាណអង្ករដើមដែលកិនបានកាន់តែតិច (ក្រាហ្វិក២)។ ដូច្នេះ កសិករមិនត្រូវទុកឲ្យស្រូវទុំជ្រុលទើបប្រមូលផលនោះទេ ផ្ទុយទៅវិញត្រូវប្រមូលផលស្រូវនាពេលស្រូវមានសំណើមមិនក្រោម២២-២៣% ជាពិសេសពេលដែលប្រមូលផលដោយកុំបៃ ដើម្បីធានាបាននូវបរិមាណអង្ករដើមច្រើន។




**ក្រាហ្វិក១. ទំនាក់ទំនងរវាងសំណើមគ្រាប់** (x, %) **និងអង្ករប្រេះស្រាំ** (y, %)




**ក្រាហ្វិក២. ទំនាក់ទំនងរវាងអង្ករប្រេះស្រាំ** (x,%) **និងអង្ករដើម** (y, %)

- ការសិក្សាអំពីតុល្យភាពសារធាតុចិញ្ចឹមក្នុងការដាំដុះដំឡូងមី៖ អស់រយៈពេល៣ឆ្នាំនៃការដាំដុះដំឡូងមី (២០១៤-២០១៧) យើងបានដឹងថា សារធាតុអាសូត (N) ក្នុងដីបានធ្លាក់ចុះដល់កម្រិតអវិជ្ជមានរវាងពី -៨៥ ទៅ -១៥០ គ.ក្រ/ហត/ដំណាំ ហើយសារធាតុផូស្វ័រ (P) វិញ បានធ្លាក់ចុះអវិជ្ជមានក្នុងករណីដាំមិនដាក់ជីនិងការដាក់ជីកម្រិតទាប (តារាង៥)។ កម្រិត នៃការធ្លាក់ចុះទាំងសារធាតុ N និង P មានកាន់តែខ្ពស់ក្នុងករណីដាំមិនដាក់ជី។ ក្នុងលក្ខខណ្ឌដីដែលបានធ្វើពិសោធន៍ក្នុងស្រុកភ្នំព្រឹកនាពេលបច្ចុប្បន្ននេះ

ការដាំដុះដំឡូងមីគួរត្រូវយកចិត្តទុកដាក់ខ្លាំងចំពោះការផ្គត់ផ្គង់សារធាតុ N និង P សម្រាប់ដំណាំដំឡូងមី។ ក្នុងរយៈពេលវែង ក៏ត្រូវគិតគូរផងដែរចំពោះសារធាតុប៉ូតាស្យូម (K) និងម៉ាញ៉េស្យូម (Mg)។

**តារាង១. តុល្យភាពសារធាតុចិញ្ចឹម (Nutrient elements) នៅក្នុងដីបន្ទាប់ពីប្រមូលផលដំឡូងមីរយៈពេល៣ឆ្នាំជាប់ៗគ្នាដោយមិនដាក់ជី (No fertilizer) ដាក់ជីកម្រិតទាប (Low) ដាក់ជីកម្រិតមធ្យម (Medium) និងដាក់ជីកម្រិតខ្ពស់ (High)**

| Nutrient | Rates of N-$P_2O_5$-$K_2O$ (kg/ha) | | | |
|---|---|---|---|---|
| elements | No fertilizer | Low (40-20-40) | Medium (80-40-80) | High (160-80-100) |
| N | -152 | -125 | -136 | -85 |
| P | -24 | -9 | 10 | 41 |
| K | 228 | 268 | 306 | 272 |
| Ca | 9,006 | 8,640 | 8,689 | 8,875 |
| Mg | 373 | 308 | 306 | 309 |

– ខ្សែសង្វាក់តម្លៃដំឡូងមីស្រស់ពីខេត្តក្រចេះដល់រោងចក្រនៅខេត្តតៃនិញ៖ លទ្ធផលនៃការសិក្សាអំពីខ្សែសង្វាក់តម្លៃដំឡូងមីស្រស់បានបង្ហាញថា តម្លៃដំឡូងមីស្រស់ដែលប្រមូលទិញនៅចម្ការក្នុងខេត្តក្រចេះគឺប្រហែល៥០,៨០ដុល្លារ/ត នៅរដូវកាលប្រមូលផលដំឡូងមីក្នុងឆ្នាំ២០១៧ ហើយតម្លៃដំឡូងមីដែលទិញដោយរោងចក្រក្នុងខេត្តតៃនិញគឺ៧០,០៩ ដុល្លារ/ត (តារាង២)។ យើងសង្កេតឃើញថាតម្លៃដំឡូងមីស្រស់នៅចម្ការគឺត្រូវនឹងប្រមាណ៦៨% នៃតម្លៃដំឡូងមីស្រស់ដែលទិញដោយរោងចក្រ ហើយកសិករដាំដំឡូងមីនៅខេត្តក្រចេះបានចំណាយទុនសរុបច្រើនជាង៨០% នៃការចំណាយសរុបរបស់ខ្សែសង្វាក់តម្លៃពីចម្ការដំឡូងនៅខេត្តក្រចេះរហូតដល់រោងចក្រកែច្នៃ និងផលិតម្សៅនៅខេត្តតៃនិញប្រទេសវៀតណាម។

**តារាង២. ខ្សែសង្វាក់តម្លៃដំឡូងមីស្រស់ពីខេត្តក្រចេះដល់ខេត្តតៃនីញ (ដុល្លារ/ត)**

| Description | Purchase price | Costs | Selling price | Gross margin | Net Margin |
|---|---|---|---|---|---|
| Cambodian farmer | | 45.74 | 50.80 | 50.80 | 5.06 |
| Cambodian small trader | 50.8 | 0.00 | 54.11 | 3.31 | 3.31 |
| Cambodian large trader | 54.11 | 3.51 | 61.84 | 7.73 | 4.22 |
| Vietnamese trader | 61.84 | 6.76 | 75.09 | 13.25 | 6.49 |
| Vietnamese factory | 75.09 | | | | |
| **Total value added (USD/t)** | | | | | **19.08** |

Purchase Price = ថ្លៃទិញ Cost = ចំណាយ Selling price = ថ្លៃលក់ Gross marging = ចំណូលសរុប Net margin = ចំណេញសុទ្ធ Description = បរិយាយ Cambodian farmer = កសិករខ្មែរ Cambodian small trader = ពាណិជ្ជករខ្មែរខ្នាតតូច Cambodian large trader = ពាណិជ្ជករខ្មែរខ្នាតធំ Vietnamese trader = ពាណិជ្ជករវៀតណាម Vietnamese factory = រោងចក្រវៀតណាម

– ឥទ្ធិពលនៃកំបោរនិងកម្រិតជីលើដំណាំឆៃថាវដាំបន្ទាប់ពីប្រមូលផលស្រូវវស្សា៖ នៅដំណាំទី១ ការដាក់កំបោរប្រើជីតាមកម្រិតណែនាំធៀបនឹងទម្លាប់កសិករ មានកំណើនទិន្នផលតិចតួច ហើយពុំមានលក្ខណៈសេដ្ឋកិច្ចទេ (តារាង៣)។ បើធៀបនឹងការដាក់ជីតាមទម្លាប់កសិករ នៅដំណាំទី២ ទិន្នផលកើនបាន១៧% និងប្រាក់ចំណេញកើនបាន៤៥១ដុល្លារ/ហត និងនៅដំណាំទី៣ ការប្រើប្រាស់ជីធ្វើឲ្យទិន្នផលកើនឡើង ២២% និងប្រាក់ចំណេញកើនបាន១.០១៧ដុល្លារ/ហត និងនៅដំណាំទី៤ ការប្រើប្រាស់ជីធ្វើឲ្យទិន្នផលកើនឡើង២៦% និងប្រាក់ចំណេញកើនបាន៨០៧ដុល្លារ/ហត។ ទិន្នផលដំណាំមានការប្រែប្រួលខ្លាំងពីដំណាំមួយទៅដំណាំមួយ អាស្រ័យលើកត្តាប្រឈមនឹងសត្វល្អិតបំផ្លាញ និងការពន្យារពេលវេលាដាំដុះដែលបានធ្វើឲ្យប៉ះពាល់ដល់ប្រាក់ចំណេញផងដែរ ដូចជាករណីដំណាំទី២និងទី៤ដែលប្រាក់ចំណេញបានធ្លាក់ចុះយ៉ាងខ្លាំង។ ការប្រើប្រាស់ជីតាមកម្រិតណែនាំដោយមិនដាក់កំបោរដែលមានការបំប៉ន៤ដង បានជួយរក្សាកំណើនទិន្នផលដំណាំក្នុងរង្វង់១៧-២៦% និងប្រាក់ចំណេញបន្ថែមពី៤៥០-១០២០ដុល្លារ/ហត។ ពេលវេលាដាំដុះសមស្របគឺក្នុងខែធ្នូ។

តារាង៨. ទិន្នផលដំណាំផែថាវនិងប្រាក់ចំណេញដោយសារការប្រើប្រាស់ជីតាមកម្រិតណែនាំលាយជាមួយកំបោរ (RR+Lime) ការប្រើប្រាស់ជីរបស់កសិករលាយជាមួយកំបោរ (FP+Lime) និងការប្រើប្រាស់ជីរបស់កសិករ (FP)

| Fertilizer Treatments | Growing period | Crop No. | Root Yield (kg/ha) | Lime | Fertilizers | Income | Profit | RR – FP |
|---|---|---|---|---|---|---|---|---|
| | | | | (US$/ha) | | | | |
| RR+Lime | Dec 2015 – Jan 2016 | 1 | 38,363 | 327 | 341 | 4,795 | 4,127 | -94 |
| FP+Lime | | | 37,057 | 327 | 327 | 4,632 | 3,979 | |
| FP | | | 36,381 | 0 | 327 | 4,548 | 4,221 | |
| RR | Feb - Mar 2016 | 2 | 27,876 | 0 | 296 | 3,485 | 3,189 | 451 |
| FP | | | 24,471 | 0 | 321 | 3,059 | 2,738 | |
| RR | Dec 2016 - Jan 2017 | 3 | 48106 | 0 | 316 | 6,013 | 5,697 | 1017 |
| FP | | | 40,028 | 0 | 323 | 5,004 | 4,680 | |
| RR | Feb - Mar 2017 | 4 | 34,127 | 0 | 296 | 4,266 | 3,970 | 807 |
| FP | | | 27,869 | 0 | 321 | 3,484 | 3,163 | |

Fertilizer treatment= បច្ច័យជី Growing period=រយៈពេលដាំដុះ Crop no.= ដំណាំទី Root yield=ទិន្នផលមើម Lime=កំបោរ Fertilizers=ជី Income=ចំណូលដល់ Profit=ចំណេញសុទ្ធ RR-FP=ចំណេញបន្ថែម

- ការដាំដុះសណ្តែកបាយនិងពោតដំណើបបន្ទាប់ពីប្រមូលផលស្រូវវស្សា៖ សណ្តែកបាយពូជ កាឌីជ័យ និងស៊ីអឹមប៊ី៣ និងពោតដំណើប ស៊ីអឹម១ បានយកមកដាំដុះដោយឧបករណ៍ដាំគ្រាំស្ងួត និងប្រើប្រាស់បច្ចេកទេសគ្រប់គ្រងរបស់កាឌី នៅក្នុងរដូវប្រាំងបន្ទាប់ពីប្រមូលផលស្រូវវស្សាហើយ ផ្តល់ផលល្អជាទីគាប់ចិត្ត ដោយក្នុងនោះ សណ្តែកបាយបានរហូតដល់៧៥០គក្រ/ហត និងពោតផ្តល់ផ្លែល្អសម្រាប់ស្ងោររហូតដល់៤៣.៦០០ផ្លែ។ ដូចនេះ នៅកន្លែងណាដែលមានប្រភពទឹកគ្រប់គ្រាន់ឬមានកម្រិតក្នុងរដូវប្រាំង កសិករគួរនាំគ្នាដាំសណ្តែកបាយនិងពោតដំណើប បន្ទាប់ពីប្រមូលផលស្រូវវស្សារួចភ្លាម ដោយដំណាំទាំងនេះមានរយៈពេលខ្លីនិងប្រើប្រាស់ទឹកតិចជាងដំណាំស្រូវ ហើយម្យ៉ាងទៀតសណ្តែកបាយ ជាប្រភេទដំណាំដែលជួយដល់គុណភាពដីផងដែរ។
- ការអភិវឌ្ឍន៍ធនធានមនុស្សនិងផ្សព្វផ្សាយ៖ បានបើកវគ្គបណ្តុះបណ្តាល ចូលរួមសិក្ខាសាលា និងសន្និបាតដល់អ្នកបច្ចេកទេសចំនួន១៦១ឱកាស ព្រមទាំងចូលរួមបង្រៀននៅសាលាកសិកម្ម និងដឹកនាំនិស្សិតសរសេរសារណាចាប់ពីថ្នាក់បរិញ្ញាបត្រដល់បណ្ឌិតបានចំនួន១៥នាក់។ ម្យ៉ាងទៀត បានបណ្តុះបណ្តាលកសិករអំពីបច្ចេកទេសដាំដុះ ថែទាំ សម្រិតសម្រាំងគ្រាប់ពូជ និងក្រោយប្រមូលផលដំណាំចំនួន ១ ៧៧៤ឱកាស បានបែងចែកឯកសារបោះពុម្ពដល់អ្នកពាក់ព័ន្ធនិងកសិករទាំងអស់ចំនួន សរុប៣៤ ៧១៣ក្បាល ព្រមទាំងបានចែកគ្រាប់ពូជស្រូវជូនដល់កសិករចំនួន៥៨៣គ្រួសារសរុបចំនួន២ ៩១៥គ.ក្រ ហើយដែលកសិករទាំងនោះ ផលិតជាគ្រាប់ពូជបានប្រមាណ៥១តោនទុកសម្រាប់ប្រើប្រាស់ក្នុងឆ្នាំក្រោយ។ បន្ថែមលើនេះ មានអ្នកចូលស្វែងរកឯកសារពីគេហទំព័រ cardi.org.kh ចំនួន៥៧៤ ៩១៨នាក់ ហើយគិតជាមធ្យមមានប្រមាណ១ ៥៧៥នាក់/ថ្ងៃ។

## ៤. ការងារកសិ-ឧស្សាហកម្ម

ក្រោមការដឹកនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការងារកសិ-ឧស្សាហកម្មកំពុងបន្តពង្រឹងការអនុវត្តលើសកម្មភាពចុះត្រួតពិនិត្យ និងវាយតម្លៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច កិច្ចសន្យាផលិតកម្មកសិកម្ម ការកែច្នៃផលិតផលកសិកម្ម និងកសិម្ហូបអាហារ គុណភាពនិងសុវត្ថិភាពផលិតផលកសិកម្មនិងកសិម្ហូបអាហារ និងកសិពាណិជ្ជកម្មសម្រាប់ ទិសដៅបន្តឆ្នាំ២០១៨ និងរៀបចំផែនការយុទ្ធសាស្ត្រ និងសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម២០១៨-២០៣០ សម្រាប់គាំទ្រការរៀបចំផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំឆ្ពោះទៅ ២០៣០។ លើសពីនេះ ក៏បានសហការជាមួយអង្គការសង្គមស៊ីវិល ព្រមទាំងសហការយ៉ាងជិតស្និទជាមួយដៃគូ

អភិវឌ្ឍន៍នានា និងបានរៀបចំលិខិតបទដ្ឋានគតិយុត្ត ការបណ្តុះបណ្តាល និងស្រាវជ្រាវ ដែលមានសកម្មភាព និងទទួលបានលទ្ធផលដូចខាងក្រោម៖

- ចូលរួមជាគណៈកម្មាធិការ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្មលើកទី១ស្តីអំពីការផ្សព្វផ្សាយលិខិតបទដ្ឋាននិងយន្តការអនុវត្តផលិតកម្មកសិកម្មកិច្ចសន្យានៅប្រទេសកម្ពុជាដែលដឹកនាំដោយឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការចូលរួមពីអង្គការពាក់ព័ន្ធនិងវិស័យឯកជន និងបានចូលរួមជាសមាជិកមេប្រយោគក្នុងការជ្រើសរើសកសិករឆ្នើមលើប្រធានបទ "ការកែច្នៃផលិផលកសិកម្ម"។
- ចូលរួមរៀបចំកិច្ចប្រជុំ និងអនុវត្តការតាមដានពិនិត្យមើលវឌ្ឍនភាព និងបញ្ហាប្រឈមលើការអភិវឌ្ឍសម្បទានដីសេដ្ឋកិច្ច។
- អនុវត្តថវិកាតាមកម្មវិធីទី១ អនុកម្មវិធីទី១៧ សកម្មភាពទី១ បណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសកែច្នៃផលិតផលកសិកម្ម និងចំណីសត្វបានចំនួន៧គោលដៅ សរុបកសិករចូលរួមមានចំនួន៤២០នាក់ នៅក្នុងខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តតាកែវ និងអនុវត្តការងារធ្វើតេស្តវិភាគគុណភាព និងសុវត្ថិភាពលើផលិតផលកសិកម្ម។
- រៀបចំចងក្រង និងបានពិភាក្សាពីស្លាកសញ្ញាផលិតផលកសិកម្ម និងនីតិវិធីផ្តល់វិញ្ញាបនបត្រអំពីសរីរាង្គ មិនមានថ្នាំសំលាប់សត្វល្អិត និងកាកសំណល់កសិកម្មមិនមានថ្នាំអង់ទីប៊ីយ៉ូទិក កសិកម្មធម្មជាតិ និងកសិកម្មក្នុងស្រុកទៅលើប្រភេទអាហារកែច្នៃ ចំណីសត្វ វារីវប្បកម្ម បន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិ។ បន្ថែមពីនេះបានបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីគុណភាពសុវត្ថិភាពផលិផលកសិកម្ម។
- សហការជាមួយវិទ្យាស្ថានជាតិចិនស្រាវជ្រាវលើចំណីអាហារ និងឧស្សាហកម្មអាហារឡើងមេ (CNRIFFI) លើការកសាងសមត្ថភាពបណ្តុះបណ្តាលមន្ត្រីមន្ទីរពិសោធន៍ និងមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)។
- បានបញ្ជូនមន្ត្រីជំនាញកសិ-ឧស្សាហកម្ម ជាពិសេសមន្ត្រីជាស្ត្រីចូលរួមវគ្គបណ្តុះបណ្តាលមួយចំនួន ដើម្បីពង្រឹងសមត្ថភាពនៅបណ្តាប្រទេសអាស៊ី និងអឺរ៉ុប និងប្រទេសតាមបណ្តោយខ្សែក្រវ៉ាត់នានាស្តីពីការត្រួតពិនិត្យក្នុងពេលនាំចេញនិងនាំចូលផលិតផលកសិកម្ម និងចំណីអាហារ និងបានបញ្ជូនគម្រោងស្នើសុំជូនសាធារណរដ្ឋប្រជាមានិតចិន (មេគង្គ-ឡាន ឆាង)។

**ការរៀបចំលិខិតបទដ្ឋានគតិយុត្ត ការសហការ និងការបណ្តុះបណ្តាលនិងស្រាវជ្រាវ**

| សកម្មភាព | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | សរុប |
|---|---|---|---|---|---|---|
| ការរៀបចំនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់មន្ទីរពិសោធន៍ | | | | | ៥ | ៥ |
| ការប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត លើការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា | | | | ៤៨០ | ៥២០ | ១ ០០០ |
| ការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា | ៣៩០ | ៣៩០ | ៣៩០ | ៤៨០ | ៤៩០ | ២ ១៤០ |
| ការរៀបចំវគ្គបណ្តុះបណ្តាល និងការបើកវេទិការផ្គូរផ្គងដែលភ្ជាប់ទំនាក់ទំនងកសិករទៅកាន់ទីផ្សារ | | | | ៤៨០ | ៥២០ | ១ ០០០ |
| ការរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ស្តីពីប្រព័ន្ធត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មនិងចំណីអាហារ | | | | ៥ | ៣ | ៨ |
| ការរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីជំនាញ ស្តីពីប្រព័ន្ធត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មនិងចំណីអាហារ | | | | ៥ | ៥៧ | ៦២ |
| ការរៀបចំក្រុមហ៊ុនចូលរួមអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា | ១ | ១៣ | ១២ | ២២ | ៣២ | ៨០ |
| សិក្សាស្រាវជ្រាវលើការធ្វើតេស្តវិភាគរកកាកសំណល់ថ្នាំពុលកសិកម្មនៃផលិតផលកសិកម្ម | | | | | ៦០ | ៦០ |
| សិក្សាស្រាវជ្រាវលើការធ្វើតេស្តវិភាគរកពពួកអតិសុខុមប្រាណនៃផលិតផលកសិកម្ម និងចំណីអាហារ | | | | | ២០ | ២០ |

## ឈ. ការបង្កើនផលិតភាពលើដំណាំកៅស៊ូ

### ១. សេចក្ដីផ្ដើម

កៅស៊ូធម្មជាតិ បានដាំជាលើកដំបូងនៅកម្ពុជានាឆ្នាំ១៩១០ នៅស្រុកព្រៃនប់។ រហូតដល់ឆ្នាំ១៩២១ ទើបមានការដាំជាលក្ខណៈឧស្សាហកម្មទ្រង់ទ្រាយធំដែលក្រុមហ៊ុនវិនិយោគរបស់បារាំងធំៗ នៅក្នុងខេត្តកំពង់ចាម និងក្រចេះ។ មកដល់ឆ្នាំ១៩៦៩ ដំណាំកៅស៊ូនៅកម្ពុជាបានពង្រីកផ្ទៃដីជាង៦៤ ០០០ហិកតា ក្នុងនោះផ្ទៃដីចៀរមានជាង ៣៩ ០០០ហិកតា ដោយទទួលបានផលិតផលកៅស៊ូបានជាង៥០ ០០០តោន សម្រាប់ការប្រើប្រាស់នៅក្នុងស្រុកនិងការនាំចេញទៅបរទេស។

កៅស៊ូធម្មជាតិ គឺជាដំណាំយុទ្ធសាស្ត្រមួយប្រភេទដែលផ្ដល់ពហុប្រយោជន៍ជាច្រើនដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិ ដល់សង្គមទាំងមូល និងបរិស្ថាន ជាពិសេសបានចូលរួមលើកកម្ពស់ប្រាក់ចំណូលសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារកសិករ ចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារ និងមុខរបរមានស្ថិរភាពជូនប្រជាពលរដ្ឋនៅតាមតំបន់ជនបទ និងកាត់បន្ថយការធ្វើចំណាកស្រុក ផ្ដល់ឈើសម្រាប់ប្រើប្រាស់ផលិតគ្រឿងសង្ហារឹម ជាឈើតន្នូនៈ ចូលរួមចំណែកជួយកាត់បន្ថយការកាប់បំផ្លាញព្រៃឈើធម្មជាតិ ការពារការហូរច្រោះដី និងជាគម្របបៃតង ដើម្បីចូលរួមក្នុងការថែរក្សាលំនឹងបរិស្ថាន ដោយកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងកាត់បន្ថយបម្រែបម្រួលអាកាសធាតុដែលជាបញ្ហាពិភពលោកដ៏ចម្បងមួយក្នុងពេលបច្ចុប្បន្ននិងពេលអនាគត។

### ២. ការបង្កើនផលិតភាពលើដំណាំកៅស៊ូ

នៅឆ្នាំ២០១៧នេះ ផ្ទៃដីកៅស៊ូកម្ពុជាសរុបមានចំនួន៤៣៦ ៣៤០ហិកតា បើធៀបទៅនឹងឆ្នាំ២០១៦ មានចំនួន៤៣២ ៧៣៥ហិកតា គឺកើនឡើងចំនួន៣ ៦០៥ហិកតា ស្មើនឹង០,៨៣%។ ផ្ទៃដីកៅស៊ូទាំងនេះត្រូវបានបែងចែកជា០២ផ្នែកគឺ៖ ក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) សរុបមានចំនួន២៨០ ២២៨ហិកតា ស្មើនឹង៦៤,២២% និងកៅស៊ូគ្រួសារមានចំនួន១៥៦ ១១២ហិកតា ស្មើនឹង៣៥,៧៨% នៃផ្ទៃដីកៅស៊ូសរុប។

ទោះបីជាថ្លៃកៅស៊ូទាបនិងមានកត្តាអវិជ្ជមានមួយចំនួន ដែលបានជួបប្រទះកន្លងមកក៏ពិតមែន តែជារួមសមិទ្ធផលបានសម្រេចទៅតាមគោលដៅដែលគ្រោងទុក។ ទាំងអស់នេះ គឺកើតឡើងដោយការខិតខំប្រឹងប្រែងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម ដៃគូអភិវឌ្ឍន៍នានា និងការចូលរួមយ៉ាងសកម្មពីកសិករកៅស៊ូគ្រួសារផងដែរ។ ទោះបីជាយ៉ាងនេះក្ដី ការបង្កើនលទ្ធភាពនិងសមត្ថភាពក្នុងការអភិវឌ្ឍឧស្សាហកម្មកៅស៊ូត្រូវតែយកចិត្តទុកដាក់និងត្រូវជំរុញបន្ថែមទៀត ដើម្បីរួមចំណែកដោយជោគជ័យក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។

**តារាងផលិតកម្មកៅស៊ូឆ្នាំ២០១៦-២០១៧**

| | ផលិតកម្មកៅស៊ូ | ប្រភេទចម្ការកៅស៊ូ | ឯកតា | ២០១៦ | ២០១៧ | ២០១៧/២០១៦ (Δ%) |
|---|---|---|---|---|---|---|
| 1 | ផ្ទៃដីដាំកៅស៊ូសរុប | កសិឧស្សាហកម្ម | ពាន់ហ.ត | 278,2 | 280,2 | 0,7 |
| | | កៅស៊ូគ្រួសារ | ពាន់ហ.ត | 154,5 | 156,1 | 1,0 |
| | | **សរុប** | **ពាន់ហ.ត** | 432,7 | 436,3 | 0,8 |
| 2 | ផ្ទៃដីចៀរជ័រ | កសិឧស្សាហកម្ម | ពាន់ហ.ត | 40,7 | 69,7 | 71,3 |
| | | កៅស៊ូគ្រួសារ | ពាន់ហ.ត | 86,3 | 100,5 | 16,5 |
| | | **សរុប** | **ពាន់ហ.ត** | 127,0 | 170,2 | 34,0 |
| 3 | ផលិតផលកៅស៊ូ | កសិឧស្សាហកម្ម | ពាន់តោន | 43,5 | 83,6 | 92,1 |
| | | កៅស៊ូគ្រួសារ | ពាន់តោន | 101,6 | 109,7 | 8,0 |
| | | **សរុប** | **ពាន់តោន** | 145,2 | 193,3 | 33,1 |




## ក. ការងារផលិតកម្មនិងនិហារ័ណកៅស៊ូ

ឆ្នាំ២០១៧នេះ ផ្ទៃដីកៅស៊ូចៀរអនុវត្តបានចំនួន១៧០ ២៣០ហិកតា ធៀបនឹងផ្ទៃដីកៅស៊ូចៀរឆ្នាំ២០១៦ មាន១២៦ ៩៩៦ហិកតា កើនឡើងចំនួន៤៣ ២៣៤ហិកតា ស្មើនឹង៣៤,០៤% (ក្រាហ្វិកទី២)។ ផលិតផលកៅស៊ូ សម្រេចបានចំនួន១៩៣ ២៨៦តោន ធៀបនឹងឆ្នាំ២០១៦ ចំនួន១៤៥ ២០០តោន កើនឡើងចំនួន៤៨ ០៨៦តោន ស្មើនឹង៣៣,១១% (ក្រាហ្វិកទី៣)។ ទិន្នផលមធ្យមមានចំនួន១ ១៣៥គ.ក្រ./ហ.ត. បើធៀបនឹងឆ្នាំ២០១៦ ដែល មានចំនួន១ ១៤៣ គ.ក្រ./ហ.ត. គឺថយចុះ០,៧% ដោយសារមានផ្ទៃដីកៅស៊ូថ្មីជាច្រើន ចាប់ផ្ដើមបើកមុខចៀរដំបូង ដែលជាទូទៅមានទិន្នផលទាប។

**ក្រាហ្វិក បង្ហាញអំពីផ្ទៃដីកៅស៊ូចៀរជ័រ ថែទាំ និងសរុបឆ្នាំ២០១៣-២០១៧**




ការនាំចេញកៅស៊ូឆ្នាំ២០១៧ សម្រេចបានចំនួន១៨៨.៨៣២តោន ស្មើនឹងទឹកប្រាក់២៩៩ ៣៩៤ ៨៤១ ដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០១៦ ដែលការនាំចេញមានចំនួន១៤៥.១០០តោន ដែលមានទឹកប្រាក់សរុប ១៨៧ ១៦៤ ៥៥១ដុល្លារអាមេរិក គឺការនាំចេញកើនឡើងចំនួន៤៣ ៧៣២តោន ស្មើនឹង៣០,១៤%។ ទឹកប្រាក់ ចំណូលកើនប្រមាណ១១២ ២៣០ ២៩០ដុល្លារអាមេរិក ស្មើនឹង៥៩,៩៦%។ កៅស៊ូនាំចេញជាមធ្យមមានតម្លៃ

១ ៥៨៥ដុល្លារអាមេរិកក្នុងមួយតោន បើធៀបនឹងឆ្នាំ២០១៦ ដែលតម្លៃមធ្យមស្មើនឹង១ ២៨៩ដុល្លារអាមេរិក ក្នុងមួយតោន ឃើញថាមានការកើនឡើងចំនួន២៩៦ដុល្លារអាមេរិកក្នុងមួយតោន ត្រូវនឹង២៧,៩៦%។

ក្រាហ្វិក បង្ហាញអំពីផលិតកម្មនិងបរិមាណកៅស៊ូនាំចេញ




នៅក្នុងឆ្នាំ២០១៧នេះ រោងចក្រ សិប្បកម្មកែច្នៃ ផលិតផលកៅស៊ូមានសរុបចំនួន១៣៩កន្លែង នៅក្នុងខេត្តចំនួន១១ (កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង រតនគិរី ឧត្តរមានជ័យ ព្រះវិហារ ព្រះសីហនុ និងប៉ៃលិន) គឺកើនឡើងចំនួន១៣កន្លែង ស្មើនឹង១០% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៦ ដែលមានតែ១២៦កន្លែង។ ក្នុងចំណោមរោងចក្រ សិប្បកម្មចំនួន១៣៩កន្លែង មានរោងចក្រកែច្នៃកៅស៊ូបញ្ជាក់តាមបច្ចេកទេស (Technically Specified Rubber: TSR) ចំនួន៣៧កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់ ចំនួន១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹក (Rubber Sheet: RS) សិប្បកម្មកែច្នៃកៅស៊ូសន្លឹកក្រឡាសម្ងួតមានផ្សែង (Ribbed smoked sheet: RSS) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅគ្មានផ្សែង (Air-dried sheet: ADS) មានចំនួន៩២កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូ (Rubber Wood Factory: RWF) ចំនួន០៩កន្លែង។

ក្រាហ្វិក៖ ចំនួនរោងចក្រ សិប្បកម្មកែច្នៃជ័រនិងឈើកៅស៊ូ ២០១៣ -២០១៧




## ខ. ការងារផែនការ ហិរញ្ញវត្ថុផ្នែកកៅស៊ូ

ចំណូលឆ្នាំ២០១៧ អនុវត្តបានចំនួន១ ៤៦៦ ០៤២ ០១០រៀល (៣៦១ ៩៨៥ដុល្លារអាម៉េរិក) ក្នុងនោះ រួមមាន៖ ការជួលដីក្រុមហ៊ុនទាំង០៧មានចំនួន១ ២៥២ ០៩៣ ៤១៧រៀល (៣០៩ ១៥៩ដុល្លារអាមេរិក) ការជួលដីសហគ្រាសសាធារណៈថ្នាក់រដ្ឋបាលកណ្តាល (ចម្ការកៅស៊ូឡាបានសៀក ខេត្តរតនគិរី) ចំនួន៩៦ ៩១២ ៩៣៤រៀល

(២៣ ៩២៩ដុល្លារអាមេរិក) និងការជួលអចលវត្ថុ (អសង្ហារឹម) ក្រុមហ៊ុននីហាវ័ណ អាហាវ័ណកៅស៊ូចំនួន ១១៧.០៣៥.៦៥៨រៀល (២៨.៩៥៨ដុល្លារអាមេរិក)។ បើធៀបនឹងគោលដៅចំនួន១ ៤០៣ ០០០ ០០០រៀល (៣៤៦ ៤១៩ដុល្លារអាមេរិក) មានការកើនឡើងចំនួន៦៣ ០៤២ ០១០រៀល (១៥ ៥៦៦ដុល្លារអាមេរិក) ស្មើនឹង ៤,៤៩%។ ការកើនឡើងនេះដោយសារការផ្អាកពិន័យទៅលើក្រុមហ៊ុនមួយចំនួនដែលយឺតយាវក្នុងការបង់ពន្ធ។

ក្នុងការអភិវឌ្ឍដំណាំកៅស៊ូ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកៅស៊ូ) បានអនុវត្តអនុកម្មវិធីចំនួន៦ ដែលរួមមាន៖

១.អនុកម្មវិធីទី១.១១៖ ជំរុញការវិនិយោគនិងអភិវឌ្ឍន៍ដំណាំកៅស៊ូប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ និងចីរភាព

- ១.១១.១ ផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារនិងមន្ត្រីបង្គោល
- ១.១១.២ ចងក្រងនិងពង្រឹងសហគមន៍កសិករកៅស៊ូគ្រួសារ
- ១.១១.៣ សិក្សាលក្ខណៈសម្បត្តិ (Profile) ចម្ការកៅស៊ូគ្រួសារ
- ១.១១.៤ ចុះពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។

២. អនុកម្មវិធីទី១.១២៖ ជំរុញខ្សែចង្វាក់តម្លៃកៅស៊ូឲ្យបានល្អ

- ១.១២.១ បណ្តុះបណ្តាលនិងផ្សព្វផ្សាយពីទីផ្សារកៅស៊ូដល់សហគមន៍កៅស៊ូគ្រួសារឲ្យបង្កើតមជ្ឈមណ្ឌលលក់ដូរកៅស៊ូរួម
- ១.១២.២ ផ្តល់ព័ត៌មានពីការផ្គត់ផ្គង់តម្រូវការនិងតម្លៃកៅស៊ូដល់ប្រតិបត្តិករកៅស៊ូ។

៣. អនុកម្មវិធីទី១.១៣: លើកកម្ពស់គុណភាពផលិតផលកៅស៊ូ

- ១.១៣.១ ផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូ
- ១.១៣.២ ផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក (USS) ដល់សហគមន៍កៅស៊ូគ្រួសារ។

៤. អនុកម្មវិធីទី១.១៤: លើកកម្ពស់ការគ្រប់គ្រងនិងបណ្តុះបណ្តាលធនធានមនុស្សក្នុងផ្នែកកៅស៊ូ

- ១.១៤.១ រៀបចំសេចក្តីព្រាងច្បាប់កៅស៊ូនិងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់
- ១.១៤.២ ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធវិស័យកៅស៊ូ
- ១.១៤.៣ បណ្តុះបណ្តាលសមត្ថភាពជំនាញដល់ប្រតិបត្តិករកៅស៊ូ។

៥. អនុកម្មវិធីទី១.១៥: ពង្រឹងការកសាង ការអនុវត្តផែនការ និងអភិបាលកិច្ចក្នុងវិស័យកៅស៊ូ

- ១.១៥.១ តាមដានវឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាព
- ១.១៥.២ តាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគសម្បទានដីសេដ្ឋកិច្ចលើវិស័យកៅស៊ូ
- ១.១៥.៣ គាំទ្រការសម្របសម្រួលការងារនិងរៀបចំប្រជុំបូកសរុបការងារ។

៦. អនុកម្មវិធីទី១.១៦៖ លើកកម្ពស់គុណភាពការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ

- ១.១៦.១ សិក្សាស្រាវជ្រាវក្នុងការបង្កាត់និងជម្រើសពូជ គ្រប់គ្រងច្បារពូជ និងអភិវឌ្ឍក្លូនកៅស៊ូប្រកបដោយប្រសិទ្ធភាពនិងបន្សាំបម្រែបម្រួលអាកាសធាតុក្នុងលក្ខខណ្ឌប្រទេសកម្ពុជា
- ១.១៦.២ សិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកទេសកសិកម្មល្អ ក្នុងការដាំដុះនិងថែទាំដំណាំកៅស៊ូទាំងមុននិងក្រោយការប្រមូលផល
- ១.១៦.៣ សិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកទេសប្រមូលផលជ័រកៅស៊ូ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនៃការលូតលាស់ក្នុងវដ្តសេដ្ឋកិច្ចដំណាំកៅស៊ូ
- ១.១៦.៤ ធ្វើតេស្តបញ្ជាក់គុណភាពកៅស៊ូអន្តរមន្ទីរពិសោធន៍ជាមួយIRA បណ្តាមន្ទីរពិសោធន៍ក្នុងស្រុក និងចុះត្រួតពិនិត្យរោងចក្រ CSR និង Lab CSR
- ១.១៦.៥ ទទួលធ្វើសវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យទទួលស្គាល់ជាអន្តរជាតិ វិភាគទានIRRDB និងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ។

ការអនុវត្តថវិកាប្រចាំឆ្នាំ (លើកលែងថវិកាស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា) សម្រាប់ការអភិវឌ្ឍដំណាំកៅស៊ូក្នុងរយៈពេល៧ឆ្នាំនេះ គិតពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៧ មានការកើនឡើងជាលំដាប់ក្នុងកម្រិតប្រមាណ៨,៦% ក្នុង១ឆ្នាំ។ បើធៀបនឹងថវិកាអនុម័ត ការអនុវត្តថវិកាក្នុងរយៈពេល៨ឆ្នាំ សម្រេចបានពី៩៥%ទៅ ១១៥%។ ការចំណាយខ្ពស់ដល់ទៅ១១៥% នេះ បណ្តាមកពីបង្កើនប្រាក់បៀវត្ស ដែលនាំឱ្យមានការចំណាយលើសនៃបន្ទុកបុគ្គលិក ប៉ុន្តែជារួម កម្រិតអនុវត្តផែនការថវិកាទាំងនេះ អាចចាត់ទុកថាបានអនុវត្តក្នុងកម្រិតល្អ (ក្រាហ្វិកទី៥)។




## គ. ការងារផ្សព្វផ្សាយនិងបណ្តុះបណ្តាល

ក្នុងគម្រោងថវិកាកម្មវិធីនៅក្នុងឆ្នាំ២០១៧នេះ បានចុះបើកវគ្គផ្សព្វផ្សាយ បណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដូចជា៖

**(១)ការបណ្តុះបណ្តាលជំនាញចៀរជ័រដល់កសិករកៅស៊ូគ្រួសារ**

ចុះបើកវគ្គបណ្តុះបណ្តាលការបើកមុខចៀរដំបូង និងបច្ចេកទេសចៀរជ័រកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារនៅខេត្តគោលដៅចំនួន០៦ខេត្ត គឺ ខេត្តសៀមរាប ឧត្តរមានជ័យ ត្បូងឃ្មុំ ព្រៃវែង រតនគិរី និងមណ្ឌលគិរី បានចំនួន ០៦វគ្គ ដោយមានកសិករចូលរួមសរុប៣០១នាក់ ក្នុងគម្រោងសរុប២៧០នាក់(៤៥នាក់/វគ្គ)។ វគ្គបណ្តុះបណ្តាលនេះ កសិករបានទទួលចំណេះដឹងទាំងមេរៀនទ្រឹស្តី និងការអនុវត្តចៀរជ័រលើដើមកៅស៊ូជាក់ស្តែងនៅនឹងកន្លែង សំដៅឲ្យការយកផលរបស់ពួកគាត់មានរយៈពេលយូរអង្វែង ទទួលបានទិន្នផលខ្ពស់ និងត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសចៀរជ័រកៅស៊ូ។

**(២) ការងារផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ**

- ចុះបើកវគ្គផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ នៅខេត្តគោលដៅទាំង៨ គឺបាត់ដំបង ប៉ៃលិន រតនគិរី ស្ទឹងត្រែង សៀមរាប ឧត្តរមានជ័យ មណ្ឌលគិរី និងក្រចេះ ដោយមានកសិករចូលរួមសរុប ៤១៣នាក់ ។ កសិករដែលបានចូលរួមទទួលបានឯកសារមេរៀន និងស្តាប់ការធ្វើបទបង្ហាញរបស់វាគ្មិន និងឆ្លើយបំភ្លឺរាល់ចម្ងល់និងសំណួរនានាតាមមេរៀននីមួយៗ ដើម្បីឲ្យកសិករអ្នកដាំកៅស៊ូ និងមានបំណងដាំកៅស៊ូទទួលបានចំណេះដឹងនេះយកទៅអនុវត្តលើការជ្រើសរើសពូជ ការងារដាំដុះនិងថែទាំ ការព្យាបាលជំងឺ និងការបើកមុខចៀរដំបូងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស សំដៅឱ្យទទួលបានលទ្ធផលល្អ
- ចុះបើកវគ្គបណ្តុះបណ្តាលចំនួន០៦វគ្គ ស្តីអំពីជំនាញផលិតកម្មកៅស៊ូ ដែលមានកសិករកៅស៊ូគ្រួសារចូលសរុបចំនួន៣៨៥នាក់

- ចុះបើកវគ្គផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក (USS) ដល់សហគមន៍កៅស៊ូគ្រួសារ ចំនួន០៦លើក នៅខេត្តគោលដៅចំនួន ០៦ គឺបាត់ដំបង កំពង់ធំ ព្រះវិហារ ស្ទឹងត្រែង មណ្ឌលគិរី និងរតនគិរី ដោយមានម្ចាស់កៅស៊ូគ្រួសារចូលរួមចំនួន៣០១នាក់ (៥០នាក់/គម្រោង) ។

**(៣) ការងារពង្រឹង និងចងក្រងសហគមន៍កសិករកៅស៊ូគ្រួសារ**

- ចងក្រងបង្កើតសហគមន៍កសិករកៅស៊ូគ្រួសារនៅខេត្តគោលដៅបានចំនួន០២សហគមន៍រួមមាន ខេត្តបាត់ដំបងនិងប៉ៃលិន។ ការបង្កើតសហគមន៍នេះ គឺដើម្បីលើកកម្ពស់អំណាចចរចាទីផ្សាររបស់ប្រជាកសិករ កាត់បន្ថយថ្លៃដើមផលិតកម្មកសិកម្មរបស់ប្រជាកសិករជាសមាជិកសហគមន៍ ផលិតកសិផលឬផ្តល់សេវាកម្មណាដែលកសិករម្នាក់ៗមិនអាចធ្វើបាន ទទួលបានព័ត៌មានទីផ្សារ និងពង្រីកឱកាសទីផ្សារកសិផលរបស់កសិករ លើកកម្ពស់គុណភាពកសិផលឬផលិតផលរបស់កសិករ និងបង្កើនប្រាក់ចំណូលគ្រួសាររបស់កសិករជាសមាជិកសហគមន៍។

- ចុះពង្រឹងសហគមន៍កសិករកៅស៊ូគ្រួសារបានចំនួន៤សហគមន៍ នៅខេត្តគោលដៅចំនួន០៤គឺ ខេត្តក្រចេះ ត្បូងឃ្មុំ ព្រះវិហារ និងស្ទឹងត្រែង។

**(៤) ការងារផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូ**

- ចុះបើកវគ្គផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូចំនួន០២លើក នៅខេត្តគោលដៅចំនួន០២ គឺត្បូងឃ្មុំនិងកំពង់ចាម ដល់ម្ចាស់រោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូ ដោយមានម្ចាស់រោងចក្រ សិប្បកម្មចូលរួមសរុបចំនួន១២០នាក់។

- វគ្គបណ្តុះបណ្តាលស្តីពីការកែច្នៃ និងការវិភាគគុណភាពជ័រ ដល់បុគ្គលិកមន្ទីរពិសោធមូលដ្ឋាន និងបណ្តារោងចក្រក្រុមហ៊ុនចម្ការកៅស៊ូចំនួន៣ក្រុមហ៊ុន ស្មើនឹង៣០នាក់

**(៥) ការងារបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់មន្ត្រីបង្គោល**

ចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូបានចំនួន០៥វគ្គ ដល់មន្ត្រីកសិកម្មខេត្ត (គ្រោង២០នាក់/១គម្រោង) នៅខេត្តគោលដៅ៖ ខេត្តមណ្ឌលគិរី រតនគិរី បាត់ដំបង ប៉ៃលិន និងខេត្តព្រះសីហនុ ដោយមានមន្ត្រីកសិកម្មខេត្តចូលរួមសរុបចំនួន១១២នាក់។ វគ្គបណ្តុះបណ្តាលនេះ សំដៅបង្កើនសមត្ថភាពយល់ដឹងដល់មន្ត្រីកសិកម្មខេត្តឲ្យក្លាយជាមន្ត្រីបង្គោលលើជំនាញកៅស៊ូ និងក្លាយជាអ្នកផ្សព្វផ្សាយបន្តដល់អ្នកដាំកៅស៊ូ ជាពិសេសកសិករកៅស៊ូគ្រួសារ ដើម្បីជំរុញអភិវឌ្ឍន៍ដំណាំកៅស៊ូប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់និងចីរភាព។

**(៦) ការងារបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីរាជការនិងនិយោជិតចម្ការកៅស៊ូកសិឧស្សាហកម្ម**

- បើកវគ្គបណ្តុះបណ្តាលស្តីពីស្ថានភាពឧស្សាហកម្មកៅស៊ូធម្មជាតិពិភពលោកដល់មន្ត្រីរាជការ ចំនួន១លើក ដោយមានអ្នកចូលរួមសរុប៤០នាក់

- បើកវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីប្រមូលទិន្នន័យស្ថិតិនិងព័ត៌មានកៅស៊ូ ដោយមានអ្នកចូលរួម៤០នាក់

- បើកវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំថវិកាកម្មវិធីដល់មន្ត្រីរាជការចំនួន១លើក ដោយមានអ្នកចូលរួមសរុប២៥នាក់

- បើកវគ្គបណ្តុះបណ្តាលសមត្ថភាពជំនាញដល់មន្ត្រីរាជការចំនួន២លើក ដោយមានអ្នកចូលរួមសរុប៥៥នាក់

- វគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយពីវិធានការបង្កើនថ្លៃកៅស៊ូធម្មជាតិក្នុងស្រុកដល់សហគមន៍កសិករកៅស៊ូគ្រួសារ បានចំនួន៦លើក នៅខេត្តគោលដៅចំនួន៤ គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៣០០នាក់។

- សិក្ខាសាលាផ្សព្វផ្សាយស្តីពីវិធានការពង្រឹងការគ្រប់គ្រងវិស័យកៅស៊ូធម្មជាតិ នៅសាលាខេត្តត្បូងឃ្មុំ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធសរុបចំនួន១៧០នាក់

- សិក្ខាសាលាថ្នាក់ជាតិស្តីអំពី "អនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជា សម្រាប់ឆ្នាំ២០១៨-២០២០" ដោយមានអ្នកចូលរួមសរុបចំនួន៥៨នាក់

- សិក្ខាសាលាអន្តរជាតិចំនួន០១លើក ក្រោមប្រធានបទ "ការផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូ" ដល់ផលិតករកៅស៊ូនិងកសិករកៅស៊ូគ្រួសារ ដោយមានអ្នកចូលរួមចំនួន១៦៩នាក់ និង

- ចូលរួមព្រឹត្តការណ៍សំខាន់ៗថ្នាក់អន្តរជាតិ ដែលទាក់ទងនឹងឧស្សាហកម្មកៅស៊ូធម្មជាតិ។

## គ. ការងារពិសោធន៍ស្រាវជ្រាវកៅស៊ូ

- បាននិងកំពុងអនុវត្តលើការស្រាវជ្រាវរួមមាន៖ (១) ស្រាវជ្រាវបង្កាត់ពូជ តាមដាន បញ្ចូលទិន្នន័យគ្រប់ឡូត៍ពិសោធន៍ក្លូនទាំងនៅខាងក្នុងនិងខាងក្រៅស្ថានីយ៍ចំនួន៥៩ (២) ការស្រាវជ្រាវអំពីការដាំដុះនិងការពារ ដោយតាមដាននិងប្រមូលទិន្នន័យនៃឥទ្ធិពលនៃដំណាំគម្រប ជី ដង់ស៊ីតេដាំ ប៉ារ៉ាម៉ែត្រក្បៀត្របរិស្ថាន ទៅលើការលូតលាស់និងទិន្នផលដើមកៅស៊ូ និង (៣) តាមដាន ស្រង់ បញ្ចូល និងវិភាគទិន្នន័យសរីរវិទ្យាទឹកជ័រ បាន៤៦៤សំណាក។

-បាននិងកំពុងអនុវត្តផ្នែកមន្ទីរពិសោធន៍យថាប្រភេទរួមមាន៖ (១) ធ្វើតេស្តវិភាគសំណាកយថាប្រភេទចំនួន៦៥១ភាគសំណាក ដើម្បីបញ្ជាក់គុណភាពកែច្នៃរបស់រោងចក្រCSR និងពិនិត្យគុណភាពកៅស៊ូប្រភេទRSS (២) ការរៀបចំធ្វើតេស្ត និងរបាយការណ៍វិភាគលទ្ធផលនៃការធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុកចំនួន៤លើក ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍មូលដ្ឋាន សម្រាប់ឈានទៅការទទួលស្គាល់ជាផ្លូវការ, (៣) ធ្វើតេស្តអន្តរមន្ទីរពិសោធន៍ជាមួយ IRA បានចំនួន២លើក ដើម្បីទទួលស្គាល់ជាមន្ទីរពិសោធន៍យោងនៅក្នុងតំបន់ ចំពោះកៅស៊ូ TSR និង(4) ចុះត្រួតពិនិត្យនិងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូTSR និងមន្ទីរពិសោធន៍មូលដ្ឋាននៃក្រុមហ៊ុនស៊ីសវីសសស់ខេមបូឌា (លីមីធីត) ចម្ការកៅស៊ូស្នួល (ចំនួន០២លើក ក្រុមហ៊ុនស៊ីហ្វារ៉ាប់បើរ លីមីតធីត) ចម្ការកៅស៊ូឡាបានសៀក ខេត្តរតនគីរីចំនួន១លើក និងរោងចក្រកែច្នៃកៅស៊ូស៊ីធីរ៉ាប់បើរ ខូអិលធីឌី ចំនួន០២លើក ក្នុងគោលបំណងផ្តល់ការអនុញ្ញាតសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និងការទទួលស្គាល់ជាផ្លូវការមន្ទីរពិសោធន៍មូលដ្ឋានពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

## ឃ. ការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកកៅស៊ូ

ក្រសួងដែលមានអគ្គនាយកដ្ឋានកៅស៊ូជាសេនាធិការ បាននិងកំពុងរៀបចំចងក្រងសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូដែលបានចាប់ផ្តើមដំណើរការចាប់តាំងពីឆ្នាំ២០១០មករហូតដល់បច្ចុប្បន្ននេះ។ បន្ទាប់ពីបានបញ្ជូនត្រឡប់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បច្ចុប្បន្នសេចក្តីព្រាងច្បាប់ កំពុងត្រូវបានបន្តពិនិត្យ ពិភាក្សាបន្ថែមទៀតនៅអគ្គនាយកដ្ឋានកៅស៊ូនិងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រៅពីសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ ក្នុងឆ្នាំ២០១៧ បានចេញប្រកាសលេខ១៨០ ប្រក.កសក.ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីនីតិវិធីនៃការគ្រប់គ្រងស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ ។

## ង. ការងារសហប្រតិបត្តិការអន្តរជាតិផ្នែកកៅស៊ូ

### ង.១ សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ(ANRPC)

ព្រះរាជាណាចក្រកម្ពុជា ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចូលជាសមាជិកពេញសិទ្ធិក្នុងសមាគមANRPC នាថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ ហើយកម្ពុជាក៏ជាប្រធានសមាគម ANRPC សម្រាប់ឆ្នាំ២០១៥-២០១៦នេះផងដែរ។ ឆ្នាំ២០១៧នេះ កម្ពុជាបានចូលរួមសន្និសីទ កិច្ចប្រជុំ និង សន្និបាតប្រចាំឆ្នាំ២០១៧របស់ANRPC រយៈពេល៥ថ្ងៃ គឺចាប់ពីថ្ងៃទី២៣ដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម។ ព្រឹត្តការណ៍ដ៏សំខាន់ទាំងនេះ ប្រព្រឹត្តទៅប្រកបដោយភាពរលូនល្អនិងជោគជ័យ ដោយមានអ្នកចូលរួមជាច្រើន ដូចជា៖ អ្នកដាំដុះ អ្នកកែច្នៃ ពាណិជ សេដ្ឋវិទូនិងកម្មន្តសាលករ។

ក្រៅពីនេះបាន៖ (១) ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការស្រាវជ្រាវនិងការវិភាគទីផ្សារកៅស៊ូធម្មជាតិ នៅទីក្រុងគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី រយៈពេល៤ថ្ងៃ ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ (២) ចូលរួមកិច្ចប្រជុំលើកទី៤របស់ក្រុមជំនាញ ANRPC ផ្នែកស្ថិរភាពវូនីយកម្មតម្លៃកៅស៊ូពិភពលោក នៅប្រទេសថៃ រយៈពេល

បីថ្ងៃចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧, និង(៣) ចូលរួមសិក្ខាសាលាស្តីពី ការផ្គត់ផ្គង់ តម្រូវការ និងការធ្វើម៉ូឌែលឧស្សាហកម្មកៅស៊ូធម្មជាតិ នៅប្រទេសហ្វីលីពីន រយៈពេលបួនថ្ងៃ ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧។

### ង.២ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB: International Rubber Research and Development Board )

គឺជាបណ្តាញស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ ដែលប្រមូលផ្តុំរាល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូធម្មជាតិស្ទើរតែគ្រប់ប្រទេសផលិតកៅស៊ូធម្មជាតិទាំងអស់ ដែលមាន៩៥%នៃបរិមាណផលិតផលកៅស៊ូធម្មជាតិ នៅក្នុងពិភពលោក បានកើតឡើងតាំងពីឆ្នាំ១៩៣៤។ កម្ពុជាបានចូលជាសមាជិកទី១៦នៃក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិក្នុងសម័យប្រជុំប្រចាំឆ្នាំរបស់ខ្លួនកាលពីថ្ងៃទី២៧-២៨ខែកញ្ញាឆ្នាំ២០០១ នៅទីក្រុង Montpellier នៃសាធារណរដ្ឋបារាំង។ ឆ្នាំ២០១៧នេះ កម្ពុជាបាន៖ (១) បើកសិក្ខាសាលាអន្តរជាតិ ការផ្ទេរបច្ចេកវិទ្យាដល់ផលិតករកៅស៊ូ និងកសិករកៅស៊ូគ្រួសារ (២) ចូលរួមសិក្ខាសាលានៅប្រទេសថៃ ចំនួន០១លើក (៣)ចូលរួមសន្និសីទនិងកិច្ចប្រជុំប្រចាំឆ្នាំនៃក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB International Rubber Conference and IRRDB Annual Meeting) នៅប្រទេសឥណ្ឌូណេស៊ីចំនួន០១លើក (៤) ចូលរួមសិក្ខាសាលានៅប្រទេសម៉ាឡេស៊ីចំនួន០១លើក និង(៥) ចូលរួមវគ្គបណ្តុះបណ្តាលខ្លីនៅប្រទេសហ្វីលីពីន។ ចំពោះកម្មវិធីប្តូរក្លូនពហុភាគីរវាងប្រទេសជាសមាជិកIRRDB ក្រោយពីកម្ពុជា បានផ្ញើមែកពូជCMS ចំនួន០៥ក្លូនទៅឱ្យប្រទេសឥណ្ឌានិងថៃ កម្ពុជាបានទទួលក្លូនកៅស៊ូចំនួន០៥ក្លូនពីប្រទេសឥណ្ឌា និង០៥ក្លូនទៀតពីប្រទេសថៃ។

### ង.៣ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD: Agence Fran–aise de D‶veloppement)

ជាមួយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងបន្តអនុវត្តគម្រោងធម្មយាមកម្មច្បារពូជដែលបានបង្កើតតាមអនុសញ្ញាហិរញ្ញប្បទាន CKH 1123 01 H ចុះហត្ថលេខាកាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២ រវាងព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ។ ក្នុងឆ្នាំ២០១៧នេះ សកម្មភាពគម្រោងដែលបានអនុវត្ត មាន៖ (១) ការផ្តល់វិញ្ញាបនបត្រច្បារពូជកៅស៊ូ (២) ការបង្កើតច្បារពូជសមុច្ច័យ និងច្បារពូជយោង (៣) ការធ្វើវិភាគADN ទៅលើច្បារពូជ និង(៤) ការត្រួតពិនិត្យច្បារពូជដែលបានចុះបញ្ជីរួច។ ក្រៅពីនេះ គម្រោងសិក្សាអំពីលទ្ធភាពអាចធ្វើបានដំណាក់កាលទី២ នៃគម្រោងស្តីពីការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារនៅកម្ពុជានៅខេត្តគោលដៅចំនួន០២ គឺខេត្តរតនគីរី និងបាត់ដំបង។ គោលបំណងសំខាន់នៃគម្រោងស្តីពីការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារនៅកម្ពុជា មាន៖

១. ធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅតាមទីតំបន់ជនបទតាមរយៈការបង្កើតការងារដល់គ្រួសារកសិករ។
២. បង្កើនប្រភពប្រាក់ចំណូលដែលបានមកពីការធ្វើអាជីវកម្មកៅស៊ូដល់កសិករ និងជួយកាត់បន្ថយភាពក្រីក្រនៅតាមជនបទ។
៣. បង្កើតប្រភពប្រាក់ចំណូលដល់ខឿនសេដ្ឋកិច្ចជាតិតាមរយៈការនាំចេញផលិតផលកៅស៊ូ។
៤. ការពារបរិស្ថានទល់នឹងភាពហួតហែងក្តៅខ្លាំងនៃធម្មជាតិ និងទប់ស្កាត់ការហូរច្រោះដី។

### ង.៤ កិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យអន្តរជាតិ

ក្នុងការសិក្សានិងស្រាវជ្រាវអំពីក្បែត្របរិស្ថានដំណាំកៅស៊ូ បានសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យអន្តរជាតិ រួមមាន៖ (១) បានចូលរួមសហការជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Nagoya នៃប្រទេសជប៉ុន ក្នុងការថែទាំ និងជួសជុលឧបករណ៍ Sap flow, CO2 profile នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (២) សហការការងារជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Kuyshu ដើម្បីស្រាវជ្រាវអំពីរស្មីសំយោគនៅស្លឹកកៅស៊ូ(leaf photo-synthesis) និង (៣) សហការការងារជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Hawaii សហរដ្ឋអាមេរិក ដើម្បីថែទាំនិងជួសជុលឧបករណ៍Flux Tower នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

### ៦.៥ កិច្ចសហប្រតិបត្តិការជាមួយក្រសួងកសិកម្មនៃសាធារណរដ្ឋប្រជាមានិតចិន

-បានបញ្ជូនសំណើគម្រោងចំនួន៥៖ (១) គម្រោងពង្រឹងកិច្ចដំណើរការរបស់ការិយាល័យកៅស៊ូនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមខេត្ត (២) គម្រោងគ្រប់គ្រងចម្ការកៅស៊ូគ្រួសារតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រGIS នៅ ១៩ខេត្ត (៣) គម្រោងបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកៅស៊ូ (៤)គម្រោងទស្សនៈកិច្ចសិក្សា ផ្លាស់ប្តូរបទពិសោធន៍ និង(៥) គម្រោងជំនួយឧបត្ថម្ភគាំទ្រហិរញ្ញប្បទាន

- បានបញ្ជូនមន្ត្រីចំនួន០១នាក់ទៅបណ្តុះបណ្តាលរយៈពេល១០ថ្ងៃ អំពីការគ្រប់គ្រងនិងការអភិរក្សផ្នែកកេរ្តិ៍តំណែលកសិកម្ម តាមផ្លូវ១ ខ្សែក្រវ៉ាត់១ (Management and Conservation of Agriculture Heritage Sitefor Countries along the Belt and Road)

- បានបញ្ជូនមន្ត្រីចំនួន០១នាក់ទៅបណ្តុះបណ្តាលរយៈពេល០១ខែអំពីការដាំដុះកៅស៊ូដែលមានទិន្នផលខ្ពស់។

### ៦.៦ ផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូនៅក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ វៀតណាម

បានប្រជុំនិងពិភាក្សាឡើងវិញលើឯកសារពាក់ព័ន្ធនឹងផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូ នៅតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា វៀតណាម ឡាវ ដើម្បីត្រៀមដាក់ជូនកិច្ចប្រជុំកំពូលថ្នាក់នាយករដ្ឋមន្ត្រីលើកទី១០ ដែលគ្រោងប្រព្រឹត្តនៅប្រទេសវៀតណាម ឆ្នាំ២០១៨។

ក្រៅពីកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌនៃក្រសួងកសិកម្ម (អគ្គនាយកដ្ឋានកៅស៊ូ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា) ខាងលើ, សមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា ក៏បានចូលជាសមាជិកពេញសិទ្ធនៃសមាគមកៅស៊ូអន្តរជាតិ (International Rubber Association: IRA) និងក្រុមប្រឹក្សាធុរកិច្ចកៅស៊ូអាស៊ាន (Asian Rubber Buiness Council: ARBC) ផងដែរ។

## ២. ការជំរុញផលិតកម្មសត្វ និងសុខភាពសត្វ

អនុវិស័យផលិតកម្មសត្វ និងសុខភាពសត្វ មានសក្តានុពលក្នុងការរួមចំណែកកំណើនសេដ្ឋកិច្ច ការងារ សន្តិសុខស្បៀង អាហារូបត្ថម្ភ និងកាត់បន្ថយគម្លាតចំណូលរវាងអ្នកទីក្រុងនិងអ្នកជនបទ។ ដោយទទួលស្គាល់នូវតម្លៃនៃអនុវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលដៅជំរុញលើកកម្ពស់ការចិញ្ចឹមសត្វឲ្យកាន់តែទូលំទូលាយថែមទៀត តាមរយៈការបង្កើតក្របខ័ណ្ឌគោលនយោបាយ ដោយផ្អែកលើខ្សែចង្វាក់តម្លៃ ដើម្បីដោះស្រាយជាកញ្ចប់នូវបញ្ហាជាឧបសគ្គដល់ការអភិវឌ្ឍអនុវិស័យនេះ និងគិតគូរផងដែរដល់បញ្ហាសុវត្ថិភាព ចំណីអាហារ និងកិច្ចដំណើរការទីផ្សារ ពិសេសអនាម័យសត្វ សាច់ និងផលិតផលមានដើមកំណើតពីសត្វ។

ដើម្បីសម្រេចបានគោលដៅជំរុញលើកកម្ពស់ចលនាចិញ្ចឹមសត្វ ក្រសួងបានខិតខំយកចិត្តទុកដាក់ពង្រឹងសមត្ថភាព រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ពង្រឹងនិងបង្កើនការផ្តល់សេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។ ជាលទ្ធផល ក្នុងរយៈពេល២ឆ្នាំកន្លងទៅនេះ ក្រសួងសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វឆ្នាំ២០១៦-២០២៥ បានអនុម័តឲ្យអនុវត្តនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦។ ចក្ខុវិស័យនៃក្របខ័ណ្ឌផែនការនេះ គឺការអភិវឌ្ឍវិស័យបសុសត្វប្រកបដោយនិរន្តរភាព។ ក្រសួងខិតខំជំរុញឱ្យមានការអនុវត្តសុខភាពសត្វនិងផលិតកម្មសត្វល្អ តាមរយៈការអភិវឌ្ឍធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ការស្រាវជ្រាវនិងផ្សព្វផ្សាយ ការរៀបចំគោលនយោបាយ និងពង្រឹងការអនុវត្តច្បាប់ អភិវឌ្ឍន៍ភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន។

ចំណុចគន្លឹះពាក់ព័ន្ធនឹងអនុវិស័យសុខភាពសត្វនិងផលិតកម្មសត្វ គឺការតម្រង់ទិសការអភិវឌ្ឍការចិញ្ចឹមសត្វជាលក្ខណៈប្រមូលផ្តុំ ដែលមានសក្តានុពលសម្រាប់កែច្នៃប្រើប្រាស់ក្នុងស្រុកនិងនាំចេញ។ យន្តការគន្លឹះដែលបានយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍនេះគឺ ការសម្របសម្រួល និងការលើកទឹកចិត្តវិស័យឯកជន ក្នុងការអភិវឌ្ឍបច្ចេកទេសកែច្នៃបសុសត្វ ស្របតាមស្តង់ដារផលិតផលអាស៊ាន និងតម្រូវការស្តង់ដារទីផ្សារអន្តរជាតិ។

ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានប្រកាសឱ្យប្រើប្រាស់នាថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦។ ការកែទម្រង់រចនាសម្ព័ន្ធនានាត្រូវបានអនុវត្តក្រោមច្បាប់នេះ។ ផ្អែកតាមសំណើរបស់ក្រសួង រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចឱ្យដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ (អនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦)។ នេះគឺពិតជាការកែទម្រង់មួយដ៏ធំ ក្នុងរចនាសម្ព័ន្ធគ្រប់គ្រងផ្នែកសុខភាពសត្វនិងផលិតកម្មសត្វ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ដើម្បីពង្រឹងការងារសុខភាពសត្វនិងផលិតកម្មសត្វ ក្រសួងបានចេញសេចក្តីជូនដំណឹង សារាចរណែនាំ ដល់គ្រប់អ្នកពាក់ព័ន្ធ ដើម្បីអនុវត្តឱ្យស្របតាមវិធាននៃច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ។ សេចក្តីជូនដំណឹងស្តីពីលក្ខខណ្ឌតម្រូវនៃការនាំចូលសត្វរស់ សាច់សត្វ និងផលិតផលសត្វពីបរទេស ត្រូវបានដាក់ចេញឱ្យអនុវត្តដោយក្រុមហ៊ុនទាំងអស់កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧។

ក្រុមការងារបច្ចេកទេសភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (Antimicrobial Resistance-AMR) ត្រូវបានបង្កើតឡើង ដើម្បីទប់ស្កាត់ កំណត់ហានិភ័យ អនុលោមទៅតាមគោលការណ៍នៃអង្គការសុខភាពសត្វពិភពលោក។ សេចក្តីណែនាំស្តីពីការចាត់វិធានការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ពិសេសបក្សីនិងផលិតផលបក្សី ត្រូវបានផ្សព្វផ្សាយឱ្យអនុវត្តដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (សេចក្តីណែនាំលេខ៤២៨ សផស ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨)។

នីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម ចាំបាច់ត្រូវរៀបចំនិងដាក់ឱ្យអនុវត្ត ស្របតាមច្បាប់ដែលតម្រូវឱ្យប្រតិបត្តិ។ ពាក់ព័ន្ធនឹងកិច្ចការនេះ ក្រសួងបានចេញប្រកាសស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨។

ដោយពិនិត្យឃើញអំពីភាពផ្តាច់មុខលើការធ្វើអាជីវកម្មសត្តឃាតដ្ឋាន ការឃុបឃិតគ្នាក្នុងចំណោមអាជីវករពិឃាតសត្វ អ្នកលក់ដុំនិងលក់រាយធ្វើការកំណត់ថ្លៃ និងភាពផ្តាច់មុខលើការធ្វើអាជីវកម្ម ព្រមទាំងការអនុវត្តច្បាប់ការគ្រប់គ្រងរបស់អាជ្ញាធរមានសមត្ថកិច្ចនៅមានកម្រិត ដែលកត្តាទាំងអស់នេះ បង្កឱ្យមានការបូកថ្លៃបន្ថែមខ្ពស់នៅគ្រប់ដំណាក់កាល នៃខ្សែចង្វាក់ផលិតកម្មនិងអាជីវកម្ម និងបានធ្វើឱ្យមានអត្រាអតិផរណាម្ហូបអាហារកើនឡើង ប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញសារាចរណែនាំស្តីពីការចាត់វិធានការពង្រឹងការគ្រប់គ្រងអាជីវកម្មសត្វ និងបានប្រកាសដាក់ឱ្យប្រើប្រាស់ក្នុងគោលដៅពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្មសត្វឱ្យមានប្រសិទ្ធភាពខ្ពស់ អនុលោមតាមលក្ខខណ្ឌបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ២.១. ការងារផលិតកម្មសត្វ

ផលិតកម្មសត្វ គ្រប់ប្រភេទមានការកើនឡើងជាលំដាប់ ជាពិសេសផលិតកម្មសត្វសម្រាប់ធ្វើពាណិជ្ជកម្ម។ ស្ថិតិសត្វចិញ្ចឹមគ្រប់ប្រភេទសរុបកើនដល់ ៤២,៨៣លានក្បាល ក្នុងឆ្នាំ២០១៧ ដែលអាចផ្គត់ផ្គង់ជាសាច់សម្រាប់តម្រូវការក្នុងស្រុកប្រមាណ ២៩៨ ១៥៨តោន នៃតម្រូវការសរុបប្រចាំឆ្នាំ ៣២៧ ២៩២តោន ក្នុងឆ្នាំ២០១៧ ដោយមិនគិតបញ្ចូលតម្រូវការសម្រាប់ភ្ញៀវទេសចរណ៍នៅឡើយ។

### ក. ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ

ស្ថិតិក្នុងរយៈពេល៥ឆ្នាំបង្ហាញថា ផលិតកម្មជ្រូកមានកំណើនពី ២,០៧លានក្បាល ដល់ ២,៣៣ (១៣%) សត្វស្លាបមានកំណើនពី ២១,៤លានក្បាល ដល់ ២៨,៧លានក្បាល(៣៤%) ប៉ុន្តែគោ ក្របីមានការថយចុះក្នុងរង្វង់ ១៤% ពី ៤លានក្បាល មក ៣,៥លានក្បាល។ បើប្រៀបធៀបឆ្នាំ២០១៦ ផលិតកម្មសត្វលក្ខណៈគ្រួសារមានកំណើន ០,៧៤%។ ក្នុងនោះផលិតកម្មគោកើន៥៤ ពាន់ក្បាល (១,៨៧%) សត្វស្លាបកើន ២៥០ ពាន់ក្បាល (០,៩%) ប៉ុន្តែជ្រូកមានការថយចុះ ៤០ពាន់ក្បាល(១,៧%) ។

### តារាងស្ថិតិសត្វចិញ្ចឹមជាលក្ខណៈគ្រួសារ ឆ្នាំ២០១៣-២០១៧

| ប្រភេទសត្វ(ពាន់) | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ធៀប ២០១៧&២០១៦ |
|---|---|---|---|---|---|---|
| សត្វគោ | ៣ ៤២៦ | ៣ ០៥៣ | ២ ៩០៣ | ២ ៨៩៧ | ២ ៩៥១ | ១,៨៧ |
| សត្វក្របី | ៦១៩ | ៥៤២ | ៥០៦ | ៥២៣ | ៥០៨ | -២,៨៤ |
| សត្វគោ-ក្របី | ៤ ០៤៥ | ៣ ៥៩៥ | ៣ ៤១០ | ៣ ៤២០ | ៣ ៤៦០ | ១,២០ |
| កម្លាំងអូសទាញ | ១ ៣៤៥ | ១ ២៥០ | ១ ១៣២ | ១ ០៥២ | ៩៣៥ | -១១,០៧ |
| សត្វជ្រូក | ២ ០៦៨ | ២ ៣៦១ | ២ ៣៥៨ | ២ ៣៧១ | ២ ៣៣២ | -១,៧១ |
| សត្វស្លាប | ២១ ៤៣០ | ២៥ ៦៣០ | ២៦ ៦៤៩ | ២៨ ៤០២ | ២៨ ៦៥២ | ០,៨៨ |
| សរុប | ៣២ ៩៣២ | ៣៦ ៤៣១ | ៣៦ ៩៩៨ | ៣៨ ៦៦៦ | ៣៨ ៨៣៩ | ០,៧៤ |

## ខ. ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម

ស្ថិតិក្នុងរយៈពេល៥ឆ្នាំបង្ហាញថា បរិមាណសត្វចិញ្ចឹមគ្រប់ប្រភេទជាលក្ខណៈពាណិជ្ជកម្មមានកំណើន ២៧% ពី ៦,៦លានក្បាល ដល់ ៨,៤លានក្បាល។ ផលិតកម្មគោ ក្របីបានកើនឡើងបួនដង ពី ៥ពាន់ក្បាល ដល់ ២១ ពាន់ក្បាល ជ្រូកកើនពី ៣៧០ពាន់ក្បាល ដល់ ៧៤៣ពាន់ក្បាល និងសត្វស្លាបកើន ១,៤លានក្បាល។ បើធៀបទៅនឹងឆ្នាំ២០១៦ ផលិតកម្មជ្រូកមានកំណើន ២៤% សត្វស្លាបកើន ៣,៦% ដោយឡែកគោ ក្របី ថយចុះ ១២%។

### តារាងស្ថិតិសត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០១៣-២០១៧

| ប្រភេទសត្វ(ពាន់ក្បាល) | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ធៀប២០១៧&២០១៦ |
|---|---|---|---|---|---|---|
| សត្វគោ ក្របី | ៥ | ៦ | ១៣ | ២៣ | ២១ | -១២% |
| សត្វជ្រូក | ៣៧០ | ៣៧៥ | ៤១៧ | ៥៩៩ | ៧៤៣ | ២៤% |
| សត្វស្លាប | ៦ ១៩៥ | ៥ ៩៥៤ | ៧ ៨៣០ | ៧ ៣៣១ | ៧ ៥៩៣ | ៣,៦% |

## គ. សរុបផលិតកម្មជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្ម

ជារួមផលិតកម្មសត្វគ្រប់ប្រភេទ គិតចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ មានកំណើនជាលំដាប់ជារៀងរាល់ឆ្នាំពី ៣៤លានក្បាល ដល់ ៤២,៨៣លានក្បាល។ ហើយបើប្រៀបធៀបទៅនឹងឆ្នាំ២០១៦ គឺមានកំណើន ១,៥៤% ក្នុងនោះគោកើន ១,៧៦% ជ្រូកកើន ៣,៥% សត្វស្លាបកើន ១,៤% រីឯក្របីថយចុះ ២,៨% ដូចមានស្ថិតិលំអិតក្នុងតារាងខាងក្រោម។ ប៉ុន្តែបើប្រៀបធៀបនឹងសូចនាករនៃផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧-២០១៩ បរិមាណសត្វសរុបកើនលើសផែនការប្រចាំឆ្នាំ២០១៧ គឺកើន ៩,៣៤%។

គួរកត់សម្គាល់ថា ស្ថិតិក្របីបានថយចុះយ៉ាងខ្លាំង ដោយក្របីជាកម្លាំងអូសទាញត្រូវបានជំនួសដោយគ្រឿងយន្តកសិកម្ម និងកង្វះវាលស្មៅរួមនិងកំលាំងពលកម្ម។ ចំណែកឯការចិញ្ចឹមគោយកសាច់បានចាប់ផ្តើមមានកំណើនជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០១៦ ហើយដែលអាចព្យាករណ៍បានថានឹងបន្តកើនឡើង អាស្រ័យដោយតម្រូវការសាច់គោបន្តកើនឡើង ដែលដើរស្របគ្នាជាមួយកំណើនប្រាក់ចំណូលក្នុងមនុស្សម្នាក់ៗ។

### តារាងស្ថិតិសត្វចិញ្ចឹមសរុបទាំងលក្ខណៈគ្រួសារ និងលក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០១៣-២០១៧

| ប្រភេទសត្វ (ពាន់ក្បាល) | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ធៀប ២០១៧&២០១៦ |
|---|---|---|---|---|---|---|
| សត្វគោ | ៣ ៤៣១ | ៣ ០៦០ | ២ ៩១៧ | ២ ៩២០ | ២ ៩៧២ | ១,៧៦ % |
| សត្វក្របី | ៦១៩ | ៥៤២ | ៥០៦ | ៥២៤ | ៥០៩ | -២,៨៤% |
| សត្វជ្រូក | ២ ៤៣៧ | ២ ៧៣៦ | ២ ៧៧៦ | ២ ៩៧១ | ៣ ០៧៤ | ៣,៥ % |
| សត្វស្លាប | ២៧ ៤៧៣ | ៣១ ៥៨៤ | ៣៤ ៥១៩ | ៣៥ ៧៣៤ | ៣៦ ២៤៥ | ១,៤៣% |

ក្រាហ្វិក បង្ហាញអំពីការប្រៀបធៀបស្ថិតិសត្វចិញ្ចឹមសរុបពីឆ្នាំ២០១៣-២០១៧




## ឃ. ការប្រៀបធៀបបែបផែនផលិតកម្មតាមប្រភេទសត្វ

ទិសដៅអាទិភាពសម្រាប់ជំរុញផលិតកម្មសត្វ គឺការបង្កើនផលិតកម្មសត្វសម្រាប់ពាណិជ្ជកម្ម។ នៅឆ្នាំ២០១៧ ផលិតកម្មជ្រូកជាលក្ខណៈពាណិជ្ជកម្មមានកំណើនប្រមាណ ២៤% និងសត្វស្លាប(មាន់ស្រុក) ២១% ដែលជាការផ្លាស់ប្តូរបែបផែនផលិតកម្មជាវិជ្ជមាន ឈានទៅកែលម្អផលិតភាព និងមានប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែល្អប្រសើរ។

ក្រាហ្វិកប្រៀបធៀបស្ថិតិជ្រូកចិញ្ចឹមតាមបែបផែនផលិតកម្ម ៣ ឆ្នាំចុងក្រោយ ពីឆ្នាំ២០១៥-២០១៧




ក្រាហ្វិកប្រៀបធៀបស្ថិតិសត្វស្លាបចិញ្ចឹមតាមបែបផែនផលិតកម្ម៣ឆ្នាំចុងក្រោយ ពីឆ្នាំ២០១៥-២០១៧




## ២.២. តម្រូវការសត្វ និងសាច់ឆ្នាំ២០១៧

ផ្អែកតាមរបាយការណ៍នៃការបរិភោគសាច់និងផលិតផលសត្វ នៃអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ ការបរិភោគសាច់នៅកម្ពុជាក្នុងម្នាក់ជាមធ្យមគឺប្រមាណ ១៧,៥៩គីឡូក្រាមក្នុងមួយឆ្នាំ ដែលចែកជា៖ សាច់គោក្របី ៥គីឡូក្រាម សាច់ជ្រូក ៩,២៩គីឡូក្រាម សាច់បក្សី ៣,៣គីឡូក្រាម និងសាច់សត្វផ្សេងៗ បន្ទាប់បន្សំ។ ដូចនេះឆ្នាំ២០១៧ កម្ពុជាត្រូវការសាច់ ៣២៧ ២៩២តោន សម្រាប់ផ្គត់ផ្គង់ប្រជាជនប្រមាណ ១៦,៩លាននាក់ ដោយមិនទាន់រាប់បញ្ចូលភ្ញៀវទេសចរប្រមាណ ៥,៦លាននាក់នៅឆ្នាំ២០១៧។ ផលិតកម្មក្នុងស្រុកមានសមត្ថភាពផ្គត់ផ្គង់បានប្រមាណជា ២៩៨ ១៥៨តោន ស្មើនឹង ៩១% នៃតម្រូវការ គឺសាច់គោក្របី ៨១ ៩៦២តោន (0,៦៨

លានក្បាល) សាច់ជ្រូក ១៦៥ ៣៩៩តោន (៣,៣១លានក្បាល) និងសត្វស្លាប ៥១ ៣៧៨តោន (៤២,៤ លានក្បាល)។ បរិមាណដែលខ្វះបានត្រូវបំពេញបន្ថែមដោយការនាំចូលសត្វរស់ និងសាច់ ក្នុងនោះជ្រូករស់មានចំនួន ៤៦១ ៦៣៥ក្បាល និងបក្សី ៣ ៧១៩ ៨១៤ក្បាល និងសាច់៨៥៦ តោន(សាច់ជ្រូក មាន់ ទា គ្រូច និងគោ)។ ដោយឡែក កម្ពុជាបាននាំចេញ គោ ក្របី ជារៀងរាល់ឆ្នាំ។ នៅឆ្នាំ ២០១៧ បាននាំចេញប្រមាណ ១១ ២៤០ក្បាល និងសាច់ ៧តោន។

**តារាងតម្រូវការ ការផ្គត់ផ្គង់ និងការបំពេញបន្ថែមសត្វ និងសាច់សត្វឆ្នាំ២០១៧**

| ប្រភេទសត្វ | ផ្គត់ផ្គង់ក្នុងស្រុក | | | តម្រូវការនាំចូល | | | តម្រូវការ |
|---|---|---|---|---|---|---|---|
| | តោន | ពាន់ក្បាល | លានរៀល | តោន | ពាន់ក្បាល | លានរៀល | តោន |
| គោ ក្របី | ៨១ ៩៦១ | ៦៨៣ | ២.៤៥៨ ៨៣០ | ៤៥៩ | ៤ | ១៣ ៧៧០ | ៨២ ៤២០ |
| ជ្រូក | ១៦៥ ៣៦៤ | ៣ ៣០៧ | ១ ៩៨៤ ៣៦៨ | ២៣ ៣២២ | ៤៦៦ | ២៧៩ ៨៦៤ | ១៨៨ ៦៨៦ |
| ពពែ-ចៀម | ១៦១ | ៥ | ៤ ៨២២ | ៩ | ០.៣ | ២៧០ | ១៧០ |
| សត្វស្លាប | ៥០ ៦៧២ | ៤២ ២២៧ | ៥០៦.៧១៧ | ៥.៣៤៥ | ៤.៤៥៤ | ៥៣.៤៥០ | ៥៦,០១៧ |
| **សរុប** | **២៩៨ ១៥៧** | **៤៦ ២២២** | **៤ ៩៥៤ ៧៣៧** | **២៩ ១៣៥** | **៤ ៩២៥** | **៣៤៧ ៣៥៤** | **៣២៧ ២៩២** |

**ការនាំចេញសត្វ និងផលិតផលសត្វ៖** កម្ពុជាក៏មានលទ្ធភាពនាំចេញគោក្របី ជ្រូក មាន់ ស្វាក្តាម សាច់ ផលិតផលមានដើមកំណើតពីសត្វ ចំណីសត្វ និងទឹកដោះគោមួយចំនួនទៅបរទេសផងដែរ។ សរុបក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ កម្ពុជាបាននាំចេញគោក្របីចំនួន ៥៦ ៧២៤ក្បាល ជ្រូកពូជ ១២៧ ៣២២ក្បាល មាន់ពូជ ១៨០ ០០០ក្បាល ស្វាក្តាម ៧២ ៥១៩ក្បាល ចំណីឆ្អែ ៦ ៥៨៤តោន ស្បែកគោក្របីប្រឡាក់អំបិល ២៦ ០៩៩តោន និងទឹកដោះគោចំនួន ៤៥១តោន។ ដោយឡែក ក្នុងឆ្នាំ២០១៧ បាននាំចេញគោក្របី ១១ ២៤០ក្បាល ជ្រូកពូជ ១ ១៤០ក្បាល ស្វាក្តាម ៦ ៩៣៤ក្បាល ស្បែកគោក្របីប្រឡាក់អំបិល ១ ៩៧២តោន និងទឹកដោះគោ ៤៥១តោន។

**តារាងព័ត៌មាននាំចេញសត្វ សាច់ ផលិតផលសត្វ និងចំណីសត្វ៥ឆ្នាំចុងក្រោយ**

| ប្រភេទសត្វនិងផលិតផល | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | សរុប |
|---|---|---|---|---|---|---|---|
| គោ ក្របី | ក្បាល | ១៩ ៧៥៣ | ១២ ១៦១ | ៧ ៣៣៥ | ៦ ២៣៥ | ១១ ២៤០ | ៥៦ ៧២៤ |
| ជ្រូកពូជ(មេ បា) | ក្បាល | ១ ៣៤៩ | ២ ០១៧ | ២ ០២១ | ១ ២៥០ | ១ ១៤០ | ៧ ៧៧៧ |
| ជ្រូកពូជ(កូន) | ក្បាល | ២១ ៦៤០ | ៥០ ៤០០ | ១៣ ៣០៥ | ៣៤ ២០០ | | ១១៩ ៥៤៥ |
| ស្វាក្តាម | ក្បាល | ៥ ៣៤៥ | ៤ ៥៣០ | ៤ ១៨០ | ៥១ ៥៣០ | ៦ ៩៣៤ | ៧២ ៥១៩ |
| កូនមាន់ | ក្បាល | ១២៤ ០០០ | | | ៥៦ ០០០ | | ១៨០ ០០០ |
| សាច់គោ | តោន | ១២ | | | ៦៨ | ៧ | ៨៨ |
| ទឹកដោះគោ | តោន | | | | | ៤៥១ | ៤៥១ |
| ចំណីឆ្អែ | តោន | ១ ០១៥ | ១ ១៨២ | ១ ៦៥២ | ១ ៣៧០ | ១ ៣៦៥ | ៦ ៥៨៤ |
| រោមសត្វ | តោន | ៥១ | ៦៣ | ៦៣ | ៥០ | ២៨ | ២៥៥ |
| ស្បែកគោ ក្របី ជ្រូក | តោន | ១ ៦៥៩ | ១ ១៦២០ | ២ ២៥៤ | ១ ៤៨៣ | ១ ៩៧២ | ២៦ ០៩៩ |

## ២.៣. កម្មវិធីកែលម្អពូជ

**ការកែលម្អពូជគោ៖** ជាកម្មវិធីអាទិភាព ដែលបានពង្រីកសកម្មភាពបង្កាត់សិប្បនិម្មិតគោនៅក្នុងខេត្តចំនួន១១ គឺ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង ខេត្តពោធិ៍សាត់ ខេត្តស្ទឹងត្រែង ខេត្តស្វាយរៀង ខេត្តតាកែវ និងខេត្តឧត្តរមានជ័យ។

វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វនិងផលិតកម្មសត្វ បានសិក្សាស្រាវជ្រាវពូជសត្វល្អដែលមានស្រាប់ក្នុងស្រុក សម្រាប់ប្រើប្រាស់ក្នុងការផលិតមេជីវិតសម្រាប់បង្កាត់សិប្បនិម្មិត ដោយប្រមូលមេជីវិត ធ្វើការបង្កកពិនិត្យគុណភាព ដើម្បីកាត់បន្ថយការនាំចូលមេជីវិតបង្កកពីបរទេស។ នៅឆ្នាំ២០១៧នេះ បានផលិតទឹកមេជីវិតបានចំនួន ១ ៩០០កម្រិត និងនាំចូលមេជីវិតគោបាពូជប្រ៉ាមាន់ និងឥណ្ឌូប្រេស៊ីលចំនួន១ ១៧០បំពង់ ហើយបង្កាត់សិប្បនិម្មិតគោបានសរុប ១ ៤២៧ក្បាល និងបង្កាត់បានកូនគោចំនួន ៧៧៣ក្បាល (ញី ៤២៣ក្បាល)។ បានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសបង្កាត់សិប្បនិម្មិតគោ ផ្សព្វផ្សាយបច្ចេកទេស និងផលប្រយោជន៍នៃការបង្កាត់សិប្បនិម្មិតគោដល់មន្ត្រីជំនាញផលិតកម្មនិងបសុព្យាបាល ទូទាំង ២៥ រាជធានី-ខេត្ត និងបានរៀបចំកម្មវិធីតាមដាន និងអនុវត្តជាក់ស្តែងជាមួយនឹងការផ្សព្វផ្សាយអំពីផលប្រយោជន៍នៃការបង្កាត់សិប្បនិម្មិតគោដល់កសិករចិញ្ចឹមសត្វ អាជ្ញាធរមូលដ្ឋាន ថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីជំនាញសរុបចំនួន១៨៣នាក់។

**ការកែលម្អពូជជ្រូក៖** ពូជជ្រូកបានត្រូវជំរុញលើកទឹកចិត្តឲ្យមានការកែលម្អបានយ៉ាងឆាប់រហ័យនៅទូទាំងប្រទេស។ ដើម្បីជំរុញកែលម្អពូជឲ្យកាន់តែប្រសើរ នៅតាមបណ្តាខេត្តមួយចំនួន បានរៀបចំឲ្យមានមជ្ឈមណ្ឌលបង្កាត់ពូជជ្រូកសិប្បនិម្មិត។ បច្ចុប្បន្នមានមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិតជ្រូកចំនួន ១២កន្លែង នៅក្នុងខេត្តចំនួន ១១ គឺខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តព្រៃវែង ខេត្តស្ទឹងត្រែង ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តឧត្តរមានជ័យ ខេត្តត្បូងឃ្មុំ និងសាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង។ មជ្ឈមណ្ឌលទាំងនេះ បាននឹងកំពុងផ្តល់សេវាកម្មផ្សព្វផ្សាយ និងដំណើរការផលិតមេជីវិត និងបង្កាត់សិប្បនិម្មិត្ត ជូនកសិករចិញ្ចឹមសត្វខ្នាតតូច។ ការបង្កាត់សិប្បនិមិត្ត មានការកើនឡើងជាលំដាប់ ពីមួយឆ្នាំទៅមួយឆ្នាំ។ សរុបក្នុងឆ្នាំ២០១៧ បង្កាត់បាន ១៤ ៣៤២ក្បាល បង្កើតបានកូនជ្រូកចំនួន៥៥ ៣២៤ក្បាល (ញី ១៧ ១១៣ក្បាល)។ ដើម្បីរក្សានិរន្តរភាពគ្រប់មជ្ឈមណ្ឌលត្រូវលើកទឹកចិត្ត ឲ្យអនុវត្តរបបប្រាក់សន្សំនៅធនាគារសម្រាប់គាំទ្រដល់មជ្ឈមណ្ឌលនីមួយៗ។ បច្ចេកទេសបង្កាត់សិប្បនិម្មិតជ្រូកត្រូវបានពង្រីកទូទាំង២៥ រាជធានី-ខេត្ត ហើយជាបណ្តើរៗ បានអនុវត្តសាកល្បងដោយមានគ្រូបង្វឹកដឹកនាំអនុវត្តផ្ទាល់ទាំងការបង្កាត់គោ និងជ្រូកសិប្បនិមិត្ត ព្រមទាំងជំរុញកម្មវិធីផ្សព្វផ្សាយកូនជ្រូកពូជផលិតដោយស្ថានីយចិញ្ចឹមជ្រូកពូជកម្ពុជា ចិន ដែលមានចំនួន ៦៩៦ក្បាល ផងដែរ។

## ២.៤. អំពីចំណីសត្វ

បានរៀបចំកម្មវិធីកែលម្អចំណីសត្វ ផ្សព្វផ្សាយពូជស្មៅដែលសំបូរទៅដោយសារធាតុចិញ្ចឹម និងផ្តល់ទិន្នផលខ្ពស់។ បច្ចុប្បន្នបានពង្រីកកម្មវិធីដំណាំចំណីសត្វនៅទូទាំង២៥ រាជធានី ខេត្ត សរុបមានកន្លែងធ្វើបង្ហាញចំនួន ៨២៣កន្លែង លើផ្ទៃដី ៣៦៣ហិតា។ កម្មវិធីបណ្តុះបណ្តាលការផលិត កែច្នៃចំណីសត្វពីវត្ថុធាតុដើមដែលអាចរកបានក្នុងស្រុកបណ្តុះបណ្តាលបច្ចេកទេសដាំ និងប្រមូលផលដំណាំចំណីសត្វ សរុបអ្នកចូលរួមចំនួន ១ ២៣០នាក់ (ស្ត្រី ៣៩២នាក់)។ បច្ចុប្បន្នមានរោងចក្រផលិតចំណីសត្វចំនួន ១៣ ដែលមានសមត្ថភាពផលិតចំណីសត្វបាន ១,៣ លានតោនក្នុងមួយឆ្នាំ។

## ២.៥. ការគ្រប់គ្រងកាកសំណល់សត្វ

ឡជីវឧស្ម័នបានត្រូវជំរុញ លើកទឹកចិត្តឲ្យសាងសង់យ៉ាងទូលំទូលាយ ដើម្បីគ្រប់គ្រងកាកសំណល់លាមកសត្វ ផ្តល់ថាមពលកកើតឡើងវិញមានតម្លៃថោក និងផ្តល់ជីធម្មជាតិ។ រហូតមកដល់បច្ចុប្បន្ន មានឡជីវឧស្ម័នជាលក្ខណៈគ្រួសារចំនួន ២៦ ៥៨៧ឡ ក្នុងខេត្តចំនួន១៣ រួមមាន ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តកំពត ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។ ដោយឡែកក្នុងឆ្នាំ២០១៧ សាងសង់បានចំនួន ១ ០៤៣ឡ។




## ២.៦. ការងារបសុពេទ្យ

**ការពង្រឹងសុខភាពសត្វ៖** នាឆ្នាំ២០១៧ អង្គភាពបានពង្រឹងសកម្មភាពត្រួតពិនិត្យ និងទប់ស្កាត់បទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ ដោយបានរៀបចំក្រុមអន្តរាគមន៍បង្ក្រាបបទល្មើស បង្កើតគណៈកម្មការគ្រប់គ្រង និងវាយតម្លៃហានិភ័យសុខភាពសត្វ និងផលិតកម្មសត្វ ចេញសេចក្ដីណែនាំស្ដីពីលក្ខខណ្ឌតម្រូវសម្រាប់ការនាំចូលសត្វ និងផលិតផលសត្វ និងពង្រឹងសកម្មភាពត្រួតពិនិត្យចរាចរសត្វ និងផលិតផលនៅតាមបណ្ដារាជធានី ខេត្ត ជាពិសេសខេត្តជាប់ព្រំដែន ព្រមទាំងបានផ្ដួចផ្ដើមរៀបចំស្ថានីយចត្តាឡីស័កសត្វនៅតាមរាជធានីខេត្ត។ ជាលទ្ធផលក្នុងរយៈពេលមួយឆ្នាំនេះ នៅទូទាំងប្រទេសបានបង្ក្រាបបទល្មើសចំនួន ៣០៣ករណី ចុះត្រួតពិនិត្យកន្លែងលក់បសុឱសថ និងចំណីសត្វបានចំនួន ២២៨កន្លែង។ ជាមួយគ្នានេះដែរក៏បានធ្វើការអង្កេតតាមដាន បង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងសត្វ ព្រមទាំងបានរៀបចំប្រព័ន្ធព័ត៌មាន និងរាយការណ៍ជំងឺឆ្លងសត្វទាំងថ្នាក់ជាតិ និងអន្តរជាតិ ចាត់វិធានការជីវសុវត្ថិភាព និងកម្មវិធីឆ្លើយតបបន្ទាន់ករណីផ្ទុះជំងឺឆ្លងសត្វ។ លទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ២០១៧ រួមមាន៖

១. ចាក់វ៉ាក់សាំងការពារជំងឺឆ្លងសំខាន់ៗដែលតែងតែកើតលើគោ ក្របី ពពែ ចៀម ដូចជាជំងឺអុតក្ដាមបូសខ្យល់ និងសារទឹក បានសរុបចំនួន១ ៥៧៩ ៣២៨ក្បាល ចាក់វ៉ាក់សាំងការពារជំងឺឆ្លងលើជ្រូកចំនួន១ ១២៩ ៥៩៤ ក្បាល ចាក់វ៉ាក់សាំងការពារជំងឺឆ្លងបក្សីបានចំនួន៨ ២៦៥ ០២៧ក្បាល និងចាក់វ៉ាក់សាំងការពារជំងឺឆ្លងឆ្កែ និងឆ្មាបានចំនួន១១ ០៥២ក្បាល។

២. ចាត់វិធានការជីវសុវត្ថិភាព ផ្សព្វផ្សាយ និងអនុវត្តផ្ទាល់នៅសត្តឃាតដ្ឋាន កសិដ្ឋានចិញ្ចឹម ពេលដឹកជញ្ជូនសត្វនិងផលិតផលសត្វ ទីកន្លែងផ្ទុះជំងឺសត្វសរុបចំនួន២៦ ២១៣លើក។

៣. ឆ្លើយតបបន្ទាន់រាល់ករណីផ្ទុះជំងឺចំនួន៦៩លើក ក្នុងចំណោមករណីផ្ទុះជំងឺសរុប ១២៥ករណី។

៤. ផ្ដល់សម្ភារបរិក្ខារបសុពេទ្យ ដល់ភ្នាក់ងារសុខភាពសត្វភូមិសម្រាប់ធ្វើអន្តរាគមន៍ និងព្យាបាលសត្វ ២៩៥ កញ្ចប់។

គួរកត់សម្គាល់ថា សេវាកម្មចាក់វ៉ាក់សាំងបង្ការ ការពារជំងឺឆ្លងសត្វ ត្រូវបានចូលរួមយ៉ាងសកម្មដោយភ្នាក់ងារសុខភាពសត្វភូមិ ដែលបច្ចុប្បន្នមានចំនួនសរុប១២ ៤២០នាក់ នៅទូទាំងប្រទេស។ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បន្តចាត់ទុកការពង្រឹងសមត្ថភាពភ្នាក់ងារសុខភាពសត្វភូមិ គឺជាកម្មវិធីអាទិភាពដូចដែលមានចែងយ៉ាងច្បាស់ក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ២០១៦-២០២៥ និងជំពូកទី១៣ នៃច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ។ ដើម្បីជំរុញ គាំទ្រដល់កម្មវិធីវិមជ្ឈការនៃសេវាសុខភាពសត្វ និងផលិតកម្មសត្វ អគ្គនាយកដ្ឋាន

បាននឹងកំពុងជំរុញរៀបចំសេចក្តីព្រាងព្រះរាជក្រិត្យ ស្តីពីគណបសុពេទ្យ ដើម្បីផ្តល់នូវក្របខ័ណ្ឌគតិយុត្តដល់ការផ្តល់សេវាកម្មសុខភាពសត្វឯកជន។

អាស្រ័យដោយមានការត្រៀមលក្ខណៈបានល្អ និងយកចិត្តទុកដាក់ខ្ពស់លើការងារអង្កេត តាមដាន ស្រាវជ្រាវប្រភព និងរាយការណ៍ស្ថានភាពសុខភាពសត្វជាប្រចាំ គ្រប់ករណីផ្ទុះជំងឺឆ្លងបានត្រូវរកឃើញ និងរាយការណ៍បានឆាប់រហ័ស និងបានចាត់វិធានការឆ្លើយតបបានទាន់ពេលវេលា រួមទាំងជំងឺផ្តាសាយបក្សីទាំង ៤ករណី នៅកំឡុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០១៧ ដែលអាចទប់ស្កាត់មិនបណ្តាលឲ្យឆ្លងរាលដាលទៅមនុស្ស និងបង្កហានីភ័យសុខភាពសារធារណៈ។

**ការពង្រឹងសុខភាពសាធារណៈបសុព្យាបាលៈ** បានចូលរួមដោះស្រាយនិងសិក្សា ដែលបានដាក់ចេញនូវវិធានការចាំបាច់នានា ក្នុងការពង្រឹងការអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ស្តង់ដារអនាម័យ នៅកន្លែងពិឃាតសត្វ កន្លែងតាំងលក់ ព្រមទាំងផ្តល់សេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ ផលិតផល បញ្ជាក់គុណភាពសុវត្ថិភាពសាច់ និងផលិតផល។ អគ្គនាយកដ្ឋានយកចិត្តទុកដាក់ រៀបចំឯកសារបច្ចេកទេសនានា និងផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេស ពាក់ព័ន្ធនឹងការធ្វើអាជីវកម្មសត្វ ផលិតផលសត្វ ការពិឃាតសត្វតាមបច្ចេកទេសដល់អ្នកពាក់ព័ន្ធ ព្រមទាំងបានបំពាក់បំប៉នបង្កើនសមត្ថភាពដល់មន្ត្រីប្រចាំការនៅតាមសត្តឃាតដ្ឋាន និងអ្នកពាក់ព័ន្ធលើជំនាញត្រួតពិនិត្យសុខភាពសត្វ អនាម័យសាច់ និងផលិតផលចំនួន ៦វគ្គ សរុបអ្នកចូលរួម ១៣៧នាក់ ជំនាញត្រួតពិនិត្យ ជំងឺចុងអង្ករនិងរបេងជ្រូក គោក្របី ៦វគ្គ មានសិក្ខាកាមចំនួន ១៦៣នាក់ និងចុះត្រួតពិនិត្យសាច់រកវត្តមានជំងឺចុងអង្ករ និងរបេងជ្រូក គោក្របីនៅសត្តឃាតដ្ឋានចំនួន ១២សត្តឃាតដ្ឋាន និងបានធ្វើវិភាគវត្ថុវិភាគគំរូដើម្បីវាយតម្លៃស្ថានភាពអនាម័យជាទូទៅផងដែរ។

គិតមកដល់ដំណាច់ឆ្នាំ២០១៧នេះ សត្តឃាតដ្ឋានបានកើនដល់ ១៦៨ ក្នុងនោះមានសត្តឃាតដ្ឋានទំនើបលំដាប់អន្តរជាតិមួយកន្លែងនៅខេត្តព្រះសីហនុ។ ថ្វីបើសត្តឃាតដ្ឋានបានកើនជាលំដាប់ ប៉ុន្តែចំនួននេះ មិនទាន់គ្រប់គ្រាន់ទាំងបរិមាណ និងមិនទាន់មានអនុលោមតាមការតម្រូវនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការបង្កើតនិងគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសាច់ និងផលិតសត្វនៅឡើយ។




## ២.៧. ការផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល និងនីតិកម្ម

### ក. ការងារផ្សព្វផ្សាយ

**ការចងក្រង និងបោះពុម្ពៈ** បានធ្វើបច្ចុប្បន្នភាពឯកសារបច្ចេកទេស ផលិតវីដេអូអប់រំ ផ្តល់បទសំភាសន៍ ចងក្រង និងបោះពុម្ពឯកសារសំខាន់ៗ មួយចំនួន រួមទាំងច្បាប់ និងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសរុប ១២ ០០០ក្បាល។

**ការងារផ្សព្វផ្សាយ៖** រៀបចំកម្មវិធីផ្សព្វផ្សាយ ផ្តល់បទសំភាសន៍ វេទិកាសាធារណៈជាមួយអ្នកពាក់ព័ន្ធទាក់ទងនឹងប្រធានបទសំខាន់ៗ និងបានផ្សព្វផ្សាយឯកសារ បទសំភាសន៍ វីដេអូរអប់រំ បច្ចេកទេសផលិតកម្ម និងបសុព្យាបាលច្បាប់ បទដ្ឋានគតិយុត្តិ ព័ត៌មាន សេចក្តីណែនាំសារាចរ ប្រកាស និងឯកសារពាក់ព័ន្ធនានា តាមវិទ្យុ ទូរទស្សន៍ គេហទំព័រ និងផ្សព្វផ្សាយតាមកិច្ចប្រជុំ សិក្ខាសាលា និងចែកជូនតាមបណ្តារាជធានី ខេត្តទាំង២៥ ព្រមទាំងការធ្វើបង្ហាញពីការចិញ្ចឹមសត្វ ការដាំដំណាំចំណីសត្វនៅគ្រប់២៥ រាជធានី ខេត្ត មានជាអាទ៍៖

១. ការចិញ្ចឹមជ្រូកមេផលិតកូនចំនួន១០៦ បង្ហាញ៖ លទ្ធផលនៃការធ្វើបង្ហាញមានកសិករចម្លងតាម ៧២០ គ្រួសារដែលមានជ្រូកសរុប ៣ ៣៣៨ក្បាល។

២. ការចិញ្ចឹមមាន់ពូជក្នុងស្រុកចំនួន១១៦ បង្ហាញ៖ លទ្ធផលនៃការធ្វើបង្ហាញមានកសិករចម្លងតាម ៥៣០ គ្រួសារ ដែលមានមាន់សរុប ៧.៣៩៧ ក្បាល។

៣. បច្ចេកទេសដាំ និងប្រើប្រាស់ដំណាំស្មៅចំណីសត្វចំនួន ១០០បង្ហាញ៖ លទ្ធផលនៃការធ្វើបង្ហាញនេះមានកសិករសាទរ និងបានចម្លងតាមចំនួន ៧ ៦៤៥គ្រួសារ លើផ្ទៃដី ៣៩ហិកតា ដែលមានគោក្របី ៤៥៣ ក្បាល។ ភ្ជាប់ជាមួយកម្មវិធីបង្ហាញក៏បានបណ្តុះបណ្តាលបច្ចេកទេសដាំ ប្រមូលផល រក្សាទុក ដល់អ្នកបង្ហាញ និងកសិករចិញ្ចឹមគោ ក្របីនៅក្នុងស្រុកគោលដៅ សរុបចំនួន ៣០វគ្គ ដែលមានអ្នកចូលរួមចំនួន ៧៥០ (ស្ត្រី ២៩១រូប)។

**ការចងក្រងក្រុម និងសហគមន៍ចិញ្ចឹមសត្វ៖** បានរៀបចំចងក្រងក្រុម និងរៀបចំបង្កើតសហគមន៍ចិញ្ចឹមសត្វ៖

១. ចងក្រងក្រុមផលិតមាន់ និងទីផ្សារចំនួន ៧០៧ក្រុម ៦ ១៦៩នាក់ (ស្ត្រី ៤១២០នាក់) និងបានជ្រើសកសិករផលិតកម្មមាន់ និងពងចំនួន ៨ ៨៥០នាក់ (ស្ត្រី ៤ ២១៨ នាក់)។

២. ចងក្រងក្រុមកម្មវិធីបង្វិលពូជ និងក្រុមសន្សំចំនួន ៤០ក្រុម។ ក្រុមទាំងនេះ បានបង្កើនសមត្ថភាពដឹកនាំគ្រប់គ្រងក្រុម និងសហគមន៍ បង្កើនសមត្ថភាពច្ចេកទេសចិញ្ចឹមសត្វ ជ្រើសរើសពូជ ជំងឺដំណាំចំណីសត្វសរុបចំនួន ៣៦វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ៤០៦ (ស្ត្រី ៦៤នាក់)។

៣. ចងក្រងសហគមន៍ចំនួន៣ គឺសហគមន៍ចិញ្ចឹមជ្រូក សហគមន៍ចិញ្ចឹមគោ និងសហគមន៍ចិញ្ចឹមទា។

**ខ. ការកសាងលិខិតបទដ្ឋានគតិយុត្ត៖** ក្នុងរយៈពេលមួយឆ្នាំនេះ អង្គភាពបាននឹងកំពុងបន្តរៀបចំ៖

១. សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីគណៈបសុពេទ្យ

២. សេចក្តីព្រាងអនុក្រឹត្យ ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិមន្ត្រីអធិការកិច្ចសុខភាពសត្វនិងផលិតកម្មសត្វ។

៣. ពិនិត្យកែសម្រួលអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ និងទីកន្លែងកែច្នៃបឋមផលិតផលសត្វ។

៤. នីតិវិធីនិងការតម្រូវបមាណីយចំណីសត្វសម្រាប់ការចុះបញ្ជីចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម

៥. នីតិវិធីនៃការចុះបញ្ជី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីបសុឱសថ សារធាតុសកម្ម និងសមាសធាតុ

៦. ការបង្កើត និងការគ្រប់គ្រងការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម

៧. នីតិវិធីនៃការជ្រើសរើស បណ្តុះបណ្តាល ការគ្រប់គ្រងឲ្យមាននិរន្តរភាព និងភារកិច្ចភ្នាក់ងារសុខភាពសត្វភូមិ

៨. គំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

៩. នីតិវិធីនៃការគ្រប់គ្រងបសុឱសថ និងវត្ថុធាតុជីវបសុព្យាបាលដែលធ្វើពាណិជ្ជកម្ម និងធ្វើការលាយផ្សំ

១០. នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត និងការកំណត់ការគ្រប់គ្រងចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមដែលត្រូវធ្វើពាណិជ្ជកម្ម ការផលិត និងធ្វើការលាយផ្សំ និង

១១. ពិនិត្យ ធ្វើបច្ចុប្បន្នភាព ប្រកាសរួមកម្រៃសេវាកម្ម សុខភាពសត្វនិងផលិតកម្មសត្វ។

## ២.៨. ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ

**ការងារស្រាវជ្រាវបសុព្យាបាល៖** បច្ចុប្បន្នវិទ្យាស្ថានមានសមត្ថភាពវិភាគ ធ្វើរោគវិនិច្ឆ័យ រកមេរោគបង្ក៖

១. លើបក្សី៖ ជំងឺផ្តាសាយបក្សី ជំងឺញូវកាសបក្សី ជំងឺប៉េស្តទា ជំងឺអាសន្នរោគ

២. លើជ្រូក៖ ជំងឺប៉េសជ្រូក ជំងឺជ្រូកត្រចៀកខៀវ ជំងឺបង្កដោយសាល់ម៉ូណែលឡា

៣. លើគោ ក្របី៖ ជំងឺសារទឹក ជំងឺអុតក្តាម ជំងឺបូសខ្យល់ ជំងឺឈាមខ្មៅ

៤. លើសត្វឆ្កែ ឆ្មា៖ ជំងឺឆ្កែឆ្កួត

៥. លើសត្វស្វា៖ ជំងឺសាល់ម៉ូណែលឡូស ជំងឺស៊ីហ្សែលឡា ជំងឺបង្កដោយអឺកូលី (SRV ,STLV, CHS, SS) ។

វិទ្យាស្ថានមានកម្មវិធីអង្កេតតាមដាន និងប្រព័ន្ធព័ត៌មានរាយការណ៍ជំងឺសត្វ ដំណើរការសកម្មនៅឆ្នាំ២០១៧ វិទ្យាស្ថានបានប្រមូលនិងវិភាគ១១ ៦២៤វត្ថុវិភាគ និងបានបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធនឹងការស្រាវជ្រាវចំនួន ៣៤៦រូប។ បានផ្តល់ការបណ្តុះបណ្តាលបង្កើនសមត្ថភាពដល់មន្ត្រីជំនាញ លើការអង្កេត តាមដានជំងឺចំនួន ៦៤រូប លើការធ្វើរោគវិនិច្ឆ័យចំនួន ២រូប លើការប្រើប្រាស់អេពីដេមីសាស្ត្រក្នុងការបង្ការនិងទប់ស្កាត់ជំងឺបានចំនួន ១០៥រូប និង លើការងារមូលដ្ឋាននៃអេពីដេមីសាស្ត្រចំនួន ១៧៥រូប ។

**ការងារស្រាវជ្រាវផលិតកម្មសត្វ៖ វិទ្យាស្ថានបានតមឡើងនិងដាក់ឲ្យដំណើរការ**ម៉ាស៊ីនវិភាគចំណីសត្វ និង ម៉ាស៊ីនផលិតទឹកនីត្រូសែន ផលិតមេជីវិតគោ និងបន្តកម្មវិធីពិសោធន៍បង្កាត់គោសិប្បនិម្មិត ដោយប្រមូលមេជីវិតគោបាពូជក្នុងស្រុក វាយតម្លៃ បង្កក រក្សាទុក និងបង្កាត់សាកល្បងជាមួយគោមេពូជក្នុងស្រុក។ ក្នុងឆ្នាំ២០១៧នេះ ផលិតទឹកមេជីវិតបង្កកបាន ១ ៩០០កម្រិត ដែលបច្ចុប្បន្នមានមេជីវិតបង្កកក្នុងស្តុកសម្រាប់បង្កាត់ ៣ ០០០កម្រិត ព្រមទាំងបានបង្កាត់ពិសោធន៍បានចំនួន ៦៨ក្បាល និងបានដំណើរការវិភាគចំណីសត្វ ៧១វត្ថុវិភាគ។

## ៣. លទ្ធផលនៃការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព

ការកែទម្រង់ស៊ីជម្រៅវិស័យជលផលត្រូវបន្តបានអនុវត្តយ៉ាងសកម្ម។ កំណែទម្រង់នេះ បានធ្វើឱ្យប្រជាជនទូទៅ ជាពិសេសអ្នកប្រកបរបរនេសាទជាលក្ខណៈគ្រួសារ អាចធ្វើអាជីវកម្មបានទូលំទូលាយជាងមុន។ រហូតមកដល់ពេលនេះ ក្រសួងបានបង្កើតសហគមន៍នេសាទចំនួន៥១៦ ដើម្បីគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាព។ សព្វថ្ងៃនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងខិតខំអនុវត្តទិសស្លោក "សហគមន៍នេសាទគ្មានបទល្មើស" ក្នុងគោលបំណងពង្រឹងសហគមន៍នេសាទឱ្យបានរឹងមាំ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមគ្រប់គ្រង ថែរក្សា ការពារធនធានជលផលឱ្យបានគង់វង្ស។

ក្នុងការចូលរួមចំណែកអនុវត្តការកែទម្រង់ ច្បាប់ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧។ វិសោធនកម្មនៃច្បាប់នេះ គឺជារបត់ថ្មីមួយនៃការកែទម្រង់វិស័យជលផល ឱ្យស្របតាមតួនាទីភារកិច្ច និងតម្រូវការជាក់ស្តែងនៃសង្គមកម្ពុជាបច្ចុប្បន្ន។

ជាការកែទម្រង់ថ្មីមួយទៀត ក្រសួងបានស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាល ដើម្បីបើកឱ្យមានការចិញ្ចឹមត្រីរស់និងត្រីឆ្តោឡើងវិញ ទាំងជាលក្ខណៈគ្រួសារនិងពាណិជ្ជកម្ម។ រាជរដ្ឋាភិបាលបានអនុញ្ញាតជាគោលការណ៍ចំពោះសំណើនេះ ប៉ុន្តែការចិញ្ចឹមនេះ ត្រូវភ្ជាប់ជាមួយលក្ខខណ្ឌមួយចំនួន ដើម្បីងាយស្រួលគ្រប់គ្រង និងផ្តល់បច្ចេកទេស និងជាពិសេសទៀតនោះ គឺសំដៅធានាឱ្យបាននូវការអនុវត្តស្របតាមបទដ្ឋានបច្ចេកទេសសមស្រប ធានានិរន្តរភាពធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ីនិងបរិស្ថាន (លិខិតលេខ៤៣៥ សជណ.កស ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦)។

ជាមួយគ្នានេះដែរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាស ស្តីពីការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម ខេត្តព្រះសីហនុ (ប្រកាសលេខ៣៦៤ ប្រក.កសក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦) ដែលប្រកាសនេះ មានគោលបំណងដើម្បីការពារ អភិរក្ស និងប្រើប្រាស់ធនធានជលផលសមុទ្រប្រកបដោយនិរន្តរភាព ស្របតាមគោលនយោបាយវិស័យជលផលជាតិ និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

គណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប ត្រូវបានបង្កើតឡើងតាមរយៈសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦។ បន្ថែមលើនេះ ក្រុមការងារពិសេសជាជំនួយការឱ្យគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប ក៏ត្រូវបានបង្កើតឡើងដែរ តាមរយៈសេចក្តីសម្រេចលេខ០១៧ សសរ.កសក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧។ នេះជាយន្តការដ៏មានប្រសិទ្ធភាព ក្នុងការអនុវត្តកម្មវិធីកែទម្រង់វិស័យជលផលនាពេលបច្ចុប្បន្ន។ វិធានការពារប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ត្រូវបានយកចិត្តទុកដាក់អនុវត្ត តាមរយៈយន្តការនៃគណៈកម្មការគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ។ ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់នេសាទត្រូវបានកែសម្រួល (សេចក្តីសម្រេចលេខ៣៨៤ សសរ.កសក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦) ឱ្យស្របតាមការវិវឌ្ឍជាក់ស្តែង និងជាយន្តការកៀរគរធនធានទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីបណ្តាដៃគូអភិវឌ្ឍន៍នានា សម្រាប់អភិវឌ្ឍន៍វិស័យជលផលប្រកបដោយចីរភាព។

### ៣.១. ការអភិវឌ្ឍន៍សហគមន៍នេសាទ

រហូតមកដល់ឆ្នាំ២០១៧នេះ បង្កើតសហគមន៍នេសាទបានចំនួន៥១៦ ក្នុងនោះសហគមន៍នេសាទទឹកសាបចំនួន៤៧៥ និងសហគមន៍នេសាទសមុទ្រ៤១ ដែលមានសមាជិកសរុបចំនួន៣៣២ ១៦៨នាក់(ស្ត្រីប្រមាណ៣៥%) ត្រូវជា១៤៧ ៥១៨គ្រួសារ។ ក្នុងចំណោមសហគមន៍ខាងលើនេះ មានសហគមន៍នេសាទចំនួន៤០៨ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសហគមន៍នេសាទចំនួន០៣ បានរៀបចំសំណុំឯកសាររួចរាល់ដែលនឹងត្រូវស្នើសុំចុះបញ្ជីបន្ថែមទៀត ជាមួយគ្នានេះមានសហគមន៍នេសាទចំនួន៣០ទៀតកំពុងដំណើរការចុះហត្ថលេខានៅថ្នាក់ក្រោមជាតិ។

ចំពោះសហគមន៍នេសាទដែលផុតអាណត្តិ ការបោះឆ្នោតជ្រើសរើសគណៈកម្មការថ្មីត្រូវបាននិងកំពុងអនុវត្តជាបន្តបន្ទាប់ ជាក់ស្តែងក្នុងឆ្នាំ២០១៧ សហគមន៍នេសាទចំនួន៤៧ នៅតាមបណ្តាខេត្ត រាជធានីភ្នំពេញ ត្រូវបានបោះឆ្នោតជ្រើសរើសគណៈកម្មការឡើងវិញ។ ទន្ទឹមនេះ ការរៀបចំផែនការគ្រប់គ្រងកន្លែងសហគមន៍ក៏បានប្រព្រឹត្តទៅយ៉ាងសកម្មផងដែរ ក្នុងនោះសហគមន៍នេសាទចំនួន៣៧ បានរៀបចំផែនការគ្រប់គ្រងរួចរាល់។ បូកយោងសហគមន៍នេសាទចំនួន២៥០ មានផែនការគ្រប់គ្រងរបស់ខ្លួន ដោយមានការចុះហត្ថលេខាទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផល។

ក្រៅពីការរៀបចំសហគមន៍នេសាទ ការរៀបចំបណ្តាញសហគមន៍នេសាទក៏បានអនុវត្តផងដែរ ជាក់ស្តែងបណ្តាញសហគមន៍នេសាទថ្នាក់ស្រុកនិងថ្នាក់ខេត្ត ក្នុងខេត្តស្ទឹងត្រែង ត្បូងឃ្មុំ និងខេត្តកំពង់ចាមត្រូវបានរៀបចំឡើង ដើម្បីធ្វើជាយន្តការមួយដែលជួយពង្រឹងដល់ការងារសហគមន៍នេសាទ និងជាតំណាងឱ្យសហគមន៍នេសាទតាមកម្រិតថ្នាក់នីមួយៗ។

### ៣.២. ការអភិរក្សធនធានជលផល

ក្រោយការកែទម្រង់ស៊ីជម្រៅផ្នែកជលផល ដោយរំសាយឡូត៍នេសាទទាំងអស់នៅទូទាំងប្រទេសមានកន្លែងអភិរក្សជលផលថ្មីចំនួន១៤៨កន្លែង សរុបទូទាំងប្រទេសមានចំនួន៦៤៤កន្លែង (សហគមន៍៤៩៦កន្លែង)។ មកដល់ឆ្នាំ២០១៧នេះ បានបោះបង្គោលកំណត់ព្រំប្រទល់កន្លែងអភិរក្សជលផលកម្ពស់៨ម៉ែត្រ ចំនួន១៣៤បង្គោល និងកម្ពស់១២ម៉ែត្រ ចំនួន៥៩បង្គោល សាងសង់ស្នាក់ការបណ្តែតទឹកចំនួន១៧ ស្នាក់ការល្បាតបណ្តែតទឹកចំនួន១៧ខ្នង ស្នាក់ការបេតុង៨ខ្នង និងស្នាក់ការធំចំនួន០២ ព្រមទាំងបានដាក់កម្លាំងយាមល្បាតជាប្រចាំ។ សកម្មភាពអភិរក្សជលផលផ្សេងៗទៀតមានដូចខាងក្រោម៖

- អភិរក្សផ្កាថ្ម ស្មៅសមុទ្រចំនួន៤ ០៥០ហ.តនៅតាមតំបន់ឆ្នេរ
- ដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួន២ ២៧០ហិកតា
- រៀបចំអន្លង់ត្រីមេពូជបានចំនួន៩៧កន្លែង នៅតំបន់មេគង្គលើក្នុងខេត្តក្រចេះនិងស្ទឹងត្រែង
- បានលែងកូនត្រីនិងកូនបង្កងចំនួនជាង៥លានក្បាល ទៅក្នុងបឹងធម្មជាតិ

- បានអភិរក្សធនធានជលផលកំពុងរងគ្រោះថ្នាក់ដូចជាអណ្តើកសរសៃ អណ្តើកសមុទ្រ កន្ធាយក្បាលកង្កែប ក្រពើត្រី ផ្សោតទឹកសាប ផ្សោតទឹកប្រៃ និងសេះសមុទ្រ។ល។ ដែលធ្វើឱ្យចំនួនកើនឡើងចន្លោះពី១០-១៥%
- បានទទួលការចុះបញ្ជីកសិដ្ឋានចិញ្ចឹមក្រពើចំនួន១៦បន្ថែមទៀតពីលេខាធិការដ្ឋានសាយតេសអន្តរជាតិ។

### ៣.៣. ការបង្រ្កាបបទល្មើសជលផល

ដោយមានបទបញ្ញា០១បប និងច្បាប់ជលផលជាបង្អែក មន្ទ្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់បានសហការជាមួយអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធខិតខំបំពេញការងារយ៉ាងសកម្ម ជាពិសេសបានយកចិត្តទុកដាក់ការពារកន្លែងអភិរក្សជលផលមិនឱ្យមានការលួចចូលធ្វើនេសាទ អនាធិបតេយ្យឡើយ។ ជាលទ្ធផលជាក់ស្តែងក្នុងឆ្នាំ២០១៧នេះ សំណុំរឿងនៃបទល្មើសជលផលសរុបចំនួន៣ ៩២៥ករណី (សមុទ្រ៣៧ករណី) ប្រៀបធៀបឆ្នាំមុនកើនឡើងចំនួន២៧៥ករណី ក្នុងនោះបានបំផ្លាញចោលវត្ថុតាងចំនួន៣ ៧២៣ករណី ពិន័យអន្តរការណ៍ចំនួន១១៦ករណី បញ្ជូនទៅតុលាការចំនួន៨៦ករណី ជាប់ពន្ធនាគារចំនួន៥៦នាក់ ប្រាក់ពិន័យនិងលក់វត្ថុតាងចំនួន៣៨៥ ៦៩៨ ០០០រៀល។ ចំពោះវត្ថុតាងរឹបអូស និងបំផ្លាញចោលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង១ ៥៥៩ ២០៤ម៉ែត្រ បង្គោល/ចម្រឹងចំនួន៧៧៣ ១៣២ដើម លូស្បៃមុង និងសាច់អួនចំនួន២២ ២៣៨មាត់ ឧបករណ៍ឆក់ត្រីចំនួន៤៥០គ្រឿង របាំងព្រួលចំនួន៥ ៩៨២ម៉ែត្រ សម្រាស់ចំនួន៣៧ ៧២០ម៉ែត្រក្រឡា លែងត្រីចម្រុះចូលក្នុងធម្មជាតិចំនួន ៨១ ៦៨០គីឡូក្រាម។

បានប្រជុំផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងអនុសាសន៍ថ្នាក់ដឹកនាំនៅតាមមូលដ្ឋានចំនួន២៩៨វគ្គអ្នកពាក់ព័ន្ធចូលរួមចំនួន៩ ៦៥៨នាក់ ក្នុងនោះស្រ្តីចំនួន១ ៥៨៣នាក់។

### ៣.៤. ការអភិវឌ្ឍន៍វារីវប្បកម្ម

ការចិញ្ចឹមត្រីអនុវត្តបាន២០៧ ៤៤៣តោន បើប្រៀបធៀបរយៈពេលដូចគ្នាកើន៣៤ ៩៤៣តោន ឬកំណើន២០,២៦%។ សកម្មភាពផ្សេងៗទៀតមានដូចខាងក្រោម៖

- ការចិញ្ចឹមក្រពើឆ្នាំ២០១៧ អនុវត្តបាន៣៩២ ៧៧៧ក្បាល កើនលើសឆ្នាំមុន៨៥ ៧៧៧ក្បាល
- ផលិតកូនត្រីពូជបាន២០៥ ០០០ ០០០ក្បាល កើនលើសឆ្នាំកន្លងទៅ១១ ០០០ ០០០ក្បាល
- កន្លែងភ្ញាស់ត្រីសរុបមានចំនួន៣០៩កន្លែង ដែលក្នុងនោះមាន២៩៦កន្លែងជារបស់ប្រជាពលរដ្ឋ តាមរយៈការផ្តល់បច្ចេកទេសពីមន្ទ្រីរដ្ឋបាលជលផល
- មានប្រជាពលរដ្ឋប្រមាណ៦៥ ០០០គ្រួសារ បានចូលរួមក្នុងសកម្មភាពចិញ្ចឹមត្រី ដោយបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមត្រីជាបន្តបន្ទាប់ ក្នុងនោះមានកសិករ១៦០នាក់ជាគ្រូបង្គោល និងជាគ្រូផ្សព្វផ្សាយនៅមូលដ្ឋាន។

### ៣.៥. ការបង្កើតស្រះជម្រកត្រីសហគមន៍

អនុវត្តតាមអនុសាសន៍ពេជ្ររបស់សម្តេចតេជោ កាលពីឆ្នាំ២០០៩ នៅខេត្តកែប មន្ទ្រីរដ្ឋបាលជលផលគ្រប់ខេត្តបានបង្កើតស្រះជម្រកត្រីសហគមន៍បានចំនួន៨៦៤កន្លែង គិតរហូតដល់ឆ្នាំ២០១៧នេះ ខេត្តកំពង់ស្ពឺមានចំនួនច្រើនជាងគេរហូតដល់១៧៣កន្លែង។ សកម្មភាពនេះក៏បានធ្វើឱ្យផលត្រីតាមវាលស្រែកើនឡើង។

### ៣.៦. ការអភិវឌ្ឍន៍បច្ចេកវិទ្យាកែច្នៃនិងគុណភាព

ការងារបច្ចេកវិទ្យាកែច្នៃនិងគុណភាព មានសក្តានុពលមួយយ៉ាងសំខាន់ សម្រាប់វិស័យជលផល ក្នុងការចូលរួមចំណែកផ្គត់ផ្គង់សន្តិសុខស្បៀង អាហារូបត្ថម្ភ ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ឆ្នាំ២០១៧នេះ ក្រសួងសម្រេចបាននូវការរៀបចំបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសមួយចំនួនរួមមាន៖ ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គំរូទម្រង់ និងបែបបទនៃវិញ្ញាបនបត្រសុខភាពសម្រាប់បញ្ជាក់គុណភាពផលផលិតផលជលផល ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាគុណភាពផល ផលិតផលជលផល

សៀវភៅណែនាំស្ដីពីការនាំចេញផល ផលិតផលជលផល គោលការណ៍បច្ចេកទេសស្ដីពីការអនុវត្តអនាម័យល្អ ការអនុវត្តផលិតល្អ និងគោលការណ៍HACCP ស្ដង់ដារទឹកត្រី ស្ដង់ដារងៀតត្រីរ៉ស់-ឆ្ពោ ស្ដង់ដារបង្គាបង្កក និងស្ដង់ដារប្រហុក និងក្រមអនុវត្តសម្រាប់ការកែច្នៃបង្គាបង្កក បង្គាក្រៀម សាច់ក្ដាម និងការកែច្នៃទឹកត្រី។ មិនតែប៉ុណ្ណោះរដ្ឋបាលជលផលបានយកចិត្តទុកដាក់យ៉ាងខ្លាំងដោយបានបញ្ជូនមន្ត្រីជំនាញសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនានាដើម្បីទប់ស្កាត់លើការប្រើសារធាតុគីមីដែលហាមឃាត់ ជាពិសេសលើផល ផលិតផលជលផលនាំចូលពីក្រៅប្រទេស។

### ៣.៧. ការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាបនិងសមុទ្របានដំណើរការល្អ ដោយសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានាដូចជា អង្គការEU, FAO, MRC, NACA, SEAFDEC, World Bank, CI និង World Fish Centre ។ល។ ដោយមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍនេសាទទឹកសាប និងសមុទ្រជាអ្នកអនុវត្តផ្ទាល់។ ចំពោះលទ្ធផលស្រាវជ្រាវ ត្រូវបានបោះពុម្ពសៀវភៅផ្សព្វផ្សាយជាច្រើនពាន់ក្បាល។

### ៣.៨. ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យជលផល

ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល១០ឆ្នាំ (២០១៥-២០២៤) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វារីវប្បកម្មឆ្នាំ២០១៦-២០៣០ បានពិនិត្យរៀបចំកែសម្រួលដោយ សហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះស្ដីពីកំណែទម្រង់ជលផល ហើយត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអនុម័តយល់ព្រមឱ្យប្រើប្រាស់ជាផ្លូវការនោះ រដ្ឋបាលជលផលបានយកមកអនុវត្តស្របតាមសភាពការណ៍ជាក់ស្ដែង។

### ៣.៩. ស្ថិតិជលផល

ផលត្រីសរុបមានចំនួន៨៥៦ ២៦៣តោន កើនលើសឆ្នាំមុនចំនួន៥៣ ៨១៣តោន ឬកំណើន៦,៧១% ក្នុងនោះមាន៖

- ផលនេសាទទឹកសាប ៥២៧ ៧៩៥តោន
- ផលនេសាទសមុទ្រ ១២១ ០២៥តោន
- ផលវប្បកម្ម ២០៧ ៤៤៣តោន

ក្រាហ្វិកបង្ហាញអំពីផលនេសាទទឹកសាប ផលនេសាទសមុទ្រ និងវារីវប្បកម្មរយៈពេល៥ឆ្នាំ២០១៣-២០១៧




### ៣.១០. ការងារហិរញ្ញវត្ថុ

ប្រាក់ចំណូលពីវិស័យជលផលមានចំនួន២ ៩៨៦ ៦៤៦ ៦៨៤,៥៦រៀល ក្នុងនោះមានប្រាក់ចំណូលពី៖ ថ្លៃឈ្នួលដាយត្រី២ ១០៣ ១០០ ០០០រៀល ថ្លៃឈ្នួលដែននេសាទសមុទ្រ៩៩ ៦២៦ ៧០០រៀល ប្រាក់ពិន័យបទល្មើសជលផល៣៨៥ ៦៩៨ ០០០រៀល សេវាសាធារណៈចំនួន២២៦ ៩០០ ០០០រៀល និងចំណូលផ្សេងៗចំនួន១៧០ ៣២១ ៩៨៤,៥៦រៀល។

### ៣.១១. ការរៀបចំលិខិតបទដ្ឋានច្បាប់

រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើវិសោធនកម្មច្បាប់ ស្តីពីជលផលឱ្យសមស្របតាមលក្ខខណ្ឌ និងស្ថានភាពជលផលក្នុងបរិបទបច្ចុប្បន្ននេះផងដែរ ដោយអនុលោមទៅតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។** លើសពីនេះទៀត ក្រសួងបាននិងកំពុងរៀបចំឯកសារចាំបាច់មួយចំនួន ដើម្បីផ្តល់សច្ចាប័នដល់លិខិតូបករណ៍អន្តរជាតិសម្រាប់វិស័យជលផលចំនួនពីរគឺៈ ទី១. "**កិច្ចព្រមព្រៀងវិធានការរដ្ឋម្ចាស់កំពង់ផែ**" ឬហៅកាត់ថា PSMA របស់អង្គការស្បៀងនិងកសិកម្មដែលត្រូវបានចាត់ទុកថាជាវិធានការក្នុងការប្រយុទ្ធប្រឆាំងនឹងការធ្វើនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងទី២. "**កិច្ចព្រមព្រៀងផលស្តុកត្រី**" របស់អង្គការសហប្រជាជាតិដែលត្រូវបានទទួលស្គាល់ថាជាកិច្ចព្រមព្រៀងដើម្បីធានាការអភិរក្សយូរអង្វែង និងការប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព និងលិខិតបទដ្ឋានគតិយុទ្ធមួយចំនួនទៀត។

## ៤. លទ្ធផលនៃការគ្រប់គ្រងព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយកចិត្តទុកដាក់ខ្ពស់ លើកម្មវិធីកំណែទម្រង់វិស័យព្រៃឈើដោយខិតខំបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ និងពិសេសយកចិត្តទុកដាក់ជាសំខាន់លើការត្រួតពិនិត្យតាមដានដ៏តឹងរ៉ឹង ព្រមទាំងសម្រេចបាននូវលទ្ធផលធំៗជាច្រើន។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកត់សម្គាល់ឃើញអំពីការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា។ លើសពីនេះទៀត ក្រសួងក៏បានចូលរួមអនុវត្តយ៉ាងសកម្មជាមួយគណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅទប់ស្កាត់ និងបង្ក្រាបសកម្មភាពអនាធិបតេយ្យកាប់ឈើ ការនាំចេញឈើខុសច្បាប់ និងបទល្មើសនានានៅភាគឦសាន្តនៃប្រទេស។

ជាការកែទម្រង់មួយថ្មីទៀត ក្រសួងបានចេញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះពីមន្ទីរកសិកម្មរាជធានីខេត្ត ទៅជាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត និងបានដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផល ឱ្យស្ថិតនៅក្រោមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត។ បន្ថែមពីនេះទៀតនោះ ក្រសួងក៏បានចេញប្រកាសលេខ៦៥២ ប្រក.កសក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីការផ្ទេរធនធាននិងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលនៃខណ្ឌ ផ្នែក សង្កាត់ រដ្ឋបាលព្រៃឈើ និង រដ្ឋបាលជលផល ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត។

អនុក្រឹត្យលេខ៣៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា១នៃអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលតួនាទីនិងភារកិច្ចរបស់ក្រសួងបរិស្ថាន និង របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងសមត្ថកិច្ច និងការគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច និងការគ្រប់គ្រងតំបន់ការពារនិងអភិរក្សព្រៃឈើនិងជលផល ត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន និងវាយតម្លៃថាមានប្រសិទ្ធភាពខ្ពស់។ ជាមួយគ្នានេះ សារាចរណែនាំលេខ០៥ សរណន ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលកម្ពុជា បានប្រគល់ភារកិច្ចដល់ថ្នាក់ក្រោមជាតិ តាមរយៈគណៈបញ្ជាការឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដឹកនាំ សម្របសម្រួលកម្លាំងអធិការ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលព្រៃឈើ និងកងកម្លាំងមានសមត្ថកិច្ចនានា ក្នុងការគ្រប់គ្រង ថែរក្សា និងការពារ ធនធានធម្មជាតិឱ្យបានគង់វង្ស។ បន្ថែមលើនេះទៀត ក្រសួងបានចេញសេចក្តីណែនាំ ស្តីពីរបៀបរបបការងារ និងទំនាក់ទំនងការងារ រវាងរដ្ឋបាលព្រៃឈើ

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត និងខណ្ឌរដ្ឋបាលព្រៃឈើ (សេចក្តីណែនាំលេខ២២២៣ សណន.កសក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧) ដែលជាលទ្ធផលកិច្ចការនេះត្រូវបានអនុវត្តបានយ៉ាងល្អប្រសើរ។

ការកែទម្រង់លើការងារដាំឈើឡើងវិញ ត្រូវបានយកចិត្តទុកដាក់អនុវត្តយ៉ាងមានប្រសិទ្ធភាព។ ផ្អែកតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជរដ្ឋាភិបាលកម្ពុជា បានអនុញ្ញាតជាគោលការណ៍ដាំឈើលើដីព្រៃរេចរិល ដោយសហការដៃគូជាមួយវិស័យឯកជន (លិខិតលេខ១២០ សជណ.កស ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាលកម្ពុជា)។ ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសស្តីពីវិធានព្រៃឯកជន (ប្រកាសលេខ៣២៧ ប្រក.កសក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧) ដែលប្រកាសនេះ មានគោលបំណងកំណត់នូវវិធានព្រៃឯកជន សម្រាប់ជាគោលការណ៍ណែនាំក្នុងការបង្កើត និងអភិវឌ្ឍន៍ព្រៃឯកជន។

ចំពោះការងារកែទម្រង់ផ្នែកគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការណែនាំអនុវត្តនូវចំណុចគន្លឹះមួយចំនួន ដើម្បីបន្តនិរន្តរភាពលើការគ្រប់គ្រង និងអភិវឌ្ឍដីសម្បទានសេដ្ឋកិច្ចឲ្យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់៖ (ទី១). ស្នើគ្រប់ក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចទាំងអស់បង្កើនល្បឿននៃការដាំដុះដំណាំកសិឧស្សាហកម្មទៅតាមកម្មវិធីការងារនិងផែនការផលិតកម្ម ដូចដែលមានចែងលម្អិតក្នុងផែនការមេរបស់ក្រុមហ៊ុននីមួយៗ និងត្រូវសហការឱ្យបានជិតស្និទ្ធជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ព្រមទាំងមានការត្រួតពិនិត្យត្រឹមត្រូវហ្មត់ចត់ពីមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន ដើម្បីធានាឱ្យការប្រើប្រាស់ដីបានចំទិសដៅ និងមានប្រសិទ្ធភាព។ (ទី២). ក្នុងករណីមានបញ្ហាទំនាស់ដីធ្លីស្រួចស្រាវ រាំងស្ទះដល់ដំណើរការវិនិយោគ ត្រូវសហការដោះស្រាយបញ្ហានេះជាមួយក្រសួង ពិសេសជាមួយគណៈកម្មការសម្របសម្រួលដោះស្រាយផលប៉ះពាល់ជាមួយប្រជាពលរដ្ឋ ដែលក្រសួងបានបង្កើតឡើង សម្រាប់សម្របសម្រួលដោះស្រាយបញ្ហាទំនាស់ ការតវ៉ាទាមទារ និងសំណូមពររបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច ដោយត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួន តាមខ្លឹមសារលិខិតជូនដំណឹងរបស់រាជរដ្ឋាភិបាល ស្របតាមរបាយការណ៍របស់គណៈកម្មការអន្តរក្រសួង ដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច។ (ទី៣). ចំពោះក្រុមហ៊ុនដែលមិនទាន់បានចុះបញ្ជីដីរដ្ឋត្រូវខិតខំជំរុញ និងរួមសហការពន្លឿនការចុះបញ្ជីដីរដ្ឋឲ្យបានឆាប់ និងទាន់ពេលវេលា ដោយត្រូវសហការឱ្យបានល្អជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថាប័នពាក់ព័ន្ធ ពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអាជ្ញាធរដែនដីនៅមូលដ្ឋាន។ (ទី៤). ផ្អែកតាមខ្លឹមសារលិខិតជូនដំណឹងរបស់រាជរដ្ឋាភិបាល ក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចទាំងឡាយណា ដែលបានដោះស្រាយផលប៉ះពាល់រួចរាល់ ចាំបាច់ត្រូវសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីរៀបចំចុះកិច្ចសន្យាជាថ្មីឡើងវិញ លើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច និងកែសម្រួលរយៈពេលវិនិយោគពី៧០ឆ្នាំមក៥០ឆ្នាំវិញ ស្របតាមរបាយការណ៍របស់គណៈកម្មការអន្តរក្រសួង ដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច។ (ទី៥). ក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច ដែលត្រូវដល់ពេលកំណត់បង់ថ្លៃឈ្នួលដីទាំងអស់ ត្រូវរួតរះបង់ថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន និងត្រូវសហការឱ្យបានល្អជាមួយគណៈកម្មការប្រមូលថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច។ (ទី៦). ក្រសួង ស្ថាប័ន អង្គភាពជំនាញពាក់ព័ន្ធទាំងអស់ រួមទាំងអាជ្ញាធរគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តត្រូវសហការចាត់ចែងគ្រប់គ្រងលើសម្បទានដីសេដ្ឋកិច្ច ដែលបានដកហូតមកវិញក្នុងស្មារតីទទួលខុសត្រូវ ជៀសវាងការហ៊ុមព័ទ្ធកាន់កាប់យកធ្វើជាកម្មសិទ្ធិដោយអនាធិបតេយ្យ និងចាត់វិធានការតាមនីតិវិធីឱ្យបានឆាប់បំផុត។

### ៤.១. ការវាយតម្លៃគម្របព្រៃឈើ និងទីជម្រាល

- បានរៀបចំសិក្ខាសាលាស្តីពីការបង្កើនសមត្ថភាពបច្ចេកទេសប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) និងប្រព័ន្ធកំណត់ទីតាំងលើផែនដី (GPS) ជូនមន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើពោធិ៍សាត់ កំពង់ធំ ស្ទឹងត្រែង បាត់ដំបង ក្រចេះ ព្រះវិហារ កំពង់ចាម មណ្ឌលគិរី និងរតនគិរី សរុបចំនួន ៩ វគ្គ មានមន្ត្រីចូលរួមសរុបចំនួន ១៣៩ នាក់ ដោយបានរៀបចំបច្ចុប្បន្នភាពផែនទីប្រើប្រាស់ដីប្រទេសកម្ពុជា បាននិងកំពុងសិក្សាស្រាវជ្រាវស្វែងរកវិធីសាស្ត្រថ្មីទាញយក

រូបភាពផ្កាយរណប Lansat8 និង Sentinel ដែលមានកម្រិតច្បាស់ក្នុងការផ្ទៀងផ្ទាត់ការបកស្រាយគម្របព្រៃឈើឆ្នាំ២០១៨។

## ៤.២. សហគមន៍ព្រៃឈើ

- ទទួលប្រកាសស្តីពីការបង្កើត និងគ្រប់គ្រងតំបន់ព្រៃសហគមន៍ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន៥១សហគមន៍ ដែលមានផ្ទៃដីសរុបទំហំ ៥៧ ៦៧៩ហ.ត ស្ថិតក្នុងខេត្តកំពង់ស្ពឺ ក្រចេះ កំពង់ធំ សៀមរាប ព្រះវិហារ ពោធិ៍សាត់ និងខេត្តស្ទឹងត្រែង
- បានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍រវាងខណ្ឌរដ្ឋបាលព្រៃឈើ និងគណៈកម្មការគ្រប់គ្រងព្រៃសហគមន៍ក្នុងខេត្តចំនួន៤ មានសហគមន៍ព្រៃឈើចំនួន ៤៩ កន្លែង ដែលមានផ្ទៃដីសរុបទំហំ ៣០ ៥៩៣ ហ.ត
- រដ្ឋបាលព្រៃឈើបានអនុម័ត និងយល់ព្រមលើផែនការគ្រប់គ្រងព្រៃសហគមន៍ក្នុងសហគមន៍ព្រៃឈើចំនួន ៨ កន្លែង នៅក្នុងខេត្តចំនួន ៤ គឺខេត្តកំពង់ធំ ក្រចេះ មណ្ឌលគិរី និងខេត្តកំពង់ស្ពឺ
- ចុះតាមដាន និងពិនិត្យការងារសហគមន៍ព្រៃឈើចំនួន ១៣៩ កន្លែង ស្ថិតក្នុងខេត្តចំនួន ១៨
- បោះពុម្ពសៀវភៅស្ថិតិសហគមន៍ព្រៃឈើឆ្នាំ២០១៦ ចំនួន ១ ០០០ ក្បាល
- ក្នុងឆ្នាំ ២០១៧ ចំនួនសហគមន៍ព្រៃឈើសរុបកើនដល់ ៦១០ ប្រៀបធៀបនឹងឆ្នាំ ២០១៦ មានចំនួន ៥៨០។

**ក្រាហ្វិក បង្ហាញអំពីចំនួនសហគមន៍ព្រៃឈើឆ្នាំ២០១៣-២០១៧**




| | 2013 | 2014 | 2015 | 2016 | 2017 |
|---|---|---|---|---|---|
| ចំនួនសហគមន៍ព្រៃឈើសរុប | 457 | 485 | 499 | 580 | 610 |
| ចំនួនសហគមន៍ព្រៃឈើទទួលបានការអនុម័ត | 345 | 364 | 404 | 404 | 464 |

## ៤.៣. ការងារដាំដើមឈើ

- បានបណ្តុះកូនឈើគ្រប់ប្រភេទចំនួន៤០៧ ៩៤៨ដើម នៅតាមថ្នាលបណ្តុះកូនឈើរដ្ឋបាលព្រៃឈើ ថ្នាលបណ្តុះកូនឈើ សម្តេច ហ៊ុន សែន និងថ្នាលឯកជន និងចែកជូនប្រជាពលរដ្ឋចំនួន៣៣០ ០៧៣ដើម សម្រាប់ដាំនៅទីសាធារណៈ
- បានចុះសិក្សាវាយតម្លៃទីតាំងដីព្រៃនៅទំនេរ និងទីតាំងដីដែលរាជរដ្ឋាភិបាលបានដកហូត និងនិរាករណ៍ពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដើម្បីដាំឈើ និងស្តារព្រៃឈើឡើងវិញ ដោយបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន៥៣កន្លែង ដែលមានផ្ទៃដីសរុបទំហំ៤១១ ០២១,០៣៨ហ.ត ក្នុងនោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានឯកភាពជាគោលការណ៍ និងបញ្ជូនទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នូវស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន៤៩កន្លែង មានផ្ទៃដីសរុបទំហំ៤០៨ ០៧៣,០៣៨ហ.ត នៅខេត្តចំនួន៩ រួមមាន៖ ខេត្តក្រចេះ មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង ឧត្តរមានជ័យ កំពង់ធំ ព្រះសីហនុ សៀមរាប និងខេត្តព្រះវិហារ

- រាជរដ្ឋាភិបាលបានចេញ សជណ អនុញ្ញាតឲ្យក្រុមហ៊ុនចំនួន៣ សហការជាមួយរដ្ឋបាលព្រៃឈើ ក្នុងការដាំឈើដៃគូលើផ្ទៃដីសរុបទំហំ ៣៦ ០៩០ហ.ត លើផ្ទៃដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ដែលទើបនឹងបង្កើតក្នុងឆ្នាំ២០១៧ នេះ

- បានរៀបចំប្រារព្ធពិធីរុក្ខទិវាថ្នាក់ជាតិនៅភូមិក្រាំងក្រូច ឃុំទួលព្រេច ស្រុកអង្គស្នួល ខេត្តកណ្តាល ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លើផ្ទៃដីសរុបទំហំ ១០ហ.ត បានដាំកូនឈើសរុបចំនួន១០ ៧២៦ដើម ក្នុងនោះមានធ្នង់ចំនួន៥ ៩២៨ដើម និងគីនីនចំនួន៤ ៧៩៨ដើម

- បានដាំជួស និងថែទាំកូនឈើនៅចម្ការពូជឈើក្នុងស្រុក (ធ្នង់ គ្រញូង គគីរ កកោះ) លើផ្ទៃដីទំហំ ៥០ហ.ត នៅខេត្តកំពង់ធំ ហើយក្រៅពីនេះនៅមានការបេះប្រមូលគ្រាប់ពូជ បេង កកោះ ធ្នង់ បាន ១ ០០០គីឡូក្រាម

- បានដាំដុះកូនឈើប្រភេទគ្រញូង ធ្នង់ គគីរ ឈើទាល និងអាកាស្យាជាមួយនឹងដំណាំកសិកម្មរួមមាន៖ ពោត និងដំឡូងលើផ្ទៃដីចំនួន ១៥ ហ.ត ដោយបង្កើតជាឡូត៍បង្ហាញកសិ-រុក្ខកម្មនៅខេត្តកំពង់ធំ

- បានជួសជុល និងកែលម្អថ្នាលបណ្តុះកូនឈើនៅស្ថានីយដាំឈើម្សៅក្រដាសហ៊ុនសែនមានក និងចុះសិក្សាវាយតម្លៃទីតាំងសម្រាប់ដាំដើមមេ (Clone Bank) ស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង

- បានធ្វើបច្ចុប្បន្នភាពស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន ៥ កន្លែង រួមមាន៖ ស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ បន្ទាយអង្គរ មានផ្ទៃដីទំហំ ១ ០៤១,៩៨ហ.ត និងត្រពាំងធំ មានផ្ទៃដីទំហំ ៩១៣,២១ហ.ត ស្ថិតនៅក្នុងខេត្តតាកែវ ស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្រសាំងមានផ្ទៃដីទំហំ ១ ៥៧៨,១៥ហ.ត ក្នុងខេត្តស្វាយរៀង ស្ថានីយម្សៅក្រដាស ហ៊ុន សែន មានផ្ទៃដីសរុបទំហំ ៤ ២២៤,៦៩ហ.ត ស្ថិតក្នុងខេត្តកំពង់ឆ្នាំង ស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើតំបន់ ទ្រនាប់ភ្នំគូលេន មានផ្ទៃដីសរុបទំហំ ៦៧៨,៤១ហ.ត ស្ថិតនៅខេត្តសៀមរាប

- បានចុះផ្សព្វផ្សាយពិគ្រោះយោបល់ស្តីពីការដាំឈើជូនដល់សហគមន៍មូលដ្ឋាន អ្នកពាក់ព័ន្ធ និងសមាជិកសហគមន៍ព្រៃឈើចំនួន៦ ក្នុងខេត្តចំនួន៣ រួមមាន៖ ខេត្តក្រចេះ រតនៈគិរី និងខេត្តមណ្ឌលគិរី

- បានរៀបចំវគ្គផ្សព្វផ្សាយ និងពិគ្រោះយោបល់ស្តីពីការលើកកម្ពស់ការអនុវត្តបច្ចេកទេស និងគ្រប់គ្រងថ្នាលបណ្តុះកូនឈើដល់មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋានចំនួន៥០នាក់ មកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្តចំនួន២២ នៅសួនបណ្តុះកូនឈើអ្នកលឿងស្ថិតនៅខេត្តព្រៃវែង

- បានជីកប្រឡាយការពារតំបន់ចម្ការឈើដាំគ្រញូង និងតំបន់ប្រភពគ្រាប់ពូជគ្រញូងមានប្រវែង ២០ ០៤៦,៨ម៉ែត្រ

- ក្រុមហ៊ុនដាំឈើដៃគូសហការចំនួនពីរបានអនុវត្តការងារដោយទទួលលទ្ធផលរួមមាន៖
ធ្វើការឈូសឆាយសម្រាប់ដាំកូនឈើបានទំហំ ៦៩០ហ.ត បណ្តុះកូនឈើបានចំនួន១ ៥០០ ០០០ដើម និងដាំដុះកូនឈើលើផ្ទៃដីទំហំ ៣៨០ហ.ត។

**ស្ថិតិការដាំឈើដោយរដ្ឋបាលព្រៃឈើ និងឯកជនឆ្នាំ២០១៣ - ២០១៧**

| ឆ្នាំ | ដាំឈើជាចម្ការ (ហ.ត) | | | | រុក្ខទិវា (ហ.ត) | | សរុប |
|---|---|---|---|---|---|---|---|
| | រដ្ឋ.ព | ដៃគូអភិវឌ្ឍន៍ | លក្ខណៈគ្រួសារ | សម្បទានដីសេដ្ឋកិច្ច | ថ្នាក់ជាតិ | រាជធានី-ខេត្ត | |
| ២០១៣ | ៣៥០ | ៨៤៥ | | ១៦ ៦៦៥ | ២០ | ៥២,៣៥ | **១៧ ៩៣២** |
| ២០១៤ | ៤១០ | ១ ៥២១ | ៣៩ | ៣ ៨៦៣ | ២០ | ៤០,៥ | **៥ ៨៩៣,៥** |
| ២០១៥ | ៤០៥ | ១ ៨១០ | ៦០ | ៥១ ៧០៧ | ១០ | | **៥៣ ៩៩២** |
| ២០១៦ | ៣៦០ | ៥៧៥ | | ២៥០ ០៥៦,៥៨ | ១២ | ៨០,៧ | **២៥១ ០៨៤** |
| ២០១៧ | ៦៥ | ៣៨០ | | ២៦ ៣១៦,៤២ | ១០ | ២៨ | **២៦ ៧៩៩,៤២** |
| **សរុប** | **១ ៥៩០** | **៥ ១៣១** | **៩៩** | **៣៤៨ ៦០៨** | **៧២** | **២០១,៥២** | **៣៥៥ ៧០១,៥២** |

## ៤.៤. ការងារស្រាវជ្រាវ និងបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាព បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពចំនួន១០លើក រួមមាន៖ ១-ការវិភាគទិន្នន័យព្រៃឈើតាមកម្មវិធី "R" ២-ការអភិវឌ្ឍសហគ្រិនភាពដោយសហការជាមួយវិទ្យាស្ថាន EDI ៣-ការដោះស្រាយទំនាស់ក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ ៤-ការថែទាំដំណុះកូនឈើដោយធម្មជាតិ និងដើមមេផ្តល់ពូជ ៥-ការគ្រប់គ្រងថ្នាលបណ្តុះកូនឈើ ៦-ការសរសេររបាយការណ៍កំណត់ហេតុ និងការទុកដាក់ឯកសារ ៨-បច្ចេកទេសសុវឌ្ឍិកម្ម និងចុះអនុវត្តផ្ទាល់ ៧-បច្ចេកទេសបណ្តុះកូនឈើ និងការគ្រប់គ្រងថ្នាលបណ្តុះកូនឈើ ៩-ការចិញ្ចឹមគោដើម្បីសេដ្ឋកិច្ចគ្រួសារ និង១០-ការចូលរួមដោយមានការស្រាវជ្រាវ

- ការងារស្រាវជ្រាវ៖ បានធ្វើការពិសោធន៍ជាលិកាវប្បកម្មដោយបានធ្វើការផ្ទេរកូនរុក្ខជាតិពីបន្ទប់បណ្តុះពន្លឺយកទៅដាក់ដាំនៅថ្នាល (ផ្ទះកញ្ចក់) មានប្រេងខ្យល់ (Eucalyptus pellita F.muell) ឥន្ទនេល (Lagerstroemia luadonii) និងកូនអ័រគីដេបានចំនួន១១០ដើម និងបានផ្លាស់ប្តូរសារធាតុចិញ្ចឹមកូនអ័រគីដេនៅថ្នាល (ផ្ទះកញ្ចក់) បានចំនួន៣៦០ផើង និងកូនគ្រញូងបានចំនួន១៨ដើម។ ទន្ទឹមនឹងនេះបានធ្វើការផ្លាស់ប្តូរសារធាតុចិញ្ចឹមក្នុងកែវបិទជិតកូនគ្រញូងចំនួន១០ដើម កូនឥន្ទនេលចំនួន១០ដើម និងអ័រគីដេបានចំនួន៩៥៧ដើម ព្រមទាំងបានកាត់មែកដើមឈើគ្រញូងចំនួន៣៥មែក និងស្លឹកចំនួន២៥ស្លឹក នៅទីវាលមកបណ្តុះជាលិកាក្នុងកែវបិទជិត

- បានរៀបចំបោះពុម្ពឯកសារប្រវត្តិកូនអ័រគីដេ និងវិធីសាស្ត្រផលិតកូនអ័រគីដេពីគ្រាប់ (ប្រភេទRoyal orchids) ចំនួន២៥ក្បាល។

## ៤.៥. ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

- ទទួលសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃពីរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន ១ ៤២៨ករណី ថយចុះ ៦២ករណី ស្មើនឹង៤,១៦% បើប្រៀបធៀបឆ្នាំ២០១៦ មានចំនួន១ ៤៩០ករណី ដែលក្នុងនោះសំណុំរឿង បទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន៦៥០ករណី និងសំណុំរឿងបទល្មើសព្រៃឈើដែលត្រូវបញ្ជូនទៅតុលាការចំនួន៧៧៨ករណី និងបានដកហូតរណារយន្តចំនួន៥២គ្រឿង

- រដ្ឋបាលព្រៃឈើបានធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋាននានារបស់រាជរដ្ឋាភិបាលចំនួន ៥៨លើក មានអ្នកចូលរួម ១ ៦៦៧នាក់ ក្នុងនោះស្រី ៥៣៣នាក់ និងចែកឯកសារពាក់ព័ន្ធចំនួន៣ ៦៣១ច្បាប់

- ចុះពង្រឹងការអនុវត្តច្បាប់ចំនួន១០៨លើក និងបានស្រង់ព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើ ក្នុងបណ្តាញសារព័ត៌មាននានាចំនួន១ ៣៧៥ករណី ហើយបានបញ្ជូនចំណិតសារព័ត៌មានចំនួន១៨៣ករណី ទៅខណ្ឌរដ្ឋបាលព្រៃឈើធ្វើការបំភ្លឺ តាមរយៈមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត និងទទួលរបាយការណ៍បំភ្លឺពីខណ្ឌរដ្ឋបាលព្រៃឈើចំនួន១២១ករណី។

ក្រាហ្វិកបង្ហាញអំពីសំណុំរឿងបទល្មើសព្រៃឈើ



### ៤.៦. ការងារអភិរក្សសត្វព្រៃ និងជីវចម្រុះ

- ចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យវត្តមានសត្វព្រៃបានចំនួន៨លើក នៅខេត្តចំនួន៧ ដោយបានកត់ត្រាប្រភេទសត្វព្រៃសរុបចំនួន២៥១ប្រភេទ ក្នុងនោះ ថនិកសត្វមានចំនួន៦២ប្រភេទ សត្វស្លាបចំនួន១៦៣ប្រភេទ និងសត្វល្មូនចំនួន២៦ប្រភេទ សត្វសំខាន់ៗដែលបានកត់ត្រារួមមាន៖ ទន្សោង ប្រើស ឆ្កែចចក ត្រដក់តូច រំពេរទន្លេ ស្វាគ្រោស ពង្រូល ខ្លាលឿងមាស ត្រដក់ធំ ត្រយ៉ងយក្សជាដើម

- សហការជាមួយវិទ្យាស្ថានជាតិស្រាវជ្រាវជីវចម្រុះកូរ៉េ បានរៀបចំសិក្ខាសាលាអន្តរជាតិស្តីពី ខួបលើកទី១០ នៃកិច្ចសហប្រតិបត្តិការសិក្សាស្រាវជ្រាវរួមគ្នាកម្ពុជា កូរ៉េ សមិទ្ធផលសិក្សាស្រាវជ្រាវរួមគ្នា និងសារសំខាន់នៃការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ជីវចម្រុះ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧

- បានចុះសិក្សាស្វែងយល់និងប្រមូលទិន្នន័យចិញ្ចឹមសត្វព្រៃជាលក្ខណៈគ្រួសារនិងកសិដ្ឋានចំនួន៣២លើក មានចំនួន១៧២ទីតាំង និង៧កសិកដ្ឋាន ព្រមទាំងបានចុះប្រមូលសំណាកថនិកសត្វតូចៗសត្វប្រចៀវ-ជ្រឹង និងពពួកបក្សីចំនួន៩ ២៨៧សំណាក ស្មើនឹង២ ១២០ក្បាល ពីសត្វព្រៃចំនួន៨១ប្រភេទ ក្នុងរាជធានី-ខេត្តទូទាំងប្រទេសដើម្បីយកសំណាកទាំងនោះទៅវិភាគរកមេរោគ និងជំងឺដែលអាចឆ្លងពីសត្វទៅមនុស្ស

- ឆ្នាំ២០១៧ ទូទាំងប្រទេសមានកសិដ្ឋានស្វាក្ដាមចំនួន៧កន្លែង កំពុងចិញ្ចឹមនិងបង្កាត់ពូជស្វាក្ដាមចំនួន៥៥ ៧៣៤ក្បាល ហើយបានធ្វើការនាំចេញចំនួន៦ ៥៥៥ក្បាល។

### ៤.៧. ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ក្រុមហ៊ុនចំនួន១០ បានធ្វើការនាំចេញផលិតផលរានទេវតា និងឈើកែច្នៃទៅក្រៅប្រទេស មានបរិមាណសរុបចំនួន៩ ១៤៩ម$^{៣}$ ជ័រទឹកចំនួន៣៥៥តោន និងធ្យូងអាកាស្យាចំនួន៣៣តោន

- ក្រុមហ៊ុនចំនួន៤ បាននាំចូលឈើ Plywood Paticle Board Radiata MDF Chanfuta Umbila និង Wood Panel ពីប្រទេស ចិន កូរ៉េ វៀតណាម ជប៉ុន សហរដ្ឋអាមេរិក នីហ្សេរីយ៉ា ញូហ្ស៊ីលែន ខេមីរ៉ូន និងប្រទេសម៉ូហ្សាំប៊ិក មានបរិមាណចំនួន៥ ៤៦០ម$^{៣}$

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផល-អនុផលព្រៃឈើចំនួន១៣ក្រុមហ៊ុន មានបរិមាណឈើកែច្នៃសរុបចំនួន១១ ៩៥២ម$^{៣}$ ចំណាំងកម្ទេចឈើចំនួន៦ ០០០តោន ជ័រទឹកចំនួន៤៣៥តោន និងផលិតផលធ្យូងអាកាស្យាចំនួន៦០តោន ព្រមទាំងបានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលផល អនុផលព្រៃឈើចំនួន៤ក្រុមហ៊ុន មានបរិមាណឈើកែច្នៃចំនួន៦ ០១៤ម$^{៣}$។

### ៤.៨. ការប្រមូលចំណូលពីផ្នែកព្រៃឈើ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈរដ្ឋបាលព្រៃឈើ បានទទួលចំណូលពីថ្លៃសួយសារផល-អនុផលព្រៃឈើ ការលក់ ជួលទ្រព្យសម្បត្តិនិងសេវា និងការផ្តល់សេវាសាធារណៈសរុបចំនួន៣៨ ១៩៦ ៣៥២ ០៤៥រៀល ក្នុងនោះបានបង់ចូលថវិកាជាតិចំនួន៣០ ៣៨១ ០២៨ ៥៣៥រៀល បង់ចូលមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិមានចំនួន២ ០៥១ ៣៥២ ៣២៤រៀល និងផ្តល់ប្រាក់រង្វាន់មានចំនួន៥ ៧៦៣ ៩៧១ ១៨៦រៀល ។

### ៤.៩. កិច្ចសហប្រតិបត្តិការផ្នែកព្រៃឈើ

- ថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលព្រៃឈើចំនួន១២៥រូប បានអញ្ជើញទៅ ២១ប្រទេស ដើម្បីចូលរួមកិច្ចប្រជុំចំនួន២២លើក សិក្ខាសាលានៅក្រៅប្រទេសចំនួន៣៨លើក និងទស្សនកិច្ចសិក្សាចំនួន៦លើក

- បានធ្វើបច្ចុប្បន្នភាពព័ត៌មានស្តីពីការអនុវត្តគម្រោងសហប្រតិបត្តិការចំនួន១៤ ក្នុងនោះ អនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃចំនួន៨គម្រោង នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ ចំនួន២គម្រោង នាយកដ្ឋានសត្វព្រៃនិងជីវចម្រុះចំនួន២គម្រោង នាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន ចំនួន១គម្រោង និងលេខាធិការដ្ឋានរេដបូកកម្ពុជា ១គម្រោង។

### ៤.១០. ការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកព្រៃឈើ

រាជរដ្ឋាបាលភិបាលកម្ពុជាបានចេញសេចក្តីសម្រេចលេខ៥៤ សសរ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិ។ ម្យ៉ាងវិញទៀតក្រសួងក៏បានចេញប្រកាសលេខ ៣២៧ ប្រក.កសក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ ស្តីពីវិធានព្រៃឯកជន ដែលប្រកាសនេះមានគោលដៅជំរុញ និងលើកទឹកចិត្តដល់វិស័យឯកជនចូលរួមដាំដុះឈើដើម្បីបង្កើតព្រៃឯកជន អភិវឌ្ឍគម្របព្រៃដាំ និងបង្កើនប្រភពផ្គត់ផ្គង់ផលអនុផលព្រៃឈើ សម្រាប់កែច្នៃប្រើប្រាស់ក្នុងស្រុកនិងនាំចេញ ព្រមទាំងលើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពី សារៈប្រយោជន៍ នៃចម្ការព្រៃដាំ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងគាំពារបរិស្ថាន។

បន្ទាប់ពីការប្តូរឈ្មោះពីមន្ទីរកសិកម្មរាជធានីខេត្ត ទៅជាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត និងបានដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលឱ្យស្ថិតនៅក្រោមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត ក្រសួងបានចេញសេចក្តីណែនាំលេខ ២២២៣សណនកសក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ ស្តីពីរបៀបរបបការងារ និងទំនាក់ទំនងការងាររវាងរដ្ឋបាលព្រៃឈើ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត និងខណ្ឌរដ្ឋបាលព្រៃឈើ។ លើសពីនេះ ក្រសួងក៏បានចេញនូវសេចក្តីណែនាំ និងសេចក្តីសម្រេចមួយចំនួនទៀតដើម្បីគាំទ្រដល់ដំណើរការប្រតិបត្តិក្នុងវិស័យព្រៃឈើផងដែរ។

## ៥. លទ្ធផលនៃការពង្រឹងស្ថាប័ន ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

### ៥.១. លទ្ធផលសម្រេចបានលើការអនុវត្តគោលនយោបាយនិងការវិនិយោគឯកជន

### ក. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្មឆ្នាំ២០១៤-២០១៨

ក្នុងអាណត្តិទី៥នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ហើយនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីខែកក្កដា ឆ្នាំ២០១៤។ ផ្អែកលើមូលដ្ឋាននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ត្រូវមានឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ស្របជាមួយគ្នាដែរ។ នៅក្នុងផែនការយុទ្ធសាស្ត្រនេះ ក្រសួងបានកំណត់នូវកម្មវិធីថ្មីចំនួន៥ អនុកម្មវិធីថ្មីចំនួន៦៣ និងចង្កោមសកម្មភាពដែលត្រូវអនុវត្តចំនួនជាង៥០០សកម្មភាព។

ដើម្បីឲ្យការរៀបចំផែនការយុទ្ធសាស្ត្រនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចអនុវត្តមានប្រសិទ្ធភាពខ្ពស់ កិច្ចប្រជុំពិគ្រោះយោបល់ពីអ្នកពាក់ព័ន្ធនានាត្រូវបានរៀបចំឡើង ដោយមានការចូលរួមពីថ្នាក់ដឹកនាំពីគ្រប់អង្គភាពជំនាញ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន អង្គការសង្គមស៊ីវិល សំដៅធ្វើយ៉ាងណាឲ្យឯកសារយុទ្ធសាស្ត្រនេះមានលក្ខណៈល្អប្រសើរ មានតម្លាភាព និងមានភាពរលូនក្នុងវិស័យរវាងអនុវិស័យឬផ្នែកនានា ក៏ដូចជាមានភាពរលូនជាមួយវិស័យពាក់ព័ន្ធនានាផងដែរ។

ពិនិត្យជារួម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨នេះ ត្រូវបានរៀបចំកសាងឡើងសំដៅរួមចំណែកដល់ការរីកចម្រើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំសម្រាប់អនុវត្តនិងជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្ម និងការនាំចេញផលិតផលកសិកម្ម រួមនឹងការគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានផ្សព្វផ្សាយនិងដាក់ឱ្យប្រើប្រាស់កាលពីខែមករា ឆ្នាំ២០១៦ ហើយផែនការនេះគឺជាមូលដ្ឋានមួយដ៏រឹងមាំសម្រាប់ការកសាង "ផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល" និង"ថវិកាកម្មវិធីប្រចាំឆ្នាំ" របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមកទល់ពេលនេះ ការងារទាំងអស់ត្រូវបានវាយតម្លៃថាទទួលបានជោគជ័យគួរជាទីពេញចិត្ត។

### ខ. ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨-២០២០

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨-២០២០ ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៤-២០១៨ ជាពិសេសស្របតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧។

ផែនការយុទ្ធសាស្ត្រថវិកានេះ គឺជាឧបករណ៍និងជាយន្តការដ៏សំខាន់ក្នុងការបង្កើនប្រសិទ្ធភាព និងភាពសក្តិសិទ្ធនៃការប្រើប្រាស់ថវិកា ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការតម្រង់វិភាជថវិកាបម្រើឲ្យសកម្មភាពជាអាទិភាព ធ្វើយ៉ាងណាសម្រេចឲ្យបាននូវគោលនយោបាយជាយុទ្ធសាស្ត្រ និងជាអាទិភាព ក៏ដូចជាគោលនយោបាយរួម និងអនុសាសន៍គន្លឹះរបស់ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព។

ទន្ទឹមនេះដែរ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨-២០២០ បានផ្តោតជាសំខាន់លើការងារបង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ពិសេសការងារស្រាវជ្រាវ ផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការពង្រឹងសេវាកសិកម្មថ្នាក់ក្រោមជាតិឲ្យមានសមត្ថភាពបច្ចេកទេសប្រសើរជាងមុន និងជំរុញការអភិវឌ្ឍវិស័យផលិតកម្មសត្វនិងវារីវប្បកម្មឲ្យមានលក្ខណៈកាន់តែល្អប្រសើរឡើង ដើម្បីសន្តិសុខស្បៀងនិងលើកស្ទួយកម្រិតជីវភាពប្រជាកសិករឲ្យរួចផុតពីភាពក្រីក្រ។ ផែនការយុទ្ធសាស្ត្រថវិកានេះ ក៏បានរួមបញ្ចូលផងដែរនូវការអនុវត្តគោលនយោបាយជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ។ លើសពីនេះទៀតនោះ កម្មវិធីជាយុទ្ធសាស្ត្រធំ២ទៀត ក៏ត្រូវបានបន្តរៀបចំនិងជំរុញឲ្យអនុវត្តសំដៅសម្រេចបាននូវការគ្រប់គ្រងធនធានធម្មជាតិ (ព្រៃឈើនិងជលផល) ប្រកបដោយចីរភាព។ ការកំណត់នូវសូចនាករនិងគោលដៅសូចនាករតាមកម្មវិធីនីមួយៗមាន លក្ខណៈច្បាស់លាស់ជាងមុនដែលបង្កភាពងាយស្រួលក្នុងការតាមដាននិងវាយតម្លៃលើរាល់កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពនានា ដែលបានប្រើប្រាស់ធនធានហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍។ ទន្ទឹមនឹងនេះក្រសួងក៏បានពិនិត្យនិងកែសម្រួលអនុកម្មវិធីនិងចង្កោមសកម្មភាពនៃកម្មវិធីទាំង៥របស់ផែនការយុទ្ធសាស្ត្រថវិកានេះ ដើម្បីឱ្យមានសង្គតភាពជាមួយប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយក្នុងនោះអនុកម្មវិធីមានចំនួន៥៩ ចង្កោមសកម្មភាពដែលត្រូវអនុវត្តចំនួន១៦៣ និងមានថវិកាសម្រាប់ អនុវត្តសរុបចំនួន១៦៣ ២៤០ ២០០ ០០០រៀល (រួមបញ្ចូលទាំងបន្ទុកបុគ្គលិក)។ ចំពោះលទ្ធផលនៃការអនុវត្តទទួលលទ្ធផលស្មើ៩៨% ដោយប្រើប្រាស់ថវិកាស្មើ៩៤% នៃឥណទានសរុបចំនួន១៣៨ ៩៣២ ១០០ ០០០រៀល (ឥណទានថ្មីក្រោយការផ្ទេរទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត)។ លទ្ធផលដែលសម្រេចបានខាងលើនេះ អាស្រ័យដោយមានការយកចិត្តទុកដាក់និងគាំទ្រពីថ្នាក់ដឹកនាំក្រសួង និងការខិតខំប្រឹងប្រែងរបស់មន្ត្រី ជំនាញគ្រប់កម្រិត រួមជាមួយកិច្ចសហការនិងការសម្របសម្រួលល្អ ពីគ្រប់ដៃគូពាក់ព័ន្ធក្នុងការអនុវត្តសកម្មភាពឲ្យ ទទួលបានលទ្ធផលល្អប្រសើរ ស្របតាមគោលបំណងនិងគោលនយោបាយរបស់ក្រសួងក៏ដូចជារបស់រាជរដ្ឋាភិបាល ផងដែរ។

### គ. ការរៀបចំផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០

ក្រុមការងារបច្ចេកទេសរៀបចំ និងកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលមធ្យមនិងវែងរបស់ក្រសួងបានខិតខំរៀបចំតាក់តែងខ្លឹមសារនៃផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ និងបានសម្រេចនូវលទ្ធផលសំខាន់ៗជាបន្តបន្ទាប់ ដូចខាងក្រោម៖

- បានធ្វើបច្ចុប្បន្នភាពសេចក្តីសម្រេចលេខ១២១ សសរ.កសក ស្តីពីការក្រុមការងារបច្ចេកទេស និងកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលមធ្យម និងវែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានរៀបចំប្រជុំជាលក្ខណៈបច្ចេកទេសចំនួន០៣លើក ដោយទទួលបានលទ្ធផល៖ (១) ឯកភាពលើការកំណត់ **ចក្ខុវិស័យ** "កសិកម្មកម្ពុជាជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលធានាបាននូវសន្តិសុខ និងសុវត្ថិភាពស្បៀង ព្រមទាំងអាហារូបត្ថម្ភសម្រាប់វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ "**បេសកកម្ម**" ផ្តល់សេវាគាំទ្រមានគុណភាពខ្ពស់ប្រកប

ដោយលក្ខណៈវិទ្យាសាស្ត្របច្ចេកទេស បទដ្ឋានគតិយុត្តសម្រាប់បម្រើឱ្យការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។ "**គោលដៅ**" ជំរុញកំណើនកសិកម្ម និងបង្កើនការនាំចេញផលិតផលកសិកម្មប្រកបដោយគុណភាពនិងសុវត្ថិភាព តាមរយៈការលើកកម្ពស់ផលិតភាពកសិកម្ម បង្កើនតម្លៃបន្ថែម និងពង្រីកការប្រកួតប្រជែងទីផ្សារ ព្រមទាំងរក្សាបានតុល្យភាពនៃការប្រើប្រាស់ដីកសិកម្ម និងធានាការគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព" (២) ឯកភាពបង្កើតក្រុមការងារពិសេស (Core Team) ចេញពីក្រុមការងារបច្ចេកទេស និងកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលមធ្យម និងវែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីបន្តការងាររៀបចំផែនការមេនេះ។

### ឃ. ការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយជាតិពាក់ព័ន្ធ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចូលរួមរៀបចំផែនការសកម្មភាពរបស់វិស័យ ដើម្បីចូលរួមអនុវត្តនូវគោលនយោបាយជាតិពាក់ព័ន្ធមួយចំនួនរួមមាន (១) គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ ២០១៥-២០២៥ (២) គោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០ (៣) គោលនយោបាយជាតិស្តីពីមនុស្សចាស់ឆ្នាំ២០១៧-២០៣០។

ទន្ទឹមនឹងកិច្ចការរៀបចំផែនការសកម្មភាពខាងលើក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំក្រុមការងារ ដើម្បីចូលរួមអនុវត្តគោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ២០១៦-២០២៦ និងក្រុមការងារបង្គោលប្រចាំក្រសួង ដើម្បីចូលរួមអនុវត្តព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិភស្តុភារកម្ម។

### ង. ការគ្រប់គ្រងវិនិយោគឯកជន

រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្តល់ដីសម្បទានសេដ្ឋកិច្ច ក្នុងគោលបំណងលើកទឹកចិត្ត និងទាក់ទាញការវិនិយោគឯកជនទាំងក្នុងនិងក្រៅប្រទេស សំដៅអភិវឌ្ឍវិស័យកសិកម្ម កសិ-ឧស្សាហកម្ម ជាលក្ខណៈប្រពលវប្បកម្ម និងពិពិធកម្ម ដែលរួមចំណែកដល់ការបង្កើតការងារនៅជនបទ លើកស្ទួយជីវភាពប្រជាពលរដ្ឋឱ្យមានលក្ខណៈ ប្រសើរឡើង បង្កើនការនាំចេញផលិតផលកសិកម្ម និងបង្កើនចំណូលរដ្ឋសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ទាក់ទងទៅនឹងកំណែទម្រង់ដីធ្លី រាជរដ្ឋាភិបាលកម្ពុជាបន្តជំរុញល្បឿននៃការចុះបញ្ជីនិងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ទាំងដីរដ្ឋដីឯកជន និងដីសហគមន៍ជនជាតិដើមភាគតិច តាមរយៈការចុះបញ្ជីនៅក្នុងក្របខ័ណ្ឌផែនការទូទៅ និងការបន្តអនុវត្ត "គោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី" បន្តបែងចែក និងប្រើប្រាស់ដីរដ្ឋ ជាពិសេសសម្បទានដីសេដ្ឋកិច្ច ដើម្បីបម្រើផលប្រយោជន៍ នៃការអភិវឌ្ឍប្រកបដោយតម្លាភាពនិងសមធម៌ តាមរយៈការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច និងការធ្វើប្រទានកម្ម។

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការបន្តធ្វើកំណែទម្រង់ដីធ្លីដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងបែងចែក និងប្រើប្រាស់ដីធ្លី ធានាសុវត្ថិភាពនៃកម្មសិទ្ធិដីធ្លី លុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ និងការទប់ស្កាត់ការប្រមូលដីទុកដោយមិនប្រើប្រាស់ជាដើម។ ក្រោមគោលនយោបាយកំណែទម្រង់ដីធ្លីស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជា រាជរដ្ឋាភិបាលបានសម្រេចបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ចតាមរយៈបទបញ្ជា០១ បប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២។ ឆ្លើយតបទៅនឹងគោលដៅនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានបេសកកម្មដ៏ឧត្តុង្គឧត្តមក្នុងការចូលរួមចំណែកសម្រេចឲ្យបានតាមគោលការណ៍ ដែលបានកំណត់នូវគន្លឹះសកម្មភាពជាអាទិភាពរបស់រាជរដ្ឋាភិបាល។ កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងកន្លងមកត្រូវបានឆ្លុះបញ្ចាំងតាមរយៈការដាក់ចេញ និងដាក់ឲ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ និងគោលនយោបាយមួយចំនួនសំដៅជំរុញវិស័យកសិកម្មឲ្យមានកំណើន តាមរយៈការអនុវត្តកម្មវិធីអាទិភាពសំខាន់របស់ខ្លួន ក្នុងនោះ មានការងារវិនិយោគឯកជននៅក្នុងវិស័យកសិកម្មផងដែរ ពិសេសពាក់ព័ន្ធនឹងគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច ដែលរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្តល់ឲ្យក្នុងគោលបំណងលើកទឹកចិត្ត និងទាក់ទាញការវិនិយោគឯកជនទាំងក្នុង

និងក្រៅប្រទេស សំដៅអភិវឌ្ឍវិស័យកសិកម្ម កសិ-ឧស្សាហកម្ម ជាលក្ខណៈប្រពលវប្បកម្ម និងពិពិធកម្ម ដែលរួមចំណែកដល់ការបង្កើតការងារនៅជនបទ លើកស្ទួយជីវភាពប្រជាពលរដ្ឋឱ្យមានលក្ខណៈប្រសើរឡើង បង្កើនការនាំចេញផលិតផលកសិកម្ម កាត់បន្ថយចំណាកស្រុក និងបង្កើនចំណូលរដ្ឋសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ជាក់ស្តែងគិតមកដល់ពេលនេះ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលទទួលបានគោលការណ៍វិនិយោគពីរាជរដ្ឋាភិបាលកម្ពុជា និងបានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ហើយកំពុងនៅមានសុពលភាពមានចំនួនសរុប២២៩គម្រោង បន្តសុពលភាពលើផ្ទៃដី១,២២លានហ.តស្ថិតនៅក្នុង១៨ខេត្ត។ ក្នុងចំណោមគម្រោងវិនិយោគទាំង២២៩ បានអនុវត្តនិងសម្រេចបានការងារដូចខាងក្រោម៖

- ឈូសឆាយបានចំនួន៥១៣ ៤០២ ហ.ត
- ដាំដុះបានចំនួន៤៣២ ៦៦៨ ហ.ត
- សាងសង់ប្រព័ន្ធផ្លូវចំនួន១៦ ៣៣៩គីឡូម៉ែត្រ
- ប្រើប្រាស់កម្លាំងពលកម្មសរុបចំនួន៤៩ ៣៣២នាក់ ក្នុងនោះ បុគ្គលិកខ្មែរចំនួន៥ ០១៧នាក់ បុគ្គលិកបរទេសចំនួន២ ២៤៣នាក់ កម្មករខ្មែរចំនួន១៥ ៩០៧នាក់ និងកម្មករអណ្តែតចំនួន២៦ ១៦៥នាក់។

ដើម្បីបន្តនិរន្តរភាពលើការគ្រប់គ្រងនិងអភិវឌ្ឍដីសម្បទានសេដ្ឋកិច្ចឲ្យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ក្រសួងបានធ្វើការណែនាំនូវចំណុចមួយចំនួនដូចខាងក្រោម៖

ទី១. ស្នើគ្រប់ក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចទាំងអស់ បង្កើនល្បឿននៃការដាំដុះដំណាំកសិ ឧស្សាហកម្មទៅ តាមកម្មវិធីការងារនិងផែនការផលិតកម្ម ដូចដែលមានចែងលម្អិតក្នុងផែនការមេ របស់ក្រុមហ៊ុននីមួយៗ។

ទី២. ក្នុងករណីមានបញ្ហាទំនាស់ដីធ្លីស្រួចស្រាវ រាំងស្ទះដល់ដំណើរការវិនិយោគ ត្រូវសហការដោះស្រាយបញ្ហានេះជាមួយក្រសួង ពិសេសជាមួយគណៈកម្មការសម្របសម្រួលដោះស្រាយផលប៉ះពាល់ជាមួយប្រជាពលរដ្ឋដែលក្រសួងទើបបានបង្កើតឡើង។

ទី៣. ចំពោះក្រុមហ៊ុនដែលមិនទាន់បានចុះបញ្ជីដីរដ្ឋ ត្រូវខិតខំជំរុញ និងរួមសហការពន្លឿនការចុះបញ្ជីដីរដ្ឋឲ្យបានឆាប់ និងទាន់ពេលវេលា ដោយត្រូវសហការឱ្យបានល្អជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថាប័នពាក់ព័ន្ធ ពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងអាជ្ញាធរដែនដីនៅមូលដ្ឋាន។

ទី៤. ផ្អែកតាមខ្លឹមសារលិខិតជូនដំណឹងរបស់រាជរដ្ឋាភិបាល ក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចទាំងឡាយណា ដែលបានដោះស្រាយផលប៉ះពាល់រួចរាល់ ចាំបាច់ត្រូវសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីរៀបចំចុះកិច្ចសន្យាជាថ្មីឡើងវិញ លើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច និងកែសម្រួលរយៈពេលវិនិយោគពី៧០ឆ្នាំមក៥០ឆ្នាំវិញ។

ទី៥. ក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច ដែលត្រូវដល់ពេលកំណត់បង់ថ្លៃឈ្នួលដីទាំងអស់ ត្រូវរួតរះបង់ថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច ស្របតាមគោលការណ៍និងនីតិវិធីជាធរមាន។

ទី៦. ចំពោះក្រុមហ៊ុនដែលបានទទួលគោលការណ៍វិនិយោគ មុនបទបញ្ជាលេខ០១បប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាលត្រូវបន្តអនុវត្តនីតិវិធី តាមខ្លឹមសារគោលការណ៍វិនិយោគរបស់រាជរដ្ឋាភិបាល។

ទី៧. ក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចទាំងអស់ ចាំបាច់ត្រូវមានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ដែលករណីនេះគឺជាការតម្រូវមួយសម្រាប់ជួយឱ្យមានការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងអាចចូលរួមចំណែកក្នុងការកាត់បន្ថយទំនាស់បានមួយផ្នែកផងដែរ។ ដោយយោងលើភាពចាំបាច់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានស្នើដល់ក្រុមហ៊ុនត្រូវខិតខំជំរុញការធ្វើរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ រួចផ្ញើមកក្រសួងឱ្យបានឆាប់តាមតែអាចធ្វើទៅបាន។

ទី៨. ក្រសួង ស្ថាប័ន អង្គភាពជំនាញពាក់ព័ន្ធទាំងអស់ រួមទាំងអាជ្ញាធរគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តត្រូវសហការចាត់ចែងគ្រប់គ្រងលើសម្បទានដីសេដ្ឋកិច្ច ដែលបានដកហូតមកវិញក្នុងស្មារតីទទួលខុសត្រូវ ជៀសវាងការហ៊ុមព័ទ្ធកាន់កាប់យកធ្វើជាកម្មសិទ្ធិដោយអនាធិបតេយ្យ និងចាត់វិធានការតាមនីតិវិធីឱ្យបានឆាប់បំផុត។

ទី៩. ត្រូវជំរុញការអនុវត្តច្បាប់ និងគោលនយោបាយ ព្រមទាំងពង្រឹងយន្តការស្ថាប័ន ដើម្បីជំរុញការធ្វើពាណិជ្ជកម្ម និងការនាំចេញកសិផល ការលើកកម្ពស់សមត្ថភាពកែច្នៃ ការកែលម្អបន្ថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម រួមបញ្ចូលនូវយន្តការ ច្រកចេញ-ចូលតែមួយ ការពង្រឹងប្រព័ន្ធឡូជីស្ទីក ការលើកស្ទួយគុណភាពកសិផលឲ្យស្របតាមស្តង់ដារអន្តរជាតិ ការបង្កើនសមត្ថភាពក្នុងការផ្តល់ហិរញ្ញប្បទានតាមថ្លៃសមរម្យ ការលើកស្ទួយភាពជាដៃគូរវាងកសិករនិងពាណិជ្ជករ ក៏ដូចជាការលើកស្ទួយភាពជាដៃគូរវាងកសិ-ឧស្សាហកម្មខ្នាតធំ និងកសិកម្មជាលក្ខណៈគ្រួសារតាមរយៈការអនុវត្តយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា ព្រមទាំងចូលរួមកាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋ។

## ៥.២. ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នៅក្នុងឆ្នាំ២០១៧ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបន្តរៀបចំផែនការថវិកា ដោយឈរលើគោលបំណងគោលនយោបាយរួមមួយគឺ "ជំរុញកំណើនក្នុងវិស័យកសិកម្មឲ្យបានក្នុងរង្វង់៥%ក្នុងមួយឆ្នាំ តាមរយៈការលើកកម្ពស់ផលិតភាពពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម និងការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារ និងការគ្រប់គ្រងធនធានព្រៃឈើនិងជលផល ប្រកបដោយចិរភាព" និងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តជាកម្មវិធី អនុកម្មវិធិ និងចង្កោមសកម្មភាពទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង៤៥អង្គភាព ក្នុងនោះថ្នាក់កណ្តាលមានចំនួន២០អង្គភាពថវិកា និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន២៥រាជធានី ខេត្ត ។ ដើម្បីសម្រេចនូវគោលបំណងគោលនយោបាយខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលកញ្ចប់ថវិកាឆ្នាំ២០១៧ សរុបចំនួន២៧០ ១៨៧,៣លានរៀល។ ថវិកានេះត្រូវបានបែងចែក សម្រាប់រដ្ឋបាលកណ្តាលចំនួន២០៦ ២៤០,២លានរៀល និងមន្ទីររាជធានី ខេត្ត ចំនួន៦៣ ៩៤៧,១លានរៀល។ ទន្ទឹមនឹងនេះ ក្រសួងត្រូវប្រមូលចំណូលមិនមែនសារពើពន្ធបង់ចូលថវិការដ្ឋទៅតាមច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ ដែលមានទឹកប្រាក់សរុបចំនួន៣៩ ៤២៤,២លានរៀល ក្នុងនោះរដ្ឋបាលកណ្តាលចំនួន៣៧ ១២០,២លានរៀល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ចំនួន២ ៣០៤លានរៀល។ ឆ្លងតាមការអនុវត្តថវិកាជាក់ស្តែង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចបានលទ្ធផលដូចខាងក្រោម៖

### ក- ផ្នែកចំណូល

ក្នុងឆ្នាំ២០១៧ ក្រសួងសម្រេចអនុវត្តប្រមូលចំណូលសរុបបានចំនួន៦១ ០០៣,១លានរៀល ស្មើនឹង១៥៤,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ ក្នុងនោះរដ្ឋបាលកណ្តាលអនុវត្តបានចំនួន៥៧ ៦០៨,១លានរៀល ស្មើនឹង១៥៥,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ។ ការកើនឡើងទឹកប្រាក់ចំណូល គឺដោយសារ៖ (១)- ចំណូលពីផលព្រៃឈើដែលបានមកពីការបង់សួយសារឈើលើដីសម្បទានសេដ្ឋកិច្ច ដែលផ្ទេរពីក្រសួងបរិស្ថាន (២)- ចំណូលពីថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច ដែលក្រុមហ៊ុនមួយចំនួនបានបង់សងបំណុលឆ្នាំចាស់ (៣)- ចំណូលពីការលក់ផលនិងអនុផលព្រៃឈើ (៤)- ចំណូលពីការត្រួតពិនិត្យអនាម័យសាច់ និងផលដំណាំផ្សេងៗ និង (៥)- ការកើនឡើងចំណូលពីការផាកពិន័យលើសេវារបស់រដ្ឋបាលជលផល ព្រៃឈើ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងនាយកដ្ឋាននិតិកម្មកសិកម្ម។ ដោយឡែក មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត អនុវត្តប្រមូលចំណូលបានចំនួន៣ ៣៩៣,២លានរៀល ស្មើនឹង១៤៧,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧។

### ខ- ផ្នែកចំណាយ

ក្នុងឆ្នាំ២០១៧ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តចំណាយថវិកាសរុបសម្រេចបានចំនួន២៥២ ២១៣,៩លានរៀល ស្មើនឹង៩៣,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ឬស្មើនឹង៩៩,៤% ធៀបនឹងឥណទានកែតម្រូវ ក្នុងនោះ៖

- រដ្ឋបាលកណ្តាល សម្រេចបានចំនួន១៧៥ ៦៨៦,៧លានរៀល ស្មើនឹង៨៥,២%ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ឬស្មើនឹង៩២,៥% ធៀបនឹងឥណទានកែតម្រូវ។ ចំណាយចរន្តសម្រេចបានចំនួន១៣១ ០៥២,៣លានរៀល ស្មើ

នឹង៨៣,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ឬស្មើនឹង៩៣,៧% ធៀបនឹងឥណទានកែតម្រូវ។ ការអនុវត្តចំណាយចរន្តទាបជាងច្បាប់ហិរញ្ញវត្ថុនេះគឺដោយសារការផ្ទេរឥណទានថវិកាពីរដ្ឋបាលកណ្តាលទៅឲ្យខណ្ឌរដ្ឋបាលព្រៃឈើ និងជលផលនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត និងការបន្ថែមឥណទានថវិកាជំពូក៦៤ សម្រាប់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ និងចូលឆ្នាំខ្មែរ។ ចំណាយមូលធនសម្រេចបានចំនួន៤៤ ៦៣៤,៤លានរៀល ស្មើនឹង៨៩,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ។

- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចបានចំនួន៧៦ ៥២៧,២លានរៀល ស្មើនឹង១១៩,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ។ ការអនុវត្តលើសច្បាប់ហិរញ្ញវត្ថុនេះ គឺដោយសារការផ្ទេរឥណទានថវិកាជំពូក៦៤ សម្រាប់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ និងចូលឆ្នាំខ្មែរ។

## ៥.៣. ការងារសហប្រតិបត្តិការអន្តរជាតិ

### ៥.៣.១. កិច្ចសហប្រតិបត្តិការអន្តរជាតិ

កិច្ចសហប្រតិបត្តិការអន្តរជាតិត្រូវបានអនុវត្តដូចខាងក្រោម៖

– សម្របសម្រួល និងបំពេញបែបបទជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចូលរួមកិច្ចប្រជុំ សន្និសីទ វេទិកា សិក្ខាសាលា ទស្សនកិច្ច និងវគ្គបណ្តុះបណ្តាលផ្សេងៗ នៅក្រៅប្រទេសបានចំនួនសរុប ៤៧៧រូប

– រៀបចំសំណើដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងគ្រឿងឥស្សរិយយស ជូនមន្ត្រីរាជការតាមការកំណត់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

– ទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំចំនួន០៣ ៖ (១) កិច្ចប្រជុំលើកទី១២ របស់ក្រុមការងារបច្ចេកទេសអាស៊ានស្តីពីការងារស្រាវជ្រាវ និងអភិវឌ្ឍកសិកម្ម (២) កិច្ចប្រជុំលើកទី២៤ របស់គណៈកម្មការរួម ស្តីពីកិច្ចសហប្រតិបត្តិការអាស៊ានលើប្រព័ន្ធជំរុញផលិតផលកសិកម្ម និងព្រៃឈើ និង (៣) កិច្ចប្រជុំលើកទី២ របស់រដ្ឋមន្ត្រីកសិកម្ម GMS

– ទទួលបានគោលការណ៍អនុញ្ញាត ដើម្បីរៀបចំទិវាចំនួន០២ ៖ (១) ទិវាប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និង(២) ទិវាស្បៀងអាហារពិភពលោកនៅខេត្តត្បូងឃ្មុំ

– អនុវត្តគោលការណ៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល (NGOs) ទាំងអស់ដែលកំពុងសហការនៅកម្ពុជាឱ្យមានសុក្រឹតភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចាត់តាំង**ឯកឧត្តម សាន វណ្ណទី** ជាសមាជិកគណៈកម្មការអន្តរក្រសួង និងលោក**បណ្ឌិត ព្រំ សុមានី** ជាមន្ត្រីទំនាក់ទំនងក្រសួងបានរៀបចំប្រជុំផ្ទៃក្នុងជាមួយអង្គភាពជំនាញ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីវិធានការគ្រប់គ្រង និងត្រួតពិនិត្យការអនុវត្តគម្រោងសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលចំនួន ២លើក និងរៀបចំកិច្ចប្រជុំជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលកំពុងសហការក្នុងវិស័យកសិកម្ម ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការបានចំនួន១លើក។

– រៀបចំបំពេញបែបបទទៅស្ថានទូតចិន ដើម្បីស្នើសុំអ្នកជំនាញការចិនចំនួន០២រូប និងអញ្ជើញគណៈប្រតិភូចិន ចំនួន០៥រូប ដើម្បីមកទស្សនកិច្ចនៅកម្ពុជា

– សម្របសម្រួលបញ្ជូនលិខិតទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីស្នើអន្តរាគមន៍សុំអ្នកជំនាញការស្ម័គ្រចិត្តជនជាតិកូរ៉េចំនួន០២ រូប ពីទីភ្នាក់ងារ KOICA សម្រាប់បម្រើការងារនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម

– សម្របសម្រួលបញ្ជូនលិខិតទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីស្នើអន្តរាគមន៍សុំគម្រោងសំណើ ODA ចំនួន០២ គម្រោង ពីទីភ្នាក់ងារ JICA សម្រាប់អគ្គនាយកដ្ឋានកសិកម្ម និងនាយកដ្ឋានកសិ-ឧស្សាហកម្ម

– សម្របសម្រួលបញ្ជូនលិខិតទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីអន្តរាគមន៍រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីគាំទ្រ និងផ្តល់ថវិកា ព្រមទាំងបច្ចេកទេសសម្រាប់ការសាងសង់ និងប្រតិបត្តិការមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍជលផល និងវារីវប្បកម្មសមុទ្ទ នៅខេត្តទាំងបួននៃតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា។

– សម្របសម្រួលបញ្ជូនលិខិតទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អំពីការគាំទ្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកម្ពុជា ដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជប៉ុន ចំពោះការស្នើសុំឲ្យកម្ពុជា គាំទ្រការប្រើប្រាស់ត្រីបាឡែនដោយចីរភាពផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ

– ទទួលបានសិទ្ធិប្រទានពីរាជរដ្ឋាភិបាលក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបង្កើតមជ្ឈមណ្ឌលសម្របសម្រួលអាស៊ានសម្រាប់សុខភាពសត្វ និងជំងឺស៊ូណូស (Agreement on the Establishment of ASEAN Coordinating Center for Animal Health and Zoonoses)។

## ៥.៣.២. កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា

### ក. គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប (TSSD)

គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប បានអនុវត្តនៅក្នុងស្រុក ២៨ ឃុំ១៩៦ ក្នុងខេត្តគោលដៅ០៥ មានដូចជា ខេត្តត្បូងឃ្មុំ (២១ឃុំ) ខេត្តកំពង់ចាម (៤០ឃុំ) ខេត្តកំពង់ធំ (៤៥ឃុំ) ខេត្តសៀមរាប ៥៨ឃុំ) និងខេត្តបន្ទាយមានជ័យ (៣២ឃុំ) ដែលមានប្រជាជនទទួលផលប្រហែល ២ លានកន្លះ (៦៣,០០០គ្រួសារ) ។ គម្រោងបានចាប់ផ្តើមអនុវត្តពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ និងមានថវិកាសរុប ៥៥ ៣០១ ២០០,00ដុល្លារអាមេរិក ដែលក្នុងនោះមានថវិកាកម្ចីហិរញ្ញប្បទាន ជំនួយហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម និងជំនួយហិរញ្ញប្បទានរដ្ឋាភិបាលហ្វាំងឡង់ និងថវិកាបដិភាគរាជរដ្ឋាភិបាលកម្ពុជា ។ គម្រោងបានចុះកិច្ចព្រមព្រៀងហិរញ្ញប្បទានរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយធនាគារអភិវឌ្ឍន៍អាស៊ីនាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៩ សម្រាប់កម្ចីហិរញ្ញប្បទាន និងជំនួយហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) នាថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ សម្រាប់កម្ចីហិរញ្ញប្បទាន និងជំនួយហិរញ្ញប្បទានរបស់មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម បានចុះកិច្ចព្រមព្រៀងហិរញ្ញប្បទាននាថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ និងជំនួយហិរញ្ញប្បទាន របស់រដ្ឋាភិបាលហ្វាំងឡង់នាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ។

គោលដៅរបស់គម្រោងជំរុញការអភិវឌ្ឍសកម្មភាពនៅសហគមន៍មូលដ្ឋាន តាមរយៈការវិនិយោគកែលំអផលិតភាព ហេដ្ឋារចនាសម្ព័ន្ធនៅជនបទ និងការអភិវឌ្ឍធនធានមនុស្ស ។

គោលបំណងរបស់គម្រោងគឺបង្កើនជីវភាពរបស់កសិករក្រីក្រក្នុងតំបន់គោលដៅក្នុងអំឡុងឆ្នាំ២០២០។ គម្រោងមានសមាសភាគបី (១) ការអភិវឌ្ឍឃុំ-សង្កាត់តាមរយៈការផ្តល់កញ្ចប់ថវិកា (២) បង្កើនផលិតភាពកសិកម្ម និងពិពិធកម្ម (៣) ការគ្រប់គ្រងគម្រោងប្រកបដោយប្រសិទ្ធិភាព ។

ក្នុងឆ្នាំ២០១៧ គម្រោងបានអនុវត្តការចំណាយសរុបចំនួន**៣ ០២៦ ០៩៥,00ដុល្លារអាមេរិក** (**៩៨,២%**) ដែលក្នុងនោះអង្គភាពសម្របសម្រួលការអភិវឌ្ឍ បានចំណាយចំនួន ៦៩០ ៩៧៦,00ដុល្លារអាមេរិក (១០០.៣%) អគ្គនាយកដ្ឋានកសិកម្មមានចំនួន៦០៤ ៥០៤,00ដុល្លារអាមេរិក(១១៤,៤%) និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានចំនួន១ ៧៣០ ៦១៥,00ដុល្លារអាមេរិក (៩២,៩%)។ គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប បានបញ្ចប់ការអនុវត្តនាថ្ងៃទី២៨ខែកុម្ភៈឆ្នាំ២០១៨ ដោយបានចំណាយថវិកាសរុប **៤៧ ៦៤៩ ២៩១**,00 ដុល្លារអាមេរិក (**៩៤**%) និងអនុវត្តប្រកបដោយជោគជ័យជារូបវ័ន្តសរុប **៩៩**,**៨២**%។

## ខ. គម្រោងកម្មវិធីជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាពនិងបរិយាប័ន្ន អនុវិស័យជលផល និងផលិតកម្មសត្វ ក្រោមជំនួយហិរញ្ញប្បទានឥតសំណងរបស់សហភាពអឺរ៉ុប

### ខ.១. ការគាំទ្រគោលនយោបាយ

**គោលបំណង៖** គឺដើម្បីជំរុញកំណើនសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព នៃអនុវិស័យជលផល និងផលិតកម្មសត្វតាមរយៈការគាំទ្រដោយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ស្របតាមគោលការណ៍អភិក្រមគ្របដណ្តប់នៃកម្មវិធី។

**រយៈពេលអនុវត្ត៖** មានចំនួន៥ឆ្នាំ គិតចាប់ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដល់ទី១៩ ខែមិថុនា ឆ្នាំ២០១៨

**អង្គភាពអនុវត្ត៖** កម្មវិធីនេះអនុវត្តផ្ទាល់ដោយអង្គភាពចំនួនបី (១)នាយកដ្ឋានផែនការនិងស្ថិតិ (២)រដ្ឋបាលជលផល និង (៣)អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ។

លទ្ធផលសម្រេចបានរបស់សមាសភាគគាំទ្រគោលនយោបាយវិស័យកសិកម្មដែលអនុវត្តដោយនាយកដ្ឋានផែនការ និងស្ថិតិ មានដូចខាងក្រោម:

**លទ្ធផលទី១៖ បង្កើតក្របខ័ណ្ឌគោលនយោបាយ និងផែនការ រួមបញ្ចូលទាំងផែនការមេសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម**

- បានជ្រើសរើសទីប្រឹក្សារយៈពេលខ្លីដើម្បីរៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម
- បានរៀបចំកិច្ចប្រជុំចំនួនបីលើក ដើម្បីពិភាក្សាលើការពង្រាងផែនការមេសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម ដែលបានប្រារព្ធឡើងនៅថ្ងៃទី១៣ ខែកញ្ញា ថ្ងៃទី២៦ ខែកញ្ញា និងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧
- បានបែងចែកសៀវភៅមគ្គុទ្ទេសក៍សម្រាប់វិនិយោគិនលើវិស័យកសិកម្មនៅកម្ពុជា ចំនួន២៥០ច្បាប់ដល់ថ្នាក់ដឹកនាំ និងស្ថាប័នពាក់ព័ន្ធនានា

**លទ្ធផលទី២៖ ការអភិវឌ្ឍធនធានមនុស្សក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បានចុះប្រមូលទិន្នន័យសម្រាប់ការអភិវឌ្ឍធនធានមនុស្ស រួមបញ្ចូលទាំងសកម្មភាពពង្រឹងការអភិវឌ្ឍស្ថាប័ន ពីខេត្តក្រចេះ កំពង់ចាម ព្រះវិហារ សៀមរាប បាត់ដំបង ព្រះសីហនុ ត្បូងឃ្មុំ កំពង់ឆ្នាំង កណ្តាល ភ្នំពេញ និងនាយកដ្ឋានចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន១លើកស្តីអំពីការគ្រប់គ្រងមន្ទីរពិសោធន៍ នៃសាលាជាតិកសិកម្មព្រែកលៀបត្រូវបានប្រារព្ធឡើងលើកទី១ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧

**លទ្ធផលទី៤៖ គាំទ្រយុទ្ធសាស្ត្រវិស័យឯកជន ផ្តែកលើមូលដ្ឋានហិរញ្ញវត្ថុសម្រាប់ផលិតកម្មកសិកម្មគ្រួសារ និងការអភិវឌ្ឍខ្សែសង្វាក់ផលិតកម្មកសិកម្ម**

- បានផ្តល់វគ្គបណ្តុះបណ្តាលអំពីការផ្ញើសារព័ត៌មានទីផ្សារដល់មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាមចំនួន៤៦នាក់ (ស្ត្រី២១នាក់)
- បានផ្តល់វគ្គបណ្តុះបណ្តាលអំពីការផ្ញើសារព័ត៌មានទីផ្សារដល់អាជីវករនៅក្រុងភ្នំពេញចំនួន ៣០នាក់ (ស្រី២៣នាក់)

**លទ្ធផលទី៥៖ គាំទ្រកិច្ចប្រតិបត្តិការនៃក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក**

- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសកសិកម្ម និងទឹកចំនួន៣លើក

**លទ្ធផលទី៦៖ គាំទ្រការកែទម្រង់ប្រព័ន្ធគ្រប់គ្រងនិងការពង្រឹងសមត្ថភាព**

- **គាំទ្រការកសាងផែនការថវិកា និងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
  + បានបញ្ចប់របាយការណ៍វាយតម្លៃតម្រូវការវគ្គបណ្តុះបណ្តាលការគ្រប់គ្រងហិរញ្ញវត្ថុ ក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- **គាំទ្រការពង្រឹងប្រព័ន្ធស្ថិតិកសិកម្ម**

+ បានផ្ដល់វគ្គបណ្ដុះបណ្ដាលការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ សម្រាប់ការងារស្ថិតិកសិកម្មដល់មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត និងការិយាល័យកសិកម្មស្រុកចំនួន៤៦នាក់ (ស្ត្រីចំនួន៨នាក់)

○ **គាំទ្រការផ្ដល់វគ្គបណ្ដុះបណ្ដាលលើការងារវាយតម្លៃផលប៉ះពាល់បរិស្ថាន**

+ បានចុះពង្រឹងបន្ថែមអំពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ដល់មន្ត្រីមន្ទីរកសិកម្មចំនួន ៣វគ្គ នៅខេត្តតាកែវ កែប និងកំពត មានមន្ត្រីចូលរួមចំនួន ៦៣នាក់ (ស្ត្រី២១នាក់)។

### ខ.២. វឌ្ឍនភាពផ្នែកហិរញ្ញវត្ថុ

ថវិកាធានាចំណាយ (Imprest Commitment) សម្រាប់សមាសភាពគាំទ្រគោលនយោបាយកសិកម្មមានចំនួន ៤ ៩១៦ ២៦៨ ៥៨៣រៀល។ ថវិកាចំណាយសរុបសម្រាប់គម្រោងប្រតិបត្តិទី៣គិតត្រឹមត្រីមាសទី៤មានចំនួន ៥១៨ ៩៥៦ ១០០,០០ រៀល។

## គ. គម្រោងកែលម្អប្រព័ន្ធគ្រប់គ្រងអនាម័យ និងភូតគាមអនាម័យនៅមហាអនុតំបន់មេគង្គ

គម្រោងកែលម្អប្រព័ន្ធគ្រប់គ្រងអនាម័យនិងភូតគាមអនាម័យនៅក្នុងមហាអនុតំបន់មេគង្គ បានដំណើរការសកម្មភាពនិងការងារចាប់តាំងពីខែធ្នូ ឆ្នាំ២០១២ ក្នុងចំនួនថវិកាសរុប ១១,៤លានដុល្លារអាមេរិក លើសមាសភាពសំខាន់ចំនួនបួនគឺ៖

ទី១. ការពង្រឹងកម្មវិធីអង្កេតនិងតាមដាន(Strengthened Surveillance and Inspection Programs) ទី២.ការលើកកម្ពស់សមាហរណកម្មនិងកិច្ចសហការក្នុងតំបន់លើការងារអនាម័យនិងភូតគាមអនាម័យ(Improved Regional Cooperation and Harmonization)

ទី៣. ការកែលម្អកម្រិតកម្មវិធីសិក្សានិងវគ្គបំពាក់បំប៉នជំនាញអនាម័យនិងភូតគាមអនាម័យ (Enhanced Education Level/ University Training of SPS Specialists) និងទី៤. ការគ្រប់គ្រងនិងតាមដានការអនុវត្តគម្រោង(Project Management and Monitoring)។

មកដល់ដំណាច់ឆ្នាំ២០១៧នេះ គម្រោងបានអនុវត្តនិងសម្រេចបាននូវលទ្ធផលតាមផែនការសកម្មភាពដែលមានដូចខាងក្រោម៖

### ១. ការពង្រឹងកម្មវិធីអង្កេតនិងតាមដាន

គម្រោងបានអនុវត្ត លើការពង្រឹងកម្មវិធីអង្កេត និងតាមដាន ដែលទទួលបានលទ្ធផល ៨១ភាគរយ មានការត្រួតពិនិត្យឡើងវិញ និងកែសម្រួលនូវឯកសារចាំបាច់មួយចំនួន ដូចជា៖ បច្ចេកទេស និងក្របខណ្ឌគតិយុត្តនានា ស្តង់ដារនីតិវិធីប្រតិបត្តិ និងឯកសារណែនាំស្ដីពីការត្រួតពិនិត្យលើផ្នែកភូតគាមអនាម័យ សុខភាពសត្វ និងសុវត្ថិភាពចំណីអាហារ ដើម្បីសម្រួលពាណិជ្ជកម្ម និងសុខដុមនីយកម្ម បទដ្ឋានគតិយុត្ត ស្តង់ដារ និងគោលការណ៍ណែនាំបច្ចេកទេសក្នុងតំបន់មាន៖

### ១.១ ផ្នែកភូតគាមអនាម័យ (Plant Health CIU)

ផ្នែកភូតគាមអនាម័យ ដែលអនុវត្តដោយអគ្គនាយកដ្ឋានកសិកម្ម បានអនុវត្តការងារដូចជា៖

- បានបញ្ចប់អង្កេតតាមដាននិងស្រាវជ្រាវ ប្រមូលបាននូវសំណាកពីរប្រភេទ វិភាគនិងកំណត់អត្តសញ្ញាណកត្តាចង្រៃ គឺសត្វល្អិតចង្រៃ និងជម្ងឺ លើដំណាំដំឡូងមី ក្រូច និងស្វាយ ក្នុងខេត្តគោលដៅ ព្រមទាំងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងបញ្ចប់ការរៀបចំបញ្ជីសមាសភាពចង្រៃលើមុខដំណាំចំនួន០៣មុខ។ បានវិភាគកំណត់អត្តសញ្ញាណកត្តាចង្រៃ និងបញ្ចប់ការរៀបចំបញ្ជីសមាសភាពចង្រៃលើដំណាំចេក និងម្រេច ព្រមទាំងបានរៀបចំបញ្ជីសមាសភាពចង្រៃលើដំណាំស្រូវ និងពោត ដោយអង្កេត និងស្រាវជ្រាវបន្ថែមនូវលើកត្តាចង្រៃចំនួន០៣មុខបន្ថែមទៀតដូចជា បាកតេរី វីរុស និងនេម៉ាតូតក្នុងឆ្នាំ២០១៨

- ការធ្វើពិសោធន៍សុខភាពគ្រាប់ពូជ(Seed Health Testing) បានបញ្ចប់ការធ្វើពិសោធន៍សុខភាពគ្រាប់ពូជបន្លែចំនួន០៥មុខ ដែលមានពូជប៉េងប៉ោះ ម្ទេស ស្ពៃក្តោប ខាត់ណា និងត្រប់វែង ដើម្បីតាមដានកំណត់អត្តសញ្ញាណកម្មភ្នាក់ងារបង្ក ក្នុងខេត្តគោលដៅចំនួន០៥ គឺខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តបាត់ដំបង និងខេត្តកណ្តាល

- ការប្រមូលសំណាក់ថ្នាំកសិកម្មដើម្បីវិភាគគុណភាព (Pesticide Sample Collection for Quality Analysis) បានបញ្ចប់សកម្មភាពចុះប្រមូលសំណាកថ្នាំកសិកម្ម ដើម្បីវិភាគគុណភាពជំហានទី២ ក្នុងខេត្តគោលដៅចំនួន០៤ មានខេត្តតាកែវ ព្រៃវែង សៀមរាប និងខេត្តបន្ទាយមានជ័យ ដោយប្រមូលបានសំណាកចំនួន ៦០សំណាក ដែលបានចុះបញ្ជីរួចរាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ជាលទ្ធផលមានសំណាកចំនួន៥៨ សំណាក មានគុណភាពល្អនិងបានចុះបញ្ជី

- ការរៀបចំវគ្គបណ្តុះបណ្តាល បានបញ្ជូនមន្ត្រីជំនាញចំនួន១៦រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Regional individual training on plant pestលើការអង្កេត និងតាមដាន និងការរៀបចំបញ្ជីសមាសភាពចង្រៃ និងវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនៅប្រទេសហ្វីលីពីន ដើម្បីពង្រឹងសមត្ថភាព និងផ្លាស់ប្តូរបទពិសោធន៍។ ជាមួយគ្នានេះ ក៏បានរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីជំនាញអធិការកិច្ចនៅតាមច្រកព្រំដែននិងបានរៀបចំសិក្ខាសាលាស្តីពី សមាសភាពចង្រៃលើរុក្ខជាតិឈើព្រៃឈើ។

### ១.២ ផ្នែកសុខភាពសត្វ (Animal Health CIU)

ផ្នែកសុខភាពសត្វ អនុវត្តដោយអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ដោយបានលទ្ធផលដូចខាងក្រោម៖

- **ការតាមដានលើជំងឺឆ្លងសត្វយុទ្ធនាការផ្សព្វផ្សាយ** បានចុះអនុវត្តកម្មវិធីតាមដានឃ្លាំមើលជំងឺសត្វនៅក្នុងខេត្តគោលដៅចំនួន០៣ គឺខេត្តកំពង់ចាម ខេត្តតាកែវ និងខេត្តស្វាយរៀង និងបានបានប្រមូលសំណាក និងការវិភាគលើសំណាកឆ្លងជំងឺសត្វ។ យុទ្ធនាការផ្សព្វផ្សាយជំងឺឆ្លងសត្វត្រូវបានបញ្ចប់កាលខែមិថុនា ឆ្នាំ២០១៧ ដោយមានការចុះជួបជាមួយកសិករចំនួន៣៥០០នាក់ក្នុងខេត្តគោលដៅ។ ការចុះយុទ្ធនាការផ្សព្វផ្សាយនេះ បានផ្តល់ដល់កសិករនូវចំណេះដឹង និងចែកជូននូវសម្ភារ និងឯកសារមួយចំនួនក្នុងការការពារជំងឺឆ្លងសត្វនៅក្នុងតំបន់។

- **ការឆ្លើយតបនឹងការផ្ទុះឡើងនៃជំងឺឆ្លងសត្វ** បានធ្វើវិធានការឆ្លើយតបនឹងការផ្ទុះឡើងលើជំងឺឆ្លងសត្វចំនួនប្រាំបីដង នៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង ជាលទ្ធផលយើងសង្កេតឃើញមានជំងឺFMDបានកើតមានលើសត្វគោនិងក្របីផ្ទុះឡើងច្រើនជាងគេ និងជំងឺ HS បានកើតមានលើសត្វគោបីទៅបួនករណី។

- **ការអង្កេតតាមដានតាមច្រកព្រំដែន និងយុទ្ធនាការផ្សព្វផ្សាយ** បានបន្តចុះអនុវត្តកម្មវិធីអង្កេតតាមដានតាមច្រកព្រំដែនចំនួន០៤លើក ដោយបានជួបជាមួយមន្ត្រីជំនាញ និងកសិករសរុបចំនួន៤០០នាក់ នៅក្នុងខេត្តតាកែវ ព្រៃវែង ស្វាយរៀង និងកំពង់ចាម ដើម្បីត្រួតពិនិត្យការនាំចូលសត្វនិងផលិតផលមានដើមកំណើតពីសត្វ និងបានបញ្ចប់យុទ្ធនាការផ្សព្វផ្សាយចំនួន០៤លើក ដោយបានជួបជាមួយកសិករចំនួន ៣៨លើក នៅក្នុងខេត្តតាកែវ ខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ និងខេត្តស្វាយរៀង។

- **ការរៀបចំវគ្គបណ្តុះបណ្តាល៖** បើកវគ្គបណ្តុះបណ្តាលចំនួន០៥វគ្គ នៅខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តស្វាយរៀង ដើម្បីពង្រឹងសមត្ថភាពបច្ចេកទេសដល់មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្ម និងមន្ត្រីបច្ចេកទេសខេត្ត អំពីតាមដាន ការទប់ស្កាត់ និងការឆ្លើយតបពីជំងឺឆ្លងសត្វ។

- **កម្មវិធីជីវសុវត្ថិភាព** (Biosecurity Measure) បានប្រជុំផ្សព្វផ្សាយ អប់រំ និងពិភាក្សាអំពីការធ្វើជីវសុវត្ថិភាពក្នុងនោះមានការយល់ដឹងអំពីជំងឺឆ្លងសត្វ វិធានការការពារ ការព្យាបាល ការចាក់វ៉ាក់សាំង និងការលើកទឹកចិត្តឲ្យកសិករផ្សព្វផ្សាយបន្តទៅភូមិផ្សេងៗនៅក្បែរបន្តទៀត។ បានធ្វើអាងជីវសុវត្ថិភាពនៅផ្លូវដើរចូលចំនួន៨០កន្លែង ជួយចាក់សាប ក្រោលឬរោងចិញ្ចឹមសត្វ ផ្តល់ជាសំណាញ់ការពារមូសស័ង្កសី ថ្នាំសម្លាប់មេរោគ ធុងសម្រាប់

ផឹកទឹក ថ្នាំសម្លាប់មេរោគនានា ការចាក់វ៉ាក់សាំការពារព្យាបាល និងណែនាំអំពីការធ្វើជីវសុវត្ថិភាពបន្ថែម និងលើកទឹកចិត្តឲ្យកសិករចំនួន ៨០គ្រួសារ ក្នុងខេត្តស្វាយរៀង និងខេត្តព្រៃវែង បានអនុវត្តសកម្មភាពជាបន្តលើការតាមដានការអនុវត្តរបស់កសិករ ការតាមដានការផ្ទុះជំងឺសត្វ និងការរាយការណ៍របស់ពេទ្យសត្វ។

- **ប្រព័ន្ធគ្រប់គ្រងទិន្នន័យ** (Development of TAD information database) បានតម្លើងប្រព័ន្ធគ្រប់គ្រងទិន្នន័យលើការតាមដានលើជំងឺឆ្លងសត្វ និងចលនាសត្វ ដើម្បីងាយស្រួលក្នុងការតាមដាន និងស្តុកទុកឯកសារដែលពាក់ព័ន្ធនិងបញ្ហាសុខភាពសត្វ និងផលិតកម្មសត្វ។

### ១.៣ ផ្នែកសុវត្ថិភាពចំណីអាហារ (Food Safety CIU)

អនុវត្តដោយនាយកដ្ឋានឱសថ ចំណីអាហារ គ្រឿងសម្អាង និងបរិក្ខាពេទ្យ នៃក្រសួងសុខាភិបាល សហការជាមួយអគ្គនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម លើសកម្មភាពមួយចំនួនខាងក្រោម៖

- **ការតាមដានអង្កេតស្រាវជ្រាវ(Surveillance)** បានចុះអង្កេតតាមដានការចម្លងរោគគីមីនៅក្នុងម្ហូបអាហារនៅលើទីផ្សារក្នុងប្រទេសកម្ពុជាមានដូចជារាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ។ សំណាកដែលបានប្រមូលនិងបានធ្វើពិសោធន៍មានសរុបចំនួន ៧៨៥ សំណាក។ ជាលទ្ធផលបានបង្ហាញថា៖

- ការវិភាគពពួកកូលីហ្វមនៅក្នុងទឹកកកមានកូលីហ្វម ដែលបញ្ជាក់ថាកង្វះអនាម័យនៅពេលផលិត និងការដឹកជញ្ជូន ចំណែកទឹករ៉ូប៊ីនេមានវត្តមានកូលីហ្វមនៅពេលដែលបើកទុកចោល។

- ការវិភាគពពួកកូលីហ្វមនៅក្នុងចំណីអាហារដោយផ្តោតលើចំណីអាហារដែលដាក់លក់តាមផ្លូវនិងក្នុងសាលារៀនមានវត្តមានពពួកកូលីហ្វមមានភាពកង្វះអនាម័យដោយមិនបានគ្របឲ្យបានត្រឹមត្រូវ។

- ការវិភាគរកភាពស្អាតលើសម្ភារ (ចាន ស្លាបព្រា សម ចង្កឹះ កែវ កាំបិត ដៃអ្នកលក់) មានភាពមិនស្អាតដោយសារការលាងសម្អាត និងទុកដាក់មិនត្រឹមត្រូវ។

- **ការចុះធ្វើ Pre Auditing** បានសហការជាមួយជំនាញការ S2 ក្នុងការចុះធ្វើ Pre Auditing នៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តសៀមរាប នៅតាមភោជនីយដ្ឋាន និងអាហារដ្ឋានដែលមានវិញ្ញាបនបត្របញ្ជាក់អនាម័យ និងវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ មានសរុបចំនួន៣៧៥កន្លែង សម្រាប់ធ្វើសវនកម្ម។

- ***វគ្គបណ្តុះបណ្តាល និងសិក្ខាសាលា*** បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពី Food Safety Emergency and Outbreak Response នៅខេត្តសៀមរាប និងសិក្ខាសាលាចំនួន០២ទៀតគឺ សិក្ខាសាលាស្តីពីការពិនិត្យ សម្រេចក្របខណ្ឌហានិភ័យម្ហូបអាហារសម្រាប់ការនាំចូលដែលមានសក្តានុពលសម្រាប់អនុវត្តចំពោះផលិតផលក្នុងស្រុកនិង សិក្ខាសាសាស្តីពី "ការគ្រប់គ្រងអនាម័យនិងភូតគាមអនាម័យ" នៅរាជធានីភ្នំពេញមានការសហការជាមួយគម្រោង RETA 8732។

- **ការងារតាមដាន** សម្រាប់ឆ្នាំ២០១៦ និងឆ្នាំ២០១៧នេះ កំណើននៃចំនួនភោជនីយដ្ឋាន និងអាហារដ្ឋានដែលទទួលបានវិញ្ញាបនបត្របញ្ជាក់អនាម័យ និងវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ (Logo) ច្រើនគួរឲ្យកត់សម្គាល់។ មានភោជនីយដ្ឋាន និងអាហារដ្ឋានដែលទទួលបាន៖ វិញ្ញាបនបត្របញ្ជាក់អនាម័យមានចំនួន ១១៧៧កន្លែង ស្លាកសញ្ញា Logo A មានចំនួន ២១៥កន្លែង ស្លាកសញ្ញា Logo B មានចំនួន ៤០កន្លែង ស្លាកសញ្ញា Logo C មានចំនួន ០១កន្លែង។

- **ការរៀបចំរបាយការណ៍** INFOSAN **និង** ARASFF៖ បានរៀបចំរបាយការណ៍ INFOSAN និង ARASFFសម្រាប់ឆ្នាំ២០១៦ និងឆ្នាំ២០១៧ ដោយបានឆ្លងថ្នាក់ដឹកនាំក្រសួងសាមី និងស្ថាប័នពាក់ព័ន្ធ រួចនឹងបញ្ជូនមកអង្គភាពគ្រប់គ្រងគម្រោងដើម្បីបោះពុម្ព និងផ្សព្វផ្សាយ។

ការជំរុញការធ្វើសមាហរណកម្មនិងកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ាននិងមហាអនុតំបន់មេគង្គ បានរៀបចំ Concept Note ក្នុងការជំរុញការធ្វើសមាហរណកម្ម និងកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ាន និងមហាអនុ

តំបន់មេគង្គ ដើម្បីរៀបចំយន្តការមួយដែលឆ្ពោះទៅការដាក់ចេញនូវកិច្ចព្រមព្រៀងលើកកម្ពស់អនាម័យ និងភូតគាមអនាម័យបំពេញឲ្យការសម្របសម្រួលពាណិជ្ជកម្មជាសំខាន់ជាមួយប្រទេសក្នុងមហាអនុតំបន់មេគង្គ ដូចជាប្រទេសវៀតណាម ថៃ ឡាវ និងចិនខណៈដែលកិច្ចសហប្រតិបត្តិការលើផ្នែកនេះមិនទាន់បានអនុវត្តពេញលេញនៅឡើយ។ កិច្ចសហប្រតិបត្តិការនេះនឹងគ្រោងអនុវត្តក្នុងឆមាសបន្ទាប់ឆ្នាំ២០១៧ នេះ។

### ២. ការលើកកម្ពស់សមាហរណកម្មនិងកិច្ចសហការក្នុងតំបន់លើការងារអនាម័យ និងភូតគាមអនាម័យ

ផ្នែកអប់រំដែលមានសាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA)បានអនុវត្តសកម្មភាពដូចខាងក្រោម៖

- **ការរៀបចំវគ្គបណ្តុះបណ្តាល** បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "សុវត្ថិភាពចំណីអាហា និងការគ្រប់គ្រងក្រោយពេលប្រមូលផលបន្លែ និងផ្លែឈើ" នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដោយមានអ្នកចូលរួមចំនួន ២៥នាក់ ក្នុងនោះមានស្ត្រីចំនួន០៨នាក់។ បានបញ្ជូនសាស្ត្រាចារ្យចូលរួមវគ្គបណ្តុះបណ្តាលនៅបរទេសចំនួន០២លើក និងបានរៀបចំវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០៩វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៣២៦រូប។
- **កិច្ចប្រជុំពិភាក្សាអំពីកិច្ចសហប្រតិបត្តិការកម្មវិធីសិក្សាស្រាវជ្រាវ** បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយសាកលវិទ្យាល័យកាលីហ្វ័នីញ៉ា (UC Davis) នៅសហរដ្ឋអាមេរិក ទស្សនកិច្ចមន្ទីរពិសោធន៍ស្តង់ដារ ថ្នាក់ដឹកនាំគម្រោងនិងផ្នែកអប់រំ។ ផ្នែកអប់រំគ្រោងនឹងរៀបចំទស្សនកិច្ចសិក្សាជាលើកទី២ ក្នុងឆ្នាំ២០១៨ខាងមុខនេះ ក្នុងគោលបំណងដើម្បីពិភាក្សាលើកម្មវិធីសិក្សាស្រាវជ្រាវមួយចំនួនក្នុងគោលដៅពង្រឹងការគ្រប់គ្រង និងការស្រាវជ្រាវរបស់មន្ទីរពិសោធន៍មីក្រូជីវសាស្ត្រ។
- **កម្មវិធីស្រាវជ្រាវលើ** Aflatoxins កំពុងអនុវត្តកម្មវិធី Detection of Aflatoxins in Agricultural Products (rice, maize, groundnuts and soybeans) from selected producers, suppliers and wet markets ដើម្បីកំណត់អំពីវត្តមាននៃ AflatoxinB1 ឬក៏សារធាតុ Aflatoxins ទាំងអស់នៅក្នុងផលិតផលពាក់កណ្តាលសម្រេច និងគ្រាប់ពូជ និងលើកជាសំណើនូវវិធានការបង្ការនានា។ ជាលទ្ធផលជំហានដំបូង ផ្នែកអប់រំបានប្រមូលសំណាកបានចំនួន ១៨២សំណាកនិងសំណាកគំរូបន្ទាប់ពីបណ្តុះចំនួន ១០១សំណាក ហើយជំហានបន្ទាប់គឺជាការវិភាគដោយប្រើប្រាស់ Test Kit ដើម្បីបញ្ជាក់លើកម្រិតជាភាគរយនៃ Aflatoxinsក្នុងសំណាក។ បន្ទាប់ពីការប្រមូលសំណាក និងការវិភាគត្រូវបានបញ្ចប់ ផ្នែកអប់រំនឹងរៀបចំសិក្ខាសាលាផ្សព្វផ្សាយក្នុងឆ្នាំ២០១៨។

### ៣. ផ្នែកសំណង់ស៊ីវិល (Civil Works)

បាននូវការងារជួសជុលអាគារមួយចំនួនដូចជា៖ (១)-ការជួសជុលកែសម្រួលបន្ទប់ពិសោធន៍ សម្រាប់ដាក់ម៉ាស៊ីន UPLC និងឧបករណ៍បំពាក់មួយចំនួនដើម្បីដំណើរការវិភាគកាកសំណល់បសុឱសថនៅក្នុងសាច់សត្វ និងសារធាតុគីមីនៅក្នុងចំណីសត្វនៅមន្ទីរពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ នៃផ្នែកអនុវត្តគម្រោងសុខភាពសត្វ (២)- ជួសជុលការខូចខាតផ្នែកខ្លះនៃអគារផ្ទះកញ្ចក់ (Post Entry Quarantine Green House) នៅស្ថានីយ៍ការពារដំណាំពោធិលាស់ ខេត្តព្រៃវែង និង(៣)- ការងារជួសជុលបន្ថែមមួយចំនួននៃអគារមន្ទីរពិសោធន៍មីក្រូជីវសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

## ឃ. កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ(ASPIRE) ជាកម្មវិធីជាតិមួយដែលមានទឹកប្រាក់សរុបចំនួន ៥២.៤ លានដុល្លារអាមេរិក ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២២ នៅខេត្តគោលដៅចំនួន១១ មានខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់ ខេត្តបាត់ដំបង ខេត្តព្រះវិហារ ខេត្តក្រចេះ ហើយនៅឆ្នាំ ២០១៨ កម្មវិធីបានពង្រីកទៅខេត្តស្ទឹងត្រែង ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តព្រៃវែង និងខេត្តស្វាយរៀង។ កម្មវិធីមានគោលបំណងនៅឆ្នាំ២០២១ គំរូនៃសេវាផ្សព្វផ្សាយកសិកម្មនៅកម្ពុជាមានប្រសិទ្ធភាពនិងជួយកសិករខ្នាតតូចក្នុងការរួមចំណែកដល់កំណើនសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការធ្វើអាជីវកម្មកសិកម្មទទួលបានប្រាក់ចំណេញនិងមានភាពធន់។ គោលដៅរបស់កម្មវិធីគឺ៖ ១) តម្លៃផលិតកម្មកសិកម្មជាមធ្យមរបស់គ្រួសារគោលដៅ១២០.០០០ គ្រួសារ

កើនឡើង១៥% ២) តម្លៃទ្រព្យសម្បត្តិគ្រួសារកើនឡើង ២៥% (រាប់បញ្ចូលទាំងគ្រួសារងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ)។ កម្មវិធីមានសមាសភាព៤ គឺ៖

- ការរៀបចំ និងអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្ម
- ការអភិវឌ្ឍន៍សមត្ថភាពសេវាផ្សព្វផ្សាយកសិកម្ម
- ការកែលម្អសេវាផ្សព្វផ្សាយកសិកម្ម និង
- ការគាំទ្រហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តកសិកម្មធន់នឹងការប្រែប្រួលអាកាសធាតុ។

មកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ កម្មវិធី ASPIRE បានចំណាយថវិកាអស់សរុបចំនួន១១ ៥១៥ ១៣២ ដុល្លារអាមេរិក ស្មើនឹង២២% នៃថវិកាកម្មវិធីសរុបចំនួន៥២ ៥៨០ ១១៩ដុល្លារអាមេរិក ដែលជាហិរញ្ញប្បទានរបស់មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម-IFAD និងបានសម្រេចនូវលទ្ធផលដូចខាងក្រោម៖

**១). ការរៀបចំ និងអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មៈ៖**

- ពង្រឹងសមត្ថភាពដល់៤៦អង្គភាពថវិកាទាំងនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋានមានជំនាញក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី រួមទាំងរបៀបប្រើប្រាស់ថវិកា និងដំណើរការតាមដាននិងវាយតម្លៃ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២៥រាជធានី ខេត្តបានទទួលការបណ្តុះបណ្តាល និងមានសមត្ថភាពរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មខេត្ត
- រៀបចំគោលការណ៍និងវិភាជន៍ថវិកាជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងខេត្តគោលដៅកម្មវិធីអនុវត្តតាមគោលការណ៍ស្តីពីគម្រោងគាំទ្រសេវាផ្សព្វផ្សាយកសិកម្ម (Grant Extension Support Services-GESS) តាមយន្តការថវិកាតាមកម្មវិធី
- កៀរគរដៃគូអភិវឌ្ឍន៍ចូលរួមគាំទ្រការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា មាន USAID (for CESAIN) និង EU។

**២). ការអភិវឌ្ឍសមត្ថភាពផ្សព្វផ្សាយកសិកម្ម៖**

គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាបានដំណើរការអនុវត្ត ដោយមានសមត្ថភាពផ្តល់សេវា និងយុទ្ធសាស្ត្រអភិឌ្ឍន៍ធនធានមនុស្សផ្សព្វផ្សាយកសិកម្មដោយមាន៖

**២.១. ការកែលំអគុណភាព និងចំណេះដឹងផ្សព្វផ្សាយកសិកម្ម**

បានរៀបចំ និងដំណើរការកិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាយោបល់ សម្រាប់ផ្សព្វផ្សាយកសិកម្ម និងអនុគណៈកម្មាធិការបច្ចេកវិទ្យាកសិកម្មថ្នាក់ជាតិចំនួន៣លើក និងអនុម័តលើសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រចំនួន៣ និងគោលការណ៍ណែនាំចំនួន៦ និងឯកសារប្រតិបត្តិមជ្ឈមណ្ឌលបណ្តុំព័ត៌មានកសិកម្ម និងគេហទំព័រផ្សព្វផ្សាយកសិកម្មដែលមានឯកសារផ្សព្វផ្សាយមាន៖

- ឯកសារព្រាងក្របខណ្ឌយុទ្ធសាស្ត្រផ្សព្វផ្សាយកសិកម្មនៅកម្ពុជា យុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សផ្សព្វផ្សាយកសិកម្មនៅកម្ពុជា និងយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានកសិកម្ម (Mass Media)
- ឯកសារគោលការណ៍ណែនាំចំនួន៦គឺ៖ គោលការណ៍ណែនាំស្តីពីតួនាទី និងការទទួលខុសត្រូវការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា គោលការណ៍ណែនាំធានាគុណភាពផ្សព្វផ្សាយកសិកម្ម ការអនុវត្តការផ្សព្វផ្សាយពីកសិករទៅកសិករ ការអនុវត្តកិច្ចសន្យាខាងក្រៅ និងការអនុវត្តភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន
- បានដំណើរប្រតិបត្តិមជ្ឈមណ្ឌលបណ្តុំព័ត៌មានកសិកម្ម (Extension hub) និងគេហទំព័រផ្សព្វផ្សាយកសិកម្ម (Extension portal) បានតម្លើង ឧបករណ៍ និងសម្ភារស្តុកឯកសារ (Server) និងផ្ទុកឯកសារផ្សព្វផ្សាយនៅក្នុង Cloud តាមគេហទំព័រផ្សព្វផ្សាយ www.khmeragri.info ដែលមានឯកសារផ្សព្វផ្សាយចំនួន ២១០ឯកសារ និងបានបណ្តុះបណ្តាលមន្ត្រីជំនាញ ៧នាក់សម្រាប់គ្រប់គ្រង និងប្រតិបត្តិ

និងមានអ្នកចូលមើល និងទាញឯកសារផ្សព្វផ្សាយចំនួន ១២ ០៥០នាក់។ មានភ្នាក់ងារកសិកម្មឃុំចំនួន ១៨០នាក់ ស្រី ៨៥នាក់ ទទួលបានការប្រើប្រាស់ឯកសារផ្សព្វផ្សាយកសិកម្មពីគេហទំព័រផ្សព្វផ្សាយ។

- បានធ្វើបច្ចុប្បន្នភាព និងបានបណ្តុះបណ្តាលដល់មន្ត្រីផ្សព្វផ្សាយចំនួន១៩១នាក់ ស្រី៥១នាក់ នូវឯកសារគោលការណ៍ណែនាំស្តីពីការវាយតម្លៃលទ្ធផលមន្ត្រីផ្សព្វផ្សាយកសិកម្ម និងបានអនុវត្តវាយតម្លៃលទ្ធផលមន្ត្រីសាកល្បង១១១នាក់ នៃមន្ត្រី៣៦៥នាក់ នៅក្នុងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ការិយាល័យផ្សព្វផ្សាយកសិកម្មខេត្ត និងការិយាល័យកសិកម្មស្រុក ក្នុងខេត្តគោលដៅកម្មវិធី ASPIRE។

### ២.២. ការពង្រឹងសមត្ថភាពធនធានមនុស្សសម្រាប់ផ្សព្វផ្សាយកសិកម្ម

- បានរៀបចំ និងអនុវត្តកម្មវិធីសិក្សាមន្ត្រីជំនាញ និងឯកទេសផ្សព្វផ្សាយកសិកម្ម និងការសិក្សាតាមប្រព័ន្ធអេឡិត្រូនិកសម្រាប់អ្នកផ្សព្វផ្សាយឃុំ និងបានបណ្តុះបណ្តាលមន្ត្រី ជំនាញផ្សព្វផ្សាយកសិកម្ម បន្ថែមសរុបចំនួន៦២នាក់ ស្រី២២នាក់ និងបណ្តុះបណ្តាល ភ្នាក់ងារផ្សព្វផ្សាយឃុំស្តីពីការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកចំនួន៣០នាក់ ស្រី២៤នាក់
- បណ្តុះបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំបន្ថែមចំនួន៥វគ្គ ដែលមានអ្នកចូលរួមចំនួន១២៣ នាក់ ស្រី២៥នាក់
- បានរៀបចំសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សផ្សព្វផ្សាយកសិកម្ម
- បានបញ្ជូនសាស្ត្រាចារ្យ និងគ្រូចំនួន៣នាក់ ទៅកម្មសិក្សាចំនួន២វគ្គ ស្តីពីរៀបចំកម្មវិធីសិក្សា និងការអប់រំផ្សព្វផ្សាយកសិកម្ម នៅសាកលវិទ្យាល័យប្រទេសវៀតណាម។

### ២.៣. ការគាំទ្រការកែលម្អសេវាផ្សព្វផ្សាយកសិកម្ម

ការគាំទ្រការកែលម្អសេវាផ្សព្វផ្សាយកសិកម្ម មានការរៀបចំនិងបណ្តុះបណ្តាលស្តីពីឯកសារ គោលការណ៍គម្រោងជាដៃគូររវាងរដ្ឋនិងឯកជន គម្រោងកិច្ចសន្យាពីខាងក្រៅ ការវាយតម្លៃលទ្ធផលការងារមន្ត្រីផ្សព្វផ្សាយ ការផ្សព្វផ្សាយពីកសិករទៅកសិករ និងការធានាគុណភាពសេវាផ្សព្វផ្សាយកសិកម្ម និងគោលការណ៍ណែនាំនានា ចំនួន ២៣វគ្គដែលមានមន្ត្រីផ្សព្វផ្សាយ ៣៦៥ នាក់ចូលរួម ស្រី៣១ នាក់។ បានបណ្តុះបណ្តាលបំពេញបន្ថែម (Refresh Training) ដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំចំនួនវគ្គមានអ្នកចូលរួមចំនួន៩៦នាក់ ស្រី៥០នាក់ បានយល់ដឹងសម្រាប់គាំទ្រកម្មវិធី។

## ៣. ការកែលំអសេវាផ្សព្វផ្សាយកសិកម្ម

បានអនុវត្តគម្រោងគាំទ្រសេវាផ្សព្វផ្សាយកសិកម្ម (GESS) តាមរយៈជួយគាំទ្រកសិករតាមវិធីសាស្ត្រ៖ ១)-ណែនាំប្រព័ន្ធកសិកម្មដែលមានភាពធន់ ២)-សិក្សាពីតម្រូវការទីផ្សារនិងការបង្កើតក្រុមផលិត ៣)-បង្កើតកន្លែងបណ្តុះពូជដំណាំ ៤)-សហការជាមួយវិស័យឯកជនសម្រាប់រួមចំណែកក្នុងការផ្តល់សេវាកសិកម្ម។ វិធីសាស្ត្រទាំងនេះបានរួមចំណែកជួយដល់គ្រួសារកសិករមានចំនួនដូចខាងក្រោម៖

- កសិករចំនួន ២០ ៩៦២នាក់ បានទទួលការបណ្តុះបណ្តាលលើមុខជំនាញដំណាំ (ស្ត្រីចំនួន១១ ៤៨០)
- កសិករចំនួ១៩ ៦២២នាក់ បានទទួលការបណ្តុះបណ្តាលលើមុខជំនាញចិញ្ចឹមសត្វ (ស្ត្រីចំនួន៩ ៩៤៥នាក់)
- កសិករចំនួន៣ ៤១៨គ្រួសារ បានទទួលយកនូវបច្ចេកទេសថ្មីពីកម្មវិធី និងមានវិធានការសម្រាប់ទប់ទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ
- កសិករចំនួន ២ ៩៧៣គ្រួសារ បានទទួលប្រាក់ចំណេញពីការអនុវត្តបច្ចេកទេសថ្មី។

## ៤. ការគាំទ្រហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តកសិកម្មធន់នឹងការប្រែប្រួលអាកាសធាតុ

កម្មវិធីបានសហការជាមួយអាជ្ញាធរឃុំ ក្នុងការរៀបចំអភិវឌ្ឍន៍លើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តកសិកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុ ដែលបានផ្តល់ថវិកាចំនួន៨០០ ០០០ដុល្លាអាមេរិក ស្មើនឹង៣០% នៃសរុបថវិកាវិនិយោគរបស់ឃុំ នៅក្នុងឃុំចំនួន៨៣

- គាំទ្រគម្រោងឃុំសរុបចំនួន៨៩គម្រោង ប្រឡាយ៣៦គម្រោង ទំនប់ទឹក១៣គម្រោងស្រះទឹក២១គម្រោង លូរបង្ហូរទឹក៥គម្រោង ផ្លូវលំជនបទ១៤គម្រោង
- កសិករងាយរងគ្រោះចំនួន១០ ០០០គ្រួសារ បានប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មានពីប្រព័ន្ធស្រោចស្រព និងអាងស្តុកទុក សម្រាប់គាំទ្រការងារផលិតកម្ម និងអាជីវកម្ម កសិកម្ម។

ក្នុងឆ្នាំ២០១៧ កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ(ASPIRE) បានលទ្ធផលគួរកត់សំគាល់និងបានសម្រេចលទ្ធផលស្មើនឹង៧៣%នៃផែនការឆ្នាំ (ព័ត៌មានលម្អិតមាននៅក្នុង www.aspirekh.org។

## ខ. កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជាជំហានទី២ឆ្នាំ២០១៧ (Cambodia Agricultural Value Chain Program II-CAVACII)

កម្មវិធីខ្សែចង្វាក់តម្លៃសិកម្មកម្ពុជាជំហានទី២(CAVAC II) ជាកម្មវិធីបន្តពីកម្មវិធីជំហ៊ានទី១(CAVAC I) ដែលជាប្រភេទជំនួយឥតសំណងមានរយៈ ៦ឆ្នាំនៅកម្ពុជា ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២១ ដោយផ្តោតទៅលើប្រភេទដំណាំ(ផ្នែកកសិកម្ម) និងការកែលម្អប្រព័ន្ធស្រោចស្រព ដែលមានថវិកាសរុប៨៩.៧០លាន ដុល្លាអូស្ត្រាលី។ កម្មវិធី CAVAC II ក្នុងគោលបំណងបង្កើនផលិតភាពនិងប្រាក់ចំណូលរបស់គ្រួសារកសិករខ្នាតតូចនិងពាណិជ្ជកម្មស្រូវ អង្ករ និងដំណាំផ្សេងៗ (ដំណាំបន្លែ និងដំណាំស្មៀងផ្សេងៗ)និងពង្រឹងប្រព័ន្ធទីផ្សារ និងវិនិយោគហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព។ លទ្ធផលបញ្ចប់កម្មវិធី CAVAC II នឹងទទួលបាន ១៣៥.០០០គ្រួសារកសិករខ្នាតតូចនឹងទទួលបានចំណេះដឹង និងអនុវត្តបច្ចេកទេសកសិកម្ម ១៨.០០០ គ្រួសារកសិករខ្នាតតូចនឹងងទទួលបានផលពីការស្រោចស្រពដោយនិរន្តរភាព និងពូជស្រូវថ្មីចំនួន៥នឹងបានបញ្ចេញនិងប្រើប្រាស់ក្នុងផលិតកម្ម។

ក្នុងឆ្នាំ២០១៧ កម្មវិធីCAVAC II មានសកម្មភាព និងទទួលបានលទ្ធផលដូចខាងក្រោម៖

សមាសភាពទី១ ផ្នែកផលិតភាព(Productivity) និងពិពិធកម្ម (Diversification)៖ បានអនុវត្តផ្តោតលើទីផ្សារជី និងថ្នាំកសិកម្ម និងការធ្វើពិពិធកម្មកសិកម្ម (Diversification) ទៅលើដំណាំជំឡូងមី ពោត និងពពួកសណ្តែក ដែលបានសហការអនុវត្តជាមួយដៃគូមានក្រុមហ៊ុនឯកជន និងអង្គភាពរដ្ឋ សម្រាប់កែលម្អការអនុវត្តក្នុងផលិតកម្មកសិកម្មរបស់កសិករចំនួន៦៣៨៨គ្រួសារ តាមរយៈការកែលម្អចំណេះដឹង និងអនុវត្តបច្ចេកទេសកសិកម្មថ្មី។

សមាសភាពទី២ ផ្នែកស្រោចស្រព និងគ្រប់គ្រងទឹកដោយផ្តោតលើការសាងសង់ ជួសជុល និងថែទាំប្រព័ន្ធស្រោចស្រព ការិយាល័យសហគមន៍កសិករប្រើប្រាស់ទឹក និងកិច្ចការគ្រប់គ្រងទឹកក្នុងស្រែ។ ជាលទ្ធផលបានបញ្ចប់ការសាងសង់ប្រព័ន្ធស្រោចស្រពចំនួន៨ (៦ពីឆ្នាំ២០១៦) និងជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តស្រោចស្រពចំនួន៦ និងបានរៀបចំសហគមន៍កសិករប្រើប្រាស់ទឹកបានចំនួន៧ សហគមន៍សម្រាប់គ្រប់គ្រង ប្រើប្រាស់ និងថែទាំប្រព័ន្ធស្រោចស្រព ដែលមានកសិករទទួលបានទឹកប្រើប្រាស់ក្នុងផលិតកម្មកសិកម្មសរុបចំនួន ១១ ៣៥៤ គ្រួសារ ហើយនៅពេលបញ្ចប់ការស្តារ និងសាងសង់ប្រព័ន្ធចំនួន២ទៀត អ្នកទទួលបានកើនឡើងបន្ថែមចំនួន២ ៤១៥ គ្រួសារទៀត។

សមាសភាពទី៣ ផ្នែកកែច្នៃអង្ករ និងការនាំចេញ គាំទ្រគោលនយោបាយផលិតកម្មស្រូវ និងនាំអង្ករចេញ ផ្តោតលើការកែលំអពូជស្រូវ សម្របសម្រួលការកែច្នៃអង្ករ និងការនាំចេញ ការអភិវឌ្ឍពូជស្រូវមានគុណភាព គ្រឿងយន្តកសិកម្ម សកម្មភាពគាំទ្រពាក់ព័ន្ធនឹងពាណិជ្ជកម្មអង្ករ ការកសាងសមត្ថភាពស្ថាប័ន និងការសិក្សា និងស្រាវជ្រាវ។ ជាលទ្ធផលបានសហការអនុវត្តជាមួយដៃគូចំនួន២៩ និងធ្វើការសិក្សាវាយតម្លៃពូជស្រូវក្រអូបចំនួន៤ ពូជដែលមានសក្តានុពលនាំចេញមានពូជស្រូវស្រាលសែនក្រអូប នឹងបញ្ចេញឱ្យប្រើប្រាស់ក្នុងផលិតកម្មស្រូវនៅពាក់កណ្តាលឆ្នាំ២០១៨ និងពូជស្រូវចំនួន២ទៀត និងបញ្ចេញនៅក្នុងឆ្នាំ២០១៩ ហើយពូជស្រូវអង្ករសគ្រាប់វែង CAR15 បានបញ្ចេញកសិករ និងរោងម៉ាស៊ីនកិនស្រូវប្រើប្រាស់ក្នុងផលិតកម្ម និងទីផ្សារ។

## ច. ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកសិកម្មនិងទឹក (TWG-AW)

ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកសិកម្មនិងទឹក (TWG-AW) បានរៀបចំកិច្ចប្រជុំចំនួន ០៥លើក ចាប់ពីខែឧសភា ឆ្នាំ២០១៧ ដល់ខែកុម្ភៈ ឆ្នាំ២០១៨ ដោយមានការចូលរួមពីសមាជិកក្រុមការងារប្រមាណ ៨៨នាក់ ក្នុងមួយលើកៗ។ កិច្ចប្រជុំបានពិភាក្សា និងតាមដានលើបញ្ហាដែលបានឯកភាពគ្នា អនុម័តកិច្ចការមួយចំនួន រួមទាំងការបង្កើតគម្រោងអភិវឌ្ឍន៍ ក្នុងគោលបំណងលើកកម្ពស់ភាពដឹកនាំ និងភាពជាម្ចាស់របស់ក្រសួងទាំងពីរ និងចែករំលែកព័ត៌មានអំពីវឌ្ឍនភាពគម្រោង ដែលបានកំពុងអនុវត្តដោយដៃគូ និងស្ថាប័នពាក់ព័ន្ធនានា។ កិច្ចប្រជុំបានពិភាក្សា និងសម្រេចការងារសំខាន់ៗមួយចំនួនរួមមាន៖

ទី១៖ ***ផែនការសកម្មភាពរបស់*** TWG-AW ***សម្រាប់ឆ្នាំ២០១៧*** ត្រូវបានរៀបចំឡើង ដោយផ្អែកលើគោលការណ៍ណែនាំស្តីពីតួនាទីនិងមុខងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ ដែលបានអនុម័ត និងដាក់ឲ្យប្រើប្រាស់ដោយរាជរដ្ឋាភិបាលនៅដើមឆ្នាំ២០១៦ ដើម្បីកំណត់ទិសដៅការងាររបស់ TWG-AW សំដៅពង្រឹងភាពជាដៃគូ និងសហប្រតិបត្តិការអភិវឌ្ឍឈានទៅធានាឲ្យបាននូវប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រសិទ្ធភាពនៃការអភិវឌ្ឍនៅកម្រិតវិស័យ។ ផែនការនេះនឹងជួយសម្របសម្រួលជាមួយសមាជិកក្រុមការងារទាំងអស់ និងគៀរគរហិរញ្ញប្បទានក្នុងការធ្វើសង្គតិភាពរវាងអាទិភាពគោលនយោបាយរបស់ក្រសួងទាំងពីរជាមួយយុទ្ធសាស្ត្រផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ តាមរយៈ (១) ការពិគ្រោះយោបល់កម្រិតគោលនយោបាយរវាងក្រសួង និងដៃគូអភិវឌ្ឍន៍ (២) ការពិភាក្សាការបង្កើតគម្រោងសម្រាប់វិស័យកសិកម្ម ក្នុងកម្រិតបច្ចេកទេស រវាងក្រសួងជាមួយនឹងដៃគូអភិវឌ្ឍន៍ និង (៣) បន្តពង្រឹងភាពជាដៃគូដែលមានស្រាប់ សំដៅធានាប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។

ទី២៖ ***ផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ២០៣០*** (Agriculture Sector Master Plan 2030) ត្រូវបានពិនិត្យ និងពិភាក្សាជាមួយសមាជិកក្រុមការងារបច្ចេកទេសចម្រុះស្តីពីកសិកម្មនិងទឹកទាំងអស់ អំពីលក្ខខណ្ឌយោងនៃផែនការមេ ដើម្បីធានាការចូលរួមពីភាគីពាក់ព័ន្ធ ពិសេសដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន និងភាពគ្រប់ជ្រុងជ្រោយនៃតម្រូវការរបស់វិស័យ។ បន្ថែមលើនេះទៀត វឌ្ឍនភាពរបស់ផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ក៏ត្រូវបានរាយការណ៍ជាប្រចាំក្នុងកិច្ចប្រជុំដល់សមាជិកក្រុមការងារ TWG-AW។ ផែនការមេនេះគាំទ្រផ្នែកហិរញ្ញវត្ថុដោយសហភាពអឺរ៉ុប (EU)។ ព្រមពេលជាមួយគ្នានេះ នៅក្នុងកិច្ចប្រជុំ TWG-AW ដៃគូអភិវឌ្ឍន៍មួយចំនួនដូចជា អង្គការកសិកម្ម និងស្បៀងអាហារ (FAO) អង្គការ IFAD អង្គការ USAID ធនាគារពិភពលោក ក៏មានការចាប់អារម្មណ៍ និងមានបំណងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដើម្បីធានាសម្រេចបាននូវផែនការមេសម្រាប់អភិវឌ្ឍន៍កសិកម្ម ២០៣០។

ទី៣៖ ***គម្រោងពិពិធកម្មកសិកម្ម*** ជាគម្រោងថ្មី ដែលនឹងគាំទ្រផ្នែកហិរញ្ញវត្ថុដោយធនាគារពិភពលោក និងបានពិភាក្សាក្នុងកិច្ចប្រជុំក្រុមការងារ TWG-AW ជាច្រើនលើក ដើម្បីប្រមូលធាតុចូលនិងយោបល់សំខាន់ពីដៃគូពាក់ព័ន្ធ ពិសេសដៃគូអភិវឌ្ឍន៍ផ្សេងទៀត សំដៅធានាសង្គតិភាពតម្រូវជាអាទិភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការគាំទ្ររបស់ធនាគារពិភពលោក ព្រមទាំងបញ្ចៀសការជាន់គ្នានៃគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ដទៃទៀត។ គម្រោងនេះស្ថិតក្នុងដំណាក់កាលសិក្សា និងរៀបចំគម្រោងនៅឡើយ និងគ្រោងអនុម័តពីធនាគារពិភពលោកនៅចុងឆ្នាំ២០១៨ ខាងមុខនេះ។ គម្រោងនេះគ្រោងនឹងដាក់ឲ្យអនុវត្តនៅដើមឆ្នាំ ២០១៩ ។

ទី៤៖ ***ឯកសារបរិស្ថានគ្របដណ្តប់សម្រាប់វិស័យកសិកម្ម ឆ្នាំ២០១៨*** *(*Enabling the Business of Agriculture *2018)* ត្រូវបានដាក់ជារបៀបវារៈមួយសម្រាប់កិច្ចប្រជុំក្រុមការងារបច្ចេកទេស TWG-AW ដែលបានស្នើដោយធនាគារពិភពលោក (World Bank) ដើម្បីប្រមូលយោបល់ និងធាតុចូលពីក្រសួង និងអ្នកពាក់ព័ន្ធដទៃសម្រាប់កែសម្រួលឯកសារនេះឲ្យកាន់តែឆ្លើយតបទៅនឹងតម្រូវការទីផ្សារកសិកម្មនៅកម្ពុជា។ ធនាគារពិភពលោកនឹងជួបពិភាក្សាបន្ថែមទៀតជាមួយនាយកដ្ឋានជំនាញ និងអ្នកពាក់ព័ន្ធផ្សេងទៀត។

ទី៥៖ ***វឌ្ឍនភាពរបស់អនុក្រុមការងារបច្ចេកទេស***

- អនុក្រុមការងារបច្ចេកទេសស្តីពីការផ្សព្វផ្សាយកសិកម្ម (Sub-Technical Working Group on Agricultural Extension) បានរៀបចំកិច្ចប្រជុំរបស់ខ្លួនចំនួន៤ដងក្នុងឆ្នាំ២០១៧ និងដើម

ឆ្នាំ២០១៨នេះ ដោយមានការចូលរួមពីសមាជិកទាំងអស់ រួមទាំងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល។ លទ្ធផលសំខាន់ៗនៃកិច្ចប្រជុំរួមមាន ការបង្កើតគេហទំព័រផ្សព្វផ្សាយកសិកម្ម មជ្ឈមណ្ឌលបណ្ណាល័យព័ត៌មានកសិកម្ម ដើម្បីប្រមូលផ្តុំព័ត៌មានកសិកម្មទាំងអស់ រួមទាំងឯកសារ ឬសៀវភៅណែនាំអំពីបច្ចេកទេសកសិកម្ម ដូចជាការដាំដំណាំ និងការរៀបចំផែនការអនុវត្តគោលនយោបាយកសិកម្ម។ អនុក្រុមការងារនេះគាំទ្រ ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដោយអង្គការ IFAD តាមរយៈកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE Program) ។

- អនុក្រុមការងារផ្នែកសុខភាពសត្វនិងផលិតកម្មសត្វ (ដែលត្រូវប្តូរឈ្មោះមកពី អនុក្រុមការងារផ្នែកបសុសត្វ) បានរៀបចំកិច្ចប្រជុំចំនួន០៣លើក ក្នុងឆ្នាំ២០១៧ និង២០១៨ ដែលមានការចូលរួមពីភាគីពាក់ព័ន្ធ ពិសេសដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីពិភាក្សាអំពីបញ្ហានានាក្នុងវិស័យបសុសត្វ។ លទ្ធផលគន្លឹះនៃកិច្ចប្រជុំ មានដូចជា ការដាក់ឲ្យប្រើប្រាស់ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ ២០១៦-២០២៥ ការបង្កើតឯកសារគតិយុត្តិ និងដំណោះស្រាយបច្ចេកទេស ។ អនុក្រុមការងារនេះគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដោយសហភាពអឺរ៉ុប តាមរយៈកម្មវិធីជម្រុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្ន។
- អនុក្រុមការងារបច្ចេកទេសស្តីពីការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ (Sub-TWG on Irrigation Scheme Management) បានរៀបចំកិច្ចប្រជុំចំនួន ០១លើក ដើម្បីពិភាក្សាអំពីលក្ខខណ្ឌយោង (TOR) របស់ក្រុមការងារ និងការស្វែងរកការគាំទ្រពីសមាជិក ពិសេសដៃគូអភិវឌ្ឍន៍នានា។ បច្ចុប្បន្ន អនុក្រុមការងារនេះកំពុងស្វែងរកការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីដំណើរការការងារអនុក្រុមការងារ ពីដៃគូអភិវឌ្ឍន៍ ក្នុងការធានាការសម្របសម្រួល និងកៀរគរហិរញ្ញប្បទាន នៅក្នុងវិស័យនេះ។

អនុក្រុមការងារបច្ចេកទេសអនុក្រុមការងារទាំងអស់ មានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ និងជាទីពេញចិត្ត។ ទោះជាយ៉ាងនេះក្តី អនុក្រុមការងារទាំងនេះ គួរត្រូវបានជម្រុញបន្ថែមក្នុងការពង្រឹងសមត្ថភាព និងទទួលបានការគាំទ្រពីថ្នាក់ដឹកនាំរបស់ខ្លួន ដើម្បីឆ្លើយតប ឲ្យកាន់តែមានប្រសិទ្ធភាព ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម ក៏ដូចជាគោលនយោបាយរបស់វិស័យកសិកម្មដទៃទៀត។

ទី៥៖ ***ដំណើរគេហទំព័ររបស់*** TWG-AW ត្រូវបានគ្រប់គ្រងដោយលេខាធិការដ្ឋាននៃក្រុមការងារ TWG-AW។ លេខាធិការដ្ឋានក៏បានបញ្ចូលឯកសារសំខាន់ជាច្រើនដូចជា យុទ្ធសាស្ត្ររបស់វិស័យកសិកម្មនិងទឹក គោលនយោបាយនានារបស់ក្រសួងទាំងពីរ (រួមមានគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម គោលនយោបាយនាំចេញអង្ករ) យុទ្ធសាស្ត្រ និងកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍នានា ដែលពាក់ព័ន្ធក្នុងវិស័យកសិកម្មនិងទឹក និងរបាយការណ៍ការប្រជុំក្រុមការងារ។ លើសពីនេះ ឯកសារសហប្រតិបត្តិការអភិវឌ្ឍកម្រិតសកលក៏ត្រូវបញ្ចូលក្នុងគេហទំព័រនេះដែរ ដើម្បីធានាការផ្តល់ព័ត៌មានអំពីសហប្រតិបត្តិការអភិវឌ្ឍឲ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយដល់សមាជិកទាំងអស់ ក៏ដូចជាសាធារណៈជនផងដែរ។

ទី៦៖ ***ការចែករំលែកព័ត៌មានដល់សមាជិកក្រុមការងារ*** ក្រៅពីការចែករំលែកព័ត៌មានអំពីការវិវឌ្ឍនៃសហប្រតិបត្តិការអភិវឌ្ឍទាំងកម្រិតសកល និងកម្រិតប្រទេសដូចជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឯកសារអំពីហិរញ្ញប្បទានអភិវឌ្ឍន៍ ព័ត៌មានអំពីការអនុវត្តគម្រោង និងកម្មវិធីរបស់សមាជិកក្រុមការងារ ពិសេសដៃគូអភិវឌ្ឍន៍បានរាយការណ៍ជូនដល់ក្រុមការងារជាប្រចាំរាល់កិច្ចប្រជុំ ដើម្បីជាការចែករំលែកព័ត៌មាន និងជាបទពិសោធន៍ដល់សមាជិកពីការអនុវត្តល្អនៃគម្រោង ឬកម្មវិធី របស់ដៃគូ។

## ឆ. គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ

គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ គឺជាគម្រោងជំនួយបច្ចេកទេសផ្លូវការរបស់រដ្ឋាភិបាលជប៉ុនដែលបានផ្តល់ឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈអង្គការJICA ដោយ

មាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃអគ្គនាយកដ្ឋានកសិកម្មជាអ្នកអនុវត្ត ដោយសហការជាមួយអង្គការ JICA នៅកម្ពុជា។ គម្រោងកំពុងអនុវត្តនៅក្នុងខេត្តគោលដៅចំនួន០៤ គឺខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពង់ចាម និងខេត្តស្វាយរៀង ដែលមានរយៈពេលប្រាំឆ្នាំ គឺចាប់ពីខែឧសភា ឆ្នាំ២០១៤ ដល់ ខែឧសភា ឆ្នាំ២០១៩។

គម្រោងមានគោលដៅបង្កើតសហគមន៍កសិកម្មគំរូនៅក្នុងខេត្តគោលដៅចំនួនបួន គឺខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពង់ចាម និងខេត្តស្វាយរៀង។ លទ្ធផលរំពឹងទុកសំខាន់ៗរបស់គម្រោងមានចំនួន០៤ គឺ ទី(១) ការពង្រឹងប្រព័ន្ធគាំទ្ររបស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគោលដៅគម្រោង ទី(២) ពង្រឹងប្រព័ន្ធគ្រប់គ្រង និងដំណើរការមុខរបររបស់សហគមន៍កសិកម្ម ទី(៣) ការបញ្ចូលមុខរបរសាកល្បងគំរូដល់សហគមន៍កសិកម្មសាកល្បង និងទី(៤) បង្កើត/ពង្រឹងបណ្តាញធុរកិច្ចសហគមន៍កសិកម្មក្នុងចំណោមសហគមន៍កសិកម្ម និងជាមួយផ្នែកឯកជន។

ចាប់ពីខែឧសភា ឆ្នាំ២០១៤ រហូតដល់ ខែធ្នូ ឆ្នាំ២០១៧ កន្លងមក គម្រោងសម្រេចបានលទ្ធផលសំខាន់ៗមួយចំនួនដែលរួមមាន៖ បានចងក្រងឯកសារបណ្តុះបណ្តាល និងគោលការណ៍ណែនាំនានាសម្រាប់សហគមន៍កសិកម្មប្រើប្រាស់បានចំនួន២៥មុខ បានបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពមន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម និងមន្ត្រីមន្ទីរកសិកម្មខេត្តគោលដៅចំនួន២២នាក់ ឱ្យក្លាយជាគ្រូបង្គោល បានបណ្តុះបណ្តាលពង្រឹងសមត្ថភាពសហគមន៍កសិកម្មចំនួន១៨០ បានជ្រើសរើសកំណត់យកសហគមន៍កសិកម្មសាកល្បងគំរូចំនួន១០ ដើម្បីអនុវត្តមុខរបរសាកល្បងគំរូចំនួន៥មុខ និងបានបង្កើត បណ្តាញធុរកិច្ចសហគមន៍កសិកម្មចំនួន០២ នៅក្នុងខេត្តគោលដៅគម្រោង។

បច្ចុប្បន្ននេះសហគមន៍កសិកម្មចំនួន១៨០ ដែលទទួលបានផលប្រយោជន៍ពីគម្រោងបានពង្រឹងសមត្ថភាពដឹកនាំនិងគ្រប់គ្រងរបស់ខ្លួនបានកាន់តែល្អប្រសើរ។ ជាងនេះទៅទៀត គម្រោងសង្ឃឹមថា សហគមន៍កសិកម្មសាកល្បង និងមុខរបរសាកល្បងគំរូដែលគាំទ្រដោយគម្រោង នឹងក្លាយទៅជាសហគមន៍កសិកម្មគំរូ និងមុខរបរគំរូរបស់សហគមន៍កសិកម្ម នៅពេលអនាគត ក្រោយពេលគម្រោងបញ្ចប់។

### ឈ. គម្រោងជំរុញផលិតកម្មស្បៀង (BFP)

ក្នុងឆ្នាំ២០១៧ គម្រោងសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ រួមទាំងការគាំទ្របណ្តុះបណ្តាលគ្រូបង្គោលដល់មន្ត្រីអនុវត្តគម្រោងនៅថ្នាក់ជាតិនិងថ្នាក់ខេត្ត ការចុះពិនិត្យនិងពង្រឹងការអនុវត្តសកម្មភាពការងារតាមខេត្តគោលដៅ ការប្រជុំថ្នាក់ដឹកនាំនិងក្រុមការងារ ក្នុងការដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើង និងការគាំទ្រផ្នែកបច្ចេកទេស ធាតុចូលកសិកម្ម ទីផ្សារ និងឧបត្ថម្ភធនដល់កសិករ និងសហគមន៍កសិកម្មផលិតពូជស្រូវ និងផលិតស្រូវចំណី ដែលចូលរួមជាមួយគម្រោង។ ការគាំទ្រសំខាន់ៗក្នុងឆ្នាំ២០១៧ ដល់កសិករ និងសហគមន៍កសិកម្មទាំងនោះរួមមាន៖

| សម្រាប់កសិករផលិតបន្លែខ្នាតមធ្យម និងធំ | សម្រាប់សហគមន៍កផលិតស្រូវពូជ និងស្រូវចំណី |
|---|---|
| -ប្រព័ន្ធស្រោចស្រពបែបទំនើបសម្រាប់កសិករចំនួន១ ៦៤០ គ្រួសារ<br>-អគារប្រមូលផ្តុំនិងលាងសម្អាតកសិផល (ចំនួន ២០)<br>-សំណាញ់ស្បៃគ្របដំណាំបន្លែ (ចំនួន ៤៦០ដុំ)<br>-ជីគីមី (ចំនួន ១៥០តោន)<br>-ឧបករណ៍ពិនិត្យជាតិពុលក្នុងបន្លែ (ចំនួន ៥០)<br>-ខិតប័ណ្ណបច្ចេកទេសសម្រាប់កសិករ<br>-វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ និងការអនុវត្តកសិកម្មល្អ (GAP) (ចំនួន៦០)<br>-ការធ្វើបង្ហាញអំពីការអនុវត្តកសិកម្មល្អ (GAP) (ចំនួន៦០)<br>-រៀបចំទស្សនកិច្ចសិក្សាសម្រាប់កសិករ | -លានហាលគ្រាប់ពូជ (ចំនួន ១៥)<br>-ឃ្លាំងស្តុកគ្រាប់ពូជ (ចំនួន ១៥)<br>-ឡសម្ងួត (ចំនួន ០៣)<br>-ម៉ាស៊ីនបក់សម្អាតគ្រាប់ពូជ (ចំនួន ៦៥)<br>-ឧបករណ៍វាស់សំណើមគ្រាប់ពូជ (ចំនួន ៤៥)<br>-ម៉ាស៊ីនច្រូតកន្ត្រៃ (ចំនួន ១៥)<br>-ម៉ាស៊ីនបោកស្រូវ (ចំនួន ១៥)<br>-វគ្គបណ្តុះបណ្តាលបច្ចេកទេស<br>-ការចុះត្រួតពិនិត្យស្រែផលិតកម្ម និងផ្តល់បច្ចេកទេសជាប្រចាំពីសំណាក់មន្ត្រីគម្រោង |

| | |
|---|---|
| -ការចុះត្រួតពិនិត្យនិងផ្តល់បច្ចេកទេសជាប្រចាំពីសំណាក់មន្ត្រីកសិកម្ម<br>-ចងក្រងជាក្រុមផលិតនិងសហគមន៍កសិកម្ម ដោយមានការរៀបចំប្រតិទិនដាំដុះសម្រាប់ក្រុមកសិករ<br>-សម្របសម្រួលទីផ្សារកសិផលបន្លែសុវត្ថិភាព និងផ្សារភ្ជាប់រវាងអ្នកលក់និងអ្នកទិញ ដោយធ្វើការស្ទង់បរិមាណតម្រូវការបន្លែជាប្រចាំ និងស្វែងរកឈ្មួញជូនកសិករ<br>-បញ្ញាក់វិញ្ញាបនបត្រការអនុវត្តកសិកម្មល្អ (GAP) ជូនកសិករ ដោយឥតគិតថ្លៃប្រសិនបើកសិករអនុវត្តតាមបទដ្ឋានបច្ចេកទេស<br>-ប្រាក់ឧបត្ថម្ភធនចំនួន១ ៩៥០ ០០រៀល ក្នុងមួយគ្រួសារ (ប្រាក់នេះនឹងប្រើប្រាស់ជាទុនបង្វិលក្នុងក្រុមរបស់កសិករ) | -ត្រួតពិនិត្យគុណភាពគ្រាប់ពូជ និងចេញវិញ្ញាបនបត្រ<br>-ធូបទកម្មគ្រប់គ្រងសមាសភាពចង្រៃក្នុងឃ្លាំង<br>-ការផ្តល់ប្រាក់ឧបត្ថម្ភធនលើការផលិតគ្រាប់ពូជស្រូវក្រអូប មានគុណភាពល្អ (ផ្តល់ឧបត្ថម្ភធន ១ ០០០រៀល/គ.ក្រ)<br>-ការផ្តល់ប្រាក់ឧបត្ថម្ភធនលើការទិញគ្រាប់ពូជស្រូវក្រអូបមានគុណភាពល្អ (ផ្តល់ឧបត្ថម្ភធន១ ០០០រៀល/គ.ក្រ) សម្រាប់ផលិតស្រូវចំណី<br>-ការផ្សារភ្ជាប់រវាងសហគមន៍និងសហគមន៍ និងសហគមន៍ជាមួយរោងម៉ាស៊ីនស្រូវ តាមរយៈការសិក្សាអំពីតម្រូវការស្រូវ ក្រអូបរបស់រោងម៉ាស៊ីនកិនស្រូវ<br>-សម្របសម្រួលការចចារនិងចុះកិច្ចសន្យារវាងសហគមន៍ និងរោងម៉ាស៊ីនកិនស្រូវ |

**១- ផ្នែកផលិតកម្មស្រូវ**

បានជ្រើសរើសសហគមន៍ផលិតពូជស្រូវនិងស្រូវចំណី ដែលមានសក្តានុពល មានផ្ទៃដីធំ ដើម្បីផលិតស្រូវក្រអូបសម្រាប់បំពេញតម្រូវការរបស់រោងម៉ាស៊ីនកិនស្រូវ និងបានផ្សារភ្ជាប់រវាងសហគមន៍ផលិតពូជស្រូវ និងសហគមន៍ផលិតស្រូវចំណី និងផ្សារភ្ជាប់សហគមន៍ផលិតស្រូវចំណីជាមួយរោងម៉ាស៊ីនកិនស្រូវ តាមរយៈការសិក្សាអំពីតម្រូវការស្រូវក្រអូបរបស់រោងម៉ាស៊ីនកិនស្រូវ សម្របសម្រួលការចរចារនិងចុះកិច្ចសន្យារវាងសហគមន៍ និងរោងម៉ាស៊ីនកិនស្រូវ។ លើសពីនេះ ក្រុមការងារបច្ចេកទេសរបស់គម្រោង សហការជាមួយមន្ត្រីអនុវត្តគម្រោងថ្នាក់ខេត្ត បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សហគមន៍ផលិតពូជស្រូវចំនួន២១សហគមន៍ និងសហគមន៍ផលិតស្រូវចំណី ចំនួន៥៥សហគមន៍ ដើម្បីធានាថាផលិតកម្មស្រូវពូជនិងស្រូវចំណី អនុវត្តទៅតាមលក្ខណៈបច្ចេកទេស។

ក្នុងឆ្នាំ២០១៧ ផលិតកម្មពូជស្រូវចុះបញ្ជីមានចំនួន២៩០តោន ផលិតកម្មពូជស្រូវវិញ្ញាបនបត្រមានចំនួន ២ ៧៦០តោន និងផលិតកម្មស្រូវចំណីមានចំនួន ៤០ ៣៣៤តោន ក្នុងនោះប្រភេទស្រូវផ្ការំដួលចំនួន ៧ ៤៤៣ តោន ស្រូវសែន ក្រអូបចំនួន៣២ ៩០០តោន។ ចំពោះការផ្សារភ្ជាប់ទីផ្សារ គម្រោងបានសម្របសម្រួលក្នុងការចុះកិច្ចសន្យាជាផ្លូវការរវាងសហគមន៍កសិកម្មនិងរោងម៉ាស៊ីនកិនស្រូវចំនួន១៦កិច្ចសន្យា ដែលមានបរិមាណស្រូវចំណីសរុបចំនួន១៣ ៥០៧តោន។

**២- ផ្នែកផលិតកម្មបន្លែ**

បានចងក្រងក្រុមកសិករផលិតបន្លែសុវត្ថិភាពចំនួន ៦០ក្រុម ដែលមានសមាជិកសរុបចំនួន ៨២០គ្រួសារ ក្នុងខេត្តគោលដៅចំនួន០៨។ បច្ចុប្បន្ន ក្រុមកសិករទាំងនេះ ត្រូវបានចងក្រងជាសហគមន៍កសិកម្មចំនួន ១២សហគមន៍ ក្រោមការគាំទ្ររបស់គម្រោងជំរុញផលិតកម្មស្បៀង។ ជាការគាំទ្រដល់កសិករ គម្រោងបានផ្តល់ធាតុចូល ដូចជាប្រព័ន្ធស្រោចស្រពទំនើប ជីគីមី កន្លែងប្រមូលផ្តុំនិងលាងសម្អាតបន្លែ និងសំណាញ់គ្របបន្លែជាដើម។

ដើម្បីដោះស្រាយបញ្ហាទីផ្សារបន្លែ គម្រោងជំរុញផលិតកម្មស្បៀងបានអនុវត្តយុទ្ធសាស្ត្រ ផ្តោតលើតម្រូវការទីផ្សារ ដោយធ្វើយ៉ាងណាឱ្យការផលិតកសិផលឆ្លើយតបនឹងតម្រូវការទីផ្សារ។ ក្នុងឆ្នាំ២០១៧ គម្រោងបានធ្វើអង្កេតអំពីតម្រូវការបន្លែរបស់អាជីវករលក់ដុំចំនួន ៣៦២នាក់ នៅក្នុងចំនួន២ដង (រដូវប្រាំង និងរដូវវស្សា) ព្រមទាំងសិក្សាពីតម្រូវការបន្លែជាប្រចាំរបស់ឈ្មួញលក់ដុំក្នុងផ្សារធំៗ ក្នុងខេត្តគោលដៅនីមួយៗព្រមទាំងក្រុមហ៊ុនលក់បន្លែសុវត្ថិភាពនានា។ លើសពីនេះ ក្រុមការងារក៏បានស្វែងរក និងធ្វើការចងក្រងឈ្មោះអ្នកប្រមូលទិញ អ្នកលក់ដុំ និងនាំកសិករឱ្យជួបជាមួយឈ្មួញផ្ទាល់តែម្តង។

**៣- ការឧបត្ថម្ភធនដល់កសិករផលិតបន្លែ ស្ថានីយផលិតពូជស្រូវ និងសហគមន៍កសិកម្ម**

ជាការជួយជ្រោមជ្រែងដល់កសិករ និងលើកទឹកចិត្តដល់កសិករក្នុងការប្រើប្រាស់ពូជស្រូវសុទ្ធល្អ គម្រោងបានផ្តល់ប្រាក់ឧបត្ថម្ភធនសម្រាប់ទិញគ្រាប់ពូជស្រូវក្រអូបមានគុណភាពល្អ ដោយក្នុងមួយគ.ក្រ ផ្តល់ឧបត្ថម្ភធន ១០០០ រៀល។

ក្នុងឆ្នាំ២០១៧នេះ គម្រោងបានផ្តល់ប្រាក់ឧបត្ថម្ភធនសរុបចំនួន ៤ ៥៥០ ០០០ ០០០រៀល ស្មើនឹង១០០% នៃផែនការ សម្រាប់ផលិត និងទិញពូជស្រូវក្រអូបសរុបចំនួន ៤ ៥៥០តោន ក្នុងការផលិតស្រូវចំណី។

ដើម្បីគាំទ្រដល់កសិករក្នុងផលិតកម្មបន្លែសុវត្ថិភាព គម្រោងបានផ្តល់ប្រាក់ឧបត្ថម្ភធនដល់កសិករខ្នាតមធ្យម ចំនួន ៨០០គ្រួសារ ក្នុងខេត្តគោលដៅទាំង៨ ដោយក្នុងមួយគ្រួសារទទួលបានប្រាក់ឧបត្ថម្ភធនចំនួន ១ ៩៥០ ០០០ រៀល ស្មើនឹង១០០% នៃផែនការ។ ប្រាក់នេះនឹងត្រូវយកទៅប្រើប្រាស់សម្រាប់បម្រើដល់ការទិញធាតុចូលផ្សេងៗ ក្នុងផលិតកម្មបន្លែរបស់ពួកគាត់ ហើយនឹងត្រូវបង្វិលក្នុងក្រុមរបស់គាត់ដើម្បីជានានិរន្តរភាព។ ដូចនេះ ប្រាក់ឧបត្ថម្ភធន សរុបសម្រាប់កសិករ ផលិតបន្លែក្នុងឆ្នាំ២០១៧ មានចំនួន ១ ៥៦០ ០០០ ០០០រៀល។

**៤- ការងារបោះពុម្ព និងផ្សព្វផ្សាយ**

ជាលទ្ធផលក្នុងការងារបោះពុម្ពឯកសារសម្រាប់ចែកចាយដល់មន្ត្រីអនុវត្តគម្រោងនិងកសិករ គម្រោងបាន បោះពុម្ព ចងក្រងជាឯកសារ និងផ្សព្វផ្សាយលទ្ធផលអង្កេត និងឯកសារផ្សេងៗទៀតសរុបចំនួន ៣៥ ៧៤៥ច្បាប់។ ដើម្បីលើកកម្ពស់ការយល់ដឹង ពីបន្លែសុវត្ថិភាព។ រៀបចំផ្សារណាត់និងពិព័ណ៌បន្លែសុវត្ថិភាពចំនួន០៥កន្លែង ក្នុងខេត្ត គោលដៅចំនួន០៥ ដែលមានថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរដែនដី កសិករ និង សាធារណៈជនចូលរួមសរុបប្រមាណជាង ១៥០០នាក់ និងបានយល់ដឹងអំពីបន្លែសុវត្ថិភាព។

## ៥.២. ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យកសិកម្ម

### ៥.២.១-ការគ្រប់គ្រងធនធានមនុស្ស

ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការសម្រេចឲ្យបាននូវស្ទូចនាករគោលដៅនៃគោលនយោបាយ នានាដែលមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការគ្រប់គ្រងធនធានមនុស្សតាមរយៈ ការសិក្សាពីតម្រូវការធនធានមនុស្សទាំងបរិមាណ និងគុណភាពដោយផ្អែកលើទំហំការងារជាក់ស្តែង ការកំណត់តួ នាទីភារកិច្ច ការពិព័ណនាការងារ ការវាយតម្លៃលើលទ្ធផលការងារ ការរៀបចំគោលនយោបាយធនធានមនុស្ស ការរៀបចំប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា ការកែទម្រង់រចនាសម្ព័ន្ធ មុខងារនិងការអនុវត្តការងារ ការចុះពង្រឹងការគ្រប់គ្រងមន្ត្រីកសិកម្មនៅតាមបណ្តាអង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាប់ជាប្រចាំ។

ក្នុងឆ្នាំ២០១៧នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមន្ត្រីរាជការសរុបចំនួន៦ ៧០៣នាក់ នារី១ ៥២២នាក់ ស្មើនឹង២២% ក្នុងនោះថ្នាក់កណ្តាលមានចំនួន២ ៧៥១នាក់ នារី៧៨៣នាក់ ស្មើនឹង២៨% ថ្នាក់រាជធានីខេត្តមានចំនួន៣ ៩៥២នាក់ នារី៧៣៩នាក់ ស្មើនឹង១៨%។ ទន្ទឹមនឹងនេះ ក្រសួងបានដាក់មន្ត្រីឲ្យ ចូលនិវត្តន៍ចំនួន១៥៧នាក់ ដាក់មន្ត្រីស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន១៤២នាក់ និងបានលុបឈ្មោះមន្ត្រីចេញពី ក្របខ័ណ្ឌចំនួន៤៧នាក់ (បោះបង់ការងារ លាឈប់ពីការងារ មរណៈភាព)។ ក្រសួងបានធ្វើការប្រឡងប្រជែង ជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីចំនួន១៨៤នាក់ (ក្របខ័ណ្ឌ ″ក″ ចំនួន១៧៤នាក់ នារីចំនួន៤៧នាក់ និង ″ខ″ ចំនួន ១០នាក់ នារីចំនួន០២នាក់ ក្នុងនោះមន្ត្រីរាជការចំនួន០៤នាក់ ។ ដើម្បីលើកទឹកចិត្តដល់មន្ត្រីរាជការដែលបានខិតខំ អនុវត្តការងារទទួលបានស្នាដៃឆ្នើម ក្រសួងបានតែងតាំង និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការបានចំនួន៤៦៧នាក់ នារីចំនួន៩៩នាក់ ព្រមទាំងបានផ្តល់គ្រឿងឥស្សរិយយសជូនដល់មន្ត្រីរាជការចំនួន៧២៩នាក់ នារីចំនួន១៤១នាក់ (ពីមេដាយសំរឹទ្ធដល់ជាតូបការ)។




ផ្អែកតាមក្រាហ្វិកនៃស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការក្នុងរយៈពេល០៥ឆ្នាំ (២០១៣-២០១៧) បង្ហាញថា ចំនួនក្របខ័ណ្ឌបានថយចុះជាបន្តបន្ទាប់ទន្ទឹមនឹងក្របខ័ណ្ឌថ្មីទទួលបានមិនមានតុល្យភាពនិងក្របខ័ណ្ឌ ដែលបានបាត់បង់។ ករណីនេះ វាជាបញ្ហាប្រឈមសម្រាប់ការចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសកម្មវិធីកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការធ្វើឲ្យសម្រេចជោគជ័យនូវផែនការយុទ្ធសាស្ត្ររបស់ក្រសួងដែលក្នុងនោះ ក្រសួងបានពង្រីករចនាសម្ព័ន្ធកសិកម្មឲ្យដល់មូលដ្ឋានឃុំ សង្កាត់ ដើម្បីជំរុញការបញ្ជ្រាបនិងផ្ទេរបច្ចេកទេសកសិកម្មឲ្យកាន់តែមានប្រសិទ្ធភាពដល់កសិករ តាមរយៈការអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មរបស់ក្រសួង។

### ៥.២.២-ការអភិវឌ្ឍធនធានមនុស្ស

នៅក្នុងនីតិកាលកន្លងមកនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលបានកំណត់អាទិភាពចម្បងចំនួន៤គឺ ផ្លូវ ទឹក ភ្លើង និងមនុស្ស ។ ប៉ុន្តែនៅក្នុងបរិបទ សេដ្ឋកិច្ចពុទ្ធិ និងបច្ចេកវិទ្យាទំនើបប្រកបដោយឧត្តមភាព និងការប្រកួតប្រជែងដែលមានសន្ទុះយ៉ាងខ្លាំងក្លា រាជរដ្ឋាភិបាល នីតិកាលទី៥នៃរដ្ឋសភាពបានផ្តល់ការយកចិត្តទុកដាក់កាន់តែខ្លាំងលើការអភិវឌ្ឍធនធានមនុស្សមានន័យថា ប្រែក្លាយអាទិភាពចម្បងចំនួន៤ គឺមនុស្ស ផ្លូវ ទឹក និងភ្លើង។

ដើម្បីឆ្លើយតបទៅនឹងការកំណត់អាទិភាព "មូលធនមនុស្ស" របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការប្រកប ដោយគុណវុឌ្ឍិខ្ពស់ តាមរយៈការបណ្តុះបណ្តាលរយៈពេលខ្លី និងរយៈពេលវែងទាំងក្នុង និងក្រៅប្រទេស។ ជាក់ស្តែងក្នុងឆ្នាំ២០១៧ កន្លងមកនេះ ក្រសួងបានបណ្តុះបណ្តាលមន្ត្រីរាជការបានចំនួន៣ ៥៨៩នាក់ នារីចំនួន៩៨៣នាក់។ វគ្គបណ្តុះបណ្តាលក្នុងប្រទេសសរុបបានចំនួន២ ៨១៥នាក់ នារី ៨១២នាក់ ក្នុងនោះវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងមធ្យមបានចំនួន២ ៨០៥នាក់ នារីចំនួន៨១០នាក់ និងបណ្តុះបណ្តាលរយៈពេលវែងបានចំនួន១០នាក់ នារីចំនួន០២នាក់។ ដោយឡែកចំពោះវគ្គបណ្តុះបណ្តាលក្រៅប្រទេសសរុបបានចំនួន ៧៧៤នាក់ នារីចំនួន១៧១នាក់ ក្នុងនោះវគ្គបណ្តុះបណ្តាលរយៈពេលខ្លីបានចំនួន៧៥៨នាក់ នារីចំនួន១៦៦នាក់ និងវគ្គបណ្តុះបណ្តាលរយៈពេលវែងបានចំនួន១៦នាក់ នារីចំនួន០៥នាក់ (ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន១២នាក់ នារី០៤នាក់ និងថ្នាក់បណ្ឌិតបានចំនួន០៤នាក់ នារី០១នាក់) ។

### ៥.២.៣-ការងារបណ្តុះបណ្តាលនិស្សិត

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានគ្រឹះស្ថានអប់រំជំនាញបីគឺ សាកលវិទ្យាល័យភូមិន្ទ កសិកម្ម (ស.វ.ភ.ក) សាលាជាតិកសិកម្មព្រែកលៀប(ក.ព.ល.) និងសាលាជាតិកសិកម្ម កំពង់ចាម(ស.ជ.ក.ក.ច)។

តារាងស្ថិតិមន្ត្រី គ្រូបង្រៀន និស្សិត របស់គ្រឹះស្ថានបណ្តុះបណ្តាលកសិកម្មទាំងបី ឆ្នាំ២០១៧-២០១៨ មានដូចខាងក្រោម៖

| លរ | គ្រឹះស្ថានសិក្សា | បណ្ឌិត | | អនុបណ្ឌិត | | បរិញ្ញាបត្រ | | បរិញ្ញាបត្ររង | | បឋម | | គ្មានជំនាញ | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | សាកលវិទ្យាល័យភូមិន្ទកសិកម្ម | | | | | | | | | | | | | | |
| ក | *ចំនួនមន្ត្រី* | *27* | *4* | *100* | *32* | *30* | *13* | *0* | *0* | *2* | *2* | *4* | *3* | *163* | *54* |
| ខ | *ចំនួននិស្សិត* | *7* | *2* | *44* | *16* | *2806* | *1006* | *137* | *31* | *0* | *0* | *0* | *0* | *2994* | *1055* |
| | អាហារូបករណ៍ | 0 | 0 | 0 | 0 | 812 | 357 | 0 | 0 | 0 | 0 | 0 | 0 | 812 | 357 |
| | សិក្សាបង់ថ្លៃ | 7 | 2 | 44 | 16 | 1994 | 649 | 137 | 31 | 0 | 0 | 0 | 0 | 2182 | 698 |
| ២ | សាលាជាតិកសិកម្មព្រែកលៀប | | | | | | | | | | | | | | |
| ក | *ចំនួនមន្ត្រី* | 4 | 0 | 46 | 11 | 70 | 29 | 2 | 0 | 0 | 0 | 4 | 2 | 126 | 42 |
| ខ | *ចំនួននិស្សិត* | 0 | 0 | 0 | 0 | 621 | 216 | 259 | 96 | 0 | 0 | 0 | 0 | 880 | 312 |
| ៣ | សាលាជាតិកសិកម្មកំពង់ចាម | | | | | | | | | | | | | | |
| ក | *ចំនួនមន្ត្រី* | 0 | 0 | 30 | 5 | 21 | 7 | 2 | 1 | 0 | 0 | 0 | 0 | 53 | 13 |
| ខ | *ចំនួននិស្សិត* | *0* | *0* | *0* | *0* | *631* | *247* | *199* | *56* | *0* | *0* | *0* | *0* | *830* | *303* |
| | អាហារូបករណ៍ | 0 | 0 | 0 | 0 | 426 | 186 | 185 | 54 | 0 | 0 | 0 | 0 | 611 | 240 |
| | សិក្សាបង់ថ្លៃ | 0 | 0 | 0 | 0 | 205 | 61 | 14 | 2 | 0 | 0 | 0 | 0 | 219 | 63 |

ក្នុងរយៈពេល០៥ឆ្នាំនេះ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានទទួលនិស្សិតឱ្យចូលរៀន និងបញ្ចប់ការសិក្សាដោយជោគជ័យដូចមានក្នុងតារាងនេះ៖

- ***ចំនួននិស្សិតចូលរៀនរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម៖***

| និស្សិត | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | អនុបណ្ឌិត | | បណ្ឌិត | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 2012-2013 | 37 | 6 | 1550 | 504 | 188 | 36 | 2 | 0 | 1777 | 546 |
| 2013-2014 | 44 | 4 | 1448 | 421 | 139 | 22 | 9 | 0 | 1640 | 447 |
| 2014-2015 | 789 | 260 | 86 | 19 | 35 | 11 | 11 | 0 | 921 | 290 |
| 2015-2016 | 93 | 20 | 945 | 364 | 40 | 13 | 0 | 0 | 1078 | 397 |
| 2016-2017 | 61 | 17 | 920 | 339 | 60 | 24 | 0 | 0 | 1041 | 380 |
| សរុបរួម ៥ឆ្នាំ | 1024 | 307 | 4949 | 1647 | 462 | 106 | 22 | 0 | 6457 | 2060 |



- ***ចំនួននិស្សិតបញ្ចប់ការសិក្សារបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម៖***

| និស្សិត | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | អនុបណ្ឌិត | | បណ្ឌិត | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 2012-2013 | 50 | 17 | 397 | 104 | 37 | 6 | 2 | 0 | 486 | 127 |
| 2013-2014 | 12 | 0 | 852 | 172 | 79 | 15 | 1 | 0 | 944 | 187 |
| 2014-2015 | 52 | 13 | 1234 | 309 | 19 | 5 | 0 | 0 | 1305 | 327 |
| 2015-2016 | 93 | 20 | 1024 | 302 | 37 | 9 | 1 | 1 | 1155 | 332 |
| 2016-2017 | 51 | 10 | 586 | 187 | 13 | 3 | 0 | 0 | 650 | 200 |
| សរុបរួម ៥ឆ្នាំ | 258 | 60 | 493 | 1074 | 185 | 38 | 4 | 1 | 4540 | 1173 |




តារាងរបាយការណ៍សង្ខេបសមិទ្ធផលរបស់សាលាជាតិកសិកម្មព្រែកលៀបរយៈពេល០៥ឆ្នាំ៖

- ***ចំនួននិស្សិតចូលរៀនរបស់សាលាជាតិកសិកម្មព្រែកលៀប៖***

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 2012-2013 | ១៦២ | ៤៥ | ៤៧៣ | ១៤០ | ៦៣៥ | ១៩៥ |
| 2013-2014 | ៨១ | ១៦ | ៣៦០ | ១០៦ | ៤៤១ | ១២២ |
| 2014-2015 | ១៤០ | ៣១ | ១៦១ | ៤១ | ៣០១ | ៧២ |
| 2015-2016 | ១៧០ | ៥០ | ២៥៨ | ៨៥ | ៤២៨ | ១៣៥ |
| 2016-2017 | ១១៩ | ៤៩ | ១០៤ | ៤០ | ២២៣ | ៨៩ |
| សរុប៥ឆ្នាំ | ***៦៧២*** | ***១៩១*** | ***១៣៥៦*** | ***៤១២*** | ***២០២៨*** | ***៦១៣*** |




- *ចំនួននិស្សិតបញ្ចប់ការសិក្សារបស់សាលាជាតិកសិកម្មព្រែកលៀប៖*

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១២-២០១៣ | ១៥៧ | ៤៤ | ២៥៩ | ៧៨ | ៤១៦ | ១២២ |
| ២០១៣-២០១៤ | ១២៣ | ៣៩ | ៤០៣ | ១២៨ | ៥២៦ | ១៦៧ |
| ២០១៤-២០១៥ | ៣៩៦ | ១៥ | ៣៧៨ | ១១១ | ៧៧៤ | ១២៦ |
| ២០១៥-២០១៦ | ១០៤ | ២៤ | ២៨៨ | ១០៨ | ៣៩២ | ១៣២ |
| ២០១៦-២០១៧ | ១៣៧ | ៥២ | ២០៧ | ៧៣ | ៣៤៤ | ១២៥ |
| សរុប៥ឆ្នាំ | ***៩១៧*** | ***១៧៤*** | ***១៥៣៥*** | ***៤៩៨*** | ***២៤៥២*** | ***៦៧២*** |



- *ចំនួននិស្សិតចូលរៀននៅសាលាជាតិកសិកម្មកំពង់ចាម៖*

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១២-២០១៣ | ១០៩ | ២០ | ១៦៤ | ៥៨ | ២៧៣ | ៧៨ |
| ២០១៣-២០១៤ | ៦១ | ២១ | ៧១ | ២០ | ១៣២ | ៤១ |
| ២០១៤-២០១៥ | ៥០ | ២១ | ៨៣ | ៤៣ | ១៣៣ | ៦៤ |
| ២០១៥-២០១៦ | ៦៣ | ២៦ | ១០៥ | ៦១ | ១៦៨ | ៨២ |
| ២០១៦-២០១៧ | ៧៩ | ៣២ | ១២២ | ៧០ | ២០១ | ១០២ |
| សរុប៥ឆ្នាំ | ***៣៦២*** | ***១២០*** | ***៥៤៥*** | ***២៥២*** | ***៩០៧*** | ***៣៦៧*** |




- *ចំនួននិស្សិតបញ្ចប់ការសិក្សារបស់កសិកម្មកំពង់ចាម៖*

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ២០១២-២០១៣ | ១១៤ | ៦៤ | ២២១ | ៧៣ | ៣៣៥ | ១៣៧ |
| ២០១៣-២០១៤ | ១០៣ | ៤៩ | ២២៩ | ៨២ | ៣៣៧ | ១៣១ |
| ២០១៤-២០១៥ | ២២១ | ៧០ | ២២២ | ៧២ | ៤៤៣ | ១៤២ |
| ២០១៥-២០១៦ | ២៨ | ៩ | ២១៦ | ៤៧ | ២៤៤ | ៥៦ |
| ២០១៦-២០១៧ | ៥៣ | ១៨ | ១៨៩ | ៧៣ | ២៤២ | ៩១ |
| សរុប៥ឆ្នាំ | ***៥១៩*** | ***២១០*** | ***១០៧៧*** | ***៣៤៧*** | ***១៦០១*** | ***៥៥៧*** |




គ្រឹះស្ថានអប់រំទាំងអស់ បានកំពុងរៀបចំផែនការយុទ្ធសាស្ត្រដើម្បីអនុវត្តកម្មវិធីសិក្សា ដែលបានធ្វើបច្ចុប្បន្នភាពដើម្បីពង្រឹងគុណភាពបណ្តុះបណ្តាល ស្រាវជ្រាវ និងសេវាកម្មសម្រាប់សហគមន៍ក្នុងបរិបទសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននិងសកលភាវូបនីយកម្ម។

លើផ្នែកកិច្ចសហប្រតិបត្តិការអន្តរជាតិ មានអ្នកជំនាញការបរទេសចំនួន១៣នាក់ កំពុងបម្រើការនៅក្នុងគ្រឹះស្ថានសិក្សា និងមានគ្រឹះស្ថានដៃគូសហប្រតិបត្តិការអន្តរជាតិ ទាំងទ្វេរភាគី និងពហុភាគី សរុបចំនួន៥៨ សាកលវិទ្យាល័យ។ លើសពីនេះសាលាជាតិកសិកម្មកំពង់ចាម បានបង្កើតកិច្ចសហការជាមួយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ KOICA ដើម្បីអនុវត្តគម្រោងការបណ្តុះបណ្តាល និងផ្សព្វផ្សាយគោលការណ៍ចលនាភូមិថ្មី។ បន្ថែមពីនេះ តាមរយៈគម្រោងកែលម្អគុណភាពអនាម័យនិងភូតគាមអនាម័យ (SPS) សាកលវិទ្យាល័យភូមិន្ទកសិកម្ម បានសាងសង់មន្ទីរពិសោធន៍ថ្មីមួយខ្នងមានពីរជាន់បានរួចរាល់ ព្រមទាំងបានបំពាក់បន្ថែមនូវឧបករណ៍ និងមធ្យោបាយសម្ភារសិក្សាពិសោធន៍ នៅក្នុងបន្ទប់ពិសោធន៍ដែលមានស្រាប់។

ចំពោះការងារស្រាវស្រាវ គ្រឹះស្ថានសិក្សាទាំងបី បាននិងកំពុងអនុវត្តគម្រោង ស្រាវជ្រាវចំនួន៣០ គម្រោងពាក់ព័ន្ធលើផ្នែកវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ ព្រៃឈើ ជលផល កសិឧស្សាហកម្ម រៀបចំដែនដី។ល។ ប្រភពហិរញ្ញវត្ថុសំខាន់ៗទទួលបានពី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងបរិស្ថាន អូស្ត្រាលី កាណាដា សាធារណរដ្ឋឆេកូស្លាវ៉ាគី សហគមន៍អឺរ៉ុប ប្រទេសកូរ៉េ ប្រទេសជប៉ុន សហរដ្ឋអាមេរិក។ល។ បន្ថែមពីនេះទៅទៀត មជ្ឈមណ្ឌលស្រាវជ្រាវធំៗចំនួន៣ត្រូវបានបង្កើតឡើងនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម រួមមានមជ្ឈមណ្ឌលឧត្តមភាព ប្រពលវប្បកម្មកសិកម្ម និរន្តរភាព និងអាហារូបត្ថម្ភ ឧបត្ថម្ភដោយភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) មជ្ឈមណ្ឌលស្រាវជ្រាវដំឡូងបារាំង ឧបត្ថម្ភដោយមជ្ឈមណ្ឌលកសិកម្មអន្តរជាតិកូរ៉េ (KOPIA) និងមជ្ឈមណ្ឌល បច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ ឧបត្ថម្ភដោយអង្គការសហប្រជាជាតិ ដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO)។

## ៥.៣. ការងារសវនកម្មផ្ទៃក្នុង

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ គឺជាឯកសារផែនការគោលនយោបាយ និងយុទ្ធសាស្ត្រមួយដ៏សំខាន់សម្រាប់រយៈពេលមធ្យម និងជាផែនទីបង្ហាញផ្លូវដែលបានកំណត់ច្បាស់អំពីទិសដៅអភិវឌ្ឍន៍វិស័យកសិកម្មជាមួយនឹងគោលបំណង លទ្ធផលរំពឹងទុក សូចនាករ និងចង្កោមសកម្មភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ជាមួយគ្នានេះ កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល **"ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"** បានធ្វើឱ្យមុខងារសវនកម្មផ្ទៃក្នុងកាន់តែមានសារៈសំខាន់ក្នុងការរួមចំណែកឱ្យសម្រេចគោលដៅនេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថភាពផ្តល់សេវាសវនកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដែលអាចធានាជូនថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នូវរាល់ប្រតិបត្តិការប្រកបដោយតម្លាភាព គណនេយ្យភាព និរន្តរភាព និងធ្វើឱ្យក្រសួងសម្រេចបាននូវសមិទ្ធកម្មខ្ពស់ និងមានបេសកកម្មផ្តល់នូវសេវាកម្មសវនកម្មស្របតាមស្តង់ដា ក្រមសីលធម៌វិជ្ជាជីវៈ និងអនុសាសន៍បន្ថែមតម្លៃដល់សវនដ្ឋានតាមរយៈការផ្តល់នូវការធានាសមស្របមួយទាក់ទងនឹងប្រសិទ្ធភាព និងប្រសិទ្ធផលនៃប្រតិបត្តិការ ការផ្តល់ព័ត៌មានទាន់ពេលវេលា របាយការណ៍ហិរញ្ញវត្ថុដែលជឿទុកចិត្តបាន និងអនុលោមភាពទៅនឹងច្បាប់ និងបទដ្ឋានគតិយុត្តនានា ក្នុងការលើកកម្ពស់ស្មារតីអំពីការគ្រប់គ្រងផ្ទៃក្នុង បញ្ចេញគំនិតថ្មីៗ សុចរិតភាព សត្យានុម័ត និងក្រមសីលធម៌ក្នុងចំណោមថ្នាក់ដឹកនាំ និងមន្ត្រី ដើម្បីធានាឱ្យមានប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងគ្រប់គ្រាន់ សង្គតិភាព និងបច្ចុប្បន្នភាព ជួយថ្នាក់ដឹកនាំក្នុងការកាត់បន្ថយហានិភ័យ ពេលវេលា ថ្លៃដើម និងបង្កើនទិន្នផលប្រកបដោយគុណភាព។

ក្នុងឆ្នាំ២០១៧ ឥណទានថវិកាចំនួន១ ០១៤ ៤០០ ០០០រៀល សម្រាប់ចំណាយលើពីរចង្កោមសកម្មភាពទៅតាមគោលបំណង និងសូចនាករ ដែលបានកំណត់ក្នុងផែនការថវិកាកម្មវិធីសម្រាប់ឆ្នាំ២០១៧ ក្នុងទម្រង់ P3 និង P4។ ដោយឡែក សកម្មភាពចុះធ្វើសវនកម្មមានឥណទានថវិកាចំនួន៣១២ ០០០ ០០០រៀល សម្រាប់ចុះធ្វើសវនកម្មចំនួន៤៦សវនដ្ឋាន តាមលិខិតលេខ៣៩៤ កសក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ ស្តីពីការអនុវត្តផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០១៧ និងលិខិតលេខ០០៦ សផក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការណែនាំអនុវត្តផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០១៧ តាមនីតិវិធីស្តង់ដាសវនកម្មផ្ទៃក្នុង។ ក្រៅពីនេះ រាជរដ្ឋាភិបាលបានចេញសារាចរណែនាំលេខ១២ សរណ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការបន្តពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានចេញលិខិតលេខ៦៥៤៤ កសក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការណែនាំអនុវត្តមុខងារសវនកម្មផ្ទៃក្នុង។ ទាំងនេះ គឺជាធាតុចូល និងជាឧបករណ៍យ៉ាងសំខាន់សម្រាប់នាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុវត្តការងាររបស់ខ្លួនឱ្យទទួលបានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

**លទ្ធផលការងារហិរញ្ញវត្ថុ**

ប្រកាសអន្តរក្រសួងលេខ៣៤៦ ប្រក.កសក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិការវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការចំណាយថវិកាកម្មវិធីឆ្នាំ២០១៧ មានដូចក្នុងតារាងខាងក្រោម ៖

| ជំពូក | គណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
|---|---|---|---|---|---|
| **សរុបរួម** | | | ១ ០១៤ ៤០០ ០០០ | ៩៦៧ ១៣០ ៨២០ | ៩៥,៣៤ |
| ៦០ | | ការទិញ | ៧៥ ៤០០ ០០០ | ៧០ ១៧៨ ០០០ | ៩៣,០៧ |
| | ៦០០១ | សម្ភារផ្គត់ផ្គង់ថែទាំ | ៣០ ៤០០ ០០០ | ៣០ ២៣១ ៤០០ | ៩៩,៤៥ |
| | ៦០០២ | សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល | ១៤ ០០០ ០០០ | ១៣ ៦០៩ ០០០ | ៩៩,២១ |
| | ៦០០៣ | ស្បៀងអាហារ | ៤ ០០០ ០០០ | ២ ៩៤២ ៦០០ | ៧៣,៥៧ |
| | ៦០០៤ | សំលៀកបំពាក់ | ៣ ០០០ ០០០ | | |
| | ៦០០៥ | សង្ហារិម បរិក្ខាបច្ចេកទេស | ២៤ ០០០ ០០០ | ២៣ ៣៩៥ ០០០ | ៩៦,៧៤ |
| ៦១ | | សេវាកម្ម | ៤២០ ៦០០ ០០០ | ៣៩៨ ៧៤០ ១០០ | ៩៤,៨០ |
| | ៦១០៤ | សោហ៊ុយបណ្តុះបណ្តាល | ២៨ ៦០០ ០០០ | ២៨ ៦០០ ០០០ | ១០០ |
| | ៦១០៥ | ការថែទាំ និងជួសជុល | ៤៤ ០០០ ០០០ | ៤៣ ៩៧៣ ០០០ | ៩៩,៩៤ |
| | ៦១១០ | ទំនាក់ទំនងសាធារណៈ | ១៥ ០០០ ០០០ | ១៣ ១០០ ០០០ | ៨៧,៣៣ |

| | | | | | |
|---|---|---|---|---|---|
| | ៦១១២ | ចំណាយទូទាត់សោហ៊ុយ | ៣៣០ ០០០ ០០០ | ៣១២ ១២០ ០០០ | ៩៤,៥៨ |
| | ៦១១៤ | សោហ៊ុយប្រៃសណីយ៍ | ៣ ០០០ ០០០ | ៩៤៧ ១០០ | ៣១,៥៧ |
| ៦៣ | | ពន្ធនិងអាករ | ២ ០០០ ០០០ | ១ ៨០០ ០០០ | ៩០,០០ |
| ៦៤ | | បៀវត្ស | ៥១៦ ៤០០ ០០០ | ៤៩៦ ៤១២ ៧២០ | ៩៦,១៣ |

ក្នុងឆ្នាំ២០១៧ ការចុះធ្វើសវនកម្មបានចំនួន៤៦សវនដ្ឋាន ស្មើនឹង១០០% នៃផែនការ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន៥០% នៃផែនការចំនួន៤៦% (លិខិតលេខ៣៩៤ កសក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧) ហើយបានរកឃើញលទ្ធផលសវនកម្មនិងផ្តល់អនុសាសន៍ សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានចំនួន៣៦៣អនុសាសន៍ បើគិតជាមធ្យមមានចំនួន៧អនុសាសន៍ក្នុងមួយសវនដ្ឋាន ក្នុងនោះ ២២សវនដ្ឋានមានអនុសាសន៍ក្រោមមធ្យម ៧សវនដ្ឋានមានអនុសាសន៍មធ្យម និង១៧សវនដ្ឋានមានអនុសាសន៍លើមធ្យម។

## ៥.៤. ការងារយេនឌ័រ និងកុមារ

អង្គភាពគាំទ្រគម្រោងយេនឌ័រ និងកុមារ ប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានបង្កើតឡើងដើម្បីជាយន្តការសម្របសម្រួលការអនុវត្តគម្រោង ដែលពាក់ព័ន្ធទៅនឹងការបញ្ជ្រាបយេនឌ័រ និងការការពារ និងអភិ-វឌ្ឍន៍កុមារក្នុងវិស័យកសិកម្ម។ បច្ចុប្បន្ននេះ អង្គភាពបាន និងកំពុងខិតខំបំពេញការងារទៅតាមតួនាទី និងភារកិច្ចរបស់ខ្លួន ឆ្ពោះទៅសម្រេចបាននូវទិសដៅ ដែលបានកំណត់ក្នុងគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ការអភិវឌ្ឍ និងការពារកុមារក្នុងវិស័យកសិកម្មឆ្នាំ២០១៦-២០២០ សំដៅលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនអាហារូបត្ថម្ភ និងធានានូវសុវត្ថិភាពកុមារក្នុងវិស័យកសិកម្ម។

ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង នៅក្នុងឆ្នាំ២០១៧នេះ អង្គភាពគាំទ្រគម្រោងយេនឌ័រ និងកុមារ សម្រេចបាននូវលទ្ធផលគួរឲ្យកត់សម្គាល់ រួមមាន៖

- ការផ្សព្វផ្សាយគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការពារកុមារក្នុងវិស័យកសិកម្មឆ្នាំ២០១៦-២០២០ ទៅកាន់មន្ត្រីថ្នាក់ក្រោមជាតិចំនួន២វគ្គ សិក្ខាកាមសរុប១១៧នាក់។
- វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់កណ្តាលចំនួន៣វគ្គ និងថ្នាក់ខេត្តចំនួន៩វគ្គ សម្រាប់គ្រូបង្គោលចំនួន៩០រូប លើប្រធានបទ **ការបញ្ជ្រាបយេនឌ័រនិងការអភិវឌ្ឍ និងការពារកុមារក្នុងវិស័យកសិកម្ម ការវិភាគខ្សែសង្វាក់តម្លៃដែលគិតគូរពីយេនឌ័រ កសិកម្មនិងអាហារូបត្ថម្ភ ការកសាងផែនការដែលឆ្លើយតបនឹងយេនឌ័រ ការតាមដាននិងវាយតម្លៃគម្រោង និងយេនឌ័រនិងការប្រែប្រួលអាកាសធាតុ។**
- វគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយបន្តទៅដល់មន្ត្រីថ្នាក់ស្រុក និងកសិករសរុបប្រមាណជាង **២៦០** នាក់ លើការងារបញ្ជ្រាបយេនឌ័រ និងការការពារនិងអភិវឌ្ឍន៍កុមារក្នុងវិស័យកសិកម្ម ព្រមទាំងគាំទ្រជាសម្ភារ គ្រាប់ពូជ និងឧបករណស្រោចស្រព (Drip Irrigation & Sola Pumping) មួយចំនួនទៅដល់មាតាបិតា និងអាណាព្យាបាលដើម្បីជំរុញការធ្វើសួនបន្លែតាមផ្ទះ សំដៅលើកកម្ពស់អាហារូបត្ថម្ភកុមារ និងស្ត្រី។
- លើសពីនេះទៅទៀតកិច្ចសហការក៏បានផ្តល់នូវសមិទ្ធផលជាច្រើនផងដែរ លើការបោះពុម្ពផ្សាយ សៀវភៅ ខិត្តប័ណ្ណ ផ្ទាំងរូបភាព (Poster) រួមមាន៖

  ១. សៀវភៅណែនាំការបណ្តុះបណ្តាលស្តីពី "ការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម" សម្រាប់គ្រូបង្គោល

  ២. សៀវភៅណែនាំការបណ្តុះបណ្តាលស្តីពី "ការអភិវឌ្ឍ និងការពារកុមារក្នុងវិស័យកសិកម្ម" សម្រាប់គ្រូបង្គោលថ្នាក់ខេត្ត

  ៣. ខិត្តប័ណ្ណ ផ្ទាំងរូបភាព (Poster) ស្តីពី "ការអភិវឌ្ឍ និងការពារកុមារក្នុងវិស័យកសិកម្ម"

៤. សៀវភៅរឿងខ្លីស្តីពីការផលិតម្សៅត្រី ដើម្បីលើកកម្ពស់អាហារូបត្ថម្ភ
៥. វីដេអូអប់រំខ្លីចំនួន៣ ស្តីពី "ការលូតលាស់ទាំងអស់គ្នា (Growth Together)" និងបានដាក់បញ្ចាំងក្នុងកម្មវិធីទូរទស្សន៍ ព្រមទាំងដាក់បង្ហោះឯសារ និងវីដេអូអប់រំខ្លីទាំងនោះទៅក្នុងគេហទំព័រ និងហ្វេកប៊ុករបស់ក្រសួងផងដែរ។

## V- បញ្ហាប្រឈម

ក្នុងឆ្នាំ២០១៧នេះ ក្នុងផលិតកម្មដំណាំកសិកម្ម ការទទួលយកអនុវត្តនូវបច្ចេកទេសកសិកម្មថ្មីនិងការផ្តល់សេវាបច្ចេកទេសកសិកម្មនៅមានកំរិត ដោយនៅមានកង្វះមន្ត្រីផ្សព្វផ្សាយកសិកម្មនៅថ្នាក់ស្រុក ការប្រែប្រួលអាកាសធាតុ សមត្ថភាពទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឧបករណ៍ សម្ភារ និងខ្វះមន្ត្រីជំនាញ នៅតាមអង្គភាពជំនាញនៅតាមកសិកដ្ឋាន ស្ថានីយពិសោធន៍ស្រាវជ្រាវ មណ្ឌលអភិវឌ្ឍន៍កសិកម្មនានា និងមន្ទីរពិសោធន៍ជាតិកសិកម្មនៅមានកម្រិត ហើយផលិតភាពនិងគុណភាពកសិផលនៅទាបមិនទាន់ឆ្លើយតបតាមតម្រូវការទីផ្សារ និងការប្រកួតប្រជែងទីផ្សារកសិផល។ ថ្លៃដើមផលិតកម្មខ្ពស់ពិបាកប្រកួតប្រជែងជាមួយនឹងផលិតផលនាំចូល។ល។

ចំពោះផលិតកម្មកៅស៊ូ ថ្លៃកៅស៊ូនៅបន្តទាបដែលនាំបាត់បង់ចំណូលរបស់អ្នកដាំដុះកៅស៊ូ ការយល់ដឹងពីបច្ចេកវិទ្យាកៅស៊ូថ្មីៗរបស់ប្រតិបត្តិករកៅស៊ូនៅមានកម្រិត ពុំទាន់មានច្បាប់ស្តីពីកៅស៊ូ និងខ្វះលិខិតបទដ្ឋានគតិយុត្តនានា មួយចំនួនពាក់ព័ន្ធនឹងកៅស៊ូ កង្វះទីតាំងនិងផ្ទៃដីសម្រាប់សាងសង់អនុស្ថានីយពិសោធន៍និងចម្ការបង្ហាញនៅតាមតំបន់មានដំណាំកៅស៊ូ ទំនាក់ទំនង និងកិច្ចសហការណ៍ពីម្ចាស់ចម្ការកៅស៊ូ រោងចក្រសិប្បកម្មមួយចំនួននៅមានកម្រិត រោងចក្រ សិប្បកម្មកែច្នៃជ័រកៅស៊ូ ឯកជនដែលបម្រើសេវាកែច្នៃមួយចំនួនប្រឈមនឹងការបិទទ្វារ ដោយសារលំហូរ ជ័រកៅស៊ូមិនទាន់កែច្នៃចេញទៅប្រទេសជិតខាង។

ថ្លៃដើមផលិតកម្មសត្វខ្ពស់ ដោយនៅបន្តពឹងផ្អែកលើការនាំចូលចំណីសម្រេចប្រមាណ៦០% និងការនាំចូលសារធាតុបន្ថែមសម្រាប់លាយផ្សំចំណីសត្វ បសុឱសថ និងវ៉ាក់សាំង ស្ទើរទាំងស្រុង ដែលមានតម្លៃប្រមាណជាង ២៣០ លានដុល្លារអាមេរិក រួមទាំងតម្លៃថាមពលខ្ពស់ជាងប្រទេសជិតខាងផង កម្រៃពលកម្មឡើងថ្លៃ និងមិនមានយន្តការច្បាស់លាស់ សម្រាប់ការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលសត្វ គ្រប់គ្រងការនាំចូល នាំចេញ និងនាំឆ្លងកាត់ គឺជាឧបសគ្គចំបង ក្នុងការពង្រឹងសមត្ថភាពប្រកួតប្រជែងនៃផលិតកម្មសត្វ និងការធ្វើទំនើបកម្មនៃឧស្សាហកម្មសត្វ និងការកែច្នៃ។ ជាការពិត អត្រាឈឺ ស្លាប់សត្វ និងស្ថានភាពរាតត្បាតនៃជំងឺឆ្លងសត្វនៅតែជាការគំរាមកំហែងដល់ផលិតកម្មសត្វ ធ្វើឱ្យផលិតភាពសត្វថយចុះ ហើយកង្វះការផ្គត់ផ្គង់វ៉ាក់សាំងការពារ ថ្នាំព្យាបាលសត្វ និងឧបករណ៍សម្ភារបរិក្ខា បសុព្យាបាលនៅតែជាការប្រឈម ក្នុងការបំពេញភារកិច្ចស្នូលរបស់អគ្គនាយកដ្ឋានសុខភាព សត្វនិងផលិតកម្មសត្វ។ លើសពីនេះ ភាពមិនច្បាស់លាស់នៃសមត្ថកិច្ច និងយន្តការសម្របសម្រួលលើការងារគ្រប់គ្រង ត្រួតពិនិត្យ និងការចាត់វិធានការអនាម័យនៅតាមច្រកព្រំដែន ការគ្រប់គ្រងបទល្មើសដឹកជញ្ជូនសត្វ និងផលិតផលសត្វ ការគ្រប់គ្រងសត្តឃាតដ្ឋាន គឺជាបញ្ហាប្រឈមដែលរាំងស្ទះដល់ការជំរុញអនុវត្តច្បាប់ និងវិធានបច្ចេកទេស និងអនាម័យដោយប្រសិទ្ធភាព បណ្តាលឲ្យមានហានីភ័យសុខភាពសាធារណៈ សុវត្ថិភាពម្ហូបអាហារ និងការរាលដាលនៃជំងឺឆ្លងដែន។

ការយល់ដឹងពីសារៈសំខាន់ព្រៃឈើក្នុងចំណោមប្រជាជនមូលដ្ឋាននៅមានកម្រិតទាបនៅឡើយ ដែលទាមទារឱ្យមានការពន្យល់ផ្សព្វផ្សាយបន្ថែមទៀត។ ការងារបង្ក្រាបបទល្មើស និងការកាប់រានដីព្រៃយកដីធ្វើជាកម្មសិទ្ធិល្មើសច្បាប់មានភាពស្មុគស្មាញ ចម្ការឈើដាំមួយចំនួន និងទីតាំងដីសម្រាប់ត្រៀមដាំឈើតែងតែមានការទាមទារតវ៉ាពីប្រជាពលរដ្ឋ ដើម្បីយកដីធ្វើជាកម្មសិទ្ធិ។

## VI- ទិសដៅអនុវត្តឆ្នាំ២០១៨-២០១៩

សម្រាប់ឆ្នាំ២០១៨-២០១៩នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវទិសដៅ និងផែនការអនុវត្តដូចខាងក្រោម៖

### ១. ផែនការផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

#### ក. សូចនាករទិសដៅ

- ជំរុញការដាំដុះដំណាំស្រូវទូទាំងប្រទេសឆ្នាំ២០១៧-២០១៨ ឱ្យបានយ៉ាងតិចក្នុងរង្វង់២,៩៥លានហ.ត ក្នុងនោះ ស្រូវវស្សា២,៥លានហ.ត និងប្រាំង០,៤៥លានហ.ត។ ទិន្នផលសរុប៣,២៩៦ត/ហ.ត។ បរិមាណផលស្រូវត្រូវផលិតឱ្យបានយ៉ាងតិច៩,៧៤លានតោន។

- ជំរុញការធ្វើផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម (ពោត ដំឡូងឈើ ដំឡូងជ្វា បន្លែ សណ្តែកបាយ សណ្តែកដី សណ្តែកសៀង អំពៅ ល្ង) ឱ្យបានកើនផ្ទៃដីដាំដុះចំនួន២% និងបរិមាណផលប្រមាណ៥% ធៀបនឹងឆ្នាំ២០១៧។

#### ខ. វិធានការអនុវត្តដើម្បីសម្រេចបានទិសដៅកំណត់

- ជំរុញការបង្កើនផលិតភាព ពិពិធកម្មកសិកម្ម លើមុខដំណាំដែលមានផលចំណេញខ្ពស់ និងមានតម្រូវការទីផ្សារ បង្កើនគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម ដោយយកចិត្តទុកដាក់ដល់ការផលិតកសិកម្មសរីរាង្គ ឬការអនុវត្តកសិកម្មល្អ (Good Agriculture Practice-GAP) ប្រកបដោយភាពវៃឆ្លាត រួមនឹងការបញ្ចូលនូវបច្ចេកវិទ្យាទំនើបឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ ដើម្បីប្រែក្លាយកសិកម្មកម្ពុជាឱ្យទៅជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុនិងនិរន្តរភាព ដែលចូលរួមចំណែកក្នុងការផ្តល់សន្តិសុខ និងសុវត្ថិភាពស្បៀង ព្រមទាំងអាហារូបត្ថម្ភ សម្រាប់វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

- ពង្រឹងសមត្ថភាពសហគមន៍កសិកម្មដែលបានចុះបញ្ជីរួចហើយឲ្យមានលក្ខណៈជាជំនាញអាជីព ដោយជំរុញឱ្យអនុវត្តបច្ចេកវិទ្យាសមស្រប ការផ្គត់ផ្គង់សន្ទុំសំចៃទឹក នៅតាមសហគមន៍/សហករណ៍កសិកម្ម និងអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ព្រមទាំងលើកកម្ពស់ការចូលរួមវិនិយោគពីវិស័យឯកជនក្នុងគ្រប់ខ្សែចង្វាក់តម្លៃកសិកម្មតាមអភិក្រមភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍កសិកម្ម។

- ជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម និងប្រព័ន្ធព័ត៌មានវិទ្យាប្រកបដោយភាពច្នៃប្រឌិតខ្ពស់នៅក្នុងគ្រប់ដំណាក់ខ្សែចង្វាក់ផលិតកម្មកសិកម្ម ដោយធានាបាននូវគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ ហើយកាត់បន្ថយជាអតិបរមារដល់ការហូរច្រោះខូចគុណភាពដី ការខ្វះខ្វាយថាមពល ទឹក និងការបាត់បង់ផលដែលផលិតបាន។

- ជំរុញគំនិតច្នៃប្រឌិតថ្មីៗសម្រាប់បង្កើនសន្ទុះ ទំនើបភាវូបនីយកម្មកសិកម្មឱ្យកាន់តែមានឧត្តមភាពប្រកួតប្រជែងខ្ពស់នោះ ដោយយកចិត្តទុកដាក់លើការស្រាវជ្រាវ អភិវឌ្ឍន៍ ផ្សព្វផ្សាយ និងប្រើប្រាស់របកគំហើញថ្មីៗ ដូចជា បច្ចេកទេសផលិត កែច្នៃ បច្ចេកវិទ្យាកសិកម្ម ធាតុចូលកសិកម្ម គ្រឿងយន្តកសិកម្ម ម៉ាស៊ីនកសិកម្ម និងឧបករណ៍កសិកម្មច្នៃប្រឌិតថ្មីប្រកបដោយគុណភាពសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។

- ពន្លឿនការងារកំណត់តំបន់ដាំដុះដំណាំកសិកម្ម ជាពិសេស រៀបចំនិងបោះពុម្ពជាផែនទីកំណត់តំបន់ដាំដុះ ដើម្បីអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង និងជំរុញផលិតកម្មកសិកម្ម ពិសេសដំណាំទៅតាមតំបន់មានសក្តានុពល និងទាក់ទាញវិនិយោគទុន ឱ្យស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥។

- បន្តជំរុញការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មឱ្យបានខ្លាំងថែមទៀត ក្នុងទិសដៅបង្កើនបរិមាណ និងគុណភាពផលិតផលកសិកម្ម តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗក្នុងបរិបទបម្រែបម្រួលអាកាសធាតុ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារក្នុងប្រទេស តំបន់ និងពិភពលោក។ បង្កាត់និងអភិវឌ្ឍពូជដំណាំ និងពូជសត្វថ្មីៗដែលមានលក្ខណៈ

ទំនើបធន់ទ្រាំជាមួយការប្រែប្រួលអាកាសធាតុ (ការឡើងកម្តៅ រាំងស្ងួត ទឹកជំនន់ ទឹកសមុទ្រ) និងសមាសភាពចង្រៃ (ជំងឺ សត្វចង្រៃ សត្វល្អិតចង្រៃ និងស្មៅចង្រៃ) ជាមួយការផ្តល់ទិន្នផលខ្ពស់មានគុណភាពល្អ អាហារូបត្ថម្ភនិងជីវជាតិល្អ (functional varieties) ឆ្លើយតបតាមត្រូវការទីផ្សារ ព្រមទាំងមានរយៈពេលសមស្របតាមក្បេត្រ-បរិស្ថានដាំដុះ ត្រូវបានយកចិត្តទុកដាក់ខ្ពស់ និងលើកទឹកចិត្តបំផុត។

- បន្តការងារពិសោធន៍ ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាដាំដុះដំណាំមានសក្តានុពលទីផ្សារ មានផលិតភាពខ្ពស់ធន់ទ្រាំនឹងបម្រែបម្រួលអាកាសធាតុ និងកាត់បន្ថយឱនភាពនៃការប្រើប្រាស់ដីកសិកម្ម។

- ជំរុញការអភិវឌ្ឍជាកសិដ្ឋានគំរូ (Model Farm) ប្រកបដោយភាពសម្បូរបែប មានលទ្ធភាពដាំដុះលើផ្ទៃដីដដែលបានច្រើនដងក្នុងមួយឆ្នាំ ប្រើប្រាស់បច្ចេកទេសដាំដុះទំនើប ដូចជាបច្ចេកទេសសន្សំសំចៃទឹក មានគម្របដីសំដៅកាត់បន្ថយការប្រើប្រាស់ទឹកនិងការដុះស្មៅ ប្រើប្រាស់បច្ចេកទេសការអនុវត្តកសិកម្មល្អ ដើម្បីធានាឱ្យបាននូវសុវត្ថិភាពចំណីអាហារ។

- ជំរុញកសាងសមត្ថភាព សមត្ថកិច្ចត្រួតពិនិត្យអនាម័យនិងភូតគាមអនាម័យ (SPS) ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការងារត្រួតពិនិត្យ និងការទទួលស្គាល់ជាអន្តរជាតិ លើសមត្ថកិច្ចដែលមានតួនាទីដ៏សំខាន់នៅក្នុងពេលដែលកម្ពុជាជំរុញកសិ-ពាណិជ្ជូបនីយកម្ម និងបរិបទពាណិជ្ជកម្មសេរី។

- ធ្វើបច្ចុប្បន្នភាព និងពង្រឹងនូវការអនុវត្តបទដ្ឋានគតិយុត្តដែលចាំបាច់ ព្រមទាំងរៀបចំកែលម្អមន្ទីរពិសោធន៍សម្រាប់វិភាគគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ដោយសហការជាមួយជំនាញពាក់ព័ន្ធតាមភារកិច្ចឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ដើម្បីជួយសម្រួលដល់ការអនុវត្តប្រព័ន្ធតាមដាន និងត្រួតពិនិត្យគុណភាពឱ្យកាន់តែមានប្រសិទ្ធភាព ពិសេសការយកចិត្តទុកដាក់បញ្ជូនមន្ត្រីជំនាញ សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនានាដើម្បីទប់ស្កាត់លើការប្រើប្រាស់សារធាតុគីមីដែលហាមឃាត់ ដោយត្រូវត្រួតពិនិត្យឲ្យបានតឹងរឹងបំផុត ដើម្បីធានាសុខុមាលភាពសាធារណៈ។

## ២. ផែនការផលិតកម្មដំណាំកៅស៊ូ

### ក. សូចនាករទិសដៅ

ក្នុងឆ្នាំ២០១៨ សូចនាករគោលដៅសំខាន់ៗ ដែលបានគ្រោងនឹងត្រូវសម្រេចរួមមាន៖

- ជំរុញបង្កើនផ្ទៃដីចៀរ ឱ្យបាន២០៤ពាន់ហ.ត
- ជំរុញបង្កើនផលិតកម្មកៅស៊ូឱ្យដល់២២២ពាន់តោន ក្នុងកំណើន១៥%
- បង្កើនការនាំចេញកៅស៊ូឱ្យបានប្រមាណ២១៨ពាន់តោន
- ប្រមូលចំណូលឱ្យសម្រេចតាមចំណុចដៅចំនួន១៤០៣លានរៀល
- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជា២០១៦-២០២៥
- បន្តអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០១៨ ឱ្យសម្រេចបាននូវចំណុចដៅដែលបានកំណត់
- រៀបចំគម្រោងថវិកាកម្មវិធីឆ្នាំ២០១៩។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងលិខិតគតិយុត្តពាក់ព័ន្ធនានា
- ជំរុញការពង្រីកផ្ទៃដីដំណាំកៅស៊ូរបស់ក្រុមហ៊ុនឯកជននិងកៅស៊ូគ្រួសារ ពិសេសចូលរួមពិនិត្យតាមដានការអនុវត្តផែនការកម្មវិធីវិនិយោគកៅស៊ូលើដីសម្បទានសេដ្ឋកិច្ច និងវាយតម្លៃលទ្ធផលដែលសម្រេចបាន
- រៀបចំផែនការយុទ្ធសាស្ត្រថវិកា (បីឆ្នាំរំកិល) និងគម្រោងផែនការសកម្មភាពថវិកាកម្មវិធីឆ្នាំ២០១៩ ដោយពិនិត្យឡើងវិញនូវការកំណត់អនុកម្មវិធី ចង្កោមសកម្មភាព សូចនាករ គោលដៅសូចនាករ និងថវិកាចំណាយ ដើម្បីឱ្យសមស្របតាមស្ថានភាព និងលទ្ធភាពជាក់ស្តែង

- ធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជា២០១១-២០២០
- បន្តអនុវត្តនិងពិនិត្យតាមដានការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០១៨ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី
- ខិតខំធ្វើការប្រមូលចំណូល ឱ្យសម្រេចតាមចំណុចដៅ
- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រស្តីពីការដាំដុះ ថែទាំកូនកៅស៊ូ ការប្រើប្រាស់ថ្នាំសម្លាប់ស្មៅ ការគ្រប់គ្រងសមាសភាពចង្រៃ ការយកផល និងការកែច្នៃ
- បន្តស្វែងរកទីតាំងអនុស្ថានីយនិងចម្ការបង្ហាញបន្ថែម និងបង្កើនសមត្ថភាពស្រាវជ្រាវ ផ្សព្វផ្សាយ និងបង្ហាញ
- បន្តចុះផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ
- ជំរុញការចងក្រងសហគមន៍កសិករកៅស៊ូគ្រួសារ
- អនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ (CSR) សម្រាប់នាំចេញកៅស៊ូ អនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជ ជំរុញការអនុវត្តកម្មវិធីផ្លាស់ប្តូរក្លូនពហុភាគីក្នុងរង្វង់ប្រទេសជាសមាជិកនៃ IRRDB
- បង្កើនកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន (ខេត្ត ស្រុក និងសមត្ថកិច្ចនៅតាមច្រកព្រំដែន) ដើម្បីជួយទប់ស្កាត់សកម្មភាពការបើកស្ទាក់ការប្រមូលទិញកៅស៊ូគ្រួសារដែលគ្មានលិខិតអនុញ្ញាត និងការនាំចេញកៅស៊ូនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេសដោយខុសច្បាប់
- បន្តចូលរួមសន្និសីទ កិច្ចប្រជុំ និង សន្និបាតប្រចាំឆ្នាំរបស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ និងអង្គការកៅស៊ូអន្តរជាតិនានា
- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារ និងអង្គការកៅស៊ូអន្តរជាតិនានា លើកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិជ្ជាវិទ្យាសាស្ត្រព័ត៌មានអំពីការផ្គត់ផ្គង់ និងតម្រូវការប្រើប្រាស់កៅស៊ូ អំពីនិន្នាការនៃតម្លៃកៅស៊ូលើទីផ្សារក្នុងនិងក្រៅប្រទេស
- ពង្រីកដៃគូសហប្រតិបត្តិការក្នុងការស្វែងរកថវិកានិងបច្ចេកទេស ដើម្បីគាំទ្រអភិវឌ្ឍន៍កៅស៊ូគ្រួសារ និងបន្តចូលរួមសហការជាមួយគ្រឹះស្ថានសិក្សានានា ក្នុងការបណ្តុះបណ្តាលធនធានមនុស្សខាងវិស័យកៅស៊ូ។

## ៣. ផែនការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ

### ក. សូចនាករទិសដៅ

- ជំរុញកំណើនសត្វចិញ្ចឹមលក្ខណៈគ្រួសារ និងពាណិជ្ជកម្ម ក្នុងរង្វង់ ៣%៖ គោក្របី ១% ជ្រូក ២% និងសត្វស្លាប ៤%
- ជំរុញចាក់វ៉ាក់សាំងសារទឹក បូសខ្យល់ និងអុតក្តាម គោក្របីចិញ្ចឹមលក្ខណៈគ្រួសារឱ្យបាន១,៧៥លានក្បាល
- ជំរុញរៀបចំបទដ្ឋានគតិយុត្ត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់សុខភាពសត្វ និងផលិតកម្មសត្វ
- បង្កើនការអនុវត្តវិធានការនានា ដើម្បីជំរុញឲ្យសត្តឃាតដ្ឋានចំនួន ២៥កន្លែង ឲ្យអនុវត្តតាមស្តង់ដារអនាម័យ និងសុវត្ថិភាពស្របតាមបច្ចេកទេស និងគោលការណ៍ច្បាប់។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត នៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- ជំរុញការអភិវឌ្ឍសមត្ថភាពស្ថាប័ន ធនធានមនុស្ស សមត្ថភាពជំនាញ និងឆន្ទៈការងារ
- ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត បទដ្ឋានបច្ចេកទេសស្តង់ដារពាក់ព័ន្ធនានា និងចាត់វិធានការពង្រឹងការអនុវត្តលិខិតបទដ្ឋានទាំងនោះ

- បង្កើនការផ្តល់សេវាកម្មសុខភាពសត្វនិងផលិតកម្មសត្វ ការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វ ការព្យាបាលសត្វ ការគ្រប់គ្រងជីវសុវត្ថិភាព ការធ្វើអនាម័យ
- ពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ និងត្រួតពិនិត្យគុណភាព សុវត្ថិភាពចំណីសត្វនិងបសុឱសថ រួមទាំងសម្ភារបសុព្យាបាល
- ពង្រឹងការតាមដាន ត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ ការអង្កេតតាមដាន ឃ្លាំមើលលើសុខភាពនិងជំងឺសត្វ ដើម្បីទប់ស្កាត់បានទាន់ពេលវេលា
- ជំរុញលើកទឹកចិត្តដល់ការវិនិយោគផលិតចំណីសត្វ កែច្នៃផលិតផលសត្វ ការបង្កើតសត្តឃាតដ្ឋានដើម្បីគាំទ្រដល់ចលនាចិញ្ចឹមសត្វ រួមជាមួយនឹងការលើកកម្ពស់ប្រព័ន្ធផ្តល់សេវាបច្ចេកទេសពូជ និងសម្របសម្រួលទីផ្សារ ការសម្រួលពាណិជ្ជកម្មលើសត្វនិងផលិតផលសត្វ តាមរយៈការខិតខំកែលម្អសេវាសាធារណៈ
- ចងក្រងក្រុម និងសហគមន៍អ្នកចិញ្ចឹមសត្វនិងភ្នាក់ងារសុខភាពសត្វភូមិ
- បន្តគាំទ្រដល់ការបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិ និងការបណ្តុះបណ្តាលវិជ្ជាជីវបសុព្យាបាល
- បន្តនិងធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការលើអនុវិស័យផលិតកម្ម និងបសុព្យាបាលជាមួយបណ្តាប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិនានា និងកិច្ចសហការជាមួយផ្នែកឯកជនដើម្បីទទួលបានការគាំទ្រក្នុងការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

## ៤ ផែនការផ្នែកជលផល

### ក. សូចនាករទិសដៅ

- នេសាទទឹកសាបៈ
  - . នេសាទដាយត្រី ដាយបង្កង និងសិប្បកម្ម ១២ ០០០តោន
  - . នេសាទគ្រួសារក្នុងដែននេសាទ ៣៤៥ ០០០តោន
  - . នេសាទគ្រួសារក្នុងវាលស្រែ ១៤៥ ០០០តោន
- អាជីវកម្មនេសាទសមុទ្រ ១១០ ០០០តោន
- វារីវប្បកម្មៈ
  - . ការចិញ្ចឹមត្រី បង្គា ២៥០ ០០០តោន
  - . ការចិញ្ចឹមក្រពើ ៣០០ ០០០ក្បាល
  - . ការផលិតកូនត្រីពូជ ២២០ ០០០ ០០០កូន
- ការកែច្នៃផលនេសាទៈ
  - . ការកែច្នៃផលនេសាទទឹកសាប ៨២ ០០០តោន
  - . ការកែច្នៃផលនេសាទសមុទ្រ ៩ ០០០តោន
  - . ការផលិតទឹកត្រី ៦០ ០០០ ០០០លីត្រ
- ការនាំចេញផលនេសាទ ២០ ០០០តោន

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- បន្តការផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងអនុសាសន៍៧ចំណុចរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បន្តពង្រឹងកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសគណៈបញ្ជាការឯកភាពរដ្ឋបាល រាជធានីខេត្តក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសជលផលឱ្យបានល្អប្រសើរ

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល ពង្រឹងការអនុវត្តច្បាប់ ស្ដីពីជលផលឲ្យបានតឹងរឹងបំផុត
- បន្តពង្រឹងសហគមន៍នេសាទឱ្យទទួលខុសត្រូវលើភាពជាម្ចាស់នៃការគ្រប់គ្រងធនធានជលផល ក្នុងកន្លែងនេសាទសហគមន៍ដើម្បីសំដៅធានា "សហគមន៍នេសាទគ្មានបទល្មើសជលផល"
- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីជំរុញការចូលរួមរបស់សហគមន៍នេសាទក្នុងការគ្រប់គ្រងជលផលឱ្យបានសកម្ម
- បន្តពង្រឹងការងារបង្រ្កាបបទល្មើសជលផល ជាពិសេសឧបករណ៍ឆក់ ស្បៃមុង និងឧបករណ៍ភ្លើងពណ៌ជាដើម
- បន្តការងារសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិ ដើម្បីជំរុញការងារអភិវឌ្ឍន៍វារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផល
- បន្តលែងកូនត្រីពូជក្នុងតំបន់ទឹកធម្មជាតិ ដើម្បីបង្កើនផលស្តុកក្នុងធម្មជាតិសម្រាប់បម្រើសេចក្តីត្រូវការរបស់ប្រជាកសិករ
- បន្តពង្រីកតំបន់ផ្សព្វផ្សាយការអភិវឌ្ឍវិស័យវារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផលនៅតាមមូលដ្ឋាន
- បង្កើនការយល់ដឹងនិងសមត្ថភាពរបស់អ្នកកែច្នៃឲ្យកាន់តែល្អប្រសើរឡើង លើការអនុវត្តការធ្វើអនាម័យល្អ និងការអនុវត្តការផលិតល្អ ក្នុងខ្សែចង្វាក់ផលិតកម្មកែច្នៃជលផល
- បង្កើនការត្រួតពិនិត្យនិងអធិការកិច្ចគុណភាព សុវត្ថិភាពលើផល ផលិតផលជលផលតាមបណ្តាទីកន្លែងកែច្នៃនានានិងការនាំចូល
- បង្កើនសមត្ថភាពផ្តល់សេវាសាធារណៈឲ្យកាន់តែល្អប្រសើរឡើង ដើម្បីជួយសម្រួលសកម្មភាពនាំចេញផលផលិតផលជលផល
- សិក្សាវាយតម្លៃទិន្នន័យគោលនៃចរាចរជលផលនៅតំបន់គម្រោងទំនប់វារីអគ្គិសនីសំបូរ និងសេកុង
- បន្តសិក្សាស្រាវជ្រាវកន្លែងពងកូននិងការរស់នៅរបស់ប្រភេទត្រីទឹកសាប
- ជំរុញសេវាកម្មខាងការងារស្រាវជ្រាវ និងវគ្គបណ្តុះបណ្តាលលើជំនាញជលផល និងវារីវប្បកម្មដែលមានគុណភាព និងប្រសិទ្ធភាពខ្ពស់ដល់បណ្តាស្ថាប័នជាដៃគូ។

## ៥. ផែនការផ្នែកព្រៃឈើ

### ក. សូចនាករទិសដៅ

- ធ្វើការសិក្សាទីតាំង កំណត់ព្រំប្រទល់ និងចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើដែលរាជរដ្ឋាភិបាលបានដកហូតនិងនិរាករណ៍ សម្រាប់ស្តារនិងដាំឈើឡើងវិញ ដោយត្រូវយកចិត្តទុកដាក់លើការជំរុញការដាំដុះពីវិស័យឯកជននិងគ្រួសារ និងត្រូវបណ្តុះកូនឈើឱ្យបាន៥លានដើម
- ចំនួនសហគមន៍ព្រៃឈើចំនួន ២០ ត្រូវបានអនុម័ត និងពង្រឹងការគ្រប់គ្រង។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- បន្តពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ចល្អ ដោយធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទបញ្ញាសេចក្តីជូនដំណឹងលិខិតបទដ្ឋានក្រោមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យព្រៃឈើឲ្យជ្រាបដល់អាជ្ញាធរថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋមូលដ្ឋាន
- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយភាគីពាក់ព័ន្ធនានា ជាពិសេសប្រព័ន្ធព័ត៌មាន ព្រះរាជអាជ្ញា ស្ថាប័នតុលាការ និងគណៈបញ្ជាការឯកភាពខេត្ត-រាជធានី ស្រុក ក្នុងយុទ្ធនាការទប់ស្កាត់ និងបង្រ្កាបបទល្មើសព្រៃឈើជាមួយគណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្រ្កាបបទល្មើសព្រៃឈើ

- បន្តស្វែងរកដៃគូអភិវឌ្ឍន៍សម្រាប់សហការដាំឈើដៃគូ និងសិក្សាស្វែងរក និងកំណត់តំបន់ដីទំនេរ តំបន់ព្រៃរេចរិល ឬដីដែលរាជរដ្ឋាភិបាលបានដកហូតពីសម្បទានដីសេដ្ឋកិច្ចកន្លងមក ដើម្បីធ្វើការដាំដុះឡើងវិញសម្រាប់ផលិតកម្ម
- បន្តជំរុញបង្កើនសហគមន៍ព្រៃឈើឱ្យបានកាន់តែច្រើន តាមរយៈការបង្កើនកិច្ចខិតខំចូលរួមកាត់បន្ថយភាពក្រីក្រដើម្បីបង្កើនជីវភាពក្នុងសហគមន៍
- បន្តសហការជាមួយដៃគូអភិវឌ្ឍន៍នានា និងស្វែងរកដៃគូថ្មីៗទៀត ដើម្បីអនុវត្តគម្រោងការបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ
- បន្តជំរុញការចុះបញ្ជីនៃការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ការធ្វើវិបុលកម្មសត្វព្រៃ ការសង្គ្រោះ និងការបង្កាត់ពូជសត្វព្រៃជាពិសេសប្រភេទសត្វមានដោយកម្រ ជិតផុតពូជ និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសត្វព្រៃ
- ចុះពង្រឹងការគ្រប់គ្រង ការផ្តល់លិខិតអនុញ្ញាតបង្កើតរោងសន្និធិ រោងសិប្បកម្ម និងរោងម៉ាស៊ីនអារ កែច្នៃផលអនុផលព្រៃឈើ។

## VII- សេចក្តីសន្និដ្ឋាន

ផ្អែកលើសមិទ្ធផលដែលទទួលបានក្នុងរយៈពេលពេញមួយឆ្នាំ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា យើងអាចវាយតម្លៃជារួមថា បើទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិ ពិសេសគ្រោះរាំងស្ងួតនៅដើមរដូវ និងជំនន់នៅចុងរដូវវស្សា តែក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំនិងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាព របស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយបាននូវការលំបាកផ្សេងៗដូចបានរៀបរាប់ខាងលើ បានធ្វើឱ្យផលិតកម្មកសិកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់។

ការបង្វែរទិសពីការអភិវឌ្ឍតាមបែបទូលាយ ឬតាមបែបវិបុលកម្មទៅកាន់ការអភិវឌ្ឍតាមបែបស៊ីជម្រៅ ឬតាមបែបប្រពលវប្បកម្ម ពោលគឺការពង្រីកសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់តាមរយៈប្រពលវប្បកម្ម និងការបង្កើនរដូវដាំដុះបានក្លាយជារបៀបវារៈអាទិភាពមួយដ៏សំខាន់។ ជាកត្តាសត្យានុម័ត ការពង្រីកនិងការពង្រឹងសេវាកម្មគាំទ្រដ៏មានប្រសិទ្ធភាព ដូចជាការស្រាវជ្រាវ ការផ្សព្វផ្សាយនូវបច្ចេកវិទ្យាទំនើបទៅតាមអនុវិស័យ អាស្រ័យទៅតាមសក្តានុពលនៃភូមិសាស្ត្រ ការបែងចែកពូជ ជី សម្ភារកសិកម្ម និងការផ្តល់ឥណទានជនបទ ត្រូវបានយកចិត្តទុកដាក់និងជាអាទិភាពរបស់រាជរដ្ឋាភិបាល សំដៅលើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាពកសិកម្ម ឆ្លើយតបទៅតាមតម្រូវការទីផ្សារ និងស្តង់ដារជាតិនិងអន្តរជាតិ។

បច្ចុប្បន្ននេះ យើងបានកត់សម្គាល់ឃើញថា ប្រជាកសិករយើងកំពុងប្រែប្រួលទម្លាប់ ពីការផលិតសម្រាប់បម្រើសេចក្តីត្រូវការផ្ទាល់ខ្លួន មកជាការផលិតដើម្បីលក់ ព្រោះមានតម្រូវការទីផ្សារកាន់តែកើនឡើង។ ផ្អែកលើការប្រែប្រួលនេះ យើងអាចសន្និដ្ឋានបានថា សហគមន៍កសិកម្មកំពុងក្លាយជាកម្លាំងចលករមួយយ៉ាងសំខាន់ ដែលនាំឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសង្គមជនបទកម្ពុជា។ ជាការកត់សម្គាល់មួយទៀត កសិករបានចងក្រងគ្នាបង្កើតជាសហគមន៍អភិវឌ្ឍន៍កសិកម្មផលិតបន្លែសរីរាង្គ ហើយធ្វើការសម្អាតរួចវេចខ្ចប់ ដើម្បីផ្គត់ផ្គង់ទៅកាន់ទីផ្សារទំនើបផ្សេងៗនៅរាជធានីភ្នំពេញ។ នេះបង្ហាញឱ្យឃើញថា កសិករយើងបាននិងកំពុងប្រែក្លាយខ្លួនចេញពី "កសិករទៅជាកសិ-ពាណិជ្ជករ" ដើម្បីទទួលបានតម្លៃបន្ថែមក្នុងជីវភាពរស់នៅរបស់ខ្លួន។ ក្នុងបរិបទនេះ យើងសង្កេតឃើញថាមានស្ថាប័នជាច្រើនទាំងរដ្ឋ វិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាលបាននិងកំពុងផ្តល់សេវាកម្ម ដើម្បីបង្កើនចំណេះដឹង និងចំណេះធ្វើដល់កសិករនៅមូលដ្ឋាន ហើយក៏មានកសិករជាច្រើនបានក្រេបជញ្ជក់យកបទពិសោធន៍

និងទេពកោសល្យទាំងអស់នេះយកទៅអនុវត្តប្រកបដោយភាពឧស្សាហ៍ព្យាយាមនិងថ្លៃប្រឌិត ដោយទទួលបានលទ្ធផល ជាផ្លែផ្កាយ៉ាងត្រចះត្រចង់នៅក្នុងតំបន់ជាច្រើន ទៅតាមអនុវិស័យនីមួយៗ។

ជារួមផលិតកម្មដំណាំ ពិសេសដំណាំស្រូវតាមការកត់សម្គាល់ឃើញថា បានទទួលលទ្ធផលល្អប្រសើរ ហើយអាចសល់ស្បៀង (ជាអង្ករ) សរុបចំនួនប្រមាណជាង៣,៥៦លានតោន ឬ៥,៥៦លានតោនស្រូវ នៅឆ្នាំ២០១៧ (កើនប្រមាណ៨,៦៦%ធៀបនឹងឆ្នាំ២០១៦) ដែលនេះជាជោគជ័យមួយសម្រាប់កសិកម្មកម្ពុជា។ កត្តាកើនឡើងនៃទិន្នផលផលិតកម្មកសិកម្មកម្ពុជា ពិសេសផលិតកម្មស្រូវពីមួយឆ្នាំទៅមួយឆ្នាំ មានការរីកវឌ្ឍឈានឡើងជាលំដាប់ ដោយសារកត្តា២យ៉ាងគឺ (១). ការពង្រីកផ្ទៃដីដាំដុះ ដែលរួមទាំងការធ្វើបង្កើនដជូវនិងប្រពលវប្បកម្ម (២). សមិទ្ធផលនៃការសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយពូជថ្មី បច្ចេកទេសដាំដុះសមស្រប ការថែទាំដំណាំប្រកបដោយប្រសិទ្ធភាព ពិសេសការកែប្រែទម្លាប់របស់ប្រជាកសិករ។ ការនាំចេញអង្ករជាផ្លូវការបានកើនពី ៣៧៨ពាន់តោន នៅឆ្នាំ២០១៣ ដល់៦៣៥ពាន់តោន នៅឆ្នាំ២០១៧ ។

ដំណាំឧស្សាហកម្ម ដំណាំឈើហូបផ្លែនិងដំណាំអចិន្ត្រៃយ៍ កំពុងមានការរីកចម្រើនជាបន្តបន្ទាប់ ជាលក្ខណៈគ្រួសារ និងជាលក្ខណៈវិនិយោគខ្នាតតូច មធ្យម និងធំ។ ជាក់ស្តែងផ្ទៃដីកៅស៊ូមានសន្ទុះកើនឡើង ពិសេសការអភិវឌ្ឍ កៅស៊ូគ្រួសារមានការរីកវឌ្ឍតាមសន្ទុះមួយគួរឱ្យចាប់អារម្មណ៍។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវបង្កើនការលើកកម្ពស់ការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មបន្ថែមទៀត ក្នុងទិសដៅបង្កើនបរិមាណនិងគុណភាពផលិតផលកសិកម្ម តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាបច្ចេកទេស និងនុវានុវត្តថ្មីៗ ក្នុងបរិបទបម្រែបម្រួលអាកាសធាតុ និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារក្នុងប្រទេស តំបន់ និងអន្តរជាតិ។

អនុវិស័យសុខភាពសត្វ និងផលិតកម្ម ក្នុងឆ្នាំ២០១៧នេះ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ និងបទដ្ឋានគតិយុត្តមួយចំនួនត្រូវបានអនុម័ត ព្រមទាំងការតម្លើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ជំរុញការវិនិយោគដោយមានរោងចក្រផលិតចំណីសត្វចំនួន១៣ មានសត្តឃាតដ្ឋានពិឃាតគោទំនើបខ្នាតអន្តរជាតិ។ ការផ្តល់សេវាកម្មសុខភាពសត្វនៅទូទាំងប្រទេសមានលក្ខណៈល្អប្រសើរ ហើយកត្តានេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយការផ្ទុះជំងឺសត្វ និងចូលរួមចំណែកក្នុងការជំរុញកំណើនផលិតកម្មសត្វឱ្យមានការកើនឡើងជាលំដាប់ ដោយក្នុងនោះ អនុវិស័យនេះបានជំរុញការចិញ្ចឹមសត្វឱ្យសម្រេចបាន១,៥៤% ធៀបទៅនឹងឆ្នាំ២០១៦ ក្នុងនោះគោកើន១,៧៦% ជ្រូកកើន៣,៥% សត្វស្លាបកើន១,៤% រីឯក្របីថយចុះ ២,៨%។ ទោះបីជាផលិតកម្មសត្វសម្រេចបានដូចនេះក៏ដោយ ក៏បរិមាណនេះមិនទាន់ឆ្លើយតបនឹងតម្រូវការហូបចុករបស់ប្រជាជនកម្ពុជា និងភ្ញៀវទេសចរដែលមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ហើយកង្វះខាតនេះត្រូវបានបំពេញបន្ថែមដោយការនាំចូលសត្វរស់និងផលិតផលសាច់។

ការគ្រប់គ្រងធនធានព្រៃឈើនិងជលផល ពិសេសកំណែទម្រង់ក្នុងផ្នែកទាំងពីរនេះ កំពុងស្ថិតនៅតែជាប្រធានបទមួយសំខាន់ ហើយដែលត្រូវតែខិតខំបង្កើនសកម្មភាព ជាមួយនឹងការបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗ ដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។ ក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងជលផលឱ្យមានប្រសិទ្ធភាពខ្ពស់ អង្គភាពជំនាញថ្នាក់កណ្តាលនិងរាជធានីខេត្តនឹងត្រូវបន្តពង្រឹងកិច្ចសហការជាមួយគណៈកម្មការឯកភាពរាជធានីខេត្តឱ្យបានល្អប្រសើរ។ លើសពីនេះទៀត ការបន្តចូលរួមសហការជាមួយគណៈកម្មការជាតិដែលបានបង្កើតឡើង ក៏ជាការងារសំខាន់មួយទៀត ដើម្បីរួមគ្នាទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ និងបទល្មើសនេសាទឱ្យបានជោគជ័យ។

ដោយឡែក កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា រួមទាំងវិស័យឯកជនផងដែរ កំពុងត្រូវបានពង្រឹងនិងយកចិត្តទុកដាក់ខ្ពស់ រួមទាំងការអភិវឌ្ឍន៍ធនធានមនុស្ស ដែលជាកត្តាគន្លឹះសំខាន់មិនអាចមើលរំលង

បានឡើយ។ រីឯដំណើរការប្រព្រឹត្តទៅនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាការលើកកម្ពស់ការពង្រឹងរចនាសម្ព័ន្ធចាត់តាំងក្បាលម៉ាស៊ីនដឹកនាំរបស់ក្រសួងទាំងថ្នាក់កណ្តាល រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំងអស់ក៏ត្រូវបានពង្រឹងក្នុងស្មារតីយកចិត្តទុកដាក់ខ្ពស់ និងប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

លើសពីនេះទៅទៀត ផ្នែកសេវាកម្មនិងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល ពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ គ្រប់ផ្នែកទាំងអស់ក៏មិនដែលមើលរំលងអំពីការចូលរួមយ៉ាងសកម្មរបស់កិច្ចការយេនឌ័រផងដែរ។ ទន្ទឹមនឹងនេះ អង្គភាពជំនាញនីមួយៗជាសេនាធិការនឹងបន្តអនុវត្តតាមទិសដៅ និងផែនការយុទ្ធសាស្ត្រដែលបានដាក់ចុះសម្រាប់ឆ្នាំ២០១៨-២០១៩ ដោយស្មារតីទទួលខុសត្រូវខ្ពស់។

តែទោះយ៉ាងណាក្តី យើងត្រូវបន្តដំណើរវែងឆ្ងាយទៅមុខទៀត ដើម្បីសម្រេចបានគោលដៅ និងមហិច្ឆតាធំធេងដែលយើងចង់បាន សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាមួយតាមលក្ខណៈវិទ្យាសាស្ត្រទំនើប និងមានប្រសិទ្ធភាពខ្ពស់ សំដៅចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ការលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ តាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក៏ដូចជាក្នុងបរិបទនៃសាកលភាវូបនីយកម្ម ក្រោមការដឹកនាំតម្រង់ទិសប្រកបដោយគតិបណ្ឌិតដ៏ត្រឹមត្រូវ និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

ថ្ងៃពុធ ១១កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

# ឧបសម្ព័ន្ធ

# ផែនការផលិតកម្មដំណាំស្រូវឆ្នាំ២០១៨-២០១៩

ឧបសម្ព័ន្ធទី ១

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៧-២០១៨ | | | ទិសដៅសម្រាប់ឆ្នាំ២០១៨-២០១៩ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ | សម្រេចបាន | % ធៀប ផែនការ | ផែនការ | បញ្ជាក់មូលហេតុ បម្រែបម្រួល |
| **១** | **ផ្ទៃដីដាំដុះស្រូវប្រចាំឆ្នាំ** | **ហ.ត** | **2,940,490** | **3,206,523** | **109.05** | **2,954,400** | ដោយសារលក្ខខណ្ឌធម្មជាតិ (ជំនន់និងរាំងស្ងួត) មិនអាចព្យាករណ៍ជាមុនបាន។ ដូចនេះផែនការដាំដុះស្រូវរដូវវស្សានឹងប្រាំងអាចសម្រេចបាន ២,៩៥លានហិកតានៅឆ្នាំ២០១៨។ |
| | ផ្ទៃដីដាំដុះស្រូវវស្សា | ហ.ត | 2,496,790 | 2,657,768 | 106.45 | 2,508,955 | |
| | ផ្ទៃដីដាំដុះស្រូវប្រាំង | ហ.ត | 443,700 | 548,755 | 123.68 | 445,445 | |
| **២** | **ទិន្នផលស្រូវ** | **តោន/ហ.ត** | **3.215** | **3.298** | **102.58** | **3.296** | |
| | ទិន្នផលស្រូវវស្សា | តោន/ហត | 2.989 | 3.047 | 101.94 | 3.077 | |
| | ទិន្នផលស្រូវប្រាំង | តោន/ហត | 4.487 | 4.508 | 100.46 | 4.530 | |
| **៣** | **បរិមាណផលប្រចាំឆ្នាំ** | **តោន** | **9,443,194** | **10,518,339** | 111.39 | **9,738,952** | |
| | បរិមាណផលស្រូវវស្សា | តោន | 7,452,617 | 8,048,797 | 108.00 | 7,720,974 | |
| | បរិមាណផលស្រូវប្រាំង | តោន | 1,990,577 | 2,469,542 | 124.06 | 2,017,978 | |

# ផែនការផលិតកម្មដំណាំរួមផ្សំ និងឧស្សាហកម្ម២០១៨-២០១៩

ឧបសម្ព័ន្ធទី ២

| ល.រ | ប្រភេទដំណាំ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៧-១៨ | | | ទិសដៅសម្រាប់ផែនការឆ្នាំ២០១៨-១៩ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ ២០១៧-១៨ | សម្រេចបាន ២០១៧-១៨ | % ធៀបផែនការ | ផែនការ ២០១៨-១៩ | បញ្ជាក់បម្រែបម្រួល |
| ១ | ពោត | ហ.ត | 142,940 | 223,886 | 156.63 | 228,364 | កំណើននឹងសម្រេចបានកើនឡើង២% ក្នុងលក្ខខណ្ឌធម្មជាតិអំណោយផល |
| ២ | ដំឡូងមី | ហ.ត | 540,428 | 599,812 | 110.99 | 611,808 | |
| ៣ | ដំឡូងជ្វា | ហ.ត | 7,260 | 5,706 | 78.60 | 5,820 | |
| ៤ | បន្លែ | ហ.ត | 52,554 | 54,451 | 103.61 | 55,540 | |
| ៥ | សណ្តែកបាយ | ហ.ត | 59,343 | 45,352 | 76.42 | 46,259 | |
| | **សរុប** | | **802,525** | **929,207** | **115.79** | **947,791** | |
| ១ | សណ្តែកដី | ហ.ត | 17,104 | 14,443 | 84.44 | 14,732 | កំណើននឹងសម្រេចបានកើនឡើង២% ក្នុងលក្ខខណ្ឌធម្មជាតិអំណោយផល |
| ២ | សណ្តែកសៀង | ហ.ត | 57,458 | 41,950 | 73.01 | 42,789 | |
| ៣ | ល្ង | ហ.ត | 27,397 | 17,006 | 62.07 | 17,346 | |
| ៤ | អំពៅ | ហ.ត | 19,065 | 19,704 | 103.35 | 20,098 | |
| ៥ | ក្រចៅ | ហ.ត | 185 | 134 | 72.43 | 137 | |
| ៦ | ថ្នាំជក់ | ហ.ត | 5,416 | 6,859 | 126.64 | 6,996 | |
| | **សរុប** | ហ.ត | **126,625** | **100,096** | **79.05** | **102,097** | |
| | **សរុបរួម** | | **929,150** | **1,029,303** | **110.78** | **1,049,889** | |

# ផែនការផលិតកម្មដំណាំកៅស៊ូឆ្នាំ២០១៨

ឧបសម្ព័ន្ធទី ៣

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៧ | | | ទិសដៅសម្រាប់ផែនការឆ្នាំ២០១៨ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ២០១៧ | សម្រេចបាន | ភាគរយ | ផែនការ | បញ្ជាក់ បម្រែបម្រួល |
| I | ផ្ទៃដីដាំដុះកៅស៊ូ | | | | | | |
| ១ | កៅស៊ូកសិឧស្សាហកម្ម□ | ហិកតា | 281,897 | 280,228 | 99.41 | 283,871 | កើនប្រមាណ១, ៣% ក្នុងមួយឆ្នាំ |
| ២ | ចម្ការកៅស៊ូគ្រួសារ | ហិកតា | 156,462 | 156,112 | 99.78 | 158,141 | កើនប្រមាណ១, ៣% ក្នុងមួយឆ្នាំ |
| | សរុបរួម | | **438,359** | **436,340** | ***99.54*** | **442,012** | 1.01 |
| II | ផលិតកម្មកៅស៊ូ | | | | | | |
| | ផលិតផលកៅស៊ូ | តោន | **169,884** | **193,285** | ***113.77*** | **226,143** | កើនប្រមាណ១៧% ក្នុងមួយឆ្នាំ |

# ផែនការផលិតកម្មសត្វជាលក្ខណៈគ្រួសារឆ្នាំ២០១៨

ឧបសម្ព័ន្ធទី ៤

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៧ | | | ទិសដៅផែនការឆ្នាំ ២០១៨ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ | សម្រេចបាន | ភាគរយ | ផែនការ | បញ្ជាក់ បម្រែបម្រួល |
| ១ | ការចិញ្ចឹមគោ | ក្បាល | 2,926,097 | 2,951,359 | *100.86* | **2,980,873** | កំណើន១% |
| ២ | ការចិញ្ចឹមក្របី | ក្បាល | 525,937 | 508,458 | *96.68* | **511,000** | កំណើន០,៥% |
| ៣ | ការចិញ្ចឹមជ្រូក | ក្បាល | 2,418,709 | 2,331,512 | *96.39* | **2,378,142** | កំណើន២% |
| ៤ | ការចិញ្ចឹមបក្សី (មាន់ ទា) | ក្បាល | 29,822,610 | 28,559,702 | *95.77* | **29,987,687** | កំណើន៥% |
| ៥ | ចាក់វ៉ាក់សាំងគោក្របី | លានក្បាល | 1.61 | 1.53 | *95.24* | **1.61** | កំណើន៥% |
| ៦ | សត្តឃាតដ្ឋានអនុវត្ត GHP | ចំនួន | 50 | 50 | *100.00* | **50** | |

# ផែនការផលិតកម្មជលផលឆ្នាំ២០១៨

ឧបសម្ព័ន្ធទី ៥

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៧ | | | ទិសដៅសម្រាប់ឆ្នាំ២០១៨ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ | សម្រេចបាន | % ធៀបផែនការ | ផែនការ | បញ្ជាក់មូលហេតុ បម្រែបម្រួល |
| ១ | នេសាទទឹកសាប | តោន | 500,000 | 527,795 | 105.56 | 546,796 | កំណើន ៣,៦% ធៀបឆ្នាំ២០១៦ |
| ២ | នេសាទសមុទ្រ | តោន | 110,000 | 121,025 | 110.02 | 110,000 | មិនមានផែនការឱ្យមានកំណើនទេ |
| ៣ | វារីវប្បកម្ម | តោន | 207,360 | 207,443 | 100.04 | 248,932 | កំណើន ២០% ធៀបឆ្នាំ២០១៦ |
| ៤ | សហគមន៍នេសាទត្រូវបានពង្រឹងសមត្ថភាព | សហគមន៍ | 100 | 85 | 85.00 | 100 | |
| ៥ | ការដាំព្រៃលិចទឹកនិងព្រៃកោងកាង | ហ.ត | 100 | 75 | 75.00 | 100 | |

# ផែនការផ្នែកព្រៃឈើឆ្នាំ២០១៨

ឧបសម្ព័ន្ធទី ៦

| ល.រ | សូចនាករលទ្ធផល | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៧ | | | ទិសដៅអនុវត្តឆ្នាំ២០១៨ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ | សម្រេចបាន | (%) ធៀបផែនការ | ផែនការ | បញ្ជាក់មូលហេតុបម្រែបម្រួល |
| ១ | ផ្ទៃដីដាំព្រៃឡើងវិញ | ហិកតា | 24,500 | 2,508 | 10.24 | 2,500 | វិស័យឯកជននឹងចូលក្នុងសកម្មភាពនេះ |
| ២ | បណ្តុះកូនឈើ | លានដើម | 10.00 | 1.65 | 16.50 | 2.00 | ថ្នាលបណ្តុះកូនឈើជាលក្ខណៈគ្រួសារនិងឯកជននឹងកើនឡើង |
| ៣ | ចំនួនសហគមន៍ព្រៃឈើត្រូវបានបង្កើន និងពង្រឹងសមត្ថភាព | ចំនួនសហគមន៍ | 550 | 580 | 105.45 | 600 | រៀបចំឱ្យបាន៥១សមគមន៍បន្ថែមទៀតដើម្បីសម្រេចបានតាមផែនការ |
| ៤ | ការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ | បង្គោល | 500 | 574 | 114.80 | 500 | ដៃគូអភិវឌ្ឍន៍នឹងមានការចូលរួម |

# ស្ថិតិផ្ទៃដីភ្ជួររាស់ និងផ្ទៃដីដាំដុះដំណាំស្រូវរដូវវស្សាឆ្នាំ ២០១៧

ឧបសម្ព័ន្ធទី ៧

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហត) | ផ្ទៃដីភ្ជួររាស់ (ហ.ត) | | | | | ផ្ទៃដីសាប (ហត) | ផ្ទៃដីព្រោះស្ទូង និងបុកដាំ (ហត) | | | | | | សរុបស្ទូងនិងព្រោះបុកដាំ (ហត) | ភាគរយ (%) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | គោ-ក្របី | | គ្រឿងយន្ត | | | ស្រូវស្រាល | | កណ្តាល | ធ្ងន់ | ចំការ | ឡើងទឹក | | |
| | | | | ហ.ត | % | ហ.ត | % | | សរុប | បង្កើនរដូវ | | | | | | |
| 01 | បន្ទាយមានជ័យ | 250,000 | 251,974 | | - | 251,974 | 100.00 | 401 | 59,869 | 50,983 | 137,379 | 43,788 | - | 10,925 | 251,961 | 100.78 |
| 02 | បាត់ដំបង | 270,700 | 334,110 | 877 | 0.26 | 333,233 | 99.74 | 347 | 135,248 | 56,070 | 120,220 | 72,009 | 395 | 5,726 | 333,598 | 123.24 |
| 03 | កំពង់ចាម | 86,540 | 92,033 | 13,965 | 15.17 | 78,068 | 84.83 | 511 | 27,421 | 7,360 | 35,081 | 28,012 | - | 1,050 | 91,564 | 105.81 |
| 04 | កំពង់ឆ្នាំង | 121,800 | 126,443 | 16,869 | 13.34 | 109,574 | 86.66 | 5,080 | 6,661 | 2,487 | 89,633 | 29,913 | - | 236 | 126,443 | 103.81 |
| 05 | កំពង់ស្ពឺ | 113,600 | 212,700 | 58,087 | 27.31 | 154,613 | 72.69 | 7,098 | 8,566 | 1,060 | 68,560 | 36,465 | 120 | - | 113,711 | 100.10 |
| 06 | កំពង់ធំ | 213,300 | 204,536 | 13,772 | 6.73 | 190,764 | 93.27 | 2,063 | 36,003 | 12,797 | 96,800 | 71,895 | 765 | 9,545 | 215,008 | 100.80 |
| 07 | កំពត | 126,000 | 138,399 | 24,644 | 17.81 | 113,755 | 82.19 | 9,612 | 24,879 | - | 82,717 | 30,803 | - | - | 138,399 | 109.84 |
| 08 | កណ្តាល | 36,000 | 48,738 | 4,369 | 8.96 | 44,369 | 91.04 | 642 | 14,113 | 3,601 | 15,023 | 9,105 | - | - | 38,241 | 106.23 |
| 09 | កោះកុង | 10,500 | 9,527 | 2,928 | 30.73 | 6,599 | 69.27 | 624 | 2,945 | - | 5,716 | 643 | 1,211 | - | 10,515 | 100.14 |
| 10 | ក្រចេះ | 32,400 | 33,240 | 4,959 | 14.92 | 28,281 | 85.08 | 1,497 | 14,513 | 1,068 | 16,021 | 2,507 | 180 | - | 33,221 | 102.53 |
| 11 | មណ្ឌលគិរី | 23,000 | 26,662 | | - | 26,662 | 100.00 | 2,683 | 4,108 | - | 14,678 | 3,842 | 1,872 | - | 24,500 | 106.52 |
| 12 | ភ្នំពេញ | 11,120 | 10,309 | 1,127 | 10.93 | 9,182 | 89.07 | 193 | 6,118 | - | 3,600 | 589 | - | - | 10,307 | 92.69 |
| 13 | ព្រះវិហារ | 83,970 | 81,535 | 2,727 | 3.34 | 78,808 | 96.66 | 3,115 | 9,141 | - | 48,711 | 25,207 | 2,780 | - | 85,839 | 102.23 |
| 14 | ព្រៃវែង | 250,000 | 272,606 | 168 | 0.06 | 272,438 | 99.94 | | 90,917 | 32,767 | 140,915 | 40,774 | - | - | 272,606 | 109.04 |
| 15 | ពោធិសាត់ | 100,000 | 117,100 | 1,090 | 0.93 | 116,010 | 99.07 | 1,570 | 50,804 | 3,324 | 42,113 | 18,927 | 1,077 | 3,836 | 116,757 | 116.76 |
| 16 | រតនគិរី | 26,300 | 15,900 | 979 | 6.16 | 14,921 | 93.84 | 1,150 | 2,604 | - | 10,263 | 3,025 | 10,215 | - | 26,107 | 99.27 |
| 17 | សៀមរាប | 186,760 | 209,445 | 8,945 | 4.27 | 200,500 | 95.73 | 1,960 | 38,060 | 1,345 | 96,220 | 41,545 | 3,540 | 7,345 | 186,710 | 99.97 |
| 18 | ព្រះសីហនុ | 16,600 | 16,600 | 3,320 | 20.00 | 13,280 | 80.00 | 107 | 210 | - | 11,690 | 4,400 | - | - | 16,300 | 98.19 |
| 19 | ស្ទឹងត្រែង | 27,800 | 25,873 | 2,965 | 11.46 | 22,908 | 88.54 | 2,505 | 11,095 | - | 13,674 | 1,039 | 2,793 | - | 28,601 | 102.88 |
| 20 | ស្វាយរៀង | 167,000 | 168,795 | 7,642 | 4.53 | 161,153 | 95.47 | 63 | 50,584 | 12,283 | 112,184 | 4,761 | - | - | 167,529 | 100.32 |
| 21 | តាកែវ | 170,000 | 363,411 | 17,361 | 4.78 | 346,050 | 95.22 | 262 | 102,226 | 53,429 | 90,695 | 6,195 | - | - | 199,116 | 117.13 |
| 22 | ឧត្តរមានជ័យ | 86,500 | 82,568 | | - | 82,568 | 100.00 | 192 | 15,332 | - | 48,133 | 17,335 | 1,615 | - | 82,415 | 95.28 |
| 23 | កែប | 3,500 | 3,610 | 267 | 7.40 | 3,343 | 92.60 | 251 | 1,039 | 458 | 1,773 | 798 | - | - | 3,610 | 103.14 |
| 24 | ប៉ៃលិន | 5,100 | 6,390 | | - | 6,390 | 100.00 | 1 | 675 | - | 4,720 | 995 | - | - | 6,390 | 125.29 |
| 25 | ត្បូងឃ្មុំ | 78,300 | 78,320 | 350 | 0.45 | 77,970 | 99.55 | 827 | 14,796 | 2,686 | 31,424 | 32,100 | - | - | 78,320 | 100.03 |
| សរុប | | **2,496,790** | **2,930,824** | **187,411** | **6.39** | **2,743,413** | **93.61** | **42,754** | **727,927** | **241,718** | **1,337,943** | **526,672** | **26,563** | **38,663** | **2,657,768** | **106.45** |
| តួលេខឆ្នាំមុន | | **2,476,446** | **3,002,753** | **265,313** | **8.84** | **2,737,440** | **91.16** | **50,642** | **632,508** | **173,005** | **1,325,809** | **571,047** | **29,493** | **40,729** | **2,599,586** | **104.97** |
| ប្រៀបធៀប | | **20,344** | **-71,929** | **-77,902** | **-2.44** | **5,973** | **2.44** | **-7,888** | **95,419** | **68,713** | **12,134** | **-44,375** | **-2,930** | **-2,066** | **58,182** | **1.47** |

# ផ្ទៃដីប៉ះពាល់ និងខូចខាតលើដំណាំស្រូវរដូវវស្សាឆ្នាំ២០១៧

ឧបសម្ព័ន្ធទី ៨

| ល.រ | រាជធានី-ខេត្ត | បញ្ចប់ផ្ទៃដីអនុវត្តបាន | ប៉ះពាល់និងខូចខាតដោយប្រការផ្សេងៗ | | | | | | | | ផ្ទៃដីស្តារឡើងវិញ (ហ.ត) | ខូចខាតទាំងស្រុង (ហ.ត) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ប៉ះពាល់ (ហ.ត) | | | | ខូចខាត (ហ.ត) | | | | | |
| | | | រាំងស្ងួត | សត្វល្អិត | ទឹកជំនន់ | សរុប | រាំងស្ងួត | សត្វល្អិត | ទឹកជំនន់ | សរុប | | |
| 01 | បន្ទាយមានជ័យ | 251,961 | 11,133 | - | 3,130 | **14,263** | 3,490 | - | 60 | **3,550** | | 3,550 |
| 02 | បាត់ដំបង | 333,598 | 27,126 | | | **27,126** | 8,974 | | | **8,974** | | 8,974 |
| 03 | កំពង់ចាម | 91,564 | | | 370 | **370** | | | 15 | **15** | 15 | - |
| 04 | កំពង់ឆ្នាំង | 126,443 | | | | - | | | | - | | - |
| 05 | កំពង់ស្ពឺ | 113,711 | 3,168 | | | **3,168** | | | | - | | - |
| 06 | កំពង់ធំ | 215,008 | | | 10,853 | **10,853** | | | 1,702 | **1,702** | 100 | 1,602 |
| 07 | កំពត | 138,399 | | | | - | | | | - | | - |
| 08 | កណ្តាល | 38,241 | | | 35 | **35** | | | 35 | **35** | | 35 |
| 09 | កោះកុង | 10,515 | | 150 | | **150** | | | | - | | - |
| 10 | ក្រចេះ | 33,221 | | | 1,666 | **1,666** | | | 400 | **400** | 375 | 25 |
| 11 | មណ្ឌលគិរី | 24,500 | | | | - | | | | - | | - |
| 12 | ភ្នំពេញ | 10,307 | | | 17 | **17** | | | 17 | **17** | | 17 |
| 13 | ព្រះវិហារ | 85,839 | | | 7,281 | **7,281** | | | 2,647 | **2,647** | 2,647 | - |
| 14 | ព្រៃវែង | 272,606 | | | 1,342 | **1,342** | | | 525 | **525** | 525 | - |
| 15 | ពោធិសាត់ | 116,757 | | | | - | | | | - | | - |
| 16 | រតនគិរី | 26,107 | | | | - | | | | - | | - |
| 17 | សៀមរាប | 186,710 | | 458 | 2,730 | **3,188** | | 15 | 175 | **190** | | 190 |
| 18 | ព្រះសីហនុ | 16,300 | | | | - | | | | - | | - |
| 19 | ស្ទឹងត្រែង | 28,601 | | | 782 | **782** | | | 244 | **244** | 203 | 41 |
| 20 | ស្វាយរៀង | 167,529 | 4,930 | | 2,175 | **7,105** | 803 | | 968 | **1,771** | 1,347 | 424 |
| 21 | តាកែវ | 199,116 | 144 | | 968 | **1,112** | 39 | | 678 | **717** | 39 | 678 |
| 22 | ឧត្តរមានជ័យ | 82,415 | | | | - | | | | - | | - |
| 23 | កែប | 3,610 | | | | - | | | | - | | - |
| 24 | ប៉ៃលិន | 6,390 | | | | - | | | | - | | - |
| 25 | ត្បូងឃ្មុំ | 78,320 | | | 6,945 | **6,945** | | | 595 | **595** | | 595 |
| សរុប | | **2,657,768** | **46,501** | **608** | **38,294** | **85,403** | **13,306** | **15** | **8,061** | **21,382** | **5,251** | **16,131** |
| តួលេខឆ្នាំមុន | | **2,599,586** | **173,613** | **3,472** | **27,031** | **204,116** | **16,751** | **43** | **6,542** | **23,336** | **5,005** | **18,331** |
| ប្រៀបធៀប | | **58,182** | **-127,112** | **-2,864** | **11,263** | **-118,713** | **-3,445** | **-28** | **1,519** | **-1,954** | **246** | **-2,200** |

# បរិមាណផល និងទិន្នផលដំណាំស្រូវរដូវវស្សាតាមប្រភេទឆ្នាំ ២០១៧

ឧបសម្ព័ន្ធទី ៩ក

| ល.រ | រាជធានី-ខេត្ត | ស្រូវស្រាល | | | | ស្រូវកណ្តាល | | | | ស្រូវធ្ងន់ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល |
| | | (ហត) | (ហត) | (ត/ហត) | (តោន) | (ហត) | (ហត) | (ត/ហត) | (តោន) | (ហត) | (ហត) | (ត/ហត) | (តោន) |
| 01 | បន្ទាយមានជ័យ | 59,869 | 58,636 | 4.306 | 252,492 | 137,379 | 135,234 | 2.847 | 384,948 | 43,788 | 43,616 | 2.955 | 128,895 |
| 02 | បាត់ដំបង | 135,248 | 135,248 | 4.185 | 566,013 | 120,220 | 113,754 | 2.530 | 287,799 | 72,009 | 69,501 | 2.843 | 197,591 |
| 03 | កំពង់ចាម | 27,421 | 27,421 | 3.715 | 101,862 | 35,081 | 35,081 | 3.396 | 119,135 | 28,012 | 28,012 | 3.497 | 97,956 |
| 04 | កំពង់ឆ្នាំង | 6,661 | 6,661 | 2.746 | 18,293 | 89,633 | 89,633 | 2.911 | 260,936 | 29,913 | 29,913 | 3.739 | 111,845 |
| 05 | កំពង់ស្ពឺ | 8,566 | 8,566 | 2.990 | 25,613 | 68,560 | 68,560 | 2.935 | 201,249 | 36,465 | 36,465 | 3.237 | 118,021 |
| 06 | កំពង់ធំ | 36,003 | 35,432 | 2.882 | 102,107 | 96,800 | 96,656 | 2.636 | 254,798 | 71,895 | 71,382 | 2.666 | 190,332 |
| 07 | កំពត | 24,879 | 24,879 | 4.330 | 107,729 | 82,717 | 82,717 | 2.921 | 241,586 | 30,803 | 30,803 | 2.873 | 88,499 |
| 08 | កណ្តាល | 14,113 | 14,078 | 3.904 | 54,956 | 15,023 | 15,023 | 2.631 | 39,526 | 9,105 | 9,105 | 2.916 | 26,548 |
| 09 | កោះកុង | 2,945 | 2,945 | 2.361 | 6,954 | 5,716 | 5,716 | 2.684 | 15,339 | 643 | 643 | 2.960 | 1,903 |
| 10 | ក្រចេះ | 14,513 | 14,488 | 3.104 | 44,964 | 16,021 | 16,021 | 2.759 | 44,200 | 2,507 | 2,507 | 2.409 | 6,040 |
| 11 | មណ្ឌលគិរី | 4,108 | 4,108 | 2.884 | 11,847 | 14,678 | 14,678 | 3.001 | 44,051 | 3,842 | 3,842 | 3.243 | 12,461 |
| 12 | ភ្នំពេញ | 6,118 | 6,118 | 2.695 | 16,488 | 3,600 | 3,600 | 2.817 | 10,142 | 589 | 572 | 2.699 | 1,544 |
| 13 | ព្រះវិហារ | 9,141 | 9,141 | 2.885 | 26,369 | 48,711 | 48,711 | 2.936 | 142,996 | 25,207 | 25,207 | 2.980 | 75,129 |
| 14 | ព្រៃវែង | 90,917 | 90,917 | 3.665 | 333,211 | 140,915 | 140,915 | 2.820 | 397,316 | 40,774 | 40,774 | 2.810 | 114,572 |
| 15 | ពោធិសាត់ | 50,804 | 50,804 | 3.535 | 179,589 | 42,113 | 42,113 | 3.243 | 136,577 | 18,927 | 18,927 | 3.290 | 62,265 |
| 16 | រតនគិរី | 2,604 | 2,604 | 2.810 | 7,317 | 10,263 | 10,263 | 2.586 | 26,544 | 3,025 | 3,025 | 2.532 | 7,659 |
| 17 | សៀមរាប | 38,060 | 38,060 | 2.461 | 93,663 | 96,220 | 96,205 | 2.584 | 248,611 | 41,545 | 41,370 | 2.674 | 110,611 |
| 18 | ព្រះសីហនុ | 210 | 210 | 1.600 | 336 | 11,690 | 11,690 | 2.815 | 32,907 | 4,400 | 4,400 | 2.900 | 12,760 |
| 19 | ស្ទឹងត្រែង | 11,095 | 11,054 | 2.443 | 27,005 | 13,674 | 13,674 | 2.594 | 35,467 | 1,039 | 1,039 | 2.654 | 2,758 |
| 20 | ស្វាយរៀង | 50,584 | 50,160 | 3.509 | 176,018 | 112,184 | 112,184 | 2.552 | 286,254 | 4,761 | 4,761 | 2.675 | 12,738 |
| 21 | តាកែវ | 102,226 | 101,548 | 3.460 | 351,379 | 90,695 | 90,695 | 3.205 | 290,649 | 6,195 | 6,195 | 3.350 | 20,751 |
| 22 | ឧត្តរមានជ័យ | 15,332 | 15,332 | 2.197 | 33,683 | 48,133 | 48,133 | 2.661 | 128,082 | 17,335 | 17,335 | 2.802 | 48,572 |
| 23 | កែប | 1,039 | 1,039 | 3.386 | 3,518 | 1,773 | 1,773 | 3.261 | 5,782 | 798 | 798 | 3.322 | 2,651 |
| 24 | ប៉ៃលិន | 675 | 675 | 2.462 | 1,662 | 4,720 | 4,720 | 2.906 | 13,714 | 995 | 995 | 3.171 | 3,155 |
| 25 | ត្បូងឃ្មុំ | 14,796 | 14,201 | 3.386 | 48,089 | 31,424 | 31,424 | 3.375 | 106,057 | 32,100 | 32,100 | 3.387 | 108,720 |
| សរុប | | **727,927** | **724,325** | **3.577** | **2,591,157** | **1,337,943** | **1,329,173** | **2.825** | **3,754,665** | **526,672** | **523,287** | **2.989** | **1,563,976** |
| តួលេខឆ្នាំមុន | | **632,508** | **630,044** | **3.360** | **2,116,849** | **1,325,809** | **1,317,162** | **2.801** | **3,689,589** | **571,047** | **564,127** | **2.981** | **1,681,385** |
| ប្រៀបធៀប | | **95,419** | **94,281** | **0.217** | **474,308** | **12,134** | **12,011** | **0.024** | **65,076** | **-44,375** | **-40,840** | **0.008** | **(117,409)** |

# បរិមាណផល និងទិន្នផលដំណាំស្រូវរដូវវស្សាតាមប្រភេទឆ្នាំ ២០១៧

ឧបសម្ព័ន្ធទី ៩ខ

| លរ | រាជធានី-ខេត្ត | ស្រូវចំការ | | | | ស្រូវឡើងទឹក | | | | សរុប | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) |
| 01 | បន្ទាយមានជ័យ | - | | - | - | 10,925 | 10,925 | 2.140 | 23,374 | 251,961 | 248,411 | 3.179 | 789,709 |
| 02 | បាត់ដំបង | 395 | 395 | 2.177 | 860 | 5,726 | 5,726 | 2.286 | 13,090 | 333,598 | 324,624 | 3.282 | 1,065,353 |
| 03 | កំពង់ចាម | - | | - | - | 1,050 | 1,050 | 2.890 | 3,035 | 91,564 | 91,564 | 3.517 | 321,988 |
| 04 | កំពង់ឆ្នាំង | - | | - | - | 236 | 236 | 1.674 | 395 | 126,443 | 126,443 | 3.096 | 391,469 |
| 05 | កំពង់ស្ពឺ | 120 | 120 | 1.667 | 200 | - | | - | - | 113,711 | 113,711 | 3.035 | 345,083 |
| 06 | កំពង់ធំ | 765 | 765 | 1.553 | 1,188 | 9,545 | 9,171 | 1.627 | 14,917 | 215,008 | 213,406 | 2.640 | 563,342 |
| 07 | កំពត | - | | - | - | - | | - | - | 138,399 | 138,399 | 3.163 | 437,814 |
| 08 | កណ្តាល | - | | #DIV/0! | - | - | | #DIV/0! | - | 38,241 | 38,206 | 3.168 | 121,030 |
| 09 | កោះកុង | 1,211 | 1,211 | 3.327 | 4,029 | - | | - | - | 10,515 | 10,515 | 2.684 | 28,225 |
| 10 | ក្រចេះ | 180 | 180 | 2.217 | 399 | - | | - | - | 33,221 | 33,196 | 2.880 | 95,603 |
| 11 | មណ្ឌលគិរី | 1,872 | 1,872 | 0.974 | 1,823 | - | | - | - | 24,500 | 24,500 | 2.865 | 70,182 |
| 12 | ភ្នំពេញ | - | | - | - | - | | - | - | 10,307 | 10,290 | 2.738 | 28,174 |
| 13 | ព្រះវិហារ | 2,780 | 2,780 | 2.691 | 7,480 | - | | - | - | 85,839 | 85,839 | 2.935 | 251,974 |
| 14 | ព្រៃវែង | - | | - | - | - | | - | - | 272,606 | 272,606 | 3.100 | 845,099 |
| 15 | ពោធិសាត់ | 1,077 | 1,077 | 3.329 | 3,585 | 3,836 | 3,836 | 2.031 | 7,790 | 116,757 | 116,757 | 3.339 | 389,806 |
| 16 | រតនគិរី | 10,215 | 10,215 | 1.873 | 19,135 | - | | - | - | 26,107 | 26,107 | 2.323 | 60,655 |
| 17 | សៀមរាប | 3,540 | 3,540 | 2.453 | 8,683 | 7,345 | 7,345 | 2.648 | 19,447 | 186,710 | 186,520 | 2.579 | 481,015 |
| 18 | ព្រះសីហនុ | - | | - | - | - | | - | - | 16,300 | 16,300 | 2.822 | 46,003 |
| 19 | ស្ទឹងត្រែង | 2,793 | 2,793 | 2.209 | 6,170 | - | | - | - | 28,601 | 28,560 | 2.500 | 71,400 |
| 20 | ស្វាយរៀង | - | | - | - | - | | - | - | 167,529 | 167,105 | 2.843 | 475,010 |
| 21 | តាកែវ | - | | - | - | - | | - | - | 199,116 | 198,438 | 3.340 | 662,779 |
| 22 | ឧត្តរមានជ័យ | 1,615 | 1,615 | 2.105 | 3,399 | - | | - | - | 82,415 | 82,415 | 2.593 | 213,736 |
| 23 | កែប | - | | - | - | - | | - | - | 3,610 | 3,610 | 3.311 | 11,951 |
| 24 | ប៉ៃលិន | - | | - | - | - | | - | - | 6,390 | 6,390 | 2.900 | 18,531 |
| 25 | ត្បូងឃ្មុំ | - | | - | - | - | | - | - | 78,320 | 77,725 | 3.382 | 262,866 |
| សរុប | | **26,563** | **26,563** | **2.144** | **56,951** | **38,663** | **38,289** | **2.143** | **82,048** | **2,657,768** | **2,641,637** | **3.047** | **8,048,797** |
| តួលេខឆ្នាំមុន | | **29,493** | **29,493** | **2.151** | **63,430** | **40,729** | **40,429** | **2.119** | **85,653** | **2,599,586** | **2,581,255** | **2.959** | **7,636,906** |
| ប្រៀបធៀប | | **-2,930** | **-2,930** | **(0.007)** | **-6,479** | **-2,066** | **-2,140** | **0.024** | **-3,605** | **58,182** | **60,382** | **0.088** | **411,891** |

# ផ្ទៃដីភ្ជួររាស់ និងដាំដុះដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៧-២០១៨

ឧបសម្ព័ន្ធទី ១០

| ល.រ | ឈ្មោះស្រុក | ផែនការ (ហ.ត) | ផ្ទៃដីភ្ជួររាស់ | | | | | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដីស្ទូង និងព្រោះ (ហត) | | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប (ហ.ត) | គោ-ក្របី | | គ្រឿងយន្ត | | | សន្ទូង | ពង្រោះ | សរុប | |
| | | | | ហ.ត | % | ហ.ត | % | | | | | |
| 01 | បន្ទាយមានជ័យ | 22,000 | 36,295 | | - | 36,295 | 100.00 | | | 36,295 | 36,295 | 164.98 |
| 02 | បាត់ដំបង | 16,500 | 20,538 | | - | 20,538 | 100.00 | | | 20,538 | 20,538 | 124.47 |
| 03 | កំពង់ចាម | 42,000 | 43,496 | 7,572 | 17.41 | 35,924 | 82.59 | 235 | 2,339 | 41,157 | 43,496 | 103.56 |
| 04 | កំពង់ឆ្នាំង | 30,700 | 37,662 | | - | 37,662 | 100.00 | 95 | 530 | 37,132 | 37,662 | 122.68 |
| 05 | កំពង់ស្ពឺ | 550 | 714 | 140 | 19.61 | 574 | 80.39 | 4 | 27 | 607 | 634 | 115.27 |
| 06 | កំពង់ធំ | 36,000 | 53,852 | | - | 53,852 | 100.00 | 15 | 420 | 53,432 | 53,852 | 149.59 |
| 07 | កំពត | 7,000 | 9,144 | | - | 9,144 | 100.00 | 2 | 12 | 9,050 | 9,062 | 129.46 |
| 08 | កណ្តាល | 62,000 | 61,700 | 2,878 | 4.66 | 58,822 | 95.34 | | | 60,815 | 60,815 | 98.09 |
| 09 | កោះកុង | | - | | | | | | | | - | - |
| 10 | ក្រចេះ | 14,000 | 14,260 | 1,442 | 10.11 | 12,818 | 89.89 | 32 | 728 | 13,323 | 14,051 | 100.36 |
| 11 | មណ្ឌលគិរី | 100 | 126 | | - | 126 | 100.00 | | | 114 | 114 | 114.00 |
| 12 | ភ្នំពេញ | 890 | 988 | 53 | 5.36 | 935 | 94.64 | 3 | 21 | 966 | 987 | 110.90 |
| 13 | ព្រះវិហារ | 130 | 35 | | - | 35 | 100.00 | | | 22 | 22 | 16.92 |
| 14 | ព្រៃវែង | 75,000 | 102,715 | | - | 102,715 | 100.00 | | | 102,715 | 102,715 | 136.95 |
| 15 | ពោធិសាត់ | 9,000 | 15,528 | | - | 15,528 | 100.00 | | | 15,105 | 15,105 | 167.83 |
| 16 | រតនគិរី | | - | | | | | | | | - | |
| 17 | សៀមរាប | 21,650 | 22,100 | | - | 22,100 | 100.00 | 30 | 140 | 21,865 | 22,005 | 101.64 |
| 18 | ព្រះសីហនុ | | - | | | | | | | | - | - |
| 19 | ស្ទឹងត្រែង | 50 | 12 | | - | 12 | 100.00 | | | 12 | 12 | 24.00 |
| 20 | ស្វាយរៀង | 20,000 | 20,639 | | - | 20,639 | 100.00 | | | 20,639 | 20,639 | 103.20 |
| 21 | តាកែវ | 75,000 | 109,902 | | - | 109,902 | 100.00 | | | 99,391 | 99,391 | 132.52 |
| 22 | ឧត្តរមានជ័យ | | 17 | | - | 17 | 100.00 | | | 15 | 15 | #DIV/0! |
| 23 | កែប | 30 | 30 | | - | 30 | 100.00 | | | 30 | 30 | 100.00 |
| 24 | ប៉ៃលិន | 600 | 700 | | - | 700 | 100.00 | | | 700 | 700 | 116.67 |
| 25 | ត្បូងឃ្មុំ | 10,500 | 10,615 | 110 | 1.04 | 10,505 | 98.96 | 60 | 575 | 10,040 | 10,615 | 101.10 |
| **សរុប** | | **443,700** | **561,068** | **12,195** | **2.17** | **548,873** | **97.83** | **476** | **4,792** | **543,963** | **548,755** | **123.68** |
| **តួលេខឆ្នាំមុន** | | **433,755** | **576,640** | **14,197** | **2.46** | **562,443** | **97.54** | **556** | **7,460** | **511,114** | **518,574** | **119.55** |
| **ប្រៀបធៀប** | | **9,945** | **-15,572** | **-2,002** | **-0.29** | **(13,570)** | **0.29** | **-80** | **-2,668** | **32,849** | **30,181** | **4.12** |

# បរិមាណផលិតកម្មដំណាំស្រូវប្រចាំឆ្នាំ២០១៧-២០១៨

ឧបសម្ព័ន្ធទី ១១

| ល.រ | រាជធានី-ខេត្ត | រដូវវស្សាឆ្នាំ២០១៧ | | | | រដូវប្រាំងឆ្នាំ២០១៧-២០១៨ | | | | សរុបប្រចាំឆ្នាំ២០១៧-២០១៨ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) |
| 01 | បន្ទាយមានជយ័ | 251,961 | 248,411 | 3.179 | 789,709 | 36,295 | 36,295 | 4.554 | 165,288 | 288,256 | 284,706 | 3.354 | 954,997 |
| 02 | បាត់ដំបង | 333,598 | 324,624 | 3.282 | 1,065,353 | 20,538 | 20,538 | 4.070 | 83,586 | 354,136 | 345,162 | 3.329 | 1,148,939 |
| 03 | កំពង់ចាម | 91,564 | 91,564 | 3.517 | 321,988 | 43,496 | 43,496 | 4.185 | 182,027 | 135,060 | 135,060 | 3.732 | 504,015 |
| 04 | កំពង់ឆ្នាំង | 126,443 | 126,443 | 3.096 | 391,469 | 37,662 | 37,662 | 4.530 | 170,607 | 164,105 | 164,105 | 3.425 | 562,076 |
| 05 | កំពង់ស្ពឺ | 113,711 | 113,711 | 3.035 | 345,083 | 634 | 633 | 3.381 | 2,140 | 114,345 | 114,344 | 3.037 | 347,223 |
| 06 | កំពង់ធំ | 215,008 | 213,406 | 2.640 | 563,342 | 53,852 | 53,852 | 4.445 | 239,361 | 268,860 | 267,258 | 3.003 | 802,703 |
| 07 | កំពត | 138,399 | 138,399 | 3.163 | 437,814 | 9,062 | 9,062 | 4.277 | 38,755 | 147,461 | 147,461 | 3.232 | 476,569 |
| 08 | កណ្តាល | 38,241 | 38,206 | 3.168 | 121,030 | 60,815 | 60,690 | 4.414 | 267,887 | 99,056 | 98,896 | 3.933 | 388,917 |
| 09 | កោះកុង | 10,515 | 10,515 | 2.684 | 28,225 | - | | - | - | 10,515 | 10,515 | 2.684 | 28,225 |
| 10 | ក្រចេះ | 33,221 | 33,196 | 2.880 | 95,603 | 14,051 | 14,051 | 4.382 | 61,571 | 47,272 | 47,247 | 3.327 | 157,174 |
| 11 | មណ្ឌលគិរី | 24,500 | 24,500 | 2.865 | 70,182 | 114 | 114 | 4.202 | 479 | 24,614 | 24,614 | 2.871 | 70,661 |
| 12 | ភ្នំពេញ | 10,307 | 10,290 | 2.738 | 28,174 | 987 | 987 | 3.501 | 3,455 | 11,294 | 11,277 | 2.805 | 31,629 |
| 13 | ព្រះវិហារ | 85,839 | 85,839 | 2.935 | 251,974 | 22 | 22 | 3.000 | 66 | 85,861 | 85,861 | 2.935 | 252,040 |
| 14 | ព្រៃវែង | 272,606 | 272,606 | 3.100 | 845,099 | 102,715 | 102,715 | 4.848 | 497,995 | 375,321 | 375,321 | 3.579 | 1,343,094 |
| 15 | ពោធិសាត់ | 116,757 | 116,757 | 3.339 | 389,806 | 15,105 | 14,324 | 4.349 | 62,296 | 131,862 | 131,081 | 3.449 | 452,102 |
| 16 | រតនគិរី | 26,107 | 26,107 | 2.323 | 60,655 | - | | - | - | 26,107 | 26,107 | 2.323 | 60,655 |
| 17 | សៀមរាប | 186,710 | 186,520 | 2.579 | 481,015 | 22,005 | 22,005 | 3.579 | 78,754 | 208,715 | 208,525 | 2.684 | 559,769 |
| 18 | ព្រះសីហនុ | 16,300 | 16,300 | 2.822 | 46,003 | - | | - | - | 16,300 | 16,300 | 2.822 | 46,003 |
| 19 | ស្ទឹងត្រែង | 28,601 | 28,560 | 2.500 | 71,400 | 12 | 12 | 3.400 | 41 | 28,613 | 28,572 | 2.500 | 71,441 |
| 20 | ស្វាយរៀង | 167,529 | 167,105 | 2.843 | 475,010 | 20,639 | 20,639 | 4.222 | 87,134 | 188,168 | 187,744 | 2.994 | 562,144 |
| 21 | តាកែវ | 199,116 | 198,438 | 3.340 | 662,779 | 99,391 | 99,391 | 4.870 | 484,061 | 298,507 | 297,829 | 3.851 | 1,146,840 |
| 22 | ឧត្តរមានជ័យ | 82,415 | 82,415 | 2.593 | 213,736 | 15 | 15 | 3.533 | 53 | 82,430 | 82,430 | 2.594 | 213,789 |
| 23 | កែប | 3,610 | 3,610 | 3.311 | 11,951 | 30 | 30 | 3.900 | 117 | 3,640 | 3,640 | 3.315 | 12,068 |
| 24 | ប៉ៃលិន | 6,390 | 6,390 | 2.900 | 18,531 | 700 | 700 | 3.300 | 2,310 | 7,090 | 7,090 | 2.939 | 20,841 |
| 25 | ត្បូងឃ្មុំ | 78,320 | 77,725 | 3.382 | 262,866 | 10,615 | 10,615 | 3.915 | 41,559 | 88,935 | 88,340 | 3.446 | 304,425 |
| **សរុប** | | **2,657,768** | **2,641,637** | **3.047** | **8,048,797** | **548,755** | **547,848** | **4.508** | **2,469,542** | **3,206,523** | **3,189,485** | **3.298** | **10,518,339** |
| **តួលេខឆ្នាំមុន** | | **2,599,586** | **2,581,255** | **2.959** | **7,636,906** | **518,574** | **518,514** | **4.465** | **2,315,364** | **3,118,160** | **3,099,769** | **3.211** | **9,952,270** |
| **ប្រៀបធៀប** | | **58,182** | **60,382** | **0.088** | **411,891** | **30,181** | **29,334** | **0.042** | **154,178** | **88,363** | **89,716** | **0.087** | **566,069** |

# តុល្យភាពស្បៀងតាមបណ្តារាជធានី-ខេត្តឆ្នាំ ២០១៨-២០១៩

ឧបសម្ព័ន្ធទី ១២

| ល.រ | រាជធានី-ខេត្ត | ចំនួនប្រជាជន (នាក់) | បរិមាណផល តោន | ទុកពូជ និងបាត់បង់ពេលប្រមូលផល១៣% តោន | ស្រូវចំណីនៅសល់ (ក្រោយពីកាត់ចេញ១៣%) តោន | គិតជាអង្ករ ៦៤% តោន | តម្រូវការស្បៀងជាអង្ករ តោន | តុល្យភាពស្បៀង (អង្ករ) តោន | តុល្យភាពស្បៀង (ស្រូវ) តោន |
|---|---|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 783,385 | 954,997 | 124,150 | 830,847 | 531,742 | 112,024 | **419,718** | **655,809** |
| 02 | បាត់ដំបង | 1,214,259 | 1,148,939 | 149,362 | 999,577 | 639,729 | 173,639 | **466,090** | **728,266** |
| 03 | កំពង់ចាម | 1,046,382 | 504,015 | 65,522 | 438,493 | 280,636 | 149,633 | **131,003** | **204,692** |
| 04 | កំពង់ឆ្នាំង | 575,245 | 562,076 | 73,070 | 489,006 | 312,964 | 82,260 | **230,704** | **360,475** |
| 05 | កំពង់ស្ពឺ | 793,483 | 347,223 | 45,139 | 302,084 | 193,334 | 113,468 | **79,866** | **124,791** |
| 06 | កំពង់ធំ | 749,197 | 802,703 | 104,351 | 698,352 | 446,945 | 107,135 | **339,810** | **530,953** |
| 07 | កំពត | 636,654 | 476,569 | 61,954 | 414,615 | 265,354 | 91,042 | **174,312** | **272,363** |
| 08 | កណ្តាល | 1,137,811 | 388,917 | 50,559 | 338,358 | 216,549 | 162,707 | **53,842** | **84,128** |
| 09 | កោះកុង | 128,274 | 28,225 | 3,669 | 24,556 | 15,716 | 18,343 | **-2,627** | **-4,105** |
| 10 | ក្រចេះ | 369,739 | 157,174 | 20,433 | 136,741 | 87,514 | 52,873 | **34,641** | **54,127** |
| 11 | មណ្ឌលគិរី | 87,520 | 70,661 | 9,186 | 61,475 | 39,344 | 12,515 | **26,829** | **41,920** |
| 12 | ភ្នំពេញ | 1,883,752 | 31,629 | 4,112 | 27,517 | 17,611 | 269,377 | **-251,766** | **-393,384** |
| 13 | ព្រះវិហារ | 319,612 | 252,040 | 32,765 | 219,275 | 140,336 | 45,705 | **94,631** | **147,861** |
| 14 | ព្រៃវែង | 1,393,140 | 1,343,094 | 174,602 | 1,168,492 | 747,835 | 199,219 | **548,616** | **857,213** |
| 15 | ពោធិសាត់ | 474,612 | 452,102 | 58,773 | 393,329 | 251,731 | 67,870 | **183,861** | **287,283** |
| 16 | រតនគិរី | 222,968 | 60,655 | 7,885 | 52,770 | 33,773 | 31,884 | **1,889** | **2,952** |
| 17 | សៀមរាប | 964,347 | 559,769 | 72,770 | 486,999 | 311,679 | 137,902 | **173,777** | **271,527** |
| 18 | ព្រះសីហនុ | 281,470 | 46,003 | 5,980 | 40,023 | 25,615 | 40,250 | **-14,635** | **-22,867** |
| 19 | ស្ទឹងត្រែង | 135,935 | 71,441 | 9,287 | 62,154 | 39,779 | 19,439 | **20,340** | **31,781** |
| 20 | ស្វាយរៀង | 687,695 | 562,144 | 73,079 | 489,065 | 313,002 | 98,340 | **214,662** | **335,409** |
| 21 | តាកែវ | 1,003,928 | 1,146,840 | 149,089 | 997,751 | 638,561 | 143,562 | **494,999** | **773,436** |
| 22 | ឧត្តរមានជ័យ | 285,012 | 213,789 | 27,793 | 185,996 | 119,037 | 40,757 | **78,280** | **122,313** |
| 23 | កែប | 44,377 | 12,068 | 1,569 | 10,499 | 6,719 | 6,346 | **373** | **583** |
| 24 | ប៉ៃលិន | 68,056 | 20,841 | 2,709 | 18,132 | 11,604 | 9,732 | **1,872** | **2,925** |
| 25 | ត្បូងឃ្មុំ | 783,068 | 304,425 | 39,575 | 264,850 | 169,504 | 111,979 | **57,525** | **89,883** |
| **សរុប** | | **16,069,921** | **10,518,339** | **1,367,383** | **9,150,956** | **5,856,613** | **2,298,001** | **3,558,612** | **5,560,331** |
| **តួលេខឆ្នាំមុន** | | **15,848,495** | **9,952,270** | **1,293,795** | **8,658,475** | **5,541,424** | **2,266,335** | **3,275,089** | **5,117,327** |
| **ប្រៀបធៀប** | | **221,426** | **566,069** | **73,588** | **492,481** | **315,189** | **31,666** | **283,523** | **443,005** |

***កំណត់សម្គាល់*** ៖ អង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ២០១៣ និងការធ្វើចំណោលឆ្នាំ២០១៨ របស់ក្រសួងផែនការ

# តុល្យភាពស្បៀងផលិតផលស្រូវឆ្នាំ ២០១៨-២០១៩

ឧបសម្ព័ន្ធទី ១៣

| កំរិតកំណត់ | ឯកត្តា | រដូវវស្សា | រដូវប្រាំង | សរុប |
|---|---|---|---|---|
| ផែនការដាំដុះ | ហ.ត | 2,496,790 | 443,700 | **2,940,490** |
| ផ្ទៃដីអនុវត្ត | ហ.ត | 2,657,768 | 548,755 | **3,206,523** |
| ផ្ទៃដីខូចខាត | ហ.ត | 16,131 | | **16,131** |
| ផ្ទៃដីប្រមូលផល | ហ.ត | 2,641,637 | 547,848 | **3,189,485** |
| ទិន្នផលមធ្យម | ត/ហ.ត | 3.047 | 4.508 | **3.298** |
| បរិមាណផល | តោន | 8,048,797 | 2,469,542 | **10,518,339** |

***<u>កំណត់សម្គាល់</u>***

| | | |
|---|---|---|
| - កាត់ចេញ ១៣ភាគរយ លើបរិមាណសរុបសំរាប់ទុកពូជ ចំណីសត្វ និងបាត់បង់ពេលប្រមូលផល | 1,367,383 | តោន |
| - ស្រូវចំណីនៅសល់ ក្រោយពីកាត់ចេញ (១៣%) | 9,150,956 | តោន |
| - សរុបស្បៀងដែលមាន គិតជាអង្ករ | 5,856,613 | តោន |
| - តម្រូវការស្បៀងមួយឆ្នាំ | 2,298,001 | តោន |
| - បរិមាណអង្ករលើស | **3,558,612** | តោន |
